សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មេសា ឆ្នាំ 2013

# លីអាហូណា



## ព្រះយេស៊ូវគ្រីស្ទ ៖ ព្រះអង្គប្រោសលោះ និង ព្រះអង្គគំរូ ទំព័រ 18, 26

មិត្តភក្ដិគឺជាមនុស្សទាំងឡាយណាដែល . . . ទំព័រ 52
តើអ្នកប្រែចិត្តជឿឬ ? វិធី 10 យ៉ាង ដើម្បីដឹង ទំព័រ 56
និយាយអំពីព្រះវិហារបរិសុទ្ធជាមួយកូនៗអ្នក ទំព័រ 62, 64



*« ពន្លឺនៃព្រះគ្រីស្ទ គឺជាអំណាច ឬ អានុភាពដ៏ទេវភាព នោះ ដែលចេញ មកពីព្រះ តាមរយៈ ព្រះយេស៊ូវគ្រីស្ទ ។ វាផ្ដល់ពន្លឺ និង ជីវិតដល់គ្រប់អ្វី ទាំងអស់ » ។*

អែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ "Peace of Conscience and Peace of Mind," *Liahona,* Nov. 2004 ទំព័រ 15 ។

# លីអាហូណា ខែ មេសា ឆ្នាំ 2013



26

## សារលិខិត

**4 សារលិខិតគណៈប្រធានទីមួយ ៖ ទ្រង់មានព្រះជន្មរស់ឡើងវិញ**
ដោយ ប្រធាន ហិនរី ប៊ី. អាវរិង

**7 សារលិខិតបង្រៀនសួរសុខទុក្ខ ៖ សេចក្ដីដឹសញ្ញាព្រះវិហារបរិសុទ្ធ**

## អត្ថបទពិសេសៗ

**12 សេចក្ដីស្លាប់ និង ជីវិត ៖ ទស្សនវិស័យរបស់អ្នកត្រួសត្រាយ អំពីដំណើររស់ឡើងវិញ**
*ពួកអ្នកត្រួសត្រាយ និង ពួកព្យាការីពីជំនាន់ដើម ធ្វើបន្ទាល់ពីការរកឃើញសេចក្ដីសង្ឃឹមក្នុងដំណើររស់ឡើងវិញ ។*

**18 បេសកកម្ម និង ការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ**
ដោយ អែលឌើរ រ័សុល អិម. ណិលសុន
*យើងអាចយកគំរូតាមទាំងប្រាំចំណុចនៃជីវិតរបស់ព្រះអង្គសង្គ្រោះ ពេលយើងព្យាយាមធ្វើតាមទ្រង់ និង ព្យាយាមយល់ពីដង្វាយធួនរបស់ទ្រង់ ។*

**26 សប្ដាហ៍នៃបុណ្យអ៊ីស្ទើរ**
*នៅសប្ដាហ៍ចុងក្រោយនៃជីវិតរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានសម្ដែងអព្ភូតហេតុដ៏អស្ចារ្យបំផុតលើសអ្វីៗទាំងអស់ ។*

**30 ការជួយកុមាររៀបចំខ្លួនសម្រាប់ពិធីបុណ្យជ្រមុជទឹក**
ដោយ ជេសីកា ឡសិន និង ម៉ារីហ្សា វិដសុន
*តើអ្វីដែលឪពុកម្ដាយអាចធ្វើ ដើម្បីធ្វើឲ្យបុណ្យជ្រមុជទឹករបស់កូនខ្លួន កាន់តែមានអត្ថន័យឡើងនោះ ?*

**34 ទាក់ទាញចិត្តឆ្ពោះទៅព្រះវិហារបរិសុទ្ធ**
ដោយអែលឌើរ ចៃរ៉ូ ម៉ាស្សាហ្គាឌី
*រៀនពីរបៀបដែលព្រះវិហារបរិសុទ្ធអាចជួយនាំឲ្យកើតមាននូវការប្រែចិត្តជឿ ។*

## ផ្នែកទាំងឡាយ

**8 សៀវភៅកត់ចំណាំពីសន្និសីទសម្រាប់ខែ មេសា ៖ សិក្សាពីសុន្ទរកថាសន្និសីទជាមួយគ្នា**
ដោយ ហ្វ្រេក បេតជី

**9 ការបង្រៀន*ដើម្បីកម្លាំងនៃយុវជន* ៖ សារៈសំខាន់នៃមិត្តល្អ**

**10 អ្វីដែលយើងជឿ ៖ ព្រះវិញ្ញាណបរិសុទ្ធ លួងលោម បំផុស និង ថ្លែងទីបន្ទាល់**

**36 សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**74 ព័ត៌មានសាសនាចក្រ**

**80 លុះត្រាជួបទៀត ៖ ផឹកទឹកពីម៉ាស៊ីនទឹក**
ដោយ អេរ៉ុន អិល. វេស

**នៅលើគម្របរ**
ក្របមុខ ៖ រចនារូបថតដោយ ធីម ថាហ្គាត © IRI ។ ខាងខ្នង ៖ រចនារូបថតដោយ ម៉ាថាយ រៀ ។ ខាងក្នុងក្របមុខ ៖ រូបថតដោយ គ្រីស្ទីន ស៊ុមស្កា ។

## មជ្ឈិមវ័យវ័យក្មេង





**40 ការជ្រើសរើសផ្នែកដ៏ល្អប្រសើរ**
ដោយ ម៉ាថាយ ឌី ហ្វិតតុន
*ដើម្បីមានការតាំងចិត្តដ៏ពេញលេញចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហ្ស៊ីស ត្រូវតែលះបង់នូវរឿងល្អមួយចំនួន ។*





## យុវវ័យ


**42 សំណួរ និង ចម្លើយទាំងឡាយ**
*តើខ្ញុំត្រូវពន្យល់ដល់មិត្តភក្តិរបស់ខ្ញុំពីហេតុផលដែលថាការធ្វើខុសច្បាប់ព្រហ្មចារីភាពគឺជាគំនិតដ៏អាក្រក់មួយ ដោយរបៀបណា ?*

**44 របៀបដើម្បីបម្រើនៅក្នុងការហៅទាំងឡាយនៃបព្វជិតភាព**
ដោយ ប្រធាន ថូម៉ាស អេស. ម៉នសុន
*រៀនពីគន្លឹះដើម្បីឈោងជួយ ដើម្បីបង្រៀន និងដើម្បីធ្វើឲ្យរញ្ជួយ ដល់ជីវិតអ្នកទាំងឡាយដែលអ្នកបម្រើ ។*

**45 ទីកន្លែងរបស់យើង**

**46 មូលហេតុដែលយើងត្រូវការព្រះគម្ពីរមរមន**
*មូលហេតុបួនយ៉ាង ដែលព្រះគម្ពីរមរមនគឺជាការចាំបាច់ ។*

**48 ការធំលូតលាស់ក្នុងដីដែលមានជីវជាតិ ៖ យុវវ័យស្មោះត្រង់នៅប្រទេស យូហ្គេនដា**
ដោយ សិនឌី ស្មីធ
*យុវជន និង យុវនារីទាំងនេះ ត្រូវបានពង្រឹងដោយការលះបង់ដែលពួកគេបានធ្វើសម្រាប់ដំណឹងល្អ ។*

**52 ដើម្បីកម្លាំងនៃយុវជន ៖ តើមិត្តពិតប្រាកដម្នាក់គឺជាអ្វី ?**
ដោយ អេលលែន អេស. ដាល់ថុន

**54 របៀបដែលខ្ញុំដឹង ៖ ការអញ្ជើញរបស់ខ្ញុំទៅរកសេចក្ដីសង្គ្រោះ**
ដោយ អិមមីសាន់ ហូសេ ដា សីលវ៉ា
*នៅពេលដែលខ្ញុំបានទទួលយកការអញ្ជើញរបស់មិត្តខ្ញុំនៅទីបំផុត នោះខ្ញុំបានដឹងថា ខ្ញុំបានរកឃើញអ្វីដែលសំខាន់ ។*

**56 របៀបដប់យ៉ាងដើម្បីដឹងថា អ្នកត្រូវបានផ្លាស់ប្រែចិត្តជឿ**
ដោយ ថៃលី អរតុន
*អ្វីដែលខ្ញុំរៀនអំពីការផ្លាស់ប្រែចិត្តជឿ ជួយខ្ញុំតាមដានការរីកចម្រើនរបស់ខ្ញុំនៅក្នុងដំណឹងល្អ ។*

**59 បណ្ណប្រកាស ៖ គ្មានកិច្ចការណាដែលហួសពីសមត្ថភាពឡើយ**




ចាំមើលថាតើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ ចូរប្រើក្រសែភ្នែកដ៏អស្ចារ្យរបស់អ្នក ។

## កុមារ





**60 អ្នកផ្សព្វផ្សាយក្មេងតូចម្នាក់របស់លោកយាយ ឌៃនី**
ដោយ អ៊ីមមីលៀ ម៉ារៀ ហ្គាម៉ាពស៍ ខូរៀ
*សេចក្ដីស្រឡាញ់របស់វិធីចំពោះដំណឹងល្អបានបញ្ចាំងពន្លឺដល់ការប្រែចិត្តរបស់លោកយាយគាត់ ។*

**61 សាក្សីពិសេស ៖ តើហេតុអ្វីបានជាសាសនាចក្រមានឈ្មោះវែងម្ល៉េះ ?**
ដោយ អែលឌើរ អិម. រ័សុល បាឡឺដ

**62 ពិធីអបអរសាទរជាមួយនឹងព្រះវិហារបរិសុទ្ធ !**
ដោយ ដាសុី ជេនសិន
*នៅទូទាំងពិភពលោក កុមារបានអបអរនឹងការមានព្រះវិហារបរិសុទ្ធមួយនៅក្បែរពួកគេ ។*

**64 សំណួរ និង ចម្លើយទាំងឡាយអំពីព្រះវិហារបរិសុទ្ធ**
*ចម្លើយទាំងឡាយចំពោះសំណួរដូចជា តើហេតុអ្វីយើងមានព្រះវិហារបរិសុទ្ធ ? តើគេធ្វើអ្វីខ្លះនៅក្នុងព្រះវិហារបរិសុទ្ធ ?*

**65 តន្ត្រី ៖ ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍**
ដោយ រ៉ូស មា ហ្គាតនី និង វេញ៉ា វ៉ាយ. វត់ឃីន

**66 ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន ៖ ព្រះយេស៊ូវគ្រីស្ទបានស្ដារសាសនាចក្ររបស់ទ្រង់ឡើងវិញនៅក្នុងថ្ងៃចុងក្រោយ**

**68 នៅតាមផ្លូវ ៖ កន្លែងដែលសាសនាចក្រត្រូវបានរៀបចំឡើង**
ដោយ ជេន ភិនបូរ៉ាហ្វ

**70 សម្រាប់កុមារតូចៗ**

**81 រូបគំនូរព្យាការ ៖ វិលហ្វូឌ វូឌជ្រុព**

**ខែ មេសា ឆ្នាំ 2013 វ៉ុល 13 លេខ 2**
**លីអាហូណា 10784 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បិយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** ស្ទេន អិម. បូវិន, ប្រ៊ែដលី ឌី. ហ្វូស្ទើរ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ្ញរ, អាន់ថូនី ឌី. ភើរគីន

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ានើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉េអិន ខារ, ឡារិននេ ផតជើរ ហ្គន
**ជំនួយការផ្នែកបោះពុម្ព ៖** មេលីស្សា ស្មិនតេណ្ឌ
**និពន្ធ និង កែសម្រួល ៖** ស៊ូសាន បារ៉េត, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, មិនឌី រ៉េ ហ្រ៊ីដមែន, ហ្គែរី អេច. ហ្គាហ្វ, ជេនីហ្វើរ ហ្គ្រេស ជូនស៍, ហ៊ីការី លូហ្វធើស, ម៉ៃឃើល អ័រ. ម៉ូរីស, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនប៊ើជ, ជូលៀ វូដប៊ឺរី

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជេនែត អែនគ្រូ, ហ្វេ ភី អែនឌ្រើស, ស៊ី. ឃិមបល ប៊ុត, ថូម៉ាស ឆាលជ៍, ឃើរី លីន ស៊ី. ហើរិន, ខូលីន ហ៊ីងគ្លី, អ៊ីរីក ភី. ចនសិន, ស្កត អិម. មូយ, ប្រេដ ធារ៉េ

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខននី ប៊ូស្រ្ទប ប្រ៊ីដ, ហាវ៉ដ ជី. ប្រោន, ជូលី ប៊ើដែត, ប្រាយអែន ដបុលយូ. ជីគី, ខាលីន ហាវ៉ដ, ដេនីស គើបែ, ហ្គីននី ជេ. នីលសុន, ថាយ ភីធើ, ហ្គេលី ថេត រ៉ាហ្វើធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីគ
**នាយកផ្នែកចែកចាយ ៖** អ៊ីវ៉ាន ឡាសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និង សំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2013 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
April 2013 Vol. 13 No. 2. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send address changes to Salt Lake Distribution Center, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368.

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពទាំងឡាយ ដែលអាចយកមកប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន ។*



រចនារូបថតដោយ ខូឌី ប៊ែល © IRI

**« បេសកកម្ម និង ការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ »** ទំព័រ 18 ៖ អែលឌើរ រ័សុល អិម. ណិលសុន បង្រៀនពីចំណុចប្រាំយ៉ាងនៃជីវិតរបស់ព្រះអង្គសង្គ្រោះ ដែលយើងអាចយកគំរូតាម ។ សូមពិចារណាពីការពិភាក្សាចំណុចទាំងនេះ និង ពីរបៀបដើម្បីអនុវត្តវានៅក្នុងជីវិតអ្នក ។ អ្នកអាចចង់អានរឿងមួយក្នុងព្រះគម្ពីរ ពីជីវិតព្រះអង្គសង្គ្រោះ ឬ មើលវីដេអូព្រះគម្ពីរប៊ីបមួយ ( biblevideos.lds.org ) ដែលបង្ហាញពីចំណុចមួយក្នុងចំណោមចំណុចទាំងនោះ ។ អ្នកអាចបញ្ចប់ដោយការថ្លែងទីបន្ទាល់ពីជីវិត និង ការបម្រើរបស់ទ្រង់ ហើយច្រៀងបទ “More Holiness Give Me” ( *Hymns,* no. 131 ) ។

**« តើមិត្តពិតប្រាកដម្នាក់គឺជាអ្វី ? »** ទំព័រ 52 ៖ អ្នកអាចចង់ចាប់ផ្ដើមដោយសួរថា តើមិត្តពិតប្រាកដម្នាក់គឺជាអ្វី ? សូមអាននិយមន័យរបស់ អែលឌើរ រ៉ូប៊ឺត ឌី. ហែល ហើយពិភាក្សា ថាតើយើងគួរធ្វើជាមិត្តបែបណា ។ សូមពិចារណាពីការដំណាលប្រាប់នូវបទពិសោធន៍មួយនៅពេលដែលនរណាម្នាក់សម្ដែងដូចជាមិត្តពិតម្នាក់ចំពោះអ្នក ហើយនិយាយពីលក្ខណៈទាំងឡាយដែលអាចជួយដល់សមាជិកក្រុមគ្រួសារ ឲ្យធ្វើជាមិត្តដែលកាន់តែប្រសើរចំពោះអ្នកដទៃទៀត ។

**« ពិធីអបអរសាទរជាមួយនឹងព្រះវិហារបរិសុទ្ធ ! »** ទំព័រ 62 ៖ មើលរូបភាពជាមួយក្រុមគ្រួសារអ្នក ពីរបៀបផ្សេងៗដែលកុមារបានធ្វើពិធីអបអរចំពោះព្រះវិហារបរិសុទ្ធ ។ សូមពិចារណាពីការបង្ហាញរូបភាពព្រះវិហារបរិសុទ្ធមួយដែលនៅជិតអ្នកបំផុត ហើយនិយាយពីមូលហេតុដែលព្រះវិហារបរិសុទ្ធសំខាន់ ។ សូមសង្កត់ធ្ងន់ថា មានតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះដែលក្រុមគ្រួសារអាចផ្សារភ្ជាប់បាន ។ អ្នកអាចចង់បញ្ចប់ដោយច្រៀងបទ « Families Can Be Together Forever » ( ទំព័រ 65 ) ។

## ជាភាសារបស់អ្នក

*លីអាហូណា* និង ធនធានផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសានៅលើគេហទំព័រ languages.lds.org ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការគោរពប្រតិបត្តិ, 40, 42, 56*
*ការចាត់ចែងសាសនាចក្រ, 61*
*ការបង្រៀន, 8, 9, 30*
*ការបម្រើ, 44, 70*
*ការបំផុសគំនិត, 36, 38*
*ការប្រែចិត្តជឿ, 34, 54, 56, 60*
*ការស្ដារឡើងវិញ, 66*
*ការអធិស្ឋាន, 18, 45*
*កិច្ចការផ្សព្វផ្សាយសាសនា, 34, 39, 48, 52, 54, 60*
*កិច្ចការព្រះវិហារបរិសុទ្ធ, 7, 64, 38, 65, 80*
*ក្រុមគ្រួសារ, 30, 65*
*គំរូ, 48*
*ដង្វាយធួន, 18, 26, 45*
*ដំណើររស់ឡើងវិញ, 4, 12, 26*
*បទដ្ឋាន, 42, 45*
*បព្វជិតភាព, 44*
*ពលិកម្ម, 40*
*ពិធីបរិសុទ្ធទាំងឡាយ, 18*
*ពិធីបុណ្យជ្រមុជទឹក, 30*
*ពិធីសាក្រាម៉ង់, 18*
*ព្រហ្មចារីភាព, 42*
*ព្រះគម្ពីរមរមន, 46*
*ព្រះយេស៊ូវគ្រីស្ទ, 4, 18, 26*
*ព្រះវិញ្ញាណបរិសុទ្ធ, 10, 36*
*ព្រះវិហារបរិសុទ្ធ, 34, 62*
*មិត្តភាព, 9, 52, 54*
*យ៉ូសែប ស្ម៊ីធ, 66*
*វិលហ្វូឌ វូឌជ្រុព្វ, 81*
*វិរណៈ, 10, 46*
*សន្និសីទទូទៅ, 8, 37*
*សេចក្ដីខ្ជាប់ខ្ជួន, 59*
*សេចក្ដីជំនឿ, 48*
*សេចក្ដីសង្ឃឹម, 12*
*សេចក្ដីសញ្ញាទាំងឡាយ, 7*
*សេចក្ដីស្លាប់, 4, 12, 39*
*សេចក្ដីអំណរ, 37*
*អាទិភាព, 40*

សារលិខិតគណៈប្រធានទីមួយ



ដោយ ប្រធាន ហិនរី ប៊ី. អាវរិង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# ទ្រង់មានព្រះជន្មរស់ឡើងវិញ

ទីបន្ទាល់មួយអំពីការពិតនៃដំណើររស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាប្រភពនៃសេចក្ដីសង្ឃឹមផង និង ការប្ដេជ្ញាចិត្តផង ។ ហើយវាអាចជាបែបនេះបានសម្រាប់បុត្ររបស់ព្រះគ្រប់គ្នា ។ ការណ៍នោះបានកើតឡើងចំពោះខ្ញុំ គឺនៅថ្ងៃមួយនារដូវក្ដៅ ក្នុងខែ មិថុនា ឆ្នាំ 1969 ពេលដែលម្ដាយខ្ញុំបានស្លាប់ តាំងពីនោះមក វាបានក្លាយជាដូច្នោះអស់ជាច្រើនឆ្នាំ ហើយវានឹងនៅដូច្នោះរហូតដល់ខ្ញុំជួបគាត់ម្ដងទៀត ។

ភាពសោកសៅដែលកើតមកពីការឃ្លាតបណ្ដោះអាសន្ន ត្រូវបានជំនួសដោយសេចក្ដីរីករាយមួយរំពេច ។ វាលើសពីសេចក្ដីសង្ឃឹម ដែលថានឹងបានការជួបជុំដ៏រីករាយមួយទៀត ។ ដោយសារព្រះអម្ចាស់បានបើកសម្ដែងអ្វីៗជាច្រើន តាមរយៈព្យាការីទាំងឡាយរបស់ទ្រង់ ហើយដោយសារព្រះវិញ្ញាណបរិសុទ្ធបានបញ្ជាក់ពីសេចក្ដីពិតនៃដំណើររស់ឡើងវិញដល់ខ្ញុំផងនោះ នោះខ្ញុំអាចឃើញនៅក្នុងគំនិតរបស់ខ្ញុំ ថាការជួបជុំគ្នាម្ដងទៀតជាមួយនឹងអ្នកជាទីស្រឡាញ់របស់យើង ដែលបានស្អាង និង បានរស់ឡើងវិញនោះ គឺយ៉ាងណា ៖

« ពួកគេនេះហើយ ដែលនឹងចេញមក ក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិត ។ . . .

« ពួកគេនេះហើយ ដែលមានឈ្មោះកត់នៅស្ថានសួគ៌ ជាទីដែលព្រះ និង ព្រះគ្រីស្ទ ជាចៅក្រមនៃមនុស្សទាំងអស់ ។

« ពួកគេនេះហើយ ដែលមនុស្សសុចរិតដែលបានធ្វើឲ្យល្អឥតខ្ចោះ តាមរយៈព្រះយេស៊ូវដ៏ជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មី ដែលបាននាំមកនូវដង្វាយធួនដ៏ល្អឥតខ្ចោះនេះ តាមរយៈការច្រួចព្រះលោហិតរបស់ព្រះអង្គផ្ទាល់ » ( គ. និង ស. 76:65, 68–69 ) ។



ដោយសារព្រះយេស៊ូវគ្រីស្ទបានផ្ដាច់នូវចំណងនៃសេចក្ដីស្លាប់ នោះកូនចៅនៃព្រះវរបិតាសួគ៌ទាំងអស់គ្នា ដែលបានកើតមកក្នុងពិភពលោកនេះ នឹងបានរស់ឡើងវិញក្នុងរូបកាយមួយដែលនឹងមិនដែលស្លាប់ទៀតឡើយ ។ ដូច្នេះ ទីបន្ទាល់របស់ខ្ញុំ និងរបស់អ្នក អំពីសេចក្ដីពិតដ៏រុងរឿងនោះ អាចដកចេញនូវទ្រនិចនៃការបាត់បង់នូវសមាជិកក្រុមគ្រួសារ ឬ មិត្តដ៏ជាទីស្រឡាញ់ ហើយជំនួយវិញនូវការរង់ចាំដល់ថ្ងៃអនាគតដែលពេញដោយអំណរ និង ការប្ដេជ្ញាចិត្តដ៏រឹងមាំ ។

ព្រះអម្ចាស់បានប្រទានដល់យើងទាំងអស់គ្នា នូវអំណោយនៃការរស់ឡើងវិញ ហេតុដូច្នេះហើយ វិញ្ញាណរបស់យើងត្រូវបានដាក់ចូលក្នុងរូបកាយ រួចផុតពីភាពមិនឥតខ្ចោះខាងសាច់ឈាម ( សូមមើល អាលម៉ា 11:42–44 ) ។ ម្ដាយខ្ញុំនឹងមានរូបរាងក្មេង ហើយភ្លឺថ្លៃងចាំង ផលដែលមកពីអាយុ និង ចំនួនឆ្នាំនៃការរងទុក្ខខាងសាច់ឈាមនឹងត្រូវដកចេញ ។ ការណ៍នោះនឹងបានមកដល់គាត់ និង ដល់យើងជាអំណោយមួយ ។

ប៉ុន្តែពួកយើង ដែលចង់យ៉ាងខ្លាំង ដើម្បីបានរស់នៅជាមួយគាត់ជារៀងរហូតនោះ ត្រូវតែធ្វើការជ្រើសរើសទាំងឡាយ ដែលធ្វើឲ្យមានភាពសក្ដិសមដើម្បីបានការរួបរួមនោះ គឺដើម្បីបានរស់នៅកន្លែងដែលព្រះវរបិតា និង ព្រះរាជបុត្រាដែលបានរស់ឡើងវិញដ៏ជាទីស្រឡាញ់របស់ទ្រង់ គង់នៅដោយសិរីរុងរឿង ។ នោះជាកន្លែងតែមួយគត់ដែលជីវិតក្រុមគ្រួសារអាចបន្តនៅដ៏អស់កល្បជានិច្ច ។ ទីបន្ទាល់អំពីសេចក្ដីពិតនោះបានបង្កើននូវការប្ដេជ្ញាចិត្តរបស់ខ្ញុំ ដើម្បីធ្វើឲ្យខ្លួនខ្ញុំ និង អ្នកទាំងឡាយដែលខ្ញុំស្រឡាញ់មានភាពសក្ដិសមនឹងទទួលបានកម្រិតដ៏ខ្ពស់បំផុតនៃនគរសេឡេស្ទាល តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលមានក្នុងជីវិតយើង ( សូមមើល គ. និង ស. 76:70 ) ។

ព្រះអម្ចាស់ប្រទានដល់យើងនូវការណែនាំមួយក្នុងដំណើរស្វែងរកជីវិតដ៏នៅអស់កល្បនេះ នៅក្នុងការអធិស្ឋានសាក្រាម៉ង់ ដែលជួយដល់ខ្ញុំ និង អាចជួយដល់អ្នក ។ យើងត្រូវបានអញ្ជើញឲ្យរំឭកឡើងវិញនូវសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង ក្នុងគ្រប់ការប្រជុំសាក្រាម៉ង់ ។

យើងសន្យាថា ចងចាំព្រះអង្គសង្គ្រោះជានិច្ច ។ និមិត្តសញ្ញានៃការពលិកម្មរបស់ទ្រង់ ជួយយើងឲ្យមានការដឹងគុណចំពោះទំហំនៃថ្លៃដែលទ្រង់បានបង់ ដើម្បីផ្ដាច់ចំណងនៃសេចក្ដីស្លាប់ ដើម្បីប្រទានដល់យើងនូវសេចក្ដីមេត្តាករុណា និង ដើម្បីប្រទានការអត់ទោសដល់អំពើបាបរបស់យើងទាំងអស់ ប្រសិនបើយើងជ្រើសរើសប្រែចិត្ត ។

យើងសន្យារក្សាបទបញ្ញត្តិរបស់ទ្រង់ ។ ការអានព្រះគម្ពីរ និង ពាក្យសម្ដីរបស់ព្យាការីដែលនៅរស់ និង ស្ដាប់ដល់អ្នកឡើងនិយាយដ៏បំផុសគំនិត នៅក្នុងការប្រជុំសាក្រាម៉ង់ រំឭកយើងពីសេចក្ដីសញ្ញារបស់យើងក្នុងការធ្វើដូច្នោះ ។ ព្រះវិញ្ញាណបរិសុទ្ធនាំបទបញ្ញត្តិដែលយើងចាំបាច់ដើម្បីគោរពបំផុត នៅថ្ងៃនោះ ចូលក្នុងគំនិត និង ដួងចិត្តរបស់យើង ។

ក្នុងការអធិស្ឋានសាក្រាម៉ង់ ព្រះសន្យាថា បញ្ជូនព្រះវិញ្ញាណបរិសុទ្ធឲ្យគង់នៅជាមួយយើង ( សូមមើល ម៉ូរ៉ូណៃ 4:3; 5:2; គ. និង ស. 20:77, 79 ) ។ ខ្ញុំបានឃើញនៅក្នុងគ្រានោះថា ព្រះអាចប្រទានដល់ខ្ញុំ នូវអ្វីដែលមានអារម្មណ៍ដូចជាការសម្ភាសន៍ផ្ទាល់ខ្លួន



## ការបង្រៀនចេញពីសារលិខិតនេះ

យើងគួរ « ប្រៀបធៀបបទព្រះគម្ពីរទាំងអស់ទៅនឹងខ្លួនយើង ដើម្បីទុកជាប្រយោជន៍ និង ការចេះដឹងដល់យើង » ( នីហ្វៃទី1 19:23 ) ។ សូមពិចារណាក្នុងការអានពីការអធិស្ឋានសាក្រាម៉ង់ ដែលមានក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា 20:76–79 ។ បន្ទាប់ពីអានការបង្រៀនរបស់ប្រធាន អាវរិង អំពីការអធិស្ឋានសាក្រាម៉ង់ហើយ អ្នកអាចចង់អញ្ជើញពួកអ្នកទាំងឡាយដែលអ្នកកំពុងបង្រៀន ឲ្យគិតពីរបៀបទាំងឡាយ ដែលការអធិស្ឋានទាំងនេះអាចដឹកនាំជីវិតពួកគេ និង ជួយពួកគេឲ្យត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទម្ដងទៀត ។

មួយអញ្ចឹង ។ ទ្រង់ធ្វើឲ្យខ្ញុំបានដឹង ពីអ្វីដែលខ្ញុំបានធ្វើដែលសព្វព្រះហឫទ័យទ្រង់ ពីសេចក្ដីត្រូវការរបស់ខ្ញុំក្នុងការប្រែចិត្ត និង សេចក្ដីត្រូវការការអត់ទោស និង ឈ្មោះ និង មុខនៃមនុស្សទាំងឡាយដែលទ្រង់ចង់ឲ្យខ្ញុំបម្រើ សម្រាប់ទ្រង់ ។

អស់ជាច្រើនឆ្នាំកន្លងមក បទពិសោធន៍ដដែលនោះ បានបង្វែរសេចក្ដីសង្ឃឹមទៅជាអារម្មណ៍នៃសេចក្ដីសប្បុរស និង នាំមកនូវការធានាអះអាងមួយថា សេចក្ដីមេត្តាករុណាគឺត្រូវបានប្រទានដល់ខ្ញុំ ដោយដង្វាយធួន និង ដំណើររស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ។

ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទដ៏មានព្រះជន្មរស់ឡើងវិញ ហើយជាគំរូ និង ជាអ្នកដឹកនាំផ្លូវដ៏ឥតខ្ចោះរបស់យើងទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ។ ■

រូបថតដោយ ម៉ាថាយ រៀ ទ្រង់មានព្រះជន្មរស់ឡើងវិញ ដោយ ដិល ថាសុន ហាមថតចម្លង

## ការសម្ភាសន៍ផ្ទាល់ខ្លួនរបស់អ្នកជាមួយព្រះ

ប្រធាន អារិង បង្រៀនថា ពេលយើងស្តាប់ការអធិស្ឋានសាក្រាម៉ង់ យើងអាចមានអារម្មណ៍ដូចជាយើងកំពុងមានការសម្ភាសន៍ផ្ទាល់ខ្លួនមួយជាមួយព្រះអញ្ចឹង ។ ប្រធាន អារិង គិតអំពីចំនុចបីដូចខាងក្រោមនេះ ។ សូមពិចារណាក្នុងការសរសេរសំណួរទាំងនេះ នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ហើយសញ្ជឹងគិតពីសំណួរទាំងនេះ នៅរៀងរាល់ថ្ងៃអាទិត្យនៅក្នុងខែនេះ ។ ពេលអ្នកសញ្ជឹងគិត និង ទទួលការបំផុសដល់អារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកក៏អាចសរសេរការបំផុសទាំងនោះនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកផងដែរ ។

- តើខ្ញុំបានធ្វើអ្វីខ្លះដែលសព្វព្រះហឫទ័យដល់ព្រះ ?
- តើអ្វីខ្លះ ដែលខ្ញុំត្រូវប្រែចិត្ត ឬ ត្រូវសុំការអត់ទោស ?
- តើព្រះចង់ឲ្យខ្ញុំបម្រើដល់អ្នកណា ?

កុមារ

## ចងចាំព្រះយេស៊ូវជានិច្ច

យ៉ាកុបកំពុងព្យាយាមដើម្បី « ចងចាំ [ ព្រះអង្គសង្គ្រោះ ] ជានិច្ច » ( គ. និង ស. 20:77 ) ។ សូមមើលជុំវិញបន្ទប់ដេករបស់គាត់ ។ តើអ្នកកត់សម្គាល់ថា អ្វីខ្លះដែលអាចជួយគាត់ឲ្យចងចាំព្រះយេស៊ូវជានិច្ចនោះ ?




រូបភាព ដោយ [illegible]

*សូមសិក្សាឯកសារនេះប្រកបដោយការអធិស្ឋាន បើសមរម្យ សូមធ្វើការពិភាក្សាអំពីឯកសារនេះជាមួយនឹងបងប្អូនស្ត្រី ដែលអ្នកទៅសួរសុខទុក្ខ ។ សូមប្រើសំណួរទាំងឡាយដើម្បីជួយអ្នកពង្រឹងដល់បងប្អូនស្ត្រីរបស់អ្នក និង ធ្វើឲ្យថ្នាក់សមាគមសង្គ្រោះក្លាយជាផ្នែកមួយដ៏សកម្ម នៅក្នុងជីវិតរបស់អ្នកផ្ទាល់ ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# សេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធ

ប្រធាន ថូម៉ាស អេស. ម៉នសុន បានមានប្រសាសន៍ថា « ពិធីបរិសុទ្ធទាំងឡាយនៃសេចក្ដីសង្គ្រោះ ដែលបានទទួលក្នុងព្រះវិហារបរិសុទ្ធ ដែលអនុញ្ញាតឲ្យយើងត្រឡប់ទៅព្រះវរបិតាសួគ៌របស់យើងនៅថ្ងៃមួយ ក្នុងទំនាក់ទំនងក្រុមគ្រួសារដ៏អស់កល្បជានិច្ចមួយ និង ត្រូវបានប្រទានឲ្យនូវពរជ័យ និង អំណាចមកពីទីខ្ពស់ ដែលសមនឹងតម្លៃនៃគ្រប់ការពលិកម្ម និង ការខិតខំប្រឹងប្រែងទាំងអស់ » ។[1] ប្រសិនបើអ្នកពុំទាន់បានទៅព្រះវិហារបរិសុទ្ធនៅឡើយទេ នោះអ្នកអាចរៀបចំខ្លួន ដើម្បីទទួលពិធីបរិសុទ្ធដ៏ពិសិដ្ឋនៃព្រះវិហារបរិសុទ្ធដោយ ៖

- ជឿលើព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ។
- បណ្ដុះនូវទីបន្ទាល់មួយអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង អំពីដំណឹងល្អដែលបានស្ដារឡើងវិញ ។
- គាំទ្រ និង ធ្វើតាមព្យាការីដែលនៅរស់ ។
- មានភាពសក្ដិសមដើម្បីកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធ ដោយការបង់ដង្វាយមួយភាគក្នុងដប់ មានភាពស្អាតស្អំខាងសីលធម៌ មានភាពស្មោះត្រង់ រក្សាច្បាប់គតិបណ្ឌិត និង រស់នៅឲ្យស្របទៅនឹងការបង្រៀនរបស់សាសនាចក្រ ។
- ផ្ដល់ពេលវេលា ទេពកោសល្យ និង ធនធាននានា ដើម្បីជួយកសាងនគររបស់ព្រះអម្ចាស់ ។
- ចូលរួមក្នុងកិច្ចការពង្សប្រវត្តិ ។[2]



*ទីបញ្ចប់នៃផ្លូវវេាលី* ដោយ គ្លិន អេស. ហូបឃីនសុន ហាមថតចម្លង

ប្រធាន ម៉នសុន បានបង្រៀនទៀតថា « ពេលយើងចងចាំសេចក្ដីសញ្ញាដែលយើងធ្វើនៅក្នុង [ ព្រះវិហារបរិសុទ្ធ ] នោះយើងនឹងកាន់តែអាចទ្រាំទ្របានជាមួយគ្រប់ការលំបាក និង កាន់តែអាចយកឈ្នះលើការល្បួងនីមួយៗ » ។[3]

### *ចេញពីព្រះគម្ពីរ*

គោលលទ្ធិ និង សេចក្ដីសញ្ញា 14:7; 25:13; 109:22

**កំណត់ចំណាំ**

1. ប្រធាន ថូម៉ាស អេស. ម៉នសុន « *The Holy Temple—a Beacon to the World* » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 92 ។
2. សូមមើល *Daughters in My Kingdom ,៖ The History and Work of Relief Society* ( ឆ្នាំ 2011 ), ទំព័រ 21 ។
3. ថូម៉ាស អេស. ម៉នសុន *លីអាហូណា* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 93 ។
4. *Daughters in My Kingdom* ទំព័រ 29–30 ។
5. សារ៉ា រីចធ៍ នៅក្នុង *Daughters in My Kingdom* ទំព័រ 30 ។

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### *ចេញពីប្រវត្តិសាស្ត្ររបស់យើង*

« ពួកបរិសុទ្ធច្រើនជាង 5,000 នាក់ បានជួបជុំគ្នានៅព្រះវិហារបរិសុទ្ធណៅវូ បន្ទាប់ពីពិធីឧទ្ទិសឆ្លងរួច ។ . . .

« កម្លាំង អំណាច និង ពរជ័យនៃសេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធ [ បានគាំទ្រ ] ដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ អំឡុងពេលនៃការធ្វើដំណើរ [ ទៅទិសខាងលិច ] របស់ពួកគេ ពេលដែលពួកគេ [ បានរងទុក្ខវេទនា ] ដោយភាពត្រជាក់ ក្ដៅ ឃ្លាន ក្រីក្រ ជំងឺ គ្រោះថ្នាក់ និង សេចក្ដីស្លាប់ » ។[4]

ដូចជាបងប្អូនស្ត្រីជាច្រើនក្នុងសមាគមសង្គ្រោះដែរ សារ៉ា រីចធ៍ បានបម្រើជាអ្នកធ្វើការក្នុងព្រះវិហារបរិសុទ្ធ ។ គាត់បាននិយាយពីបទពិសោធន៍របស់គាត់ថា « ប្រសិនបើពុំមែនដោយសារសេចក្ដីជំនឿ និង ចំណេះដឹងដែលបានប្រទានដល់យើងនៅក្នុងព្រះវិហារបរិសុទ្ធ . . . ដោយព្រះវិញ្ញាណនៃព្រះអម្ចាស់នោះទេ នោះការធ្វើដំណើររបស់យើងនឹងហាក់បីដូចជាការធ្វើដំណើរមួយដែលលោតផ្លោះដ៏ឆ្ងាយក្នុងទីងងឹតដូច្នោះដែរ ។ . . . ប៉ុន្តែយើងមានសេចក្ដីជំនឿលើព្រះវរបិតាសួគ៌របស់យើង . . .ដោយទទួលអារម្មណ៍ថា យើងជាប្រជាជនជម្រើសរបស់ទ្រង់ . . . ហើយជំនួសឲ្យទុក្ខព្រួយ យើងបានមានអារម្មណ៍រីករាយថា ថ្ងៃនៃការរំដោះរបស់យើងបានមកដល់ហើយ » ។[5]

ការលើកគ្នាទាំងក្រុមទៅនៅទីកន្លែងផ្សេងនេះ គឺមិនមែនជា « លោតផ្លោះដ៏ឆ្ងាយក្នុងទីងងឹត » សម្រាប់ពួកស្ត្រីបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់នោះទេ ។ ពួកគេត្រូវបានគាំទ្រដោយសេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធរបស់ពួកគេ ។

### *តើខ្ញុំអាចធ្វើអ្វីបាន ?*

**1.** តើខ្ញុំកំពុងថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធជាទៀងទាត់ដែរឬទេ ?

**2.** តើខ្ញុំកំពុងលើកទឹកចិត្តបងប្អូនស្ត្រីរបស់ខ្ញុំ ឲ្យទទួលពរជ័យនៃព្រះវិហារបរិសុទ្ធដែរឬទេ ?

# សិក្សាពីសុន្ទរកថាសន្និសីទជាមួយគ្នា

*ការផ្លាស់ប្ដូររបៀបរបស់យើងក្នុងការរៀនឡើងវិញពីសន្និសីទ បានបង្កើនការពិភាក្សារបស់យើង យ៉ាងអស្ចារ្យអំពីដំណឹងល្អ ក្នុងនាមជាគ្រួសារមួយ ។*

**ដោយ ហ្វ្រេក បេតធី**

អស់ជាច្រើនឆ្នាំ យើងបានមានការរីករាយក្នុងការអានសន្និសីទពីដើមដល់ចប់ ជាក្រុមគ្រួសារ មួយអត្ថបទម្ដងៗ ។ ជាធម្មតា ពេលយើងចាប់ផ្ដើម យើងប្រមូលផ្ដុំគ្នា ជុំវិញតុ ហើយដាក់វេនគ្នាអានឮៗ ម្នាក់មួយកថាខណ្ឌៗ ។ ប៉ុន្តែ យើងឃើញថា យើងអានវាគ្រាន់តែដើម្បីឲ្យចប់ ដោយមិនបានឈប់ ដើម្បីគិតឲ្យបានល្អិតល្អន់ពីសារលិខិតនោះទេ ។

ដើម្បីរៀនឲ្យបានកាន់តែច្រើនចេញពីអ្វីដែលយើងអាន ប្រពន្ធខ្ញុំ និង ខ្ញុំ បានទិញច្បាប់សន្និសីទសម្រាប់សមាជិកគ្រួសារ ម្នាក់មួយច្បាប់ៗ ហើយបានដាក់ផែនការ ថាតើសុន្ទរកថាប៉ុន្មានដែលយើងត្រូវសិក្សាក្នុងមួយសប្ដាហ៍ ដើម្បីយើងអាចអានវាទាំងអស់ ពីមុនដល់ពេលសន្និសីទបន្ទាប់ទៀតចាប់ផ្ដើម ។ នៅសប្ដាហ៍ខ្លះ យើងនឹងអានមួយសុន្ទរកថា និង សប្ដាហ៍ខ្លះទៀតយើងអានពីរ ប៉ុន្តែគ្រប់គ្នាត្រូវសិក្សាសុន្ទរកថា ហើយគូសចំណាំផ្នែកទាំងឡាយដែលពួកគេចូលចិត្ត ។ បន្ទាប់មក សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ យើងនឹងបង្រៀនគ្នាទៅវិញទៅមក ពីកន្លែងដែលយើងគូសចំណាំ ។

ជាញឹកញាប់ កូនៗរបស់យើងមានសំណួរនានា ដែលបានបើកឱកាសសម្រាប់ការពិភាក្សារបស់យើង ឬ ប្រពន្ធខ្ញុំ និង ខ្ញុំបានសួរសំណួរពីការសិក្សារបស់យើង ។ យើងផ្ដល់តម្លៃយ៉ាងខ្ពស់ក្នុងការស្ដាប់ពីកូនៗរបស់យើង ដែលជាយុវវ័យ ពន្យល់ចម្លើយរបស់ពួកគេដល់សំណួរទាំងនោះ ចែកចាយអ្វីៗដែលពួកគេបានរៀនក្នុងថ្នាក់សិក្ខាសាលា នៅព្រះវិហារ ឬ នៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ ។ ការណ៍នេះបានក្លាយជារបៀបដ៏អស្ចារ្យក្នុងការឮពីទីបន្ទាល់សាមញ្ញៗរបស់គ្នាទៅវិញទៅមក អំពីអ្វីដែលជាមូលដ្ឋានទូទៅ ក្នុងបរិយាកាសដ៏ស្រួល និងធូរស្រាល ។

មិនយូរប៉ុន្មាន យើងឃើញថា ការសិក្សាព្រះគម្ពីរពេលព្រឹករបស់យើង ក៏បានធ្វើតាមរបៀបដូចគ្នានោះដែរ ។ ថ្ងៃខ្លះ ពេលវេលាដើរទៅលឿនណាស់ ហើយយើងសិក្សាបានតែពីរបីខប៉ុណ្ណោះ ពីការពិភាក្សាអំពីខទាំងនោះ និង ពីរបៀបដែលខទាំងនោះត្រូវទៅនឹងអ្វីដែលកំពុងកើតឡើងក្នុងជីវិតរបស់យើង ។

ឥឡូវនេះ ពេលព្រឹករបស់យើងពេញទៅដោយការសន្ទនា សំណើច និង សាមគ្គីភាព ពីមុនពេលយើងម្នាក់ៗបែកគ្នាចេញទៅធ្វើកិច្ចការរៀងៗខ្លួន ។ យើងមានទីបន្ទាល់យ៉ាងរឹងមាំពីជំរឿនបួនរបស់ព្យាការីរបស់យើង ដែលឲ្យយើងសិក្សា និង អធិស្ឋានជាមួយគ្នាជារៀងរាល់ថ្ងៃ ។ ក្រុមគ្រួសាររបស់យើងបានប្រែទៅជាគ្រួសារមួយ ដែលរៀន និង ពង្រឹងគ្នាទៅវិញទៅមក ។ ទាំងអស់នេះគឺជាលទ្ធផល ដែលបានមកពីការចង់រៀនថែមបន្តិចទៀតចេញពីសន្និសីទ ។ ■

*ហ្វ្រេក បេតធី រស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



រូបថតដោយ អ៊្រេ ស្មេធីន © IRI



## សិក្សា និង អនុវត្តសារលិខិតសន្និសីទ

« ចូរចងចាំថា សារលិខិតដែលយើងបានឮអំឡុងពេលសន្និសីទនេះ នឹងត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី *Ensign* និង *លីអាហូណា* ច្បាប់ចេញក្នុងខែ ឧសភា ។ ខ្ញុំសូមជម្រុញអ្នក ឲ្យសិក្សាសារលិខិតទាំងឡាយ ឲ្យពិចារណាពីការបង្រៀនរបស់ពួកគេ ហើយបន្ទាប់មកអនុវត្តវាក្នុងជីវិតអ្នក » ។

ប្រធាន ថូម៉ាស អេស. ម៉នសុន « A Word at Closing » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2010 ទំព័រ 113 ។



# សារៈសំខាន់នៃមិត្តល្អ

**មិ**ត្តភក្តិមានឥទ្ធិពលដ៏ខ្លាំងក្លាមួយ ទៅលើសកម្មភាពរបស់យើង ជាពិសេសនៅក្នុងភាពជាយុវវ័យរបស់យើង ។ « ពួកគេនឹងជះឥទ្ធិពលទៅលើការគិត និង ការប្រព្រឹត្តរបស់អ្នក ហើយថែមទាំងជួយកំណត់អ្នកឲ្យក្លាយទៅជាមនុស្សម្នាក់ដែលអ្នកនឹងប្រែក្លាយទៀតផង » ។[1] ហើយពេលដែលអ្នកជ្រើសរើសមិត្តល្អ « ពួកគេនឹងក្លាយជាកម្លាំង និង ជាពរជ័យដ៏អស្ចារ្យដល់អ្នក ។ . . . ពួកគេនឹងជួយអ្នកឲ្យក្លាយជាមនុស្សម្នាក់ដែលកាន់តែប្រសើរឡើង ហើយនឹងធ្វើឲ្យអ្នកកាន់តែមានភាពងាយស្រួលក្នុងការរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ » ។[2]

នៅទំព័រ 52–53 នៃច្បាប់នេះ អេលែន អេស. ដាល់ថុន ប្រធានយុវនារីទូទៅ បង្រៀនពីសារៈសំខាន់ក្នុងការស្វែងរកមិត្តល្អ និង ការធ្វើជាមិត្តល្អម្នាក់ ។ គាត់បានមានប្រសាសន៍ថា « ការស្វែងរកគុណសម្បត្តិដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្សម្នាក់ផ្សេងទៀត គឺជាការចាំបាច់នៃមិត្តភាពដ៏ពិត » ។

ការសាងមិត្តភាពដោយផ្អែកលើគោលការណ៍ទាំងនេះ នឹងជួយយុវវ័យកសាងទំនាក់ទំនងដ៏យូរអង្វែង និង ជំនាញខាងសង្គម ដែលលើសពីការគ្រាន់តែក្លាយជា « មិត្តភក្តិ » នៅលើបណ្ដាញសង្គមលើអ៊ិនធើរណិតទៅទៀត ។ ក្នុងនាមជាឪពុក ឬ ម្ដាយម្នាក់ អ្នកអាចជួយកូនៗរបស់អ្នក ឲ្យយល់ពីសារៈសំខាន់នៃការធ្វើជាមិត្តល្អ និង ការជ្រើសរើសមិត្តភក្តិដែលនឹងលើកទឹកចិត្តពួកគេឲ្យរស់នៅតាមដំណឹងល្អ ។ យោបល់ខាងក្រោមនេះអាចមានប្រយោជន៍ ។

## យោបល់ទាំងឡាយសម្រាប់បង្រៀនយុវវ័យ

- ចូរស្រាវជ្រាវព្រះគម្ពីរជាមួយក្រុមគ្រួសាររកមើលគំរូទាំងឡាយពីមិត្តល្អ ។ ចូរពិភាក្សាពីគុណសម្បត្តិអ្វីខ្លះ ដែលបានធ្វើឲ្យមិត្តភាពទាំងនោះបានរឹងមាំ ។ សូមពិចារណាពី ដេវីឌ និង យ៉ូណាថាន ( សូមមើល សាំយូអែល ទី1 18–23 ), នាងរស់ និង ន៉ាអូមី ( សូមមើល នាងរស់ 1–2), និង អាលម៉ា និង បុត្រាទាំងឡាយនៃម៉ូសាយ ( សូមមើល ម៉ូសាយ 27–28; អាលម៉ា 17–20 ) ។[3]
- សូមរំឭកពីផ្នែកដែលនិយាយពីមិត្តភក្តិនៅក្នុង *ដើម្បីកម្លាំងនៃយុវជន* ។ សូមចែកចាយជាមួយយុវវ័យរបស់អ្នក ពីរបៀបដែលមិត្តភាពជះឥទ្ធិពលដល់ជីវិតរបស់អ្នក ។ សូមអញ្ជើញពួកគេឲ្យចែកចាយពីរបៀបដែលពួកគេជះឥទ្ធិពលដល់ និង ទទួលឥទ្ធិពលពីមិត្តភក្តិរបស់ពួកគេ ។
- សូមអានអត្ថបទរបស់បងស្រី ដាល់ថុន នៅក្នុងច្បាប់នេះ ។ សូមនិយាយអំពីគោលដៅដែលកូនស្រីរបស់គាត់ អេមី បានដាក់ដើម្បីស្វែងរកមិត្តល្អ ។ សូមជួយដល់កូនៗរបស់អ្នកឲ្យដាក់គោលដៅ អំពីប្រភេទមិត្តភក្តិដែលពួកគេចង់ស្វែងរក និង ចង់ក្លាយជា ។
- សូមពិចារណាអំពីការធ្វើរាត្រីជួបជុំក្រុមគ្រួសារដើម្បីចែកចាយគំនិតទាំងឡាយ ក្នុងការកសាងមិត្តភាព ដូចជា ៖ « ដើម្បីមានមិត្តល្អ ដើម្បីធ្វើជាមិត្តល្អ ។ ចូរបង្ហាញពីចំណាប់អារម្មណ៍ដ៏ពិតប្រាកដទៅដល់អ្នកដទៃទៀត ចូរញញឹម និង ធ្វើឲ្យពួកគេដឹងថាអ្នកខ្វល់ខ្វាយពីពួកគេ ។ ចូរប្រព្រឹត្តដល់មនុស្សគ្រប់រូបដោយសុភាពរាបសារ និង ការគោរព ហើយចៀសវាងពីការកាត់សេចក្ដី និង ការរិះគន់អ្នកទាំងឡាយដែលនៅជុំវិញអ្នក » ។[4]

## យោបល់ទាំងឡាយដើម្បីបង្រៀនកូនចៅ

- ការធ្វើជាមិត្តម្នាក់ គឺរួមបញ្ចូលទាំងការជួយដល់អ្នកដទៃទៀត ។ សូមអាន « ក្រោកឈរឡើងដើម្បីខេលិប » នៅក្នុង *លីអាហូណា* ខែ មិនា ឆ្នាំ 2009 ហើយនិយាយជាមួយកូនចៅរបស់អ្នក អំពីរបៀបទាំងឡាយដែលពួកគេអាចប្រព្រឹត្តិល្អដល់មនុស្សគ្រប់គ្នាដែលពួកគេជួប ។
- ក្នុងគ្រប់ស្ថានភាពទាំងអស់ យើងត្រូវតែធ្វើការសម្រេចចិត្ត ថាតើយើងនឹងធ្វើជាមិត្តភក្តិបែបណា ។ សូមច្រៀងបទ “I’m Trying to Be Like Jesus”[5] ជាមួយគ្នា ហើយបន្ទាប់មកនិយាយជាមួយកូនៗរបស់អ្នក អំពីរបៀបដែលពួកគេអាចជ្រើសរើសដើម្បីធ្វើជាមិត្តល្អម្នាក់តាមរបៀបផ្សេងៗ ដូចជាព្រះអង្គសង្គ្រោះបានធ្វើដែរ ។ ■

### បទគម្ពីរអំពីមិត្តភាព

សុភាសិត 17:17; 18:24
សាស្ដា 4:9–10
ម៉ាថាយ 25:34–40
លូកា 22:32
ម៉ូសាយ 18:8–9

**កំណត់ចំណាំ**

1. *ដើម្បីកម្លាំងនៃយុវជន* ( កូនសៀវភៅ ឆ្នាំ 2011 ) ទំព័រ 12 ។
2. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 12 ។
3. សូមមើល ជែហ្វ្រី អ័រ. ហូឡិន « Real Friendship »*New Era,* ខែ មិថុនា ឆ្នាំ 1998, ទំព័រ 62–66 ។
4. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 12 ។
5. “I’m Trying to Be Like Jesus,” *Children’s Songbook,* ទំព័រ 78–79 ។

គំនូរដោយ ម៉ាត ស្មីត

# ព្រះវិញ្ញាណបរិសុទ្ធលួងលោម បំផុស និង ថ្លែងទីបន្ទាល់

អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺជាពរជ័យមួយក្នុងចំណោមពរជ័យដ៏អស្ចារ្យបំផុតទាំងឡាយដែលយើងអាចទទួលនៅក្នុងជីវិតនេះ ត្បិតព្រះវិញ្ញាណបរិសុទ្ធលួងលោម បំផុស ដាស់តឿន ធ្វើឲ្យបរិសុទ្ធ និង ដឹកនាំយើង ។ ទ្រង់អាចបំពេញដល់យើងនូវ « សេចក្ដីសង្ឃឹម និង សេចក្ដីស្រឡាញ់ដ៏ឥតខ្ចោះ » ( មរ៉ូណៃ 8:26 ) ។ ទ្រង់បង្រៀន « សេចក្ដីពិតនៃការណ៍គ្រប់យ៉ាង » ( មរ៉ូណៃ 10:5 ) ។ យើងទទួលវិវរណៈ និង អំណោយទានខាងវិញ្ញាណពីព្រះ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សំខាន់បំផុត យើងទទួលទីបន្ទាល់របស់យើង អំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

មុនពេលអ្នកទទួលបុណ្យជ្រមុជទឹក អ្នកអាចទទួលអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធម្ដងម្កាល ។ ប៉ុន្តែ មានតែដោយការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធបន្ទាប់ពីបុណ្យជ្រមុជទឹករបស់អ្នកប៉ុណ្ណោះ ដែលអ្នកអាចរីករាយជាមួយនឹងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធយ៉ាងខ្ជាប់ខ្ជួន ប្រសិនបើអ្នកមានភាពសក្ដិសម ។ អំណោយនេះត្រូវបានផ្ដល់ឲ្យដោយអ្នកកាន់បព្វជិតភាពមិលគីស្សាដែក ដោយការដាក់ដៃលើ ( សូមមើល កិច្ចការ 19:6; គ. និង ស. 33:15 ) ។ រៀងរាល់ថ្ងៃសីលបន្ទាប់ពីនោះមក អ្នកអាចរំឭកឡើងវិញនូវសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់អ្នក ពេលដែលអ្នកទទួលសាក្រាម៉ង់ ហើយដោយធ្វើយ៉ាងដូច្នោះ ទទួលបាននូវពរជ័យពីព្រះអម្ចាស់ថា អ្នកអាច « បានព្រះវិញ្ញាណរបស់ទ្រង់ » គង់នៅជាមួយអ្នកជាដរាប ( គ. និង ស. 20:77 ) ។

ជាញឹកញាប់ ព្រះវិញ្ញាណបរិសុទ្ធត្រូវបានគេសំដៅថាជាព្រះវិញ្ញាណ ជាសមាជិកទីបីនៃក្រុមព្រះ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា ៖ « ព្រះវរបិតាទ្រង់មានព្រះកាយជាសាច់ និង ឆ្អឹង ដែលជាក់ស្ដែងដូចជារូបកាយមនុស្ស ព្រះរាជបុត្រាដ៏ដូច្នោះដែរ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធពុំមានព្រះកាយជាសាច់ និង ឆ្អឹងឡើយ តែមានរូបជាវិញ្ញាណវិញ ។ បើពុំនោះទេព្រះវិញ្ញាណបរិសុទ្ធពុំអាចសណ្ឋិតនៅក្នុងយើងបានឡើយ » ( គ. និង ស. 130:22 ) ។

« ពីព្រោះព្រះវិញ្ញាណនៃព្រះអម្ចាស់ពុំគង់នៅក្នុងព្រះវិហារណាដែលឥតបរិសុទ្ធ » ( ហេលេមិន 4:24 ) នោះយើងត្រូវតែមានភាពសក្ដិសមនឹងភាពជាដៃគូរបស់ទ្រង់ ។ ក្នុងចំណោមអ្វីៗផ្សេងទៀត យើងធ្វើដូច្នោះដោយការមានគំនិតដែលប្រកបដោយគុណធម៌ រស់នៅដោយមានសច្ចភាព និង ព្យាយាមរក្សាបទបញ្ញត្តិទាំងឡាយ ។ ■

សម្រាប់ព័ត៌មានបន្ថែម សូមមើល នីហ្វៃទី2 31:13, 17; 32:5; នីហ្វៃទី3 27:20; មរ៉ូណៃ 10:5–8; យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:70 ។



## យើងមិនត្រូវទទួលយកអំណោយនេះដោយទទេៗនោះទេ

« ដូចជាអំណោយទាំងអស់ដែរ អំណោយនេះត្រូវតែបានទទួល និង ព្រមទទួលដោយរីករាយ ។ ពេលបព្វជិតភាពដាក់ដៃលើក្បាលអ្នក ដើម្បីបញ្ជាក់អ្នកជាសមាជិកមួយរូបនៃសាសនាចក្រ អ្នកបានឮពាក្យថា ‹ ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ › ។ នេះមិនមែនមានន័យថា ព្រះវិញ្ញាណបរិសុទ្ធបានក្លាយជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់អ្នក ដោយគ្មានលក្ខខណ្ឌនោះទេ ។ បទគម្ពីរទាំងឡាយព្រមានយើងថា ព្រះវិញ្ញាណនៃព្រះអម្ចាស់នឹង ‹ មិនតវ៉ានឹងមនុស្សជាដរាបទេ › ( លោកុប្បត្តិ 6:3 ) ។ ពេលយើងទទួលការបញ្ជាក់ យើងត្រូវបានផ្ដល់ឲ្យនូវ*សិទ្ធិ*ដើម្បីមានភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែវាជាសិទ្ធិមួយ ដែលយើងត្រូវតែបន្តទទួលបានតាមរយៈការគោរពប្រតិបត្តិ និង ភាពសក្ដិសម » ។

**អែលឌើរ យ៉ូសែប ប៊ី. វ៉ឺតលីន ( ឆ្នាំ 1917–2008 )** ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ **« The Abundant Life »** ***លីអាហូណា*** **ខែឧសភា ឆ្នាំ 2003 ទំព័រ 28 ។**

បន្ទាប់ពីទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធហើយ យើងអាចធ្វើអ្វីៗជាច្រើន ដើម្បីអញ្ជើញព្រះចេស្ដារបស់ទ្រង់ចូលក្នុងជីវិតយើង ៖

*ទទួលទានសាក្រាម៉ង់ដោយសក្តិសម ។*



*អធិស្ឋាន ។*



*សិក្សាព្រះគម្ពីរ ។*







*ថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធ ។*



*មើលប្រព័ន្ធផ្សព្វផ្សាយដែលល្អ ប្រើភាសាស្អាតស្អំ និង មានគំនិតដែលប្រកបដោយគុណធម៌ ។*

រូបថតដោយ គ្រីស្ទីណា ស្មីធ, អឺរ ថាហ្វ, ឌូឌី រ៉េ និង ម៉ាថាយ រៀ

# សេចក្ដីស្លាប់ និង ជីវិត

## ទស្សនវិស័យរបស់អ្នកត្រួសត្រាយ អំពីដំណើររស់ឡើងវិញ

*ពេលដែលអ្នកប្រែចិត្តជឿដល់សាសនាចក្រពីជំនាន់មុន បានធ្វើដំណើរទៅភាគខាងលិចនៃសហរដ្ឋ ដើម្បីប្រមូលផ្ដុំគ្នាជាមួយពួកបរិសុទ្ធ នោះពួកគេបានជួបប្រទះនឹងសេចក្ដីស្លាប់ ប៉ុន្តែត្រូវបានគាំទ្រដោយសេចក្ដីជំនឿថ្មីថ្មោងរបស់ពួកគេ នៅក្នុងដំណឹងល្អដែលបានស្ដារឡើងវិញ ។ ខាងក្រោមនេះជាសេចក្ដីដកស្រង់ពីបញ្ជីប្រវត្តិរបស់អ្នកត្រួសត្រាយ ដែលបង្ហាញពីសេចក្ដីសង្ឃឹមរបស់ពួកបរិសុទ្ធក្នុងដំណើររស់ឡើងវិញ ជាមួយនឹងការបង្រៀនដែលប្រកបដោយការលួងលោមពីប្រធានសាសនាចក្រប្រាំនាក់ដំបូង ។*

*ដំណើររឿងមួយរបស់ឪពុកជាពួកបរិសុទ្ធជនជាតិស្កេនឌីណាវៀ ដែលគេមិនស្គាល់ឈ្មោះម្នាក់ ដែលមានកូនប្រុសពៅបានស្លាប់ក្នុងការធ្វើដំណើរពីទីក្រុង នូវយ៉ោក ទៅរដ្ឋ យូថាហ៍ ក្នុងឆ្នាំ 1866 ថា ៖*

« ដោយបានជំនួយពីមិត្តម្នាក់ នោះគេបានជីកផ្នូរតូចមួយ ហើយសាកសពត្រូវបានបញ្ចុះនៅទីនោះ ។ កូនតូចនោះស្លាប់ដោយសារជំងឺឆ្លងម៉្យាង ពុំមានការប្រមូលផ្ដុំអ្នកកាន់ទុក្ខ ពុំមានពិធីជាផ្លូវការអ្វីនោះទេ ពុំមានផ្កា ពុំមានចម្រៀងខាងវិញ្ញាណ ពុំមានពាក្យសសើរតម្កើងឡើយ ។ ប៉ុន្តែពីមុនពេលដែលឪពុកដ៏មានទុក្ខចាកចេញទៅ គាត់បានបន្លឺការអធិដ្ឋានដ៏ខ្លីមួយ ជាភាសាកំណើតរបស់គាត់ ( ភាសាដាណឺម៉ាក ) ដូចតទៅនេះ ៖ . . .

« ‹ ព្រះវរបិតាសួគ៌ ៖ ទ្រង់បានប្រទានដល់កូននូវរតនៈសម្បត្តិដ៏តូចនេះ—ជាកូនប្រុសជាទីស្រឡាញ់នេះ ហើយឥឡូវនេះទ្រង់បានហៅគេទៅវិញ ។ សូមទ្រង់ប្រទានពរថា សាកសពរបស់គេអាចនៅទីនេះដោយពុំមានការរំខាន រហូតដល់ព្រឹកនៃដំណើររស់ឡើងវិញ ។ សូមព្រះទ័យទ្រង់បានសម្រេច ។ អាម៉ែន › ។

« ហើយពេលក្រោកឡើងពីដី ពាក្យសម្ដីបែកគ្នារបស់គាត់គឺ ៖

« ‹ លាសិនហើយ ហានស៍ដ៏តូចជាទីស្រឡាញ់របស់ឪពុក—កូនប្រុសដ៏ស្រស់ស្អាតរបស់ឪពុកអើយ › ។ បន្ទាប់មក ដោយក្បាលឱនចុះ និង ដួងចិត្តឈឺចាប់ គាត់បានបន្តដំណើរដោយក្លាហានទៅកាន់កន្លែងបោះជំរុំ » ។[1]

*ប្រធាន យ៉ូសែប ស៊្មីធ ( 1805–44 ) ៖*

« ពេលដែលពួកគេត្រូវតែចាកចេញពីស្វាមី ភរិយា ឪពុក ម្ដាយ កូន ឬ សាច់ញាតិជាទីស្រឡាញ់ដោយសារសេចក្ដីស្លាប់ ឱ ! ជាការលួងលោមយ៉ាងណាទៅដែលដឹងថា ទោះបីជារូបកាយសាច់ឈាមត្រូវបានកប់ និង រលាយទៅ ក៏ពួកគេនឹងរស់ឡើងវិញម្ដងទៀត ដើម្បីនៅចំពោះការឆេះដ៏នៅអស់កល្បជានិច្ច ក្នុងសិរីល្អដ៏អមតៈ ពុំមានព្រួយការរងទុក្ខ ឬ ស្លាប់ទៀតឡើយ ប៉ុន្តែពួកគេនឹងក្លាយជាអ្នកគ្រងមរតកនៃព្រះ និង ជាអ្នកគ្រងមរតកជាមួយព្រះយេស៊ូវគ្រីស្ទដែរ » ។[2]

ចេឡូប្រភាពដោយ ម៉ៃឃើល ធី. ម៉ម រិង ផ្ទាំងខាងក្រោយដោយ អ៊ែលឌិន ស៊ី. អេរចេរីរ © IRI



*យ៉ូសែប វេតសុន យ៉ង់* ( 1828–73 ) *ក្មួយប្រុសរបស់ព្រិកហាំ យ៉ង់ ដែលបានធ្វើដំណើរពីប្រទេស អង់គ្លេស ទៅសហរដ្ឋក្នុងឆ្នាំ* 1853 ៖

« វាជារឿងដ៏សោកសង្រេងណាស់ ដែលត្រូវកប់សាកសពនៅក្នុងសមុទ្រនារាត្រីដ៏ងងឹតដោយមានសាក្សីតែពីរបីនាក់នោះ ។ . . . គាត់គ្មានសាច់ញាតិនៅលើកប៉ាល់ ឬ នរណាម្នាក់ដែលកាន់ទុក្ខសម្រាប់គាត់ឡើយ លើកលែងតែអ្នកបម្រើដែលមកជាមួយម្នាក់ ។ ទាំងនេះជាសេចក្តីសង្ឃឹមដ៏គួរឲ្យរីករាយបំផុតរបស់ធម្មជាតិមនុស្ស ដែលត្រូវបានបំផ្លាញភ្លាមមួយរំពេច ។ បុរសវ័យក្មេងនេះ បានលះបង់ចោលអ្វីៗទាំងអស់ ដើម្បីទៅកាន់ក្រុងស៊ីយ៉ូន ហើយដួងចិត្តរបស់គាត់ត្រូវបានបំពេញដោយក្តីសង្ឃឹមថានឹងមានអនាគតមួយដែលពេញដោយការរីករាយ និង ការរំភើប ដោយគ្រាន់តែបានគិតបន្តិចបន្តួចប៉ុណ្ណោះថាគាត់ប្រហែលត្រូវបោះរូបកាយសាច់ឈាមរបស់គាត់ទៅក្នុងរលកដ៏ស្រេកឃ្លាននោះ ។ ទោះជាយ៉ាងណា គាត់ពុំបានស្លាប់ទៅដូចជាពួកអ្នកទាំងឡាយដែលបានស្លាប់ទៅទាំងគ្មានក្តីសង្ឃឹមនោះទេ ត្បិតសេចក្តីសុខសាន្តរបស់គាត់បានជាប់នៅជាមួយនឹងព្រះរបស់គាត់ ហើយគាត់បានមានការធានាអះអាងដ៏ពេញលេញថា នឹងបានការរស់ឡើងវិញដ៏មានសិរីរុងរឿង នាពេលព្រឹកនៃមនុស្សសុចរិត » ។[3]





*ខាងឆ្វេង ៖ ប្រធាន ព្រិកហាំ យ៉ង់ ។ ខាងលើ ៖ យ៉ូសែប វេតសុន យ៉ង់ ។*

*ប្រធាន ព្រិកហាំ យ៉ង់* ( 1801–77 ) ៖

« ឱ ! វាជាជ្រលង និង ជាស្រមោលដ៏ងងឹតយ៉ាងណាទៅ ដែលយើងហៅវាថាជាសេចក្តីស្លាប់នោះ ! និយាយពីរូបកាយរមែងស្លាប់ ដើម្បីឆ្លងកាត់ពីស្ថានភាពនៃជីវិតរស់នៅនេះ ទៅក្នុងស្ថានភាពនៃការចុះទន់ខ្សោយដោយការខ្វះអាហារ [ ស្ថានភាពទទេ ] ឱ ! វាចម្លែកម៉្លេះ ! ឱ ! ជ្រលងនេះងងឹតម៉្លេះ ! ឱ ! ផ្លូវនេះអ៊ីក៏អាថ៌កំបាំងម៉្លេះ ហើយយើងត្រូវតែធ្វើដំណើរតាមផ្លូវនេះតែមួយប៉ុណ្ណោះ ។ ខ្ញុំចង់និយាយទៅកាន់អ្នក មិត្តភក្តិ និង បងប្អូនរបស់ខ្ញុំអើយ ថា ប្រសិនបើយើងអាចមើលឃើញអ្វីៗដូចដែលវាមានបែបនោះ និង ដូចដែលយើងនឹងឃើញ និង យល់ពីវានោះ នោះស្រមោល និង ជ្រលងដ៏ងងឹតនេះ គឺគួរឲ្យរំខានណាស់ ដែលយើងនឹងងាក និង មើលត្រឡប់ក្រោយវិញ ហើយគិត គឺពេលដែលយើងបានស្លាប់ទៅនោះ ពិតណាស់នេះជាប្រយោជន៍ដ៏ធំបំផុតក្នុងមួយជីវិតខ្ញុំ ត្បិតខ្ញុំបានឆ្លងផុតពីស្ថានភាពនៃទុក្ខព្រួយ សេចក្តីសោកសៅ យំយែក វេទនា ទុក៌ត ឈឺចាប់ ការថប់បារម្ភ និង ការខកចិត្ត ទៅក្នុងស្ថានភាពនៃស្ពេរភាព កន្លែងដែលខ្ញុំអាចរីករាយក្នុងជីវិតដល់អស់ពីលទ្ធភាព តាមដែលអាចធ្វើបានដោយមិនបាច់មានរូបកាយ ។[4]





នៅក្នុងរូបភាព ៖ *ព្រិកហាំ យ៉ង់* ដោយ ចន វីលឡាដ ខ្លសុន រូប យ៉ូសែប វេតសុន យ៉ង់ ដោយបានការអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ រូប ឌេន ចូនស៍ © IRI; *យ៉ូហាន ថេរ៉េសី* ដោយ អេ. វេសថ៍វុដ ដោយបានការអនុញ្ញាតជាផ្លូវការពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ



*ឌែន ចូនស៍ ( 1811–62 ) អ្នកប្រែចិត្តជឿជនជាតិវេលស៍ ដែលបានធ្វើដំណើរតាមកប៉ាល់មកកាន់សហរដ្ឋក្នុងឆ្នាំ 1849 ជាមួយលោកស្រី វីល្លៀមស៍ និង សមាជិកសាសនាចក្រដទៃទៀត ៖*

« លោកស្រី វីល្លៀមស៍ ពីក្រុងវ៉ាយនីស៊ីប៊ុនថ៍ នៅជិតក្រុងទ្រេហ្គារុន [ ប្រទេស វេលស៍ ] សុខភាពរបស់គាត់ចុះខ្សោយយ៉ាងឆាប់រហ័ស ហើយមានសញ្ញាថា គាត់ពុំអាចរស់នៅបានយូរទេ ។ . . . គាត់បាននិយាយថា កិត្តិយសដ៏ធំបំផុតដែលគាត់ទទួល គឺជាការដែលអាចក្លាយជាសមាជិកនៃសាសនាចក្រដ៏ពិតនៃព្រះរាជបុត្រានៃព្រះ ថាពុំមានសេចក្តីភ័យខ្លាចនៅក្នុងទ្រូងគាត់ដែលទាក់ទងទៅនឹងជីវិតផ្សេងទៀត និង ថាឥឡូវនេះ សាសនារបស់គាត់បានបង្ហាញពីកម្លាំងរបស់សាសនានេះខ្លាំងជាងពេលពីមុនទាំងអស់ ។ . . . គាត់បានផ្តល់ដំបូន្មានដ៏រឹងមាំដល់កូនប្រុសទាំងឡាយរបស់គាត់ ឲ្យបន្តស្មោះត្រង់រហូតដល់ស្លាប់ ដើម្បីពួកគេអាចបានទទួលនូវដំណើររស់ឡើងវិញដ៏កាន់តែប្រសើរមួយ ជាមួយគាត់ ។ . . . គាត់បានបន្តនិយាយយ៉ាងច្បាស់លាស់អស់ពេញមួយរាត្រី ហើយនៅម៉ោងបួន និង ដប់ប្រាំនាទី ព្រឹកបន្ទាប់នោះ វិញ្ញាណរបស់គាត់បានចាកចេញទៅដោយសេចក្តីសុខសាន្ត ដោយសន្សល់នូវស្នាមញញឹមនៅលើបបូរមាត់គាត់ »។[5]





*ខាងស្តាំ ៖ ប្រធាន យ៉ូហាន ថេលើរ ។ ខាងលើ ៖ ឌែន ចូនស៍ ។*

*ប្រធាន យ៉ូហាន ថេលើរ ( 1808–87 ) ៖*

« ឱ ! វាជាការលួងលោមអ្វីម្ល៉េះ ដល់ពួកអ្នកដែលត្រូវទួញសោកដោយសារការបាត់បង់មិត្តជាទីស្រឡាញ់ដោយការស្លាប់ ដែលដឹងថា យើងនឹងបានរួបរួមជាមួយពួកគេម្តងទៀតនោះ ! ឱ ! ជាការលើកទឹកចិត្តអ្វីម្ល៉េះ ដល់អ្នកទាំងអស់ដែលរស់នៅតាមគោលការណ៍នៃសេចក្តីពិតដែលបានបើកសម្តែង ប្រហែលជាពិសេសគឺដល់ពួកអ្នកដែលរស់នៅជិតដល់ទីបញ្ចប់នៃជីវិតគេទៅហើយនោះ ដែលបានទ្រាំទ្រនឹងកំដៅ និង បន្ទុកនៃជីវិតគេ ដែលដឹងថា មិនយូរប៉ុន្មានយើងនឹងបានក្រោកឡើងពីផ្នូរ និង ក្លាយជាព្រលឹងដ៏នៅរស់ និង អមតៈ ដើម្បីបានរីករាយនឹងការរួបរួមជាមួយមិត្តភក្តិដែលបានទទួលការសាកល្បង និង បានទុកចិត្ត ពុំត្រូវរងទុក្ខវេទនានឹងសេចក្តីស្លាប់ទៀតឡើយ និង ដើម្បីបញ្ចប់កិច្ចការដែលព្រះវរបិតាបានប្រទានឲ្យយើងធ្វើ ! »[6]

*អែនឌ្រូវ ជិនសុន ( 1850–1941 ) អ្នកអន្តោប្រវេសន្តជនជាតិដាណឺម៉ាក ដែលបានធ្វើដំណើរក្នុងក្រុមរទេះ អែនឌ្រូវ អេច. ស្កត់ ពីរដ្ឋ នេប្រាស្កា ស.រ.អា. ទៅរដ្ឋ យូថាហ៍ ក្នុងឆ្នាំ 1866 ៖*

« ពេលយើងបានឃើញសាកសពខាងសាច់ឈាមរបស់គេ [ អ្នកដែលធ្វើដំណើរជាមួយយើង ] ត្រូវបានកប់នៅក្នុងដី នៅក្នុងទីវាលរហោស្ថាន យើងទាំងអស់គ្នាស្រក់ទឹកភ្នែក ឬ មានមានអារម្មណ៍ដូចស្រក់ទឹកភ្នែក ត្បិតការគិតពីការកប់អ្នកជាទីស្រឡាញ់ក្នុងរបៀបនេះ គឺពេលដែលមិត្តភក្តិ និង សាច់ញាតិ ត្រូវតែប្រញាប់ចេញដំណើរទៅមួយរំពេច ដោយគ្មានក្តីសង្ឃឹមថានឹងបានមកកន្លែងដែលកប់សាច់ញាតិដែលស្លាប់របស់គេម្តងទៀតនោះ គឺជារឿងសោកសៅ និង លំបាកជាទីបំផុត ។ . . . ប៉ុន្តែផ្នូររបស់ពួកគេនឹងត្រូវបានរកឃើញនៅពេលដែលទេវតាកាព្រីយ៉ែលបន្លឺសម្លេងត្រែរបស់ទ្រង់ នៅព្រឹកនៃដំណើររស់ឡើងវិញលើកទីមួយ ។ អ្នកដែលបានឃ្លាតទៅទាំងនេះ បានផ្តេករូបកាយគេចុះ ដូចជាពួកគេកំពុងធ្វើដំណើរទៅកាន់ក្រុងស៊ីយ៉ូនដែរ ។ ព្រះអម្ចាស់បានហៅពួកគេត្រឡប់ទៅផ្ទះពីមុនពេលដែលពួកគេបានទៅដល់ទីផ្តាច់ព្រ័ត្ររបស់គេ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យបានឃើញក្រុងស៊ីយ៉ូននៅពេលជាសាច់ឈាម ប៉ុន្តែពួកគេនឹងបានទទួលសិរីល្អ និង រីករាយចាប់ពីពេលនេះតទៅ ពួកគេបានស្លាប់ខណៈដែលកំពុងខំប្រឹងប្រែងដើម្បីគោរពព្រះ និង រក្សាបទបញ្ញត្តិរបស់ទ្រង់ ហើយពួកគេត្រូវបានប្រទានពរដោយបានស្លាប់ក្នុង [ ព្រះអម្ចាស់ ] » ។[7]





*ខាងឆ្វេង ៖ ប្រធាន វិលហ្វ៊ឺឌ វូឌ្រ័ុព្វ ។ ខាងលើ ៖ អែនឌ្រូវ ជិនសុន ។*

*ប្រធាន វិលហ្វ៊ឺឌ វូឌ្រ័ុព្វ ( 1807–98 ) ៖*

« បើគ្មានដំណឹងល្អនៃព្រះគ្រីស្ទ នោះការបែកបាក់ដោយសេចក្តីស្លាប់ គឺជាប្រធានបទមួយនៃប្រធានបទដ៏អាប់អួរបំផុតទាំងឡាយ ដែលវាអាចត្រូវយកមកសញ្ជឹងគិត ប៉ុន្តែភ្លាមៗពេលដែលយើងទទួលបានដំណឹងល្អ និង រៀនពីគោលការណ៍នៃដំណើររស់ឡើងវិញ នោះភាពអាប់អួរ ទុក្ខព្រួយ និង ការរងទុក្ខ ដែលបណ្តាលមកពីសេចក្តីស្លាប់ ត្រូវបានដកចេញភាគច្រើនបំផុត ។ . . . ដំណើររស់ឡើងវិញនៃអ្នកស្លាប់ បង្ហាញខ្លួនវានៅពីមុខគំនិតដែលត្រូវបានបំភ្លឺរបស់មនុស្ស ហើយគេមាននូវគ្រឹះសម្រាប់វិញ្ញាណរបស់គេបានសម្រាក ។ នោះគឺជាឥរិយាបថរបស់ពួកបរិសុទ្ធសព្វថ្ងៃនេះ ។ យើងមិននៅក្នុងទីងងឹតទេចំពោះបញ្ហានេះ យើងពិតជាដឹងដោយខ្លួនយើងថា ព្រះបានបើកសម្តែងវាដល់យើង ហើយយើងពិតជាយល់ពីគោលការណ៍នៃដំណើររស់ឡើងវិញនៃអ្នកស្លាប់ ហើយថា ដំណឹងល្អនាំមកនូវជីវិត និង ភាពអមតៈមកកាន់ពន្លឺ » ។[8]



**កំណត់ចំណាំ**

1. Robert Aveson, “Leaves from the Journal of a Boy Emigrant,” *Deseret News*, ខែ មិនា ។ 12, 1921, 4:7; មាននៅគេហទំព័រ lds.org/churchhistory/library/pioneercompanysearch ។
2. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ( ឆ្នាំ 2007 ) ទំព័រ 52 ។
3. Joseph W. Young, Journal, ថ្ងៃទី 6 ខែ មិនា ឆ្នាំ 1853, Church History Library, Salt Lake City, Utah; មាននៅលើអ៊ិនធើណិតលើគេហទំព័រ mormonmigration.lib.byu.edu ។
4. *Teachings of Presidents of the Church: Brigham Young* ( ឆ្នាំ 1997 ) ទំព័រ 273 ។
5. « សំបុត្រមកពីនាយក្រុមនាវា D. Jones ទៅអ្នកកែសម្រួលនៃ *Udgorn Seion,* » នៅក្នុង Ronald D. Dennis, *The Call of Zion: The Story of the First Welsh Mormon*

នៅក្នុងរូបភាព ៖ *វិលហ្វ៊ឺឌ វូឌ្រ័ុព្វ* ដោយ អេច. អ៊ី. ភិតធើរសុន © IRI រូប អែនឌ្រូវ ជិនសុន ដោយ ហារូដ ហូវែល ជិនសុន ដោយបានការអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ រូប វិល្លៀម ជ្រាយវើរ ដោយបានការអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ *ឡូវែនសូ ស្នូ* ដោយ លូវីស រេមសី ដោយបានការអនុញ្ញាតជាផ្លូវការពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ © IRI



*វិល្លៀម ដ្រាយវើរ ( 1837–1920 ) ជាអ្នកត្រួសត្រាយ ដែលបានធ្វើដំណើរពីប្រទេស អង់គ្លេសមករដ្ឋ នូវយ៉ោក ស.រ.អា. ក្នុងឆ្នាំ 1866 ៖*

« វិល្លី កូនជាទីស្រឡាញ់បំផុតរបស់ខ្ញុំ បានឈឺជាទម្ងន់ អស់ពេញមួយយប់រហូតដល់ម៉ោង 7:30 នាទី ព្រឹក ពេល ដែលគេត្រូវបានដោះលែងពីការរងទុក្ខវេទនារបស់គេ ។ សូម ព្រះប្រទានពរដល់ព្រលឹងដ៏ជាទីស្រឡាញ់របស់គេ ។ ឱ ! គេ រងទុក្ខយ៉ាងណា ។ គេបានស្លាប់ដោយសាររទេះរបស់លោក ផ្លូលធើរ បានខូចនៅលើទួល សេនថ៍ អាន ក្នុងស្រុកវេនស័រវែស ក្រុង ស៊ើរី ប្រទេស អង់គ្លេស ។ ឱ ! ខ្ញុំទួញយំចំពោះទុក្ខវេទនា ដ៏ធំធេងនេះខ្លាំងណាស់ ។ ឱ ! ព្រះអម្ចាស់អើយ សូមជួយកូន ដោយព្រះចេស្ដារបស់ទ្រង់ផង ដើម្បីកូនអាចទ្រាំទ្រវាបាន តាមតែព្រះហឫទ័យរបស់ ទ្រង់ចុះ ហើយសូមប្រទានកម្លាំងដល់កូន ដើម្បីកូនបម្រើទ្រង់ឲ្យកាន់តែថ្លៃថ្នូ និង កាន់តែ ស្មោះត្រង់ ហើយសូមឲ្យកូនអាចរស់នៅដើម្បីរៀបចំទៅជួបគេ ក្នុងពិភពដែលកាន់តែ រីករាយ និង កាន់តែល្អប្រសើរជាងនេះ ជាមួយនឹងប្អូនស្រីជាទីស្រឡាញ់របស់គេគឺ អេលីស្សាបែត ម៉ារីអាន ហើយនៅឯដំណើររស់ឡើងវិញនៃមនុស្សសុចរិត សូមឲ្យ កូនអាចនៅទីនោះដើម្បីជួបពួកគេ » ។[9]





*ខាងស្ដាំ ៖ ប្រធាន ឡូរ៉េនសូ ស្នូ ។ ខាងលើ ៖ វិល្លៀម ដ្រាយវើរ ។*

*ប្រធាន ឡូរ៉េនសូ ស្នូ ( 1814–1901 ) ៖*

« នៅក្នុងជីវិតក្រោយ យើងនឹងមានរូបកាយដែលមាន សិរីរុងរឿង និង គ្មានជំងឺ និង សេចក្ដីស្លាប់ឡើយ ។ គ្មានអ្វីស្រស់ស្អាតដូចជាមនុស្សម្នាក់ដែលនៅក្នុងស្ថានភាព នៃការរស់ឡើងវិញ និង មានសិរីរុងរឿងនោះឡើយ ។ គ្មានអ្វីដែលគួរឲ្យស្រឡាញ់ជាងការនៅក្នុងស្ថានភាពនេះ និង មានភរិយា និង កូនចៅ និង មិត្តភក្តិរបស់យើងជាមួយយើង នោះទេ » ។[10] ■

*ដើម្បីភាពងាយស្រួលក្នុងការអាន នោះការប្រកប ការដាក់វណ្ណយុត្តិ និង ការសរសេរអក្សរធំមួយចំនួនត្រូវបាន ធ្វើបមាណីយកម្ម ។*

*Emigration,* vol. 2 ( ឆ្នាំ 1987 ), ទំព័រ 164–65; មាននៅគេហទំព័រ mormonmigration.lib.byu.edu ។

6. *Teachings of Presidents of the Church: John Taylor* ( ឆ្នាំ 2001 ) ទំព័រ 50–51 ។

7. កំណត់ហេតុនៃអែនឌ្រូវ ជិនសុន ថ្ងៃទី 20 ខែ សីហា ឆ្នាំ 1866 នៅក្នុង *Journal History of The Church of Jesus Christ of Latter-day Saints,* Oct. 8, 1866, Church History Library, Salt Lake City, Utah, ទំព័រ 6; មាននៅគេហទំព័រ lds.org/churchhistory/library/pioneercompanysearch ។

8. *Teachings of Presidents of the Church: Wilford Woodruff* ( ឆ្នាំ 2004 ), ទំព័រ 82–83 ។

9. Frank Driver Reeve, ed., *London to Salt Lake City in 1866: The Diary of William Driver* ( ឆ្នាំ 1942 ), ទំព័រ 42; មាននៅគេហទំព័រ mormonmigration.lib.byu.edu ។

10. ឡូរ៉េនសូ ស្នូ នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1900 ទំព័រ 63 ។



**ដោយ អែលឌើរ រ័សុល អិម. ណិលសុន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# បេសកកម្ម និង ការបម្រើរបស់ ព្រះយេស៊ូវគ្រីស្ទ

*ភស្តុតាងដ៏ល្អបំផុតនៃការគោរពរបស់យើងចំពោះព្រះយេស៊ូវ គឺការយកគំរូតាមទ្រង់ ។*

ក្នុងនាមជាសាក្សីម្នាក់ក្នុងចំណោម « ពួកសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទ នៅពេញសព្វក្នុងពិភពលោក » ( គ. និង ស. 107:23 ) ខ្ញុំជឿថា ខ្ញុំបម្រើបានល្អបំផុត ប្រសិនបើខ្ញុំបង្រៀន និង ធ្វើទីបន្ទាល់អំពីទ្រង់ ។ ទីមួយ ខ្ញុំអាចសួរសំណួរដូចគ្នានេះ ដែលមានម្ដងនោះ ទ្រង់បានសួរដល់ពួកផារិស៊ីថា ៖ « តើអ្នករាល់គ្នាគិតពីព្រះគ្រីស្ទដូចម្ដេច ? តើទ្រង់ជាព្រះវង្សអ្នកណា ? » ( ម៉ាថាយ 22:42 ) ។

ខ្ញុំបានគិតពីសំណួរទាំងនេះជាញឹកញាប់ ពេលដែលខ្ញុំជួបជាមួយពួកអ្នកដឹកនាំរដ្ឋាភិបាល និង និកាយសាសនាផ្សេងៗ ។ អ្នកខ្លះទទួលស្គាល់ថា « ព្រះយេស៊ូវជាគ្រូបង្រៀនដ៏អស្ចារ្យ » ។ អ្នកខ្លះទៀតថា « ទ្រង់ជាព្យាការីម្នាក់ » ។ អ្នកផ្សេងទៀតគឺមិនស្គាល់ទ្រង់សោះតែម្ដង ។ យើងមិនគួរមានការភ្ញាក់ផ្អើលខ្លាំងនោះទេ ។ ទោះបើយ៉ាងនោះក៏ដោយ ក៏មានមនុស្សមួយចំនួនតូចដែលមានសេចក្ដីពិតនៃដំណឹងល្អដែលស្ដារឡើងវិញ ដែលយើងមាននេះដែរ ។ សមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺមានចំនួនតិចតួចប៉ុណ្ណោះក្នុងចំណោមពួកអ្នកដែលប្រកាសថាជាពួកគ្រីស្ទាន ។

ស្ថានភាពរបស់យើងសព្វថ្ងៃនេះ ត្រូវបានទាយទុកជាមុន ជាច្រើនសតវត្សមកហើយ ដោយនីហ្វៃ ៖

« ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានមើល ហើយបានឃើញសាសនាចក្រនៃកូនចៀមនៃព្រះ ហើយសមាជិកនៃសាសនាចក្រមានចំនួនតិចណាស់ . . . ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំបានឃើញថា សាសនាចក្រនៃកូនចៀមដែលជាពួកបរិសុទ្ធរបស់ព្រះ ក៏មាននៅពាសពេញលើផ្ទៃផែនដីដែរ ហើយអំណាចរបស់ពួកគេនៅលើផ្ទៃផែនដីមានចំនួនតូច ។ . . .

« ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានឃើញថា ព្រះចេស្ដានៃកូនចៀមនៃព្រះបានយាងចុះមកសណ្ឋិតលើពួកបរិសុទ្ធក្នុងសាសនាចក្រនៃកូនចៀម ហើយលើរាស្ត្រដែលនៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ ដែលបានខ្ចាត់ខ្ចាយលើផ្ទៃផែនដី ហើយពួកគេប្រដាប់អាវុធដោយសេចក្ដីសុចរិត និង ដោយព្រះចេស្ដានៃព្រះ ដោយសិរីល្អដ៏អស្ចារ្យ » ( នីហ្វៃទី1 14:12, 14 ) ។

សេចក្ដីសុចរិតនោះ អំណាចនោះ និង សិរីល្អនោះ—ប្រាកដណាស់ គឺគ្រប់ពរជ័យជាច្រើនរបស់យើង—គឺបានមកពីចំណេះដឹងរបស់យើងអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ពីការគោរពប្រតិបត្តិ និង ការដឹងគុណ និង សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។

ដោយ ជេមស៍ ធីសុត







អំឡុងពេលនៃការអាស្រ័យនៅយ៉ាងខ្លីរបស់ទ្រង់នៅក្នុងភាពរមែងស្លាប់ ព្រះអង្គសង្គ្រោះសម្រេចបាននូវគោលបំណងដ៏ធំពីរ ។ គោលបំណងមួយគឺ « កិច្ចការ [ របស់ទ្រង់ ] និង សិរីល្អ [ របស់ទ្រង់ ] —ដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ 1:39 ) ។ គោលបំណងមួយទៀតទ្រង់បានមានបន្ទូលដោយសាមញ្ញថា ៖ « ខ្ញុំបានធ្វើដំរាប់ទុកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ » ( យ៉ូហាន 13:15 ) ។

គោលបំណងទីមួយរបស់ទ្រង់ គឺយើងស្គាល់ថាជាដង្វាយធួន ។ ការណ៍នេះជាបេសកកម្មដ៏រុងរឿងរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ ។ ព្រះអម្ចាស់ដែលបានរស់ឡើងវិញ បានប្រទាននូវសេចក្ដីថ្លែងពីបេសកកម្មរបស់ទ្រង់ ចំពោះប្រជាជនអាមេរិកពីបុរាណថា ៖

« យើងបានមកឯលោកិយនេះ ដើម្បីធ្វើតាមព្រះហឫទ័យនៃព្រះវរបិតារបស់យើង ពីព្រោះព្រះវរបិតារបស់យើង ទ្រង់បានចាត់ឲ្យយើងមក។

« ហើយព្រះវរបិតាយើង ទ្រង់បានចាត់ឲ្យយើងមក ដើម្បីឲ្យយើងអាចត្រូវបានលើកឡើងលើឈើឆ្កាង ហើយបន្ទាប់ពីយើងត្រូវបានលើកឡើងលើឈើឆ្កាង គឺប្រយោជន៍ឲ្យយើងអាចទាញនាំគ្រប់មនុស្សទាំងអស់ឲ្យមករកយើង » ( នីហ្វៃទី3 27:13–14 ) ។

ក្នុងការបន្តទេសនកថារបស់ទ្រង់ ទ្រង់បានបើកសម្ដែងនូវគោលបំណងទីពីររបស់ទ្រង់—គឺដើម្បីធ្វើជាព្រះអង្គគំរូរបស់យើង ៖ « អ្នករាល់គ្នាស្គាល់ការណ៍ទាំងឡាយដែលអ្នករាល់គ្នាត្រូវធ្វើ . . . ត្បិតកិច្ចការទាំងឡាយដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នករាល់គ្នាត្រូវធ្វើយ៉ាងនោះដែរ » ( នីហ្វៃទី3 27:21 ) ។

ខ្ញុំបានកំណត់ន័យឲ្យគោលបំណងទីមួយរបស់ទ្រង់ថាជា *បេសកកម្មរបស់ទ្រង់* ។ ចំពោះគោលបំណងទីពីររបស់ទ្រង់ ខ្ញុំចង់កំណត់ថាជា *ការបម្រើរបស់ទ្រង់* ។ចូរយើងរំឭកឡើងវិញនូវធាតុផ្សំទាំងពីរនេះនៃជីវិតរបស់ទ្រង់—បេសកកម្មរបស់ទ្រង់ និង ការបម្រើរបស់ទ្រង់ ។

## បេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ—ដង្វាយធួន

បេសកកម្មរបស់ទ្រង់គឺដង្វាយធួន ។ បេសកកម្មនោះគឺជារបស់ទ្រង់តែម្នាក់ប៉ុណ្ណោះ ។ ដោយបានប្រសូតមកជាមួយនឹងមាតាដែលមានភាពរមែងស្លាប់ និង បិតាដែលអមតៈ នោះទ្រង់ជាអង្គតែមួយគត់ ដែលអាចដាក់ជីវិតទ្រង់ចុះដោយស្ម័គ្រព្រះទ័យ និង អាចយកមកវិញបាន ( សូមមើល យ៉ូហាន 10:14–18 ) ។ លទ្ធផលដ៏រុងរឿងនៃដង្វាយធួនរបស់ទ្រង់ គឺគ្មានទីបំផុត និង អស់កល្បជានិច្ច ។ ទ្រង់បានដកចេញនូវទ្រនិចនៃសេចក្ដីស្លាប់ និង បានធ្វើឲ្យសេចក្ដីសោកសៅនៃសេចក្ដីស្លាប់គ្រាន់តែជាការបណ្ដោះអាសន្ន ( សូមមើល កូរិនថូស ទី1 15:54–55 ) ។ ការទទួលខុសត្រូវរបស់ទ្រង់សម្រាប់ដង្វាយធួន គឺត្រូវបានដឹងតាំងពីមុនការបង្កបង្កើត និង ការធ្លាក់មកម្ល៉េះ ។ វាមិនត្រឹមតែផ្ដល់នូវដំណើររស់ឡើងវិញ និង អមតភាពដល់មនុស្សជាតិទាំងអស់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ធ្វើឲ្យយើងអាចទទួលបានការអត់ទោសដល់អំពើបាបរបស់យើងផងដែរ—គឺដោយលក្ខខណ្ឌដែលទ្រង់បង្កើតឡើង ។ ហេតុដូច្នោះហើយ ដង្វាយធួនរបស់ទ្រង់បើកផ្លូវ ដែលយើងអាចរួបរួមជាមួយទ្រង់ និង ក្រុមគ្រួសារយើងម្ដងទៀតអស់កល្បជានិច្ច ។ ការសង្ឃឹមទៅថ្ងៃអនាគតនេះ យើងចាត់ថាជាជីវិតដ៏នៅអស់កល្បជានិច្ច—ជាអំណោយដ៏អស្ចារ្យបំផុតរបស់ព្រះដល់មនុស្ស ( សូមមើល គ. និង ស. 14:7 ) ។

គ្មាននរណាម្នាក់ផ្សេងទៀតអាចធ្វើដង្វាយធួនបានឡើយ ។ គ្មានមនុស្សណាផ្សេងទៀត សូម្បីតែជាមួយនឹងទ្រព្យសម្បត្តិ និង អំណាចដ៏ច្រើនបំផុតក៏ដោយ ក៏មិនអាចសង្គ្រោះព្រលឹងមួយបានដែរ—គឺមិនអាចសូម្បីតែព្រលឹងខ្លួនឯងផ្ទាល់ ( សូមមើល ម៉ាថាយ 19:24–26 ) ។ ហើយគ្មានបុគ្គលណាផ្សេងទៀតនឹងត្រូវបានតម្រូវ ឬ អនុញ្ញាតឲ្យបង្ហូរឈាមសម្រាប់សេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ចនៃមនុស្សលោកណាម្នាក់ផ្សេងទៀតបានឡើយ ។ ព្រះយេស៊ូវបានធ្វើវា « មួយដងគឺសម្រេច » ( ហេព្រើរ 10:10 ) ។

ថ្វីបើដង្វាយធួនត្រូវបានសម្រេច នៅសម័យនៃព្រះគម្ពីរសញ្ញាថ្មីក៏ដោយ ក៏ព្រឹត្តិការណ៍នានានៅក្នុងគ្រាទាំងឡាយក្នុងព្រះគម្ពីរសញ្ញាចាស់ បានប្រាប់ជាមុនពីសារៈសំខាន់របស់ដង្វាយធួនជាញឹកញាប់ផងដែរ ។ អ័ដាម និង អេវ៉ា ត្រូវបានបញ្ជាឲ្យថ្វាយជាយញ្ញបូជាដែលទុកជា « និមិត្តរូបអំពីការបូជានៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា » ( ម៉ូសេ 5:7 ) ។ ដោយរបៀបណា ? ដោយការបង្ហូរឈាម ។ ពីបទពិសោធន៍ផ្ទាល់របស់ពួកគេ ពួកគេបានបញ្ជាក់ដល់បទគម្ពីរថា « ជីវិតនៃរូបសាច់ នោះនៅក្នុងឈាម » ( លេវីវិន័យ 17:11 ) ។

គ្រូពេទ្យទាំងឡាយដឹងថា ពេលណាដែលឈាមឈប់ហូរទៅកាន់សរីរាង្គមួយ នោះចាប់ផ្ដើមមានបញ្ហាហើយ ។ ប្រសិនបើឈាមដែលហូរទៅជើងម្ខាងត្រូវរាំងស្ទះ នោះដំបៅល្អួយអាចកើតឡើង ។ ប្រសិនបើលំហូរឈាមទៅកាន់ខួរក្បាលត្រូវបានបញ្ឈប់ នោះអាចកើតមាននូវការដាច់សរសៃឈាមក្នុងខួរក្បាល ។ ប្រសិនបើឈាមហូរខុសប្រក្រតីតាមសរសៃឈាមបេះដូង នោះអាចកើតមានរោគគាំងបេះដូង ។ ហើយប្រសិនបើមិនអាចឃាត់ការហូរឈាមបានទេ នោះសេចក្ដីស្លាប់នឹងកើតមាន ។

អ័ដាម អេវ៉ា និង កូនចៅជំនាន់បន្តៗទៀត បានរៀនថា

**ព្រះ**អង្គសង្គ្រោះបានចាប់ផ្ដើមបង្ហូរព្រះលោហិតរបស់ទ្រង់សម្រាប់មនុស្សលោកទាំងអស់គ្នា មិនមែននៅលើឈើឆ្កាង ដែលជាកន្លែងដែលការរងទុក្ខឈឺចាប់នៃដង្វាយធួនបញ្ចប់សព្វគ្រប់នោះទេ ប៉ុន្តែបានចាប់ផ្ដើមតាំងពីនៅក្នុងសួនច្បារគែតសេម៉ានីមកម្ល៉េះ ។



មាតាអើយ នុះន៍ កូនរបស់មាតា ( ស្ទែបាត មេធើរ ) ដោយ ជេមស៍ ធីសុត © BROOKLYN MUSEUM, BROOKLYN, NEW YORK; ទៅក្នុងសួនច្បារ ៖ ការរៀបរាប់ពីក្នុងសួនច្បារគែតសេម៉ានី ដោយ ខាល ហ៊ីនរិច ប្លុច



ពេលណាដែលពួកគេបង្ហូរឈាមពីសត្វមួយ នោះជីវិតវាត្រូវបានបញ្ចប់ហើយ ។ សម្រាប់ពិធីយញ្ញបូជារបស់ពួកគេ មិនមែនសត្វ*ណាក៏បាន*នោះទេ ។ វាត្រូវតែជាកូនដំបូងដែលកើតពីហ្វូងសត្វ ហើយជាសត្វមួយដែលគ្មានប្រទ្បាក់អ្វីឡើយ ( សូមមើល និក្ខមនំ 12:5 ជាឧទាហរណ៍ ) ។ តម្រូវការទាំងនេះក៏ជាតំណាងនៃការពិលកម្មនៅទីបំផុតរបស់កូនចៀមដែលគ្មានប្រទ្បាក់អ្វីសោះនៃព្រះ ។

អ័ដាម និង អេវ៉ា ត្រូវបានប្រទានឲ្យនូវបទបញ្ញត្តិមួយថា ៖ « ហេតុដូច្នេះ ហើយ អ្នកនឹងត្រូវធ្វើអ្វីៗទាំងអស់ដែលអ្នកធ្វើ ដោយនូវព្រះនាមនៃព្រះរាជបុត្រា ហើយអ្នកត្រូវប្រែចិត្ត ហើយអំពាវនាវដល់ព្រះ ដោយនូវព្រះនាមនៃព្រះរាជបុត្រាជារៀងដរាបរហូតតទៅ » ( ម៉ូសេ 5:8 ) ។ តាំងពីថ្ងៃនោះមកដល់កាលដ៏ខ្ពង់ខ្ពស់បំផុត ការបូជាសត្វបន្តជាគំរូ និង ជាស្រមោលនៃដង្វាយធួននៅទីបំផុតនៃព្រះរាជបុត្រារបស់ព្រះ ។

ពេលដង្វាយធួនត្រូវបានសម្រេច ការបូជាដ៏អស្ចារ្យ និង ចុងក្រោយនោះបានបំពេញដល់ច្បាប់ម៉ូសេ ( សូមមើល អាលម៉ា 34:13–14 ) និង បញ្ចប់ការអនុវត្តន៍នៃការបូជាសត្វ ដែលបានបង្រៀនថា « ជីវិតនៃរូបសាច់ នោះនៅក្នុងឈាម » ( លេវីវិន័យ 17:11 ) ។ ព្រះយេស៊ូវបានពន្យល់ពីរបៀបដែលធាតុនៃការបូជាពីបុរាណ ត្រូវបានជំនួសដោយដង្វាយធួនវិញ និង ត្រូវបានរំឭកជាតំណាងដោយពិធីសាក្រាម៉ង់ ។ សូមកំណត់ចំណាំម្តងទៀតលើសេចក្តីយោងទៅជីវិត សាច់ និង ឈាម ៖

« នោះព្រះយេស៊ូវមានបន្ទូលទៅពួកគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនពិសាសាច់ ហើយមិនផឹកឈាមរបស់កូនមនុស្ស នោះអ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ ។

« អ្នកណាដែលបរិភោគសាច់ និង ឈាមរបស់ខ្ញុំ នោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឲ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត » ( យ៉ូហាន 6:53–54 ) ។

ដោយសារដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះមនុស្សលោកទាំងអស់—ទោះច្រើនយ៉ាងណាក៏ដោយ—នឹងបានប្រោសលោះ ។ ព្រះអង្គសង្គ្រោះបានចាប់ផ្តើមបង្ហូរព្រះលោហិតរបស់ទ្រង់ សម្រាប់មនុស្សលោកទាំងអស់គ្នា មិនមែននៅលើឈើឆ្កាងនោះទេ ប៉ុន្តែបានចាប់ផ្តើមតាំងពីនៅក្នុងសួនច្បារគែតសេម៉ានី ។ នៅទីនោះ ទ្រង់បានយកដាក់លើព្រះអង្គទ្រង់នូវទម្ងន់នៃអំពើបាបរបស់មនុស្សទាំងអស់ ដែលនឹងធ្លាប់រស់នៅ ។ នៅក្រោមបន្ទុកដ៏ធ្ងន់នោះ ទ្រង់បានហូរព្រះលោហិតពីគ្រប់រន្ធញើស ( សូមមើល គ. និង ស. 19:18 ) ។ ការឈឺចាប់ដែលមិនអាចពណ៌នាបាននៃដង្វាយធួនត្រូវបានបញ្ចប់សព្វគ្រប់នៅលើឈើឆ្កាងត្រង់កាលវ៉ារី ។

សារៈសំខាន់នៃដង្វាយធួនត្រូវបានពណ៌នាសង្ខេប ដោយព្យាការី យ៉ូសែប ស្ម៊ីធ ។ លោកបានមានប្រសាសន៍ថា « គោលការណ៍ដ៏សំខាន់នៃសាសនាចក្ររបស់យើង គឺជាទីបន្ទាល់នៃពួកសាវក និង ពួកព្យាការី អំពីព្រះយេស៊ូវគ្រីស្ទ ថាទ្រង់បានសុគត ត្រូវបានកប់ ហើយបានរស់ឡើងវិញនៅថ្ងៃទីបី ហើយបានយាងឡើងទៅស្ថានសួគ៌ ហើយរឿងផ្សេងទៀតដែលទាក់ទងនឹងសាសនារបស់យើង គឺជារឿងបន្ទាប់បន្សំទៅនឹងរឿងនេះប៉ុណ្ណោះ » ។[1]

ដោយមានសិទ្ធិអំណាចនោះ និង ដោយការដឹងគុណដ៏ជ្រាលជ្រៅ ខ្ញុំបង្រៀន និង ថ្លែងទីបន្ទាល់យ៉ាងដូច្នោះ អំពីទ្រង់ ។





### ការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ—ព្រះអង្គគំរូ

គោលបំណងដ៏អស់កល្បទីពីររបស់ព្រះអម្ចាស់នៅក្នុងជីវិតរមែងស្លាប់ គឺដើម្បីបម្រើជាគំរូមួយសម្រាប់យើង ។ ជីវិតដ៏ជាគំរូរបស់ទ្រង់ត្រូវបានចាត់ទុកថាជាការបម្រើក្នុងភាពរមែងស្លាប់របស់ទ្រង់ ។ វារួមមានការបង្រៀន រឿងប្រៀបធៀប និង ទេសនកថាទាំងឡាយរបស់ទ្រង់ ។ វារួមបញ្ចូលទាំងអព្ភូតហេតុ សេចក្ដីមេត្តាករុណា និង សេចក្ដីអត់ធ្មត់របស់ទ្រង់ ចំពោះកូនចៅមនុស្ស ( សូមមើល នីហ្វៃទី1 19:9 ) ។ វារួមទាំងការប្រើប្រាស់នូវសិទ្ធិអំណាចបព្វជិតភាពដ៏ពោរពេញដោយសេចក្ដីមេត្តាករុណារបស់ទ្រង់ ។ វារួមទាំងសេចក្ដីតូចចិត្តដ៏សុចរិតរបស់ទ្រង់ ពេលដែលទ្រង់បានកាត់ទោសអំពើបាប ( សូមមើល រ៉ូម 8:3 ) និង ពេលដែលទ្រង់ផ្ដាប់តុនៃពួកអ្នកប្ដូរប្រាក់ ( សូមមើល ម៉ាថាយ 21:12 ) ។ វាក៏រួមបញ្ចូលទាំងការឈឺចាប់ក្នុងព្រះហឫទ័យរបស់ទ្រង់ផងដែរ ។ ទ្រង់ត្រូវគេចំអក វាយ និង មិនទទួលស្គាល់ដោយប្រជារាស្ត្ររបស់ទ្រង់ផ្ទាល់ ( សូមមើល ម៉ូសាយ 15:5 )—ហួតដល់ថ្នាក់ត្រូវក្បត់ដោយសិស្សម្នាក់របស់ទ្រង់ និង ត្រូវបដិសេធដោយសិស្សម្នាក់ផ្សេងទៀត ( សូមមើល យ៉ូហាន 18:2–3, 25–27 ) ។

ទោះបីជាទង្វើដែលទ្រង់បានធ្វើអំឡុងការបម្រើរបស់ទ្រង់ល្អប្រពៃយ៉ាងណាក៏ដោយ ក៏ការណ៍ទាំងនោះមិនបានជា និង នៅតែមិនមែនជាការណ៍ដ៏ពិសេសដែលមានចំពោះតែទ្រង់មួយអង្គនោះទេ ។ ពុំមាននូវការកំណត់ចំពោះចំនួននៃមនុស្សដែលអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវនោះទេ ។ ទង្វើស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយពួកព្យាការី និង ពួកសាវករបស់ទ្រង់ និង អ្នកផ្សេងៗទៀតក្នុងចំណោមពួកអ្នកបម្រើរបស់ទ្រង់ដែលមានសិទ្ធិអំណាច ។ មនុស្សជាច្រើនបានតស៊ូនូវការធ្វើទុក្ខបុកម្នេញដើម្បីទ្រង់ ( សូមមើល ម៉ាថាយ 5:10; នីហ្វៃទី3 12:10 ) ។ ក្នុងជំនាន់របស់យើង អ្នកស្គាល់បងប្អូនប្រុសស្រី ដែលបានព្យាយាមយ៉ាងស្មោះអស់ពីចិត្ត—ទោះលំបាកយ៉ាងណាក៏ដោយ—ដើម្បីធ្វើតាមគំរូរបស់ព្រះអម្ចាស់ ។

ការណ៍នោះគឺវាត្រូវបែបដូច្នោះហើយ ។ នោះហើយគឺជាសេចក្ដីសង្ឃឹមរបស់ទ្រង់ចំពោះយើង ។ ព្រះអម្ចាស់បានសុំយើងឲ្យធ្វើតាមគំរូទ្រង់ ។ ការអំពាវនាវរបស់ទ្រង់គឺច្បាស់ដូចត្បូងគ្រីស្ទាល់ ។

- « តើអ្នករាល់គ្នាគួរធ្វើជាមនុស្សបែបណាទៅ ? . . . ត្រូវឲ្យបានដូចជាយើង » ( នីហ្វៃទី3 27:27; សូមមើលផងដែរ នីហ្វៃទី3 12:48 ) ។
- « ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឲ្យជាអ្នកនេសាទមនុស្សវិញ » ( ម៉ាថាយ 4:19 ) ។
- « ខ្ញុំបានធ្វើតម្រាប់ទុកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ » ( យ៉ូហាន 13:15; សូមមើលផងដែរ យ៉ូហាន 14:6 ) ។

បទគម្ពីរទាំងនេះ និង បទគម្ពីរស្រដៀងនេះពុំបានត្រូវកត់ត្រាទុកជាយោបល់នោះទេ ។ វាជាបង្គាប់ដ៏ចាំបាច់ត្រូវធ្វើ ! យើងត្រូវធ្វើតាមគំរូរបស់ទ្រង់ !

ដើម្បីសម្របសម្រួលសេចក្ដីប្រាថ្នារបស់យើង ឲ្យធ្វើតាមទ្រង់ ប្រហែលជាយើងអាចពិចារណាទៅលើចំណុចប្រាំយ៉ាងនៃជីវិតរបស់ទ្រង់ ដែលយើងអាចយកគំរូតាម ។

#### *សេចក្ដីស្រឡាញ់*

ប្រសិនបើខ្ញុំសួរថា តើលក្ខណៈសម្បត្តិមួយណានៃជីវិតរបស់ទ្រង់ដែលអ្នកនឹងរកឃើញមុនគេ នោះខ្ញុំគិតថា អ្នកប្រហែលជានិយាយថា លក្ខណៈសម្បត្តិនៃសេចក្ដីស្រឡាញ់របស់ទ្រង់ ។ នោះរួមបញ្ចូលទាំងសេចក្ដីអាណិតអាសូរ សេចក្ដីមេត្តា សេចក្ដីសប្បុរស ការលះបង់ការអត់ទោស សេចក្ដីករុណា សេចក្ដីយុត្តិធម៌របស់ទ្រង់ និង ច្រើនថែមទៀត ។ ព្រះយេស៊ូវស្រឡាញ់ព្រះវរបិតា និង ព្រះមាតារបស់ទ្រង់ ( សូមមើល យ៉ូហាន 19:25–27 ) ។ ទ្រង់ស្រឡាញ់ក្រុមគ្រួសារ និង ពួកបរិសុទ្ធរបស់ទ្រង់ ( សូមមើល យ៉ូហាន 13:1; ថែស្សាឡូនីច ទី2 2:16 ) ។ ទ្រង់ស្រឡាញ់អ្នកមានបាប តែពុំបានលើកលែងអំពើបាបនោះទេ ( សូមមើល ម៉ាថាយ 9:2; គ. និង ស. 24:2 ) ។ ហើយទ្រង់បានបង្រៀនយើង ពីរបៀបដែលយើងអាចបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះទ្រង់ ។ ទ្រង់បានមានបន្ទូលថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ » ( យ៉ូហាន 14:15 ) ។ បន្ទាប់មក ដើម្បីគូសបញ្ជាក់ថា សេចក្ដីស្រឡាញ់របស់ទ្រង់ពុំមែន *គ្មានព្រំដែន* នោះទ្រង់បានបន្ថែមថា « បើអ្នករាល់គ្នាកាន់តាមបញ្ញត្តិខ្ញុំ នោះនឹងនៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ខ្ញុំ ដូចជាខ្ញុំបានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់ដែរ » ( យ៉ូហាន 15:10; សូមមើលផងដែរ គ. និង ស. 95:12; 124:87 ) ។

ការបង្ហាញមួយទៀតនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ គឺការបម្រើរបស់ទ្រង់ ។ ទ្រង់បានបម្រើព្រះវរបិតាទ្រង់ ហើយទ្រង់បានបម្រើប្រជាជនដែលទ្រង់បានរស់នៅ និង បានធ្វើការជាមួយ ។ យើងត្រូវធ្វើតាមគំរូរបស់ទ្រង់តាមរបៀបទាំងពីរនេះ ។ យើងត្រូវបម្រើព្រះ « ដើរតាមគ្រប់ទាំងផ្លូវរបស់ទ្រង់ ហើយឲ្យស្រឡាញ់ទ្រង់ » ( ចោទិយកថា 10:12; សូមមើល 11:13; យ៉ូស្វេ 22:5; គ. និង ស. 20:31; 59:5 ) ។ ហើយយើងត្រូវស្រឡាញ់អ្នកជិតខាងយើង ដោយការបម្រើពួកគេ ( សូមមើល កាឡាទី 5:13; ម៉ូសាយ 4:15–16 ) ។

*លក្ខណៈដែលញែកការបង្រៀនរបស់ព្រះអង្គសង្គ្រោះចេញពីការបង្រៀនទាំងអស់របស់គ្រូបង្រៀនដទៃទៀត គឺ ទ្រង់បានបង្រៀនសេចក្ដីពិតនៃភាពចាំបាច់ដ៏នៅអស់កល្បជានិច្ច ។ មានតែទ្រង់ប៉ុណ្ណោះដែលអាចបើកសម្ដែងពីគោលបំណងរបស់យើងក្នុងជីវិត ។*



*ទេសនកថានៅលើភ្នំ* ដោយ ជេមស៍ ធីសុត ក្នុងរូបភាព ៖ *ការបៀបហប់ពីព្រះគ្រីស្ទ និង អ្នកមានវ័យក្មេង* ដោយ ហ៊ិនរិច ហូហ្វម៉ាន ដោយមានការអនុញ្ញាតពីក្រុមហ៊ុន C. HARRISON CONROY CO.



យើងចាប់ផ្ដើមជាមួយក្រុមគ្រួសារយើង ។ សេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅ ដែលចងភ្ជាប់ឪពុកម្ដាយទៅនឹងកូនចៅរបស់ពួកគេ គឺត្រូវបានបង្កើតឡើងដោយការបម្រើដល់ពួកគេ ក្នុងគ្រាដែលពួកគេនៅក្នុងបន្ទុក ។ ក្រោយមកនៅក្នុងជីវិត កូនចៅដែលយកចិត្តទុកដាក់នឹងករណីកិច្ចរបស់ខ្លួន អាចមានឱកាសក្នុងការតបស្នងសេចក្ដីស្រឡាញ់នោះវិញ ពេលដែលពួកគេបម្រើឪពុកម្ដាយជរារបស់ពួកគេ ។

***ពិធីបរិសុទ្ធទាំងឡាយ***

ចំណុចទីពីរនៃជីវិតដ៏គួរឲ្យយកគំរូតាមរបស់ព្រះអង្គសង្គ្រោះ គឺការសង្កត់បញ្ជាក់របស់ទ្រង់ទៅលើពិធីបរិសុទ្ធដ៏ពិសិដ្ឋទាំងឡាយ ។ អំឡុងពេលនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ទ្រង់បានបង្ហាញនូវសារៈសំខាន់នៃពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ។ ទ្រង់ទទួលបុណ្យជ្រមុជទឹកពីយ៉ូហាន នៅក្នុងទន្លេយ័រដាន់ ។ សូម្បីតែយ៉ូហានបានសួរថា « ហេតុអ្វី ? »

ព្រះយេស៊ូវបានពន្យល់ថា « ត្បិតគួរឲ្យ*យើង*ធ្វើសម្រេចតាមគ្រប់ទាំងសេចក្ដីសុចរិតយ៉ាងដូច្នេះ » ( ម៉ាថាយ 3:15; ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម ) ។ មិនត្រឹមតែពិធីបរិសុទ្ធទេដែលចាំបាច់នោះ ប៉ុន្តែគំរូដែលបានដាក់ដោយព្រះយេស៊ូវ និង យ៉ូហាន ក៏ចាំបាច់ផងដែរ ។

ក្រោយមកព្រះអម្ចាស់បានបង្រៀនពីពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់ ។ ទ្រង់បានពន្យល់ពីតំណាងនៃសាក្រាម៉ង់ ហើយបានធ្វើការចែកតំណាងដ៏ពិសិដ្ឋនេះទៅសិស្សរបស់ទ្រង់ ( សូមមើល ម៉ាថាយ 26:26–28; ម៉ាកុស 14:22–24; លូកា 24:30 ) ។

ព្រះវរបិតាសួគ៌របស់យើងបានប្រទានការណែនាំផងដែរ អំពីពិធីបរិសុទ្ធទាំងឡាយ ។ ទ្រង់បានមានបន្ទូលថា ៖ « នោះអ្នករាល់គ្នាត្រូវតែបានកើតម្ដងទៀត ទៅក្នុងនគរស្ថានសួគ៌ ដោយសារទឹក និង ដោយសារព្រះវិញ្ញាណ ហើយត្រូវបានសម្អាត ដោយសារឈាម គឺជាព្រះលោហិតនៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើងយ៉ាងនោះដែរ ប្រយោជន៍ឲ្យអ្នកអាចបានញែកជាបរិសុទ្ធ ចេញពីអស់ទាំងអំពើបាប ហើយមានសេចក្ដីអំណរចំពោះព្រះបន្ទូល អំពីជីវិតដ៏នៅអស់កល្បជានិច្ចនៅនាលោកិយនេះ និង ជីវិតដ៏នៅអស់កល្បជានិច្ចនៅឯនាបរលោក គឺជាសិរីល្អដ៏នៅអមតៈ » ( ម៉ូសេ 6:59 ) ។

អំឡុងពេលនៃការបម្រើក្នុងជីវិតបន្ទាប់ពីការសុគតរបស់ទ្រង់ ពិធីបរិសុទ្ធដែលកាន់តែខ្ពង់ខ្ពស់ជាងមុន នៃភាពលើកតម្កើងឡើង ត្រូវបានបើកសម្ដែង ( គ. និង ស. 124:40–42 ) ។ ទ្រង់បានប្រទានព្រះវិហារបរិសុទ្ធរបស់ទ្រង់ សម្រាប់ពិធីបរិសុទ្ធទាំងនេះ ។ ក្នុងជំនាន់របស់យើង ការលាង ការលាបប្រេង និង អំណោយទានពិសិដ្ឋ ត្រូវបានផ្ដល់ទៅបុគ្គលទាំងឡាយដែលបានរៀបចំខ្លួនយ៉ាងត្រឹមត្រូវ ( សូមមើល គ. និង ស. 105:12, 18, 33; 110:9; 124:39 ) ។ នៅក្នុងព្រះវិហារបរិសុទ្ធ បុគ្គលម្នាក់អាចផ្សារភ្ជាប់ជាមួយស្វាមី ឬ ភរិយា ជាមួយជីដូនជីតា និង ជាមួយកូនចៅ ( សូមមើល គ. និង ស. 132:19 ) ។ លោកគ្រូរបស់យើង គឺជាព្រះនៃក្រិត្យវិន័យ និង នៃរបៀបរៀបរយ ( សូមមើល គ. និង ស. 132:18 ) ។ ការផ្ដោតរបស់ទ្រង់ទៅលើពិធីបរិសុទ្ធ គឺជាផ្នែកដ៏មានព្រះចេស្ដានៃគំរូរបស់ទ្រង់ចំពោះយើង ។

***ការអធិស្ឋាន***

ចំណុចទីបីនៃការបម្រើដ៏គំរូរបស់ព្រះអម្ចាស់គឺការអធិស្ឋាន ។ ព្រះយេស៊ូវបានអធិស្ឋានទៅកាន់ព្រះវរបិតារបស់ទ្រង់ដែលគង់នៅស្ថានសួគ៌ ហើយក៏បង្រៀនយើងពី

របៀបអធិស្ឋានផងដែរ ។ យើងត្រូវអធិស្ឋានទៅព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ក្នុងព្រះនាមនៃព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល ម៉ាថាយ 6:9–13; នីហ្វៃទី3 13:9–13; ការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ 6:9–15 ) ។ ខ្ញុំស្រឡាញ់ការអធិស្ឋានសម្របសម្រួលដែលព្រះអម្ចាស់បានអធិស្ឋាន ដែលបានកត់ត្រាទុកក្នុងគម្ពីរយ៉ូហាន ជំពូក 17 ។ ក្នុងការអធិស្ឋាន ព្រះរាជបុត្រាធ្វើការទំនាក់ទំនងដោយសេរី ជាមួយនឹងព្រះវរបិតាទ្រង់ ជំនួសឲ្យសិស្សរបស់ទ្រង់ ជាអ្នកដែលទ្រង់ស្រឡាញ់ ។ វាគឺជាគំរូនៃការអធិស្ឋានដ៏មានប្រសិទ្ធិភាព និង ពេញដោយក្ដីអាណិតអាសូរ ។

***ចំណេះដឹង***

ចំណុចទីបួននៃគំរូរបស់ព្រះអម្ចាស់ គឺការប្រើប្រាស់ចំណេះដឹងដ៏ទេវភាពរបស់ទ្រង់ ។ ដូចដែលបាននិយាយពីខាងដើម ពួកអ្នកដែលមិនមែនជាពួកគ្រីស្ទានជាច្រើនបានទទួលស្គាល់ថា ព្រះយេស៊ូវជាគ្រូបង្រៀនដ៏អស្ចារ្យ ។ ប្រាកដណាស់ ទ្រង់គឺគ្រូបង្រៀនដ៏អស្ចារ្យ ។ ប៉ុន្តែ តើអ្វីទៅដែលពិតជាបានញែកការបង្រៀនរបស់ទ្រង់ពីការបង្រៀនផ្សេងៗទៀត ? តើទ្រង់ជាគ្រូបង្រៀនផ្នែកវិស្វកម្ម ផ្នែកគណិតសាស្ត្រ ឬ ផ្នែកវិទ្យាសាស្ត្រដ៏ស្ទាត់ជំនាញឬ ? ក្នុងនាមជាអ្នកបង្កបង្កើតផែនដីនេះ និង ភពផ្សេងៗទៀត ( សូមមើល ម៉ូសេ 1:33 ) ទ្រង់ពិតជាអាចធ្វើជាអាចធ្វើជាគ្រូបង្រៀនផ្នែកទាំងនោះដោយស្ទាត់ជំនាញបាន ។ ឬ ក្នុងនាមជាអ្នកនិពន្ធព្រះគម្ពីរ ទ្រង់អាចបង្រៀនការតែងសេចក្ដីផ្នែកអក្សរសាស្ត្របានយ៉ាងល្អ ។

លក្ខណៈដែលញែកការបង្រៀនរបស់ទ្រង់ចេញពីការបង្រៀនទាំងអស់របស់គ្រូបង្រៀនដទៃទៀត គឺទ្រង់បានបង្រៀនសេចក្ដីពិតនៃភាពចាំបាច់*ដ៏នៅអស់កល្បជានិច្ច* ។ មានតែទ្រង់ប៉ុណ្ណោះដែលអាចបើកសម្ដែងពីគោលបំណងរបស់យើងក្នុងជីវិត ។ មានតែតាមរយៈទ្រង់ប៉ុណ្ណោះ ដែលយើងអាចរៀនពីជីវិតរបស់យើង*មុនផែនដី* និង ពីសក្ដានុពលភាពរបស់យើង*ក្រោយពីជីវិតនេះ* ។

ក្នុងឱកាសមួយ លោកគ្រូបានប្រាប់ដល់អ្នកស្ដាប់របស់ទ្រង់ដែលមានការសង្ស័យថា ពួកគេមានទីបន្ទាល់បីយ៉ាងអំពីទ្រង់ ៖

- យ៉ូហាន បាទីស្ទ ។
- កិច្ចការទាំងឡាយដែលព្រះយេស៊ូវបានធ្វើសម្រេច ។
- ព្រះបន្ទូលរបស់ព្រះជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ( សូមមើល យ៉ូហាន 5:33–37 ) ។

បន្ទាប់មកទ្រង់បានផ្ដល់នូវទីបន្ទាល់ទីបួន ៖ « អ្នករាល់គ្នាស្ទង់មើលគម្ពីរ ដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ » ( យ៉ូហាន 5:39 ) ។

ពាក្យ *ស្មាន* នៅក្នុងឃ្លានោះ ពីដំបូង អាចហាក់បីដូចជាមិនត្រូវទេ ។ ប៉ុន្តែវាសំខាន់ខ្លាំងណាស់ចំពោះអត្ថន័យដែលព្រះយេស៊ូវព្យាយាមណែនាំ ។ ទ្រង់បានដឹងថា មានអ្នកស្ដាប់របស់ទ្រង់ជាច្រើនពិតជាបាន*ស្មាន*ថា ជីវិតដ៏នៅអស់កល្បជានិច្ច គឺនៅក្នុងព្រះគម្ពីរទាំងឡាយ ។ ប៉ុន្តែពួកគេខុសហើយ ។ ព្រះគម្ពីរតែមួយមុខ*ពុំអាច*ផ្ដល់ជីវិតដ៏នៅអស់កល្បជានិច្ចបានទេ ។ ពិតណាស់ មានអំណាចនៅក្នុងព្រះគម្ពីរ ប៉ុន្តែអំណាចនោះ គឺមកពីព្រះយេស៊ូវផ្ទាល់ ។ ទ្រង់*គឺជា*ព្រះបន្ទូល ៖ *Logos* ។ អំណាចនៃជីវិតដ៏នៅអស់កល្បជានិច្ច គឺនៅក្នុងទ្រង់ ដែល « កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ » ( យ៉ូហាន 1:1; សូមមើលផងដែរ នីហ្វៃទី2 31:20; 32:3 ) ។ បន្ទាប់មក ដោយសារតែជំហរដ៏រឹងទទឹងរបស់ពួកអ្នកសង្ស័យ នោះព្រះយេស៊ូវគ្រីស្ទបានស្ដីបន្ទោសពួកគេថា ៖ « អ្នករាល់គ្នាមិនសុខចិត្តមកឯខ្ញុំឲ្យបានជីវិត [ ដ៏នៅអស់កល្បជានិច្ច ] ទេ » ( យ៉ូហាន 5:40 ) ។

លោកគ្រូអាចធ្វើឲ្យយើងវន្ទត់ជាមួយនឹងចំណេះដឹងដ៏ខ្ពង់ខ្ពស់បំផុតរបស់ទ្រង់ ប៉ុន្តែទ្រង់មិនធ្វើដូច្នោះទេ ។ ទ្រង់គោរពដល់សិទ្ធិជ្រើសរើសរបស់យើង ។ ទ្រង់ទុកឲ្យយើងមានភាពរីករាយនៃការរុករកបកគំហើញ ។ ទ្រង់លើកទឹកចិត្តយើងឲ្យប្រែចិត្តពីកំហុសផ្ទាល់ខ្លួនរបស់យើង ។ ទ្រង់អនុញ្ញាតឲ្យយើងទទួលបទពិសោធន៍នៃសេរីភាព ដែលមកពីការគោរពប្រតិបត្តិដោយស្ម័គ្រចិត្តរបស់យើង ចំពោះក្រិត្យវិន័យដ៏ទេវភាពរបស់ទ្រង់ ។ មែនហើយ របៀបដែលទ្រង់ប្រើប្រាស់ចំណេះដឹងរបស់ទ្រង់ ផ្ដល់គំរូដ៏អស្ចារ្យដល់យើង ។

***ការស៊ូទ្រាំ***

ចំណុចទីប្រាំនៃការបម្រើរបស់ព្រះអម្ចាស់ គឺការតាំងព្រះទ័យរបស់ទ្រង់ ដើម្បីស៊ូទ្រាំដល់ទីបំផុត ។ ទ្រង់មិនដែលដកខ្លួនចេញពីការចាត់តាំងរបស់ទ្រង់ឡើយ ។ ទោះជាទ្រង់បានទទួលបទពិសោធន៍នៃការរងទុក្ខវេទនា លើសពីយើងអាចយល់បាន ក៏ទ្រង់មិនមែនជាអ្នកបោះបង់ដែរ ។ ឆ្លងកាត់ការសាកល្បងដ៏ជ្រាលជ្រៅ ទ្រង់បានតស៊ូដល់ទីបញ្ចប់នៃការចាត់តាំងរបស់ទ្រង់ ក្នុងការធ្វើដង្វាយធួនសម្រាប់អំពើបាបនៃមនុស្សលោកទាំងអស់ ។ ព្រះបន្ទូលចុងក្រោយរបស់ទ្រង់ កាលដែលទ្រង់ត្រូវព្យួរនៅឈើឆ្កាងគឺ « ការស្រេចហើយ » ( យ៉ូហាន 19:30 ) ។

## ការអនុវត្តន៍ចំពោះជីវិតរបស់យើង

ចំណុចទាំងប្រាំនៃការបម្រើរបស់ទ្រង់ អាចត្រូវបានអនុវត្តក្នុងជីវិតរបស់យើងផ្ទាល់ ។ ច្បាស់ណាស់ ភស្ដុតាងដ៏ល្អបំផុតនៃការគោរពរបស់យើងចំពោះព្រះយេស៊ូវ គឺការយកគំរូតាមទ្រង់របស់យើង ។

ពេលយើងចាប់ផ្ដើមដឹងថា ព្រះយេស៊ូវជានរណា និង អ្វីដែលទ្រង់បានធ្វើសម្រាប់យើង នោះយើងអាចយល់បាន ក្នុងកម្រិតមួយ ពីភាពជាក់លាក់នៃបទបញ្ញត្តិទីមួយ និង ធំបំផុត ដែលថា ៖ « ឯងត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកម្លាំងនៃឯង » ( ម៉ាកុស 12:30 ) ។ និយាយម្យ៉ាងទៀតគឺថា អ្វីទាំងអស់ដែលយើងគិត និង ធ្វើ និង និយាយ គួរតែចេញមកពីសេចក្ដីស្រឡាញ់របស់យើងចំពោះទ្រង់ និង ព្រះវរបិតារបស់ទ្រង់ ។

ចូរសួរខ្លួនឯងថា ៖ « តើមាននរណាម្នាក់ដែលខ្ញុំស្រឡាញ់ជាងព្រះអម្ចាស់ទេ ? » បន្ទាប់មក ប្រៀបធៀបចម្លើយរបស់អ្នកទៅនឹងបទដ្ឋានទាំងនេះដែលបានដាក់ដោយព្រះអម្ចាស់ ៖

- « អ្នកណាដែលស្រឡាញ់ឪពុក ឬ ម្ដាយ ជាជាងខ្ញុំ នោះមិនគួរនឹងខ្ញុំទេ » ។
- « អ្នកណាដែលស្រឡាញ់កូនប្រុស ឬ កូនស្រី ជាជាងខ្ញុំ នោះក៏មិនគួរនឹងខ្ញុំដែរ » ( ម៉ាថាយ 10:37 ) ។

ឯពួកអ្នកក្រុងនោះទាំងអស់ គេបានប្រឆាំង ដោយ ជេមស៍ ធីសុត



**ជី**វិតដ៏ជាគំរូរបស់ព្រះអម្ចាស់ត្រូវបានចាត់ទុកថាជាការបម្រើក្នុងភាពរមែងស្លាប់របស់ទ្រង់ ។ វារួមមានការបង្រៀនរឿងប្រៀបធៀប និង ទេសនកថាទាំងឡាយរបស់ទ្រង់ ។ វារួមទាំងការប្រើប្រាស់នូវសិទ្ធិអំណាចបព្វជិតភាពដ៏ពោរពេញដោយសេចក្ដីមេត្តាករុណារបស់ទ្រង់ ។

*សេចក្ដីស្រឡាញ់*សម្រាប់ក្រុមគ្រួសារ និង មិត្តភក្ដិ ស្រឡាញ់ខ្លាំងដូចដែលអាចស្រឡាញ់ដូចនោះ គឺកាន់តែជ្រាលជ្រៅខ្លាំងជាងមុនទៅទៀត នៅពេលដែលសេចក្ដីស្រឡាញ់នោះបោះជាយុថ្កាជាប់នៅក្នុងសេចក្ដីស្រឡាញ់នៃព្រះយេស៊ូវគ្រីស្ទ ។ សេចក្ដីស្រឡាញ់របស់ឪពុកម្ដាយចំពោះកូនចៅ កាន់តែមានអត្ថន័យនៅពេលនេះ និង ចាប់ពីពេលនេះតទៅ ដោយសារតែទ្រង់ ។ គ្រប់ទំនាក់ទំនងដ៏ជាទីស្រឡាញ់ទាំងអស់គឺត្រូវបានស្ដាបនាឡើងនៅក្នុងទ្រង់ ។ សេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌របស់យើង និង របស់ព្រះយេស៊ូវគ្រីស្ទ ផ្ដល់នូវការបំភ្លឺ ការបំផុស និង ការជម្រុញទឹកចិត្ត ឲ្យស្រឡាញ់អ្នកផ្សេងទៀតតាមរបៀបមួយដែលកាន់តែប្រសើរជាងមុនទៅទៀត ។

*ពិធីបរិសុទ្ធ*ផ្ដល់នូវការផ្ដោតទៅលើការជ្រើសសម្រាប់តម្លៃដ៏អស់កល្បជានិច្ច ។ ឪពុកម្ដាយគួរតែពិចារណាថា ពិធីបរិសុទ្ធណាមួយដែលកូនរបស់ខ្លួនត្រូវការបន្ទាប់ទៀត ។ គ្រូបង្រៀនតាមផ្ទះគួរតែគិតពីពិធីបរិសុទ្ធដ៏ត្រឹមត្រូវ ដែលក្រុមគ្រួសារដែលពួកគេបម្រើនោះត្រូវការបន្ទាប់ទៀត ។

គំរូរបស់ព្រះអង្គសង្គ្រោះអំពី*ការអធិស្ឋាន*ពាំឭកយើងថា ការអធិស្ឋានផ្ទាល់ខ្លួន ការអធិស្ឋានជាក្រុមគ្រួសារ និង ការព្យាយាមបំពេញការចាត់តាំងរបស់យើងក្នុងសាសនាចក្រប្រកបដោយការអធិដ្ឋាន គួរតែក្លាយជាផ្នែកនៃជីវិតរបស់យើង ។ ការដឹង និង ធ្វើតាមព្រះទ័យព្រះវរបិតា ផ្ដល់នូវកម្លាំង និង ទំនុកចិត្តខាងវិញ្ញាណដ៏អស្ចារ្យ ( សូមមើល គ. និង ស. 121:45 ) ។ នៅខាងព្រះ គឺជាកន្លែងដែលយើងចង់នៅ ។

*ចំណេះដឹង* « រឿងទាំងឡាយតាមដែលមាននៅពេលនេះ ហើយអំពីរឿងទាំងឡាយតាមដែលនឹងមាននៅពេលខាងមុខ » ( យ៉ាកុប 4:13 ) អនុញ្ញាតឲ្យយើងប្រព្រឹត្តិតាមគោលការណ៍ និង គោលលទ្ធិដ៏ពិត ។ ចំណេះដឹងនោះនឹងលើកកម្រិតនៃការប្រព្រឹត្តិរបស់យើងឡើង ។ តាមមួយបែបផ្សេង ទង្វើទាំងឡាយដែលអាចធ្វើឡើងដោយចេញពីចំណង់ដ៏អាត្មានិយម និង អារម្មណ៍ នោះនឹងត្រូវជំនួសដោយទង្វើទាំងឡាយដែលដឹកនាំដោយហេតុផល និង ភាពត្រឹមត្រូវ ។

ការតាំងចិត្តដើម្បី*តស៊ូដល់ទីបញ្ចប់*មានន័យថា យើងនឹងមិនសុំឲ្យមានការដោះលែងពីការហៅបម្រើនោះទេ ។ វាមានន័យថា យើងនឹងខំព្យាយាមក្នុងការឈានទៅរកគោលដៅដ៏សក្ដិសមមួយ ។ វាមានន័យថា យើងនឹងមិនដែលបោះបង់អ្នកជាទីស្រឡាញ់ម្នាក់ដែលបានវង្វេងនោះទេ ។ ហើយវាមានន័យថា យើងនឹងតែងតែស្រឡាញ់លើកតម្កើងដល់ទំនាក់ទំនងគ្រួសារដ៏អស់កល្បរបស់យើង សូម្បីតែឆ្លងកាត់ពេលវេលាដ៏លំបាកនៃការឈឺស្កាត់ ពិការភាព ឬ សេចក្ដីស្លាប់ក៏ដោយ ។

ដោយអស់ពីដួងចិត្តរបស់ខ្ញុំ ខ្ញុំអធិស្ឋានថា ឥទ្ធិពលនៃការកែប្រែរបស់ព្រះអម្ចាស់ អាចធ្វើឲ្យមានការផ្លាស់ប្ដូរមួយដ៏អស្ចារ្យក្នុងជីវិតរបស់អ្នក ។ បេសកកម្ម និង ការបម្រើរបស់ទ្រង់ អាចផ្ដល់ពរជ័យដល់យើងម្នាក់ៗនាពេលឥឡូវនេះ និង រហូតតទៅ ។ ■

*ពីសេចក្ដីថ្លែងការណ៍នៅក្នុងការប្រជុំធម្មនិដ្ឋាន ថ្ងៃទី 18 ខែ សីហា ឆ្នាំ 1998 នៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ។ សម្រាប់អត្ថបទទាំងមូលជាភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័រ speeches.byu.edu ។*

កំណត់ចំណាំ
1. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ( 2007 ), ទំព័រ 49 ។

# សប្ដាហ៍នៃបុណ្យអ៊ីស្ទើរ

ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទនៃយើងបានធ្វើដង្វាយធួន—ដែលមានរួមជាមួយនឹងការរងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី ការឆ្កាងរបស់ទ្រង់នៅលើភ្នំគាល់កូថា និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ពីផ្នូរ—នៅក្នុងសប្ដាហ៍ចុងក្រោយនៃជីវិតរបស់ទ្រង់ ។

នៅក្នុងការប្រឹក្សានៅស្ថានសួគ៌មុននឹងផែនដីត្រូវបានបង្កើតមក ព្រះវរបិតាសួគ៌បានបង្ហាញផែនការរបស់ទ្រង់សម្រាប់យើង ដែលជាបុត្ររបស់ទ្រង់ ។ យើងស្រែកឡើងដោយសេចក្ដីអំណរក្នុងពេលដែលព្រះវរបិតាសួគ៌បានជ្រើសព្រះយេស៊ូវគ្រីស្ទ ដើម្បីបំពេញផែនការនៃសេចក្ដីសង្គ្រោះ (សូមមើល យ៉ូប 38:7 និង អ័ប្រាហាំ 3:27) ។ ព្រះយេស៊ូវបានប្រសូតមកពីម៉ារា ក្នុងក្រុងបេថ្លេហិម ទ្រង់បានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប ។ ដោយព្រោះតែដង្វាយធួនរបស់ទ្រង់ យើងអាចត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌របស់យើង ហើយអាចទទួលជីវិតដ៏អស់កល្បជានិច្ច ។ ព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្ដងទៀត ក្នុងព្រះចេស្ដា និង សិរីល្អ ដើម្បីនឹងគង់នៅលើផែនដី ក្នុងសហស្សវត្សរ៍ ហើយទ្រង់នឹងឈរជាចៅក្រមរបស់មនុស្សគ្រប់រូបក្នុងថ្ងៃចុងក្រោយ ។

រូបគំនូរទាំងនេះ គឺជារូបគំនូរ ចេញពីវីដេអូព្រះគម្ពីរបរិសុទ្ធ ដែលបង្ហាញនៅសប្ដាហ៍ចុងក្រោយនៃជីវិតរបស់ ព្រះយេស៊ូវគ្រីស្ទ ។ សូមគិតអំពីការអានវគ្គនានានៃព្រះគម្ពីរដែលផ្ដល់ឲ្យសម្រាប់រូបភាពនេះ ។ សម្រាប់តារាងលំដាប់ពេលនៃព្រឹត្តិការណ៍ដ៏ពេញលេញ សូមយោងទៅភាពចុះសម្រុងគ្នានៃព្រះគម្ពីរទាំងបួន នៅក្នុងវេចនានុក្រមព្រះគម្ពីរបរិសុទ្ធ ឬ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ។ វីដេអូព្រះគម្ពីរបរិសុទ្ធគឺអាចរកបាននៅ biblevideos.lds.org ។

រូបភាព © IRI



នៅ ថ្ងៃទីប្រាំពីមុនបុណ្យរំលង ព្រះយេស៊ូវបានគង់លើសត្វលាចូលទៅក្នុងទីក្រុងយេរូសាឡិម ដូចដែលបានព្យាករទុកជាមុន ។ ប្រជាជនបានទទួលស្គាល់ទ្រង់ជាស្ដេចរបស់ពួកគេ ពួកគេបានស្រែកឡើងថា «ហូសាណា» ហើយបាន ដាក់អាវ និង មែកឈើរនៅលើដីចំពីមុខសត្វលា ។ (សូមមើល ម៉ាថាយ 21:1–11 ម៉ាកុស 11:1–11; សាការី 9:9) ។





ជាលើកទីពីរនៅក្នុងការបង្រៀនក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះយេស៊ូវបានសំអាតទីធ្លានៃព្រះវិហារបរិសុទ្ធ ។ ទ្រង់បានមានបន្ទូលទៅពួកអ្នកដូរប្រាក់ថា « ដំណាក់អញត្រូវហៅថា ជាទីសម្រាប់អធិស្ឋាន តែអ្នករាល់គ្នាបានយកធ្វើជារោងចោរវិញ » (ម៉ាថាយ 21:13) ។ រួចហើយ មានមនុស្សខ្វាក់ និង ពិការជាច្រើនបានមករកទ្រង់នៅក្នុងព្រះវិហារ ហើយទ្រង់បានប្រោស ពួកគេឲ្យជា ។ ប៉ុន្តែនៅពេលពួកមេអាចារ្យ និង អ្នកចែងច្បាប់ជាច្រើនគ្នាបានឃើញភាពអស្ចារ្យរបស់ទ្រង់ ពួកគេបាន ខឹងហើយ ព្យាយាមរកវិធីដើម្បីនឹងរកសម្លាប់ទ្រង់ ។ សូមមើល ម៉ាថាយ 21:12–17; ម៉ាកុស11:15–19 ។



ព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះវរបិតា បានយាងចុះមកផែនដី ដើម្បីស្រោច ស្រង់ប្រជាជនរបស់ទ្រង់ពីការធ្លាក់ចុះ ។ (សូមមើល នីហ្វៃទី1 11:16 –22, 26–33; អាលម៉ា 7:10–13 ។ )



ពេញមួយ សប្តាហ៍នោះ ព្រះអង្គសង្គ្រោះបានផ្តល់ឲ្យនូវការបង្រៀនដ៏ល្អវិសេសជាច្រើន រួមមានទាំងការប្រងៀនអំពី របស់ស្ត្រីម៉េម៉ាយផង ។ (សូមមើលម៉ាកុស 12:41–44; លូកា 21:1–4.)



នៅក្នុងសួនច្បារគេតសេម៉ានី ព្រះអង្គសង្គ្រោះបានលុតជង្គង់ចុះ ហើយបានអធិស្ឋាន បង្ហាញការឈឺចាប់របស់របស់ទ្រង់ចំពោះអំពើបាបនៃពិភពលោកធ្វើឲ្យទ្រង់ « ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រួច លោកហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយ និងវិញ្ញាណទៀតផង » (គ. និង ស. 19:18) ។ មិនយូរប៉ុន្មាន យូដាសអេស្ការីយ៉ុតហើយនឹងហ្វូងមនុស្សដែលប្រដាប់ដោយអាវុធបានមកចាប់ព្រះ យេស៊ូវ ហើយពួកសិស្សសទាំងអស់បានបោះបង់ចោលទ្រង់ ហើយគេចអស់ទៅ ។ (សូមមើល ម៉ាថាយ 26:36–56; ម៉ាកុស 14:32–50; លូកា 22:39–53) ។



កាលនៅគ្រាទទួលទានអាហារចុងក្រោយរបស់ទ្រង់ ព្រះយេស៊ូវបានសន្យាជាមួយពួកសាវករបស់ទ្រង់ថា ពួកគេនឹងទទួលព្រះដ៏ជាជំនួយ ឬព្រះវិញ្ញាណបរិសុទ្ធ នៅពេលទ្រង់យាងចាកចេញទៅ ។ ទ្រង់បានបង្រៀនពួកគេ ឲ្យចាំអំពីទ្រង់ ដោយការទទួលសាក្រាម៉ង់ ។ នៅល្ងាចនោះ ព្រះយេស៊ូវគ្រីស្ទបានផ្តល់នូវការអធិស្ឋានអង្វរ គឺជាទីកន្លែងដែលទ្រង់បានអធិស្ឋានសុំឲ្យពួកសិស្សរបស់ទ្រង់ក្លាយទៅជាតែមួយក្នុងសាមគ្គីភាព ។ ( សូមមើល ម៉ាថាយ 26:17–30; ម៉ាកុស 14:12–26; លូកា 22:14–32; យ៉ូហានៈ13–17) ។





*បន្ទាប់ពីការកាត់សេចក្ដីខុសច្បាប់ និងការធ្វើទុក្ខដ៏កាចសាហាវមក ព្រះយេស៊ូវគ្រីស្ទបានសុខចិត្តឲ្យគេឆ្កាងទ្រង់ដើម្បីបំពេញតាម « ការបូជាដ៏មហិមា និងចុងក្រោយបង្អស់ » ដែលធ្វើឲ្យសេចក្ដីសង្គ្រោះអាច កើតមានឡើងដល់កូនចៅរបស់ទ្រង់បាន (សូមមើល អាល់ម៉ា 34:14–15) ។ ពីមុនពេលរាត្រីកាលចូលមកដល់ នោះអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ បានយកព្រះសពរបស់ទ្រង់ចុះពីលើឈើឆ្កាង បានពាក់សំលៀកពាក់ទ្រង់នៅក្នុងសំពត់ទេសឯក និងគ្រឿងក្រអូប ហើយបានដាក់ទ្រង់នៅក្នុងផ្នូរ ។ (សូមមើល ម៉ាថាយ 27; លូកា 23; ម៉ាកុស 15; យ៉ូហាន 19) ។*





*ព្រឹកថ្ងៃអាទិត្យបានមកដល់ ហើយម៉ារាម៉ាកដាលីនហើយនិងស្ត្រីដ៏ស្មោះស្ម័គ្របានមកដល់ មាត់ផ្នូរដើម្បីនឹងចាក់ប្រេងលើព្រះសពរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេបានរកឃើញដុំថ្មត្រូវបានរមៀលចេញ ហើយមានទេវតាពីរអង្គដែលបានប្រកាសដំណឹងល្អដ៏ ត្រេកអរថា ៖ « ទ្រង់មិនគង់នៅទីនេះទេ ត្បិតទ្រង់បានមានប្រជន្មរស់ឡើងវិញហើយ » (ម៉ាថាយ 28:6) ។ ព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញបានឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ ហើយជួយឲ្យយើង អាចរស់ពីស្លាប់ឡើងវិញ ៖ « ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណានោះ គ្រប់គ្នាក៏នឹងប្រោសឲ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ » ( កូរិនថូសទី1 15:22) ។ (សូមមើល ម៉ាថាយ 28; ម៉ាកុស 16; លូកា 24; យ៉ូហាន 20) ។ ■*

# ការជួយកុមារ

## រៀបចំខ្លួនសម្រាប់ពិធីបុណ្យជ្រមុជទឹក

**ដោយ ជេសីកា ឡសិន និង ម៉ារីហ្សា វិដសុន**
ទស្សនាវដ្ដីសាសនាចក្រ

កុមារភាព គឺជាវ័យ ដ៏រីករាយដំបូង ។ គ្រាដំបូងនៃការជិះកង់ ការទៅសាលារៀន ឬការសាកអាហារថ្មី គឺជាការសាកល្បងដ៏រីករាយមួយ ដែល រៀបចំជីវិតរបស់កុមារ ។ ក្នុងនាមជាមជ្ឈិមវ័យ យើងមានឱកាសដើម្បីជួយក្មេងៗឆ្លងកាត់ផ្លូវឆ្ពោះទៅរកបទពិសោធន៍ទាំងនោះ ។ ក្នុងនាមជាមជ្ឈិមវ័យក្នុងសាសនាចក្រ យើងក៏មានឱកាសដើម្បីនឹងជួយពួកគេ ឲ្យធំឡើងក្នុងដំណឹងល្អ ផងដែរ ( សូមមើល គ. និង ស. 68:25) ។ តើយើងអាចធ្វើអ្វីខ្លះដើម្បីប្រាកដថា ពិធីបុណ្យជ្រមុជទឹករបស់កុមារម្នាក់— ជាសេចក្ដីសញ្ញាដំបូងដែលមនុស្សម្នាក់ធ្វើជាមួយព្រះវរបិតាសួគ៌ជាទីស្រឡាញ់—ក្លាយទៅជាព្រឹត្តិការណ៍ដ៏ស្រស់បំព្រង និង មានអត្ថន័យនោះ ?

ប្រធាន ប៊ុយដ៍ យេ ផាកកឺបានបង្រៀនថា « វាគឺជាគោលការណ៍មូលដ្ឋានរបស់សាសនាចក្រនេះ ដើម្បី បង្រៀនយុវវ័យ ៖ ដំបូងនៅក្នុងផ្ទះ រួចហើយនៅក្នុងសាសនាចក្រ » ។[1]

គំរូខាងក្រោមនេះ ឪពុកម្ដាយមួយចំនួនបានចែករំលែកអំពីរបៀបដែលពួកគេបានរៀបចំកូនៗរបស់ ពួកគេ សម្រាប់ពិធីបរិសុទ្ធដ៏ពិសិដ្ឋ និង សេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ ។

### យើងចាប់ផ្ដើមតាំងពីពួកគេនៅក្មេង

ឡូរី ជាម្ដាយដែលមានកូនបួននាក់បាននិយាយថា « នៅឆ្នាំដែលកូនម្នាក់ៗបានឈានចូលដល់អាយុប្រាំពីរឆ្នាំ គឺជាពេលដើម្បីនឹងធ្វើពិធីជប់លៀង » ។ គាត់ និង ស្វាមីបង្រៀនកូនៗរបស់ពួកគេ អំពីបុណ្យជ្រមុជទឹក ចាប់តាំងពីថ្ងៃដែលពួកគេបានកើតមកម្ល៉េះ ។ ប៉ុន្តែ នៅពេលកូនម្នាក់ៗឈានចូលដល់អាយុប្រាំពីរឆ្នាំ គ្រួសាររបស់គេចាប់ផ្ដើមនូវការរៀបចំកាន់តែ ជាក់លាក់ជាងមុន ។ ពួកគេបង្រៀនមេរៀនក្នុងរាត្រីជួបជុំក្រុមគ្រួសាររៀងរាល់ខែ អំពីប្រធានបទផ្សេងដែលទាក់ទងទៅ នឹងបុណ្យជ្រមុជទឹក ដូចជាសេចក្ដីសញ្ញា និង គំរូរបស់ព្រះយេស៊ូវ ។

ឡូរី និយាយថា មេរៀនទាំងឡាយដែលបង្រៀនក្នុងអំឡុងខែនៃបុណ្យខួបកំណើតអាយុ ប្រាំបីឆ្នាំរបស់ កូនៗ គឺជាមេរៀនដ៏ចាប់អារម្មណ៍យ៉ាងខ្លាំង ។ គាត់បង្ហាញដល់កូនៗនូវសម្លៀកបំពាក់ពួកគាត់បានពាក់ នៅពេលពួកគាត់បានទទួលឈ្មោះ និង ការប្រសិទ្ធិពរ ហើយគាត់និយាយអំពីថ្ងៃដែលពិធីបរិសុទ្ធត្រូវបានធ្វើឡើង ។

ឡូរី លើកឡើងដែរថា « វាគឺជាពេលវេលាដ៏ល្អបំផុតដើម្បីនឹងផ្ដោតការចាប់អារម្មណ៍ ទៅលើពរជ័យទាំងឡាយនៃសេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធ » ។ « យើងតែងតែបញ្ជាក់អំពីសារសំខាន់នៃការបង្រៀនថា ជម្រើសដើម្បីនឹងទទួលបុណ្យជ្រមុជទឹក គឺជា ជំហានដំបូងនៅក្នុងការរៀបចំសម្រាប់ពរទាំងឡាយនៃព្រះវិហារបរិសុទ្ធ ។ »



### យើងធ្វើវាជាកិច្ចការគ្រួសារមួយ

ម៉ូនីកា ជាម្ដាយម្នាក់ដែលមានកូនបួននាក់ បានផ្ដល់យោបល់អំពីការឲ្យកូនធំៗចូលរួម ជួយប្អូនៗឲ្យរៀបចំខ្លួន នៅពេលណាដែលអាចធ្វើបាន ។ គាត់បាននិយាយថា « ការស្ដាប់ឮបងបងៗពេញវ័យរបស់ពួកគេថ្លែងទីបន្ទាល់ និង ចែកចាយបទពិសោធន៍របស់ពួកគេ ពិតជាបន្ថែមឥទ្ធិពលដ៏អស្ចារ្យ » ។ ឡូរី បន្ថែមទៀតថា ជួនកាលពួកគេបានសុំដល់កូនដែលកំពុងរៀបចំខ្លួនដើម្បីទទួល បុណ្យជ្រមុជទឹក ឲ្យបង្រៀននូវអ្វីដែលគេបានរៀនទៅប្អូនៗរបស់គេ ។





## យើងប្រើមធ្យោបាយនេះ ជាកិច្ចការផ្សព្វផ្សាយសាសនា

នៅពេលកូនរបស់ដានីយ៉ែលឈានដល់អាយុប្រាំបីឆ្នាំ គាត់ដឹងថានាងនឹងចង់ចែកចាយអំពីថ្ងៃបុណ្យជ្រមុជទឹក របស់នាងជាមួយនឹងមិត្តភក្តិដែលពុំមែនជាសមាជិកនៃសាសនាចក្រ ។ ហេតុដូច្នេះហើយ គ្រួសាររបស់ពួកគេបានធ្វើនូវការអញ្ជើញ ដល់មិត្តភក្តិពីសាលារៀន និង អ្នកជិតខាងដើម្បីចូលរួម បុណ្យជ្រមុជទឹករបស់អាលីសុន ។ មិត្តភក្តិទាំងនេះត្រូវបានស្នើសុំឲ្យចែកចាយខគម្ពីរដែលគេពេញចិត្តមកពីព្រះគម្ពីរបរិសុទ្ធនៅក្នុងពិធីបុណ្យជ្រមុជទឹកនោះ ។ បន្ទាប់ពីបុណ្យជ្រមុជទឹក អាលីសុនបានគូសបន្ទាត់នៅពីខាងក្រោមខគម្ពីរទាំងនោះ នៅក្នុងព្រះគម្ពីរថ្មី របស់នាង ហើយបានសរសេរឈ្មោះមិត្តភក្តិរបស់នាងដែលចែកចាយខនោះ នៅលើគែមទំព័រ ។

« ជាការពិតណាស់ ក្នុងនាមជាសមាជិកគ្រួសារ យើងពិតជាបានចូលរួមជាច្រើនក្នុងការរៀបចំនៅក្នុងថ្ងៃនោះ ។ ដានីយ៉ែលបាននិយាយ « ប៉ុន្តែយើងក៏អនុញ្ញាតឲ្យនាងនៅជាមួយនឹងមិត្តភក្តិមួយរយៈ បន្ទាប់ពីបុណ្យជ្រមុជទឹក ហើយនិយាយជាមួយពួកគេអំពីអារម្មណ៍របស់នាង » ។ « វាគឺ ជាវេលាមួយ ដ៏ផ្អែមល្ហែម ដោយបានឃើញកូនរបស់យើងបានធ្វើជាគំរូដ៏ល្អមួយ ។ »

## យើងហាត់ធ្វើការសម្ភាសន៍របស់ប៊ីស្សព

គិមប៊ើលី ជាម្ដាយដែលមានកូនជិតដល់អាយុទទួលបុណ្យជ្រមុជទឹក គាត់បានចាំនូវការដើរចូលទៅក្នុងការិយាល័យរបស់ប៊ីស្សព សម្រាប់ការសម្ភាសន៍បុណ្យជ្រមុជទឹក នៅពេលគាត់មានអាយុប្រាំបីឆ្នាំ ។ « ខ្ញុំមានអារម្មណ៍បុកពោះខ្លាំងណាស់! » គិមប៊ើលីនិយាយថា

ឥឡូវនេះ គាត់ព្យាយាមធ្វើយ៉ាងណា កុំឲ្យកូនរបស់គាត់ មានអារម្មណ៍ភ័យខ្លាចដូចអញ្ចឹង ។ គាត់ និង ស្វាមីរបស់គាត់បាននិយាយទៅកាន់កូនៗរបស់ពួកគេ អំពីការសម្ភាសន៍របស់ប៊ីស្សព ហើយបានសួរសំណួរដល់ពួកគេ អំពីបុណ្យជ្រមុជទឹក ដែលមានលក្ខណៈស្រដៀងគ្នាដូចទៅនឹងការសំភាសន៍ពិតប្រាកដដូច្នោះ ។ ការសម្ភាសន៍ទាំងនេះមិនគ្រាន់តែជួយក្មេងៗឲ្យយល់ដឹងអំពីដំណើរការសម្ភាសន៍ប៉ុណ្ណោះទេ— ការសម្ភាសន៍ទាំងនេះក៏បាន លើកទឹកចិត្តកុមារឲ្យសញ្ជឹងគិតយ៉ាងជជ្រាលជ្រៅអំពី អត្ថន័យនៃសេចក្ដីសញ្ញាបុណ្យជ្រមុជទឹកចំពោះ ពួកគេផងដែរ ។

## យើងមានឱកាសដ៏អស្ចារ្យមួយ

ឪពុកម្ដាយទាំងនេះរហ័សនឹងចង្អុលបង្ហាញថា ពួកគេមិនបានធ្វើអ្វី ហួសហេតុនៅក្នុងការរៀបចំកូនៗរបស់ពួកគេសម្រាប់បុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ ប៉ុន្តែពួកគេជាច្រើនរូបបានប្រើពាក្យដូចជា « ហ្មត់ចត់ » និង « ជាប់លាប់ » ដើម្បី ពិពណ៌នាអំពីមេរៀនដែលពួកគេបានបង្រៀនជាច្រើនឆ្នាំនោះទេ ។ គិមប៊ើលី បាននិយាយថា « យើងបានធ្វើយ៉ាងណាឲ្យកូនៗរបស់យើងយល់ថា នេះគឺជាជំហានដ៏សំខាន់នៅក្នុងជីវិតរបស់ពួកគេ ហើយថាវាគឺជាព្រឹត្តិការណ៍ដ៏ធំមួយ » ។ « យើងតែងតែធ្វើយ៉ាងណាដើម្បីប្រាកដថា យើងគឺជាអ្នករៀបចំពួកគេ ហើយមិនត្រូវសង្ឃឹមចាំតែឲ្យគ្រូបឋមសិក្សារបស់ពួកគេ បង្រៀនពួកគេប៉ុណ្ណោះទេ ។ »

នេះគឺជាឱកាសដ៏ល្អ ដែលបានផ្ដល់មកយើង ដើម្បីនឹងជួយរៀបចំកូនៗដែលយើងស្រឡាញ់សម្រាប់ ពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ ! ក្នុងពេលដែលយើងធ្វើបែបនេះប្រកបដោយការអធិស្ឋាន ព្រះអម្ចាស់នឹងគង់នៅជាមួយយើង ដើម្បីនឹងជួយទ្រាំទ្រ បទពិសោធន៍នៃការធ្វើសេចក្ដីសញ្ញាដំបូងនេះ ឲ្យក្លាយទៅជាគ្រឹះដ៏រឹងមាំ សម្រាប់ការលូតលាស់ខាងវិញ្ញាណនាអនាគត ។ ■

*នៅទំព័របន្ទាប់នេះ នឹងឆ្លើយ សំណួរខ្លះៗ ដែលកូនៗមានអំពីពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ ។*

**កំណត់ចំណាំ**

1. ប៊ិយដ៍ ឃេ ផាកកឺ "Teach the Children," *លីអាហូណា*, ខែឧសភា ឆ្នាំ 2000, 16 ។

រូបថតដោយ យ៉ូហាន លូក ក្រេហ្គ ឌែមុនដ៍ និង ខូឌី បិល

# ការយល់អំពីពិធីបុណ្យជ្រមុជទឹក

ដោយ ម៉ារីស្សា វីដឌីសុន
ទស្សនាវដ្ដីសាសនាចក្រ





***តើនរណានឹងធ្វើបុណ្យជ្រមុជទឹកឲ្យខ្ញុំ?***

នរណាក៏ដោយដែលធ្វើបុណ្យជ្រមុជទឹកឲ្យអ្នកត្រូវតែកាន់បព្វជិតភាព— អំណាចដើម្បីនឹងប្រព្រឹត្តនៅក្នុងព្រះនាមរបស់ព្រះ ។ នៅពេលព្រះយេស៊ូវចង់ទទួលបុណ្យជ្រមុជទឹក ទ្រង់បានយាងទៅឯយ៉ូហានបាទីស្ទដែលមានបព្វជិតភាព (សូមមើល ម៉ាថាយ 3:13) ។

អ្នកដែលធ្វើបុណ្យជ្រមុជទឹកឲ្យអ្នកនឹងទទួលការអនុញ្ញាតពីប៊ីស្សពឬប្រធានសាខារបស់អ្នក ។

***តើខ្ញុំត្រូវជ្រមុជចូលទៅក្នុងទឹកដើម្បីនឹងទទួលបុណ្យជ្រមុជទឹកមែនដែរឬទេ?***

ព្រះយេស៊ូវបានជ្រមុជទឹកដោយការជ្រមុជចុះ គឺមានន័យថាទ្រង់បានជ្រមុជចូលទាំងស្រុងទៅក្នុងទឹក ហើយភ្លាមៗនោះទ្រង់បានងើបឡើងពីទឹកម្ដងទៀត (សូមមើល ម៉ាថាយ 3:16) ។ នេះគឺជារបៀបដែលអ្នកនឹងទទួលបុណ្យជ្រមុជទឹក ។ ដោយការជ្រមុជទឹកបែបនេះ វារំលឹកយើងថាយើងនឹងចាកចេញពីជីវិតចាស់របស់យើង ហើយចាប់ផ្ដើមជីវិតថ្មីដោយប្ដេជ្ញាចិត្តថានឹងបម្រើព្រះអម្ចាស់និងព្រះរាជបុត្រារបស់ទ្រង់ ។

***តើខ្ញុំបានធ្វើសេចក្ដីសន្យាអ្វីខ្លះនៅពេលខ្ញុំទទួលបុណ្យជ្រមុជទឹក?***

នៅពេលអ្នកបានទទួលបុណ្យជ្រមុជទឹក អ្នកធ្វើសេចក្ដីសញ្ញាមួយ ឬសេចក្ដីសន្យាទៅវិញទៅមកជាមួយព្រះវរបិតាសួគ៌ ។ អ្នកសន្យាដល់ទ្រង់ថាអ្នកនឹងធ្វើតាមនូវអ្វីជាក់លាក់មួយចំនួន ហើយទ្រង់សន្យានឹងប្រទានពរដល់អ្នក ។ សេចក្ដីសញ្ញានេះត្រូវបានរៀបរាប់នៅក្នុងការអធិស្ឋានសាក្រាម៉ង់ដែលត្រូវបានសូត្រជារៀងរាល់ថ្ងៃអាទិត្យ (សូមមើល គ. និង ស. 20:77–79) ។ អ្នកសន្យាថា៖

- ដើម្បីចងចាំអំពីព្រះយេស៊ូវគ្រីស្ទ ។
- រក្សាបញ្ញត្តិរបស់ទ្រង់ ។
- ដើម្បីលើកដាក់លើខ្លួនយើងនូវព្រះនាមរបស់ព្រះគ្រីស្ទ ដែលមានន័យថា ធ្វើកិច្ចការរបស់ទ្រង់ជាមុន ក្នុងជីវិតរបស់យើង ហើយធ្វើអ្វីដែលទ្រង់ចង់ឲ្យយើងយើងជាងអ្វីដែលលោកីយចង់ឲ្យយើងធ្វើ ។

នៅពេលអ្នករក្សាសេចក្ដីសន្យានេះ ព្រះវរបិតាសន្យាថាព្រះវិញ្ញាណបរិសុទ្ធ នឹងគង់ជាមួយអ្នក ហើយថាអំពើរបស់អ្នកនឹងត្រូវអភ័យទោសឲ្យ ។





រូបថត © DYNAMIC GRAPHICS; រចនារូបថតដោយដាវីឌ ស្ដូឌី ម៉ាថាយ រៀ ហើយនិងសារាហ៍ ជីនសុន ។



***តើព្រះវិញ្ញាណបរិសុទ្ធគឺជាអ្វី?***

អំណោយនៃព្រះវិញ្ញាណបរិសុទ្ធគឺជាអំណោយមួយ ដែលមានតម្លៃបំផុតរបស់ព្រះវរបិតាសួគ៌ ។ បុណ្យជ្រមុជទឹកដោយទឹករបស់អ្នកគឺមិនគ្រប់គ្រាន់ទេ រហូតដល់ពួកបុរសដែលកាន់បព្វជិតភាព មិលគីស្សាដែកប្រសិទ្ធពរដល់អ្នក ឲ្យទទួលព្រះវិញ្ញាណបរិសុទ្ធ (សូមមើល  យ៉ូហាន 3:5) ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាសមាជិកមួយអង្គនៃក្រុមព្រះ ។ ទ្រង់ថ្លែងទីបន្ទាល់អំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ហើយជួយយើងឲ្យដឹងអ្វីដែលពិត ។ ទ្រង់ជួយយើងឲ្យរឹងមាំខាងវិញ្ញាណ ។ ទ្រង់ព្រមានយើងអំពីគ្រោះថ្នាក់ ។ ទ្រង់ជួយយើងឲ្យរៀន ។ ព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងឲ្យមានអារម្មណ៍អំពីសេចក្ដីស្រឡាញ់របស់ព្រះ ។

នៅពេលអ្នកត្រូវបានបញ្ជាក់ជាសមាជិកនៃសាសនាចក្រ ព្រះវិញ្ញាណបរិសុទ្ធអាចគង់នៅជាមួយអ្នកជានិច្ច ប្រសិនបើអ្នកជ្រើសរើសត្រូវ ។



***តើហេតុអ្វីខ្ញុំត្រូវតែយ៉ាងហោចណាស់មានអាយុប្រាំបីឆ្នាំ ដើម្បីនឹងទទួលបុណ្យជ្រមុជទឹក?***

ព្រះអម្ចាស់បង្រៀនថា កូនក្មេងមិនត្រូវទទួលបុណ្យជ្រមុជទឹក រហូតដល់ពួកគេមានអាយុគ្រប់គ្រាន់ ដើម្បីនឹងយល់អំពីភាពខុសគ្នារវាង ខុស និង ត្រូវ ដែលព្រះគម្ពីរថ្លែងថា អាយុប្រាំបីឆ្នាំ (សូមមើលមរ៉ូណៃ 8:11–12; គ. និង ស. 29:46–47; 68:27) ។



ដោយអែលឌើរ ថៃរ៉ូ ម៉ាស្សាហ្គាឌី
នៃពួកចិតសិបនាក់



# ទាក់ទាញចិត្តឆ្ពោះទៅព្រះវិហារបរិសុទ្ធ

*ចំពោះមនុស្សល្អជាច្រើន ព្រះវិហារបរិសុទ្ធបំផុសអារម្មណ៍ដែលអាចជ្រៀតចូលទៅក្នុងដួងចិត្តមួយរំពេច ។*

ពីមុន ខ្ញុំត្រូវបានហៅជាសមាជិកម្នាក់ក្នុងកូរ៉ុមទីពីរនៃពួកចិតសិបនាក់ ខ្ញុំ និង ភរិយារបស់ខ្ញុំបានចំណាយពេលពីរបីឆ្នាំ បម្រើនៅក្នុងព្រះវិហារបរិសុទ្ធកាពីណាស់និង សៅ ប៉ូឡូ ប្រេស៊ីល ។ នៅក្នុងព្រះវិហារបរិសុទ្ធទាំងពីរនោះ ជាញឹកញាប់ខ្ញុំ មានការអស្ចារ្យនៅក្នុងចិត្តដោយមានមនុស្សជាច្រើនដែលធ្វើដំណើរនៅក្បែរព្រះវិហារបរិសុទ្ធ ហើយត្រូវបានទាក់ទាញចិត្តឲ្យឆ្ពោះទៅរកព្រះវិហារបរិសុទ្ធនោះ ដែលធ្វើឲ្យពួកគេ ឈប់រថយន្ត ដើរចូល និង សាកសួរអំពីព្រះវិហារបរិសុទ្ធនោះ ។

នៅពេលពួកគេបានចូលមក យើងបានប្រាប់ពួកគេថាពួកគេមិនអាចចូលទៅក្នុងទៀត ដោយគ្មានការរៀបចំដ៏ត្រឹមត្រូវឡើយ ។ រួចហើយយើងបានពន្យល់អំពីគោលបំណងនៃព្រះវិហារបរិសុទ្ធ បានចែកចាយអំពីមូលដ្ឋាននៃ គោលលទ្ធិនៃដំណឹងល្អ ហើយបានអញ្ជើញពួកគេឲ្យជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។ ចំពោះមនុស្សដ៏ល្អជាច្រើនព្រះវិហារនេះបានធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏ពូកែ ពីព្រោះវា បំផុស អារម្មណ៍ដែលអាចជ្រៀតចូលទៅក្នុងដួងចិត្តមួយរំពេច ។

ខ្ញុំ និង ភរិយារបស់ខ្ញុំ ឈ្មោះអេលីសាបេត ដឹងនូវអំណាចនៃអារម្មណ៍បែបនោះតាំងពីដំបូង ។ ជាង 40 ឆ្នាំកន្លងទៅហើយ មិត្តភក្តិ និង ជាអ្នករួមការងារដ៏ល្អម្នាក់ដែលជាសមាជិកនៃសាសនាចក្រ បានចាប់ផ្ដើមលើកយកដំណឹងល្អមកក្នុងការសន្ទនាដ៏សាមញ្ញមួយ ជាមួយនឹងយើង ។ គាត់បានបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាមកជួបនឹងយើង ពីរបីដង ។ យើងពេញចិត្តនឹងពួកផ្សព្វផ្សាយសាសនា

ហើយបានយល់ព្រមនឹងទទួលការពិភាក្សា ប៉ុន្តែយើងពិតជាមិនចាប់អារម្មណ៍នឹងអ្វីដែលពួកគេបង្រៀនទេ ។

ការណ៍នោះបានផ្លាស់ប្តូរនៅក្នុងខែតុលា ឆ្នាំ 1978 នៅពេលមិត្តរួមការងារ របស់ខ្ញុំបានអញ្ជើញមិត្តភក្តិមួយចំនួន ដែលរួមមានទាំងពួកយើងផង ដើម្បីចូលរួមពិធីបើកសម្ពោធ ព្រះវិហារបរិសុទ្ធ សៅប៉ូឡូ ប្រេស៊ីល ។ គាត់បានជួលឡានក្រុងពីរបីគ្រឿង ដោយប្រើប្រាស់ការចំណាយផ្ទាល់ខ្លួនគាត់ ដូច្នេះមិត្តរបស់គាត់អាច ចូលរួមនឹងគាត់ធ្វើដំណើរទៅព្រះវិហារបរិសុទ្ធដែលមានចម្ងាយប្រហែលជា 50 ម៉ៃល (80 គីឡូម៉ែត្រ) ។

នៅពេល អេលីសាបេត បានចូលក្នុងអាងជម្រុជទឹក នាងបានទទួលនូវ អារម្មណ៍នៃបទពិសោធន៍មួយដែលនាងមិនធ្លាប់មាន ពីមុនមក ដែលក្រោយមកនាងបានដឹង ថាជាព្រះវិញ្ញាណបរិសុទ្ធ ។ អារម្មណ៍នោះគឺជាសេចក្តីអំណរដ៏មហិមានៅក្នុងដួងចិត្តរបស់នាង ។ នៅពេលនោះ នាងបានដឹងភ្លាមថា សាសនាចក្រនោះគឺជាសាសនាចក្រដ៏ពិត ហើយថាវាគឺជាសាសនា ចក្រដែលនាងចង់ចូលរួម ។

អារម្មណ៍ស្រដៀងគ្នានោះបានកើតមានចំពោះខ្ញុំ នៅឯចុងបញ្ចប់នៃពិធីសម្ពោធនោះ នៅពេលយើងត្រូវបាននាំចូលទៅក្នុងបន្ទប់ផ្សារភ្ជាប់ និង ត្រូវបានបង្រៀនអំពីគោលលទ្ធិនៃក្រុមគ្រួសារដ៏អស់កល្បជានិច្ច នោះ ។ គោលលទ្ធិនោះបានបានប៉ះដល់ដួងចិត្តរបស់ខ្ញុំ ។ ខ្ញុំទទួលបានជោគជ័យនៅក្នុងអាជីពកម្មរបស់ខ្ញុំ ប៉ុន្តែខ្ញុំមាននូវអារម្មណ៍ទទេស្អាត នៅក្នុងព្រលឹងរបស់ខ្ញុំ ។ ខ្ញុំមិនដឹងថា តើមានអ្វីអាចនឹងមកបំពេញភាពទទេស្អាតនោះបានទេ គ្រាន់តែដឹងថា វាជាអ្វីមួយដែល ពាក់ព័ន្ធទៅនឹងគ្រួសារ ។ នៅក្នុងបន្ទប់ផ្សារភ្ជាប់នោះ អ្វីៗបានចាប់ផ្តើមបំពេញ នៅក្នុងដួងចិត្ត និង គំនិតរបស់ខ្ញុំ ។

ក្នុងអំឡុងពីបីថ្ងៃក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានទាក់ទងនឹងយើងម្តងទៀត ។ នៅពេលនេះ យើងពិតជាចាប់អារម្មណ៍ចង់ស្តាប់សារដំណឹងរបស់ពួកគេ ។

ពួកអែលឌើរបានអញ្ជើញយើងឲ្យអធិស្ឋានយ៉ាងស្មោះ អំពីការពិត ។ ខ្ញុំបានសម្រេចចិត្តថា នេះគឺជារបៀបតែមួយដែលខ្ញុំ*អាច*អធិស្ឋាន ។ ខ្ញុំបានដឹងថា ខ្ញុំមិនអាចធ្វើការប្តេជ្ញាចិត្ត ដើម្បីនឹងចូលរួមក្នុងសាសនាចក្រ ដោយគ្មានទីបន្ទាល់ដ៏ពិតមួយនោះឡើយ ។ ខ្ញុំមានចិត្តអន្ទះសាអំពីការចូលទៅឯព្រះវរបិតាសួគ៌ ដើម្បីនឹងទូលសុំនូវការបញ្ជាក់ពីទ្រង់ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ខ្ញុំដឹងយ៉ាងពិតប្រាកដថា ទ្រង់នឹងឆ្លើយតបមកខ្ញុំ ។ ខ្ញុំបានចែករំលែកជាមួយទ្រង់នូវសេចក្តីប្រាថ្នាដ៏ជ្រៅនៃដួងចិត្តរបស់ខ្ញុំ ហើយបានទូលសុំទ្រង់ឲ្យប្រទាននូវចម្លើយដល់ខ្ញុំ ដែលនឹងបញ្ជាក់ដល់ខ្ញុំថា ការចូលរួមក្នុងសាសនាចក្រគឺជាផ្លូវមួយដ៏ត្រឹមត្រូវ ។

សប្តាហ៍ក្រោយមក នៅក្នុងសាលាថ្ងៃអាទិត្យ មិត្តភក្តិរបស់ខ្ញុំដែលបានអញ្ជើញយើងទៅចូលរួមពិធីសម្ពោធព្រះវិហារបរិសុទ្ធ បានអង្គុយពីខាងក្រោយខ្ញុំ ។ គាត់បានឱនមកខាងមុខ ហើយបានចាប់ផ្តើមនិយាយជាមួយខ្ញុំ ។ ពាក្យពេចន៍ទាំងឡាយដែលគាត់បាននិយាយនោះ បានឆ្លើយចំពោះអ្វីដែលខ្ញុំបានអធិស្ឋានចង់ដឹងយ៉ាងពិត ។ ខ្ញុំមិនសង្ស័យឡើយថា ព្រះវរបិតាសួគ៌បានកំពុងតែមានព្រះបន្ទូល មកកាន់ខ្ញុំតាមរយៈគាត់ ។ នៅពេលនោះ ខ្ញុំគឺជាមនុស្សរឹងចចេស ប៉ុន្តែដួងចិត្តរបស់ខ្ញុំត្រូវបានបន្ទន់ ហើយខ្ញុំបានចាប់ផ្តើមយំ ។ នៅពេលមិត្តរបស់ខ្ញុំបានបញ្ចប់ហើយ គាត់បានអញ្ជើញខ្ញុំ និង ប្រពន្ធខ្ញុំ ឲ្យទទួលបុណ្យជ្រមុជទឹក ។ យើងបានយល់ព្រម ។

ក្នុងថ្ងៃទី 31 ខែ តុលា ឆ្នាំ 1978 មិនដល់មួយខែផង បន្ទាប់ពីបទពិសោធន៍របស់យើងនៅឯពព្រះវិហារ សៅប៉ូឡូយើងបានទទួលបុណ្យជ្រមុជទឹក និង ត្រូវបានធ្វើពិធីបញ្ជាក់ ។ ថ្ងៃបន្ទាប់មក យើងបានចូលរួមនៅក្នុងរៀនឧទ្ទិសឆ្លងទីពីនៃព្រះវិហារបរិសុទ្ធសៅ ប៉ូឡូ ប្រេស៊ីល ។ មួយឆ្នាំក្រោយមក យើងបានត្រឡប់ទៅព្រះវិហារបរិសុទ្ធជាមួយកូនប្រុសពីនាក់របស់យើង ហើយបានផ្សារភ្ជាប់ជាគ្រួសារមួយ ។ ឱកាសដ៏ល្អក្រៃលែងទាំងបីលើកនោះ ពិតជាបទពិសោធន៍ដ៏គួរឲ្យចងចាំ ។ យើងបានបន្តដើម្បីឲ្យមានអារម្មណ៍ទាំងនោះ ដោយ ការថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធយ៉ាងទៀងទាត់ ជាច្រើនឆ្នាំក្រោយមក ។

អស់រយៈពេលម្ភៃប្រាំបីឆ្នាំចាប់ពីថ្ងៃជ្រមុជទឹករបស់យើង ខ្ញុំ និង ភរិយាបានឈរម្តងទៀត នៅក្នុងព្រះវិហារបរិសុទ្ធ សៅ ប៉ូឡូ ប្រេស៊ីល ។ ខ្ញុំទើបតែត្រូវបានហៅជាប្រធាននៃព្រះបរិសុទ្ធ ។ គឺជាបទពិសោធន៍ដ៏ផ្អែមល្ហែមសម្រាប់ពួកយើង ដើម្បីដើរក្នុងសាលនៃដំណាក់របស់ព្រះអម្ចាស់ ដើម្បីនឹងរំលឹកឡើងវិញនូវអារម្មណ៍ដ៏សោមនស្សទាំងឡាយ ដែលជាជំហាននៃការប្រែចិត្តជឿរបស់យើង ។

ព្រះវិហារបរិសុទ្ធបន្តនាំមកដល់ខ្ញុំ និង ភរិយារបស់ខ្ញុំ នូវសុភមង្គលដ៏មហិមា ។ នៅពេលយើងមើលឃើញគូស្វាមីភរិយាវ័យក្មេងចូលទៅក្នុងព្រះវិហារបរិសុទ្ធ ដើម្បីនឹងផ្សារភ្ជាប់ជាគ្រួសារដ៏អស់កល្បជានិច្ចមួយ យើងមានអារម្មណ៍នៃសេចក្តីសង្ឃឹមដ៏ធំ ។

មានមនុស្សជាច្រើននៅទូទាំងពិភពលោក ដែលត្រូវបានរៀបចំដើម្បីនឹងស្តាប់សារលិខិតនៃដំណឹងល្អ ។ ពួកគេមានអារម្មណ៍ស្រេកឃ្លានស្រដៀងទៅនឹងអ្វីដែលខ្ញុំបានមានពិសោធន៍ជាង 30 មុន ។ ព្រះវិហារបរិសុទ្ធ និង ពិធិបរិសុទ្ធទាំងឡាយនៅក្នុងព្រះវិហារបរិសុទ្ធគឺមានអានុភាពយ៉ាងពេញលេញ ដើម្បីនឹងចំអែតនូវការស្រេកឃ្លាន និង បំពេញភាព ទទេស្អាតរបស់ពួកគេ ។ ■

រូបថតដោយ ឡូរេនី ហ្វូធេតូ

# មានអ្វីខុសប្រក្រតីចំពោះយន្តហោះរបស់ខ្ញុំ

នៅល្ងាចមួយ ខណៈដែលខ្ញុំបើកបរយន្តហោះរបស់ខ្ញុំ នៅលើផ្លូវរត់ ដែលមានអ្នកធ្វើដំណើរអង្គុយពេញ នោះខ្ញុំបានមានអារម្មណ៍ថា ប្រព័ន្ធចង្កូតរបស់យន្តហោះដូចជាមិនសូវស្រួលទេ ។ ដើម្បីបញ្ជាក់អំពីចំណាប់អារម្មណ៍ខាងវិញ្ញាណរបស់ខ្ញុំ ខ្ញុំបានបើកបរយន្តហោះចេញពីផ្លូវ ហើយខ្ញុំបានបើកបរវាជារង្វង់ ។ វាហាក់ដូចជាគ្មានបញ្ហាអ្វីសោះ ។

ខ្ញុំពិចារណាថា « តើខ្ញុំគប្បីគួរតែហោះឡើង នាំអ្នកធ្វើដំណើរទៅដល់គោលដៅរបស់ពួកគេឲ្យបានទាន់ពេលវេលា ឬក៏គប្បីត្រឡប់ទៅឯទ្វាចំណតវិញ ? » ខ្ញុំបានដឹងថា ការត្រឡប់ទៅវិញ នឹងធ្វើឲ្យមានការពន្យាពេលដ៏យូរមួយ ។ ផ្លូវយន្តហោះបរនោះមានតែទិសមួយប៉ុណ្ណោះ ខ្ញុំត្រូវតែរង់ចាំដល់អ្នកគ្រប់គ្រងចរាចរណ៍លើផ្លូវរត់របស់យន្តហោះនោះ ធ្វើអន្តរាគមន៍ដើម្បីឲ្យយើងអាចបរយន្តហោះបញ្រ្ចាសទិសចរាចរណ៍បាន ។ បន្ទាប់មក យើងនឹងត្រូវតែរង់ចាំ សម្រាប់ពួកត្រួតពិនិត្យ ដើម្បីមកពិនិត្យយន្តហោះនោះ ។ ការពន្យាពេលអាចបណ្ដាលឲ្យមានបញ្ហាជាច្រើន ចំពោះជើងយន្តហោះ និង ចំពោះអ្នកធ្វើដំណើរ ដែលមានបងប្អូនរង់ចាំ ពួកគេ និង នឹងជើងយន្តហោះដែលធ្វើដំណើរបន្តទៅទៀត ។ ខ្ញុំក៏បានគិតថាអំពីរបៀបដែលការិយាល័យត្រួតពិនិត្យនឹងមានប្រតិកម្មយ៉ាងណា ចំពោះការរាយកាណ៍របស់ខ្ញុំ ដោយសារយន្តហោះហាក់ដូចជាមិនមានបញ្ហាអ្វីសោះ ក្រៅតែពីអារម្មណ៍ដែលខ្ញុំមានប៉ុណ្ណោះ ។

ក្នុងនាមខ្ញុំជាប្រធានគ្រប់គ្រងលើយន្តហោះ ខ្ញុំមានទំនួលខុសត្រូវចំពោះសុវត្ថិភាពរបស់យើង ដូច្នេះ ហើយខ្ញុំបានសម្រេចចិត្តធ្វើតាម អារម្មណ៍ដែលខ្ញុំមាន ហើយត្រឡប់មកចំណតវិញ ។

នៅពេលយើងទៅដល់ទ្វារចំណត ខ្ញុំបានប្រាប់ជាងជួសជុលថា ខ្ញុំមានអារម្មណ៍ថា យន្តហោះនេះមានអ្វីមួយមិនស្រួល ប៉ុន្តែខ្ញុំមិនដឹងថា បញ្ហានោះជាអ្វីនោះទេ ។ គាត់មិនជឿថាមានបញ្ហាអ្វីនោះទេ ។

គាត់បាននិយាយ « ប្រហែលជាផ្លូវយន្តហោះសើមហើយមើលទៅ » ។ « អ្នកប្រហែលជារំអិលនៅលើដីក្រួសហើយ ។ » ប៉ុន្តែគាត់បានយល់ព្រមដើម្បីនឹងពិនិត្យមើលចង្កូត ត្រង់កង់ខាងមុខយន្តហោះ ។ បន្ទាប់ពីការពិនិត្យមើល គាត់បានប្រាប់ខ្ញុំឲ្យយកអ្នកធ្វើដំណើរចេញ ដើម្បីគាត់អាច បើកយន្តហោះសាកមើល ។

30 នាទីក្រោយមក នៅពេលគាត់បានត្រឡប់មកវិញ គាត់ហាក់ដូចជាមានការព្រួយបារម្ភខ្លាំងណាស់ ។ ក្នុងអំឡុងនៃការបើកសាកនោះ គាត់បានឮសំឡេងកកិតចម្លែកមួយ ។ នៅពេលគាត់ចាប់ហ្វ្រាំង ក្នុងពេលគាត់កំពុងតែបត់ យន្តហោះថយក្រោយ ដើម្បីត្រឡប់មកទ្វារចំណត វិញ គាត់សឹងតែមិនអាចទប់ចង្កូតយន្តហោះបានហើយស្ទើរតែរត់ធ្លាក់ពីផ្លូវយន្តហោះទៀតផង ។

ការពិនិត្យយ៉ាងផ្ចិតផ្ចង់បានបង្ហាញថា ហ្វ្រាំងមិនត្រូវបាន ជួសជុលត្រឹមត្រូវនៅយប់ពីមុនពីហោះហើរ នេះ ។ ប្រសិនបើខ្ញុំចុះចត បន្ទាប់ពីការហោះរបស់យើង ហ្វ្រាំងនឹងមិនដំណើរ ហើយខ្ញុំនឹងមិនអាចបញ្ឈប់យន្ត ហោះបានឡើយ ។

ខ្ញុំបានទទួលយន្តហោះមួយទៀតដើម្បីបើកហើយខ្ញុំបានដឹកជូនអ្នកធ្វើដំណើររបស់ខ្ញុំទៅដល់គោលដៅរបស់ពួកគេដោយសុវត្ថិភាព តែយឺតបីម៉ោង ។

ខ្ញុំមានអំណរគុណណាស់ ដែលខ្ញុំបានស្ដាប់តាមការខ្សិតប្រាប់នៃព្រះវិញ្ញាណ ។ ខ្ញុំដឹងថាព្រះវិញ្ញាណនឹងដឹកនាំយើង ប្រសិនបើយើងស្វែររកការណែនាំ និង ស្ដាប់តាមការបំផុសគំនិត ដែលកើតមាន ។ ■

គ្រេហ្គ វីលលី រដ្ឋយូថា ស.ហ.រ.



**ខ្ញុំបានគិតថា តើការិយាល័យត្រួតពិនិត្យនឹងមានប្រតិកម្មយ៉ាងណា ចំពោះការរាយកាណ៍របស់ខ្ញុំ ដោយ សារយន្តហោះហាក់ដូចជាមិនមានបញ្ហាអ្វីសោះ ក្រៅតែពីអារម្មណ៍ដែលខ្ញុំមានប៉ុណ្ណោះ ។**

រចនារូបភាពដោយយ៉ូសែប អាលមែន

# ការរកឃើញសេចក្ដីអំណរនៅក្នុងជីវិត

នៅក្នុងគ្រាមួយ ខ្ញុំកំពុងតែអានសន្និសីទទូទៅ ថ្លែងដោយអែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុម ពួកសាវកដប់ពីរនាក់ ។ ថ្វីបើខ្ញុំបានស្ដាប់ និង អានសន្ទរកថានេះពីមុនមកក្ដី ឃ្លាមួយបានទាក់ទាញសតិអារម្មណ៍របស់ខ្ញុំ ហើយ បានដក់ជាប់ក្នុងគំនិតរបស់ខ្ញុំ ។

ពីរបីម៉ោងក្រោយមក កូនប្រុសរបស់ខ្ញុំ ដែលកំពុងតែរស់ក្នុងផ្ទះជួលជាមួយមិត្តរបស់គាត់ បានមកលេង ។ គាត់បានបម្រើបេសកកម្មពេញម៉ោង ហើយបានទៅរៀនពីរបីឆមាសនៅមហាវិទ្យាល័យ ។ គាត់មិន ប្រាកដថា តើគាត់គួររៀនមុខវិជ្ជាអ្វី និង តើអាជីពអ្វីដែលគាត់ត្រូវបន្តនោះទេ ។ ព្រោះតែគេមានចិត្តស្មុគស្មាញហើយមានអារម្មណ៍ថាសាលារៀន ហាក់ដូចជាការចំណាយពេលវេលានិង ប្រាក់ឥតប្រយោជន៍ ដូច្នេះគាត់បានព្យួរការសិក្សារបស់គាត់មួយរយៈ ហើយបានចាប់ផ្ដើម ធ្វើការពេញម៉ោង ។

គាត់បានប្រាប់ខ្ញុំថាមិត្តម្នាក់របស់គាត់ បានផ្ដល់យោបលថា ពួកគេត្រូវទៅលេងកោះមួយ នៅក្នុងក្រុមកោះបាហាម៉ាស ឬ ការីប៉ៀន រកការងារធ្វើ ហើយ លេងកំសាន្តនៅទីនោះសម្រាប់បីបួនខែសិន ។ កូនប្រុសរបស់ខ្ញុំមានចិត្តរំភើបចំពោះការរំពឹងទុកនោះ ។ ខ្ញុំអាចមើលឃើញយ៉ាងងាយស្រួល អំពីការអូសទាញ ចំពោះយុវជនម្នាក់ដែលមិនទាន់ចេះគិតវែងឆ្ងាយនោះ ។

រំពេចនោះ សារលិខិតដ៏បំផុសគំនិតរបស់អែលឌើរស្កត បានចូលមកក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំបានចាប់លើកទស្សនាវដ្ដី *Ensign* ហើយអានឃ្លាដូចតទៅនេះ ទៅកូនប្រុសរបស់ខ្ញុំ ៖ « អ្នក រាល់គ្នារស់នៅលើផែនដីនោះសម្រាប់គោលបំណងដ៏ទេវភាពមួយ ។ វាពុំមែនសម្រាប់ការលេងកំសាន្តឥតឈប់ឈរ ឬមិនមែនជាការបំពេញនូវភាពរីករាយជានិច្ចនោះឡើយ ។ អ្នករាល់គ្នាមកកាន់ផែនដី នេះគឺដើម្បីទទួលនូវការ សាកល្បង ដើម្បីបង្ហាញថាអ្នកអាចនឹងទទួលបាននូវពរជ័យដែលព្រះមានសម្រាប់អ្នកបន្ថែមទៀត ។ ការអត់ធ្មត់ចំពោះអារម្មណ៍គឺ តម្រូវឲ្យមាន » (“Finding Joy in Life,” *Ensign,* ខែឧសភា ឆ្នាំ 1996, ទំព័រ 25) ។

កូនប្រុសរបស់ខ្ញុំបានយក ទស្សនាវដ្ដីនោះ ដោយមិននិយាយតបមួយម៉ាត់សោះ ហើយបានអាន សន្ទរកថាពីដើមដល់ចប់ ។ ក្រោយមក អ្វីដែលគាត់បាននិយាយនោះគឺថា គាត់នឹងមិនទៅផ្សងព្រេងនៅលើកោះទៀតឡើយ ។

ពេលនោះគាត់បានរៀនខាងផ្នែកនគរបាល គឺជាពេលមួយដែលធ្វើឲ្យគាត់បានជួបជាមួយនឹងអនាគតភរិយារបស់គាត់ ។ ពួកគេបានរៀបការនៅក្នុងព្រះវិហាររបរិសុទ្ធ មេសា អារីស្សូណា ហើយសព្វថ្ងៃនេះកំពុងែចិញ្ចឹមកូនដ៏ ល្អបីនាក់ ។ នៅក្នុងឆ្នាំ 2010 កូនប្រុសរបស់ខ្ញុំបានបញ្ចប់បរិញ្ញាបត្រ ហើយពិតជាបាន « រកឃើញសេចក្ដីអំណរក្នុងជីវិត ។ »

ការផ្សងព្រេងដែលកូនខ្ញុំបានលើកយកពិភាក្សាជាមួយខ្ញុំប្រហែលអាចជាបទពិសោធន៍ដ៏ល្អមួយប៉ុន្តែវាក៏អាចជាបទពិសោធន៍ដ៏ គ្រោះថ្នាក់ខាងវិញ្ញាណផងដែរ ។ រៀងរាល់ពេលដែលខ្ញុំសញ្ជឹងគិតអំពីបទពិសោធន៍ព្រះវិញ្ញាណប៉ះដួងចិត្តរបស់ខ្ញុំ ។

ខ្ញុំមានអំណរគុណចំពោះពាក្យពេចន៍របស់ពួកព្យាការី ដែលធ្វើឲ្យខ្ញុំត្រូវបានបំផុសគំនិត ឲ្យនឹកចាំពី សន្ទរកថាមួយ ដែលជួយផ្ដល់ដល់ខ្ញុំនូវគោលការណ៍ដឹកនាំ ។ ខ្ញុំក៏មានអំណរគុណដែលកូនប្រុសរបស់ខ្ញុំបានស្ដាប់តាមសារទូតរបស់ព្រះអម្ចាស់ ហើយអនុញ្ញាតឲ្យព្រះវិញ្ញាណមានអានុភាពចំពោះគាត់ ។ ខ្ញុំដឹងថា ពរជ័យ និង សេចក្ដីមេត្តាករុណាដ៏ស្រទន់ដ៏ច្រើននឹងកើតមាន នៅពេលយើងស្ដាប់ និង អនុវត្តតាមការប្រង្វៀនទាំងឡាយរបស់ព្រះសង្គ្រោះ និង អ្នកបម្រើរបស់ទ្រង់ ។ ■

ការិន រ៉ែកវូដ រដ្ឋអែដាហូ ស.ហ.អ




នៅពេលកូនប្រុសរបស់ខ្ញុំបានប្រាប់ខ្ញុំថា មិត្តរបស់គាត់ម្នាក់បានផ្ដល់យោបល់ថា ពួកគេទៅក្រុមកោះ បាហាម៉ាស ឬកោះការីប៉ៀនដើម្បីនឹងដើដើរលេងកំសាន្តពីរបីខែ សារលិខិតរបស់អែលឌើរស្កតបានចូលមកក្នុងគំនិតរបស់ខ្ញុំ ។

# ទូរស័ព្ទបានបិទ

នៅក្នុងខែមិនា ឆ្នាំ 1997 ខណៈពេលកំពុងរស់នៅក្នុងទីក្រុង រ៉ូស្តូវអុនដន ប្រទេសរុស្សី ខ្ញុំ និង ប្ដីរបស់ ខ្ញុំបានទទួលបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

នៅពេលដែលខ្ញុំបានសិក្សាគោលលទ្ធិនៃសាសនាចក្រ នោះសំណួរ របស់ខ្ញុំជាច្រើនត្រូវបានបកស្រាយ ។ វាគួរឲ្យចំណាប់អារម្មណ៍ខ្លាំងណាស់ ដើម្បីរៀនអំពីផែនការនៃសេចក្ដីសង្គ្រោះ ដោយមានរួមទាំង ការធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់ពួកស្លាប់ ។ ខ្ញុំរំភើបចិត្តណាស់ដោយដឹងថាយើងអាចធ្វើពិធីបុណ្យជ្រមុជទឹក ជំនួសដូនតារបស់យើងដែលបានចែកឋានទៅហើយនោះ ។

មួយឆ្នាំបន្ទាប់ពីបុណ្យជ្រមុជទឹករបស់យើង បប្រធានបេសកកម្មបានអញ្ជើញយើងឲ្យរៀបចំ ខ្លួនទៅព្រះវិហារបរិសុទ្ធ ។ ជាផ្នែកនៃការរៀបចំរបស់យើង យើងបានចាប់ផ្ដើមធ្វើការស្រាវជ្រាវប្រវត្តិក្រុមគ្រួសារ ។ ថ្ងៃមួយ នៅពេលខ្ញុំកំពុងតែគិតអំពីការធ្វើការនេះ ស្រាប់តែទូរស័ព្ទបានរោទិ៍ឡើង ។ គឺជាម្ដាយក្មេករបស់ខ្ញុំ ។ ខ្ញុំបានសួរគាត់ ប្រសិនបើគាត់អាចនឹងផ្ញើបញ្ជីឈ្មោះដូនតាខាងស្វាមីរបស់ខ្ញុំដែលបានចែកឋានទៅ ។ គាត់មានមានការភ្ញាក់ផ្អើល ហើយបានប្រាប់ខ្ញុំថាបុណ្យជម្រុជទឹកសម្រាប់មនុស្សស្លាប់ ពុំមែនជាគោលលទ្ធិរបស់ព្រះគ្រីស្ទទេ គឺជាអ្វីមួយដែលពួកមរមនបានប្រឌិតឡើងវិញតែប៉ុណ្ណោះ ។ ខ្ញុំមិនដឹងថាត្រូវឆ្លើយតបនឹងគាត់ដូចម្ដេចទេ ពីព្រោះខ្ញុំមិនស្គាល់វគ្គព្រះគម្ពីរនានា ដែលអាចគាំទ្រដល់គោលលិទ្ធិនេះ ។

ខណៈដែលខ្ញុំកំពុងតែគិតរបៀបនឹងឆ្លើយតបស្រាប់តែទូរស័ព្ទក៏បានដាច់ទៅ ។ នៅនាទីនោះ ខ្ញុំមិនច្បាស់ក្នុងចិត្តថាមានអ្វីបានកើតឡើងនោះទេ ប៉ុន្តែខ្ញុំបានបិទទូរស័ព្ទ ហើយបានចូលទៅក្នុងបន្ទប់ដេករបស់ខ្ញុំ ។ ខ្ញុំបានកាន់ព្រះគម្ពីរម្ពីរសញ្ញាថ្មីនៅក្នុងដៃរបស់ខ្ញុំ លត់ជង្គង់ចុះអធិស្ឋានហើយបានទូលសុំព្រះវរបិតាសួគ៌ សូមបង្ហាញដល់ខ្ញុំ តើខ្ញុំអាចរកឃើញចម្លើយទៅទីណាបាន ។

ក្នុងចុងបញ្ចប់នៃការអធិស្ឋានរបស់ខ្ញុំ ខ្ញុំបានបើកព្រះគម្ពីរបរិសុទ្ធ ។ ខ្ញុំបានមានអារម្មណ៍ថាហាក់ដូចជាមាននរណាម្នាក់បានប្រាប់ខ្ញុំ ឲ្យខទី 29 នៅគ្រប់ទំព័រដែលខ្ញុំ បានបើក ។ ខ្ញុំបានបើកដល់ជំពូកទី 15 នៃ កូរិនថូសទី 1 ដែលនិយាយអំពីគោលលទ្ធិនៃពិធីបុណ្យជ្រមុជទឹក សម្រាប់ពួកអ្នកស្លាប់ ។

ខ្ញុំត្រូវបានរំជួលចិត្ត និង ភ្ញាក់ផ្អើល ដែលព្រះវរបិតាបានឆ្លើយនឹងសំណួររបស់ខ្ញុំ នៅក្នុងគ្រានោះតែ ម្ដង ។ វាគឺជាអារម្មណ៍ដ៏អស្ចារ្យ ។

នៅពេលខ្ញុំបានកំពុងសញ្ជឹងគិតយ៉ាងជ្រៅអំពីបទពិសោធន៍នេះ ស្រាប់តែទូរស័ព្ទបានរោទិ៍ឡើង ម្ដងទៀត ។ គឺជាម្ដាយក្មេករបស់ខ្ញុំ បានសួរខ្ញុំថាហេតុអ្វីបានជាដាច់ទូរស័ព្ទអញ្ចឹង ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំបានសុំគាត់ឲ្យបើកព្រះគម្ពីររបស់គាត់ ហើយអានកូរិនថូសទី 1 15:29 ។

ពីរបីថ្ងៃក្រោយមក បញ្ជីឈ្មោះនៃញាតិដែលបានចែកឋានទៅនោះ បានស្ថិតនៅលើតុរបស់ខ្ញុំ ។ ម្ដាយក្មេករបស់ខ្ញុំបានអានវគ្គព្រះគម្ពីរ ហើយឥឡូវនេះគាត់ជឿថាព្រះអង្គសង្គ្រោះបានបង្រៀនគោល លទ្ធិ នៃពិធីបុណ្យទឹកសម្រាប់ពួកអ្នកស្លាប់ តាមរយៈសាវកប៉ុល ។

ព្រះអម្ចាស់បានសន្យានូវពរដ៏ធំចំពោះអស់អ្នកដែលធ្វើការស្រោចស្រង់នេះ ។ ខ្ញុំដឹងថានេះគឺពិត ។ ■

សេដា មេលិកសេថ្យាន អាម៉ិនៀ



ម្ដាយ ក្មេករបស់ខ្ញុំបានប្រាប់ខ្ញុំថាបុណ្យជម្រុជទឹកសម្រាហ៉ប់មនុស្សស្លាប់ពុំមែនជាគោលលទ្ធិ របស់ព្រះគ្រីស្ទ ប៉ុន្តែជាអ្វីមួយដែលពួកមរមនបានប្រឌិតឡើងតែប៉ុណ្ណោះ ។

# តើខ្ញុំអាចទទួលបានទស្សនាវដ្ដីបែបនេះពីទីកន្លែងណា?



ក្នុងងងុំងអំឡុងពេលធ្វើដំណើរជាមួយគ្រួសាររបស់ខ្ញុំពីរដ្ឋណារ៉ាដាស.ហ.រ. ទៅរដ្ឋ អាឡាស្កា ស.ហ.រ. ខ្ញុំបានមានការសន្ទនាជាមួយនឹងស្ត្រីដ៏ខ្ពស់ ស្រស់ស្អាត រាក់ទាក់ម្នាក់ ដែលអង្គុយនៅកៅអីម្ខាងទៀត ។

គាត់បានសួរខ្ញុំថា តើខ្ញុំកំពុងតែធ្វើដំណើរទៅណា ហើយខ្ញុំបានប្រាប់គាត់ថា យើងកំពុងតែធ្វើដំណើរទៅ ក្រុងជូណ្ណូ រដ្ឋអាឡាស្កា ដើម្បីទៅលេងកូនប្រុសរបស់យើង និង គ្រួសាររបស់គាត់ ។ គាត់បានប្រាប់ខ្ញុំថា នាងមកពីក្រុងឡាស វ៉េហ្គាស ។ បន្ទាប់មក ដោយមានអារម្មណ៍ខ្សឹបខ្សួល គាត់បាននិយាយទៀតថា គាត់កំពុងតែធ្វើដំណើរទៅជូណ្ណូ ដើម្បីទៅលេងញាតិខាងសាច់ថ្លៃ ដើម្បីនឹងធ្វើពិធីរំឭកខួបមរណភាពស្វាមីរបស់គាត់ ដែលគាត់បានរៀបការជាមួយអស់រយៈ 20 ឆ្នាំមកហើយ ។ ថ្មីៗគាត់បានទទួលមរណភាពដោយសារ ជម្ងឺមហារីក ។

ខ្ញុំបានសម្លឹងទៅគាត់ពីកៅអីម្ខាងទៀត ហើយបានគិតនៅក្នុងចិត្តថា តើខ្ញុំមានសំណាងអ្វីម្ល៉េះ ដោយបានដឹងអំពីផែនការនៃសេចក្ដីសង្គ្រោះ និង ធ្វើជាអ្នកធ្វើការនៅក្នុងព្រះវិហារបរិសុទ្ធ ណារ៉ាដា ។ ខ្ញុំបានគិតថា តើខ្ញុំអាចធ្វើអ្វី សម្រាប់ស្ត្រីនេះ ដើម្បីនឹងលើកស្ទួយវិញ្ញាណរបស់គាត់ឡើង ។

រំពេចនោះ ខ្ញុំបានចាំយ៉ាងច្បាស់នូវពាក្យដកស្រង់មួយមកពីព្យាការី យ៉ូសែប ស្ម៊ីធ ដែលខ្ញុំបានចែករំលែកនៅក្នុងសមាគមសង្គ្រោះ ។ នៅពេលគាត់បានរៀបចំសមាគមសង្គ្រោះ គាត់បានសង្កេតឃើញថា បងប្អូនស្រីៗ « នឹងចេញទៅដើម្បីសម្រាលទុក្ខ នៃជនចម្លែក ពួកគេនឹងសម្រាល និង ស្រោចស្រង់ដួងចិត្តដែលរបួសបាក់បែកនៃអ្នករងគ្រោះ ពួកគេនឹងជូតទឹកភ្នែកកុមារកំព្រា និងធ្វើឲ្យដួងចិត្តរបស់ស្ត្រីមេម៉ាយរីករាយឡើង » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ យ៉ូសែប ស្ម៊ីធ* [2007], 452) ។

ខ្ញុំបានសម្លឹងមើលទៅគាត់ម្ដងទៀត ។ ខ្ញុំបានឃើញជនចម្លែកមានទុក្ខព្រួយ ជាស្ត្រីមេម៉ាយដែលមានស្នាមរបួសដួងចិត្ត ។ ខ្ញុំបានចាំថា ខ្ញុំបានអាននៅក្នុងទស្សនាវដ្ដី *Ensign* ខែកក្កដា ឆ្នាំ 2011 ព្រឹក ថ្ងៃដដែរនោះ ។ ទស្សនាវដ្ដីនោះមាននូវអត្ថបទដ៏លើកទឹកចិត្ត ដែលខ្ញុំបានគិតថា ប្រហែលជាវាអាចផ្ដល់ដល់គាត់នូវការលើកទឹកចិត្ត និង ការលួងលោម ។

ខ្ញុំបានប្រមូលនូវសេចក្ដីក្លាហានរបស់ខ្ញុំ បើកទស្សនាវដ្ដីទៅរកអត្ថបទនោះ ហើយបានសុំឲ្យគាត់អាន ។ ខ្ញុំបានសំឡឹងមើលគាត់យ៉ាងយកចិត្តទុកដាក់ ហើយវាជាការណ៍មួយដ៏គួរឲ្យភ្ញាក់ផ្អើល ដោយសារគាត់បានអាន —យ៉ាងហ្មត់ចត់ពីបន្ទាត់មួយទៅបន្ទាត់មួយ ។ នៅពេលគាត់អានចប់ហើយ គាត់បានអានអត្ថបទមួយផ្សេងទៀត ។

មើលទៅហាក់ដូចជាមានអ្វីដែលគាត់បានអានរំជួលដល់ដួងចិត្តរបស់គាត់យ៉ាងពិត ។ គាត់បានឱបទស្សនាវដ្ដីយ៉ាងណែនទៅនឹងដើមទ្រូងរបស់គាត់ ហើយបានជូតទឹកភ្នែកចេញពីភ្នែករបស់គាត់ ។

**ខ្ញុំបានគិតថាតើខ្ញុំគប្បីនឹងធ្វើអ្វីដើម្បីលើកស្ទួយវិញ្ញាណរបស់ស្ត្រីនេះដែលប្ដីរបស់ខ្លួនទើបតែ បានស្លាប់ថ្មីៗនេះ ។**

« តើខ្ញុំអាចទទួលបានទស្សនាវដ្ដីបែបនេះពីកន្លែងណា? » គាត់បានសួរខ្ញុំ ។ ខ្ញុំបានប្រាប់គាត់ថាគាត់អាចយកវាបាន ។ រួចហើយគាត់បានអានថែមទៀត ។

នៅពេលយើងទៅដល់ក្រុងជូណ្ណូ គាត់បានចាប់ដៃខ្ញុំ បានសម្លឹងមើលចំភ្នែករបស់ខ្ញុំ ហើយបាននិយាយថា « សូមអរគុណ ។ »

ខ្ញុំបានរៀននូវមេរៀនដ៏អស្ចារ្យ មួយពីបទពិសោធន៍នោះ ។ ជនចម្លែកដែលមានស្នាមរបួសដួងចិត្តរស់នៅជុំវិញយើង ជាមនុស្សដែលត្រូវការពាក្យសម្ដីល្អៗនៃការលើកទឹកចិត្ត និង ជាអ្នកដែលត្រូវការដឹងអំពីអ្វីដែលយើងជាពួកបរិសុទ្ធដឹង ។ ■

ហ្សឺរ៉ុន វែដីរ៍ រដ្ឋនេវ៉ាដា ស.ហ.រ.

*ពេលខ្លះ អ្នកត្រូវតែបោះបង់នូវ អ្វីមួយដែលល្អ សម្រាប់អ្វីមួយទៀត ដែលល្អប្រសើរជាងនេះ ។*

# ការជ្រើសរើស **ផ្នែក** ដ៏ល្អប្រសើរ

**ដោយម៉ាថាយ ឌី ហ្វិតតុន**
ទស្សនាវដ្ដីសាសនាចក្រ

ថ្ងៃមួយ ហ្សូលតាន់ ហ្សូកស៍នៃក្រុម សេ្សច ប្រទេសហុងគ្រី បានធ្វើឲ្យគ្រូបង្វឹក អុំទូកប្រភេទខែយ៉ាកភ្ញាក់ផ្អើល ដោយគាត់បានប្រាប់ទៅ គ្រូបង្វឹកនោះថា គាត់នឹងមិនទៅប្រទេសអាឡឺម៉ង់សម្រាប់ ការប្រកួតអុំទូកទេ ។

ហ្សូលតាន់និយាយថា « ការប្រកួតនោះគឺនៅចំថ្ងៃ បុណ្យជ្រមុជទឹករបស់ខ្ញុំ ដូច្នេះហើយទើបខ្ញុំនិយាយថា មិនទៅទេ » ។

ហ្សូលតាន់មានអាយុ 17 ឆ្នាំបានឈ្នះនៅក្នុងការ ប្រកួតអុំទូក ខែយ៉ាកជាច្រើនលើក ។ ការប្រណាំងទូក នោះគឺជាកីឡាដ៏ល្បីល្បាញមួយនៅក្នុងប្រទេសហុងគ្រី ហើយ ហ្សូកស៍គឺកីឡាករល្អឯក—គឺល្អគ្រប់គ្រាន់ដើម្បី អាចនឹងក្លាយជាកីឡាការជំនាញម្នាក់ដ៏ពិតប្រាកដ ។ មិនត្រឹមតែ ការសម្រេចចិត្តមិនចូលរួមក្នុងការប្រកួត មួយនេះនោះទេ មិនយូរមិនឆាប់ ហ្សូកស៍ និងលះបង់ ចោលកីឡាអុំទូកខែយ៉ាកនេះទាំងស្រុង ។ គាត់មានអ្វី មួយដែលត្រូវធ្វើប្រសើរជាងនេះ ។

ហ្សូលតាន់ គឺជាកីឡាករដ៏ល្អម្នាក់សម្រាប់កីឡាអុំ ទូកខែយ៉ាក់ ។ ជាច្រើនឆ្នាំមកហើយ ការធ្វើការជាមួយនឹ ងគ្រូបង្ហាត់របស់គាត់ គាត់បានរៀននូវការធ្វើជាម្ចាស់ខ្លួន ឯង ការគោរពប្រតិបត្តិ និង ការខំប្រឹងធ្វើការ ។ ហ្សូកស៍ ក៏បានរៀនជៀសវាងពីគ្រឿងញៀន និង ទម្លាប់ទាំងឡាយ ដែលអាចប៉ះពាល់ដល់ការប្រកួត របស់គាត់ ។ វាពុំមែនជាជីវិតងាយស្រួលទេ ហើយវាអាចឯកោ ហើយការក្លាយទៅជាកីឡាករជំនាញម្នាក់គឺ តម្រូវពេល វេលាច្រើនថែមទៀត ។ ដើម្បីធ្វើជាកីឡាករជំនាញម្នាក់ ត្រូវហាត់ 12 ម៉ោងក្នុងមួយថ្ងៃ ហើយត្រូវតែប្រកួតនៅថ្ងៃ អាទិត្យទៀត ។

ហ្សូលតាន់និយាយថា « កីឡាទូកខែយ៉ាកបានយក ពេលវេលារបស់ខ្ញុំច្រើនណាស់ » « ខ្ញុំនិយមជ្រុលពេក ។ ពីព្រោះតែកីឡានោះ ខ្ញុំបានបោះបង់ចោលនូវកិច្ចការ ជាច្រើន ពីជីវិតរបស់ខ្ញុំ ។ »

ហេតុផលនេះហើយដែលធ្វើឲ្យ ហ្សូលតាន់ បានសម្រេចចិត្តថា គាត់មិនអាចចាប់យកដំណឹងល្អផង និង កីឡាខែយ៉ាកផងនោះទេ ។ នៅក្នុងឆ្នាំ 2004 គាត់ បានប្រាប់គ្រូបង្ហាត់របស់គាត់ថា គាត់នឹងមិនប្រកួតទូកខែ យ៉ាកទៀតទេ ។

ក្នុងដើមឆ្នាំនោះ ពួកអ្នកផ្សព្វផ្សាយបានចាប់ផ្ដើម បង្រៀនម្ដាយរបស់ហ្សូកស៍ ។ គាត់មិនបានរួម ចំណែកក្នុងមេរៀនទេ ។ គាត់បានទទួលការអញ្ជើ ញរបស់ម្ដាយគាត់ទាំងមិនពេញចិត្ត ដើម្បីចូលរួម បុណ្យជ្រមុជទឹករបស់ម្ដាយគាត់ ។ ប៉ុន្តែដួងចិត្តរបស់គា ត់ត្រូវបានប៉ះពាល់ ដោយអ្វីមួយដែលគាត់មានអារម្មណ៍ កាលដែលគាត់បានដើរចូលក្នុងអគារព្រះវិហារ ។ ហ្សូ លតាន់បានយល់ព្រមជួបជាមួយពួកអ្នកផ្សព្វផ្សាយសា សនា ដោយព្រោះតែគាត់ពេញចិត្តនឹងពួកគេ ។

គាត់បាននិយាយថា « ពួកអ្នកផ្សព្វផ្សាយសាស នាគឺគួរឲ្យចាប់អារម្មណ៍ណាស់ចំពោះខ្ញុំ ពីព្រោះពួកគេ គឺជាមនុស្សសាមញ្ញ ប៉ុន្តែបានរស់នៅក្នុងបទដ្ឋានមួយ ខ្ពស់ខ្ពស់ ។ »

ពីព្រោះតែ ហ្សូលតាន់បានរស់នៅក្នុងបទដ្ឋានខ្ពស់ កាលនៅជាកីឡាករខែយ៉ាក គាត់បានត្រៀមខ្លួនរួចជា ស្រេចដើម្បីទទួលយកការបង្រៀនដំណឹងល្អថា ជាអ្វីមួយ ដ៏មានតម្លៃ ។ គាត់បានទទួលបុណ្យជ្រមុជទឹកពីខែក្រោ យមក ។

ដំបូង គាត់បានគិតថាគាត់អាចបន្តអុំទូកខែយ៉ាក ប៉ុន្តែមិនធ្វើការប្រកួតនៅក្នុងថ្ងៃអាទិត្យទេ ។ ប៉ុន្តែដោយ ព្រោះតែគាត់ជាមនុស្សមួយប្រភេទ ដែលកាលណា បានប្ដេជ្ញាចិត្តទៅនឹងសកម្មភាព ឬមុខវិជ្ជា ណាមួយ គាត់ចង់ធ្វើវាយ៉ាងល្អប្រណិត គាត់បានជ្រើសដើម្បីនឹង បោះបង់ចោលទូកខែយ៉ាកទាំងស្រុង ។

គ្រាមួយ គាត់បានសាកអុំទូកខែយ៉ាកជាកី ឡាកំសាន្តបន្ទាប់ពីបុណ្យជ្រមុជទឹករបស់គាត់ ។ នៅពេលដែលគាត់បានសាកធ្វើបែបនោះ គ្រូ បង្ហាត់របស់គាត់បានសុំឲ្យគាត់ជួយបង្រៀនអ្ន កឯទៀត ហើយរៀបចំការធ្វើដំណើរទាំងឡាយ ព្រោះថាគាត់មិនប្រកួតទៀតឡើយ ។ ប៉ុន្ត គាត់ពុំចង់ធ្វើការប្ដេជ្ញាចិត្តនឹងអុំទូកខែយ៉ាក— ឬសកម្មភាពណាទៀត—ដែលអាចរារាំងក្នុង កិច្ចការភាពជាសិស្សរបស់គាត់ឡើយ ។

ដូច្នេះហើយហ្សូកស៍បានព្យួរចង្វាររបស់គាត់ ហើយ បានតាំងចិត្តរបស់គាត់ចំពោះការបម្រើ សាសនាចក្រជា ការសម្រេចចិត្ត ដោយនឹកដល់នូវការសម្រេចចិត្តដែ លប្រធាន ហាវឺដ ដបុលយូ ហ៊ីនធើរ (1907–95) បានសម្រេចចិត្តនៅពេលគាត់បានរៀបការ។ ប្រធាន ហ៊ីនធើរ គឺជាអ្នកលេងភ្លេងល្អឯកម្នាក់ ដែលបានលេ ងឧបករណ៍តន្ត្រីជាច្រើនប្រភេទ ។ នៅក្នុងពេលរាត្រី គាត់បានលេងនៅក្នុងវង់តន្ត្រីមួយ ប៉ុន្តែការរស់នៅ របស់ពួក អ្នកដែលគាត់សេពគប់ជាមួយ គឺប្រាសចាក ទៅនឹងបទដ្ឋាននៃដំណឹងល្អ ។ ហេតុដូច្នេះហើយ ប្រធានហ៊ីនធើរ បានទុកឧបករណ៍ភ្លេងរបស់គាត់ ទាំងនោះ ហើយយកមកលេងតែសម្រាប់ ក្រុមគ្រួសារច្រៀងកំដរតែប៉ុណ្ណោះ ។[1]

ហ្សូកស៍នឹកការអុំទូកខែយ៉ាកណាស់ ប៉ុន្តែគាត់បានដឹ



នៅខាងលើ ៖ រូបភាព © THINKSTOCK; ខាងក្រោម ៖ រូបភាពដោយ អ័ដាម ស៊ី អូលសុន



ងថាសេចក្ដីស្រឡាញ់របស់គាត់ចំពោះការអុំទូកខៃយ៉ាក ពេលខ្លះអាចនឹងខ្លាំងជាង សេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះអម្ចាស់ ប្រសិនបើគាត់នៅពាក់ព័ន្ធនឹងកីឡានោះទៀត ។

គោលការណ៍ដដែលនេះ អាចយកមកអនុវត្តលើសកម្មភាពណាមួយ ដែលអាចនាំយើងចេញឆ្ងាញពីអ្នកទាំងឡាយណាដែលព្រះសព្វព្រះទ័យយើងឲ្យយើងនៅក្បែរ ។ ចំពោះយើងម្នាក់ៗ វាប្រហែលជាប្រសើរជាង ដើម្បីនឹងឆ្លងកាត់ជីវិតដោយបោះបង់ចោលនូវអ្វីមួយ—ទោះបីជាអ្វីមួយនោះល្អក៏ដោយ —ជាជាងឲ្យការទុកឲ្យជីវិតដ៏អស់កល្បរបស់យយើងស្ថិតនៅក្នុងភាពគ្រោះថ្នាក់ដែរ ។

ហ្សូលតាន់និយាយថា « សាសនាចក្របានក្លាយទៅជាជីវិតរបស់ខ្ញុំ » « ប្រសិនបើខ្ញុំចង់សកម្មក្នុងពព្រះវិហារ ខ្ញុំដឹងថាការអុំទូកខៃយ៉ាកពុំអាចជាជីវភាពស់នៅ ហើយបើវាគ្រាន់តែជាកីឡាលេងកំសាន្ត វាគឺងាយនឹងបោះបង់ចោល។ ផ្ទុយទៅវិញ ខ្ញុំចង់ធ្វើឲ្យព្រះវរបិតាសួគ៌ជាអាទិភាពរបស់ខ្ញុំ ។»

ហ្សូលតាន់បានចាប់ផ្ដើមសិក្សាដំណឹងល្អដោយយកចិត្តទុកដាក់ ក៏ដូចគ្នាចំពោះការងារដទៃទៀតដែលគាត់ធ្វើផងដែរ ។ គាត់បានដាក់ជាគោលដៅមួយដើម្បីបម្រើបេសកកម្ម។ គាត់ចង់បម្រើ នៅក្នុងប្រទេសរបស់គាត់ និង បង្រៀនអ្នកដទៃ ។

គាត់បានបម្រើនៅក្នុងប្រទេសហុងគ្រី ហើយឥឡូវនេះធ្វើការជាគ្រូបង្រៀនភាសាអង់គ្លេសម្នាក់នៅវិទ្យាល័យ ។ គាត់បានបន្តដាក់ ដំណឹងល្អជាអទិភាពរបស់គាត់ ។ គាត់និយាយថា « មានអ្វីៗជាច្រើនដែលយើងត្រូវតែលះបង់ ដោយព្រោះវាប្រាសចាកពីដំណឹងល្អរបស់ព្រះ » ។ « វាគឺងាយស្រួលដើម្បីនឹងលះបង់អ្វីដែលមិនល្អ កាលណាយើងដឹងថាយើងត្រូវតែធ្វើដូដូច្នេះ ។ ជាញឹកញាប់យើងពុំបានដឹងទេថា យើងគួរលះបង់អ្វីមួយល្អ ដើម្បីអ្វីមួយប្រសើរជាងនោះ ។ យើងជឿថា កិច្ចការនោះមិនអាក្រក់ទេ យើងអាចធ្វើកិច្ចការនោះផង និង បន្តធ្វើតាមផែនការរបស់ព្រះផង » ។ ប៉ុន្តែ ហ្សូលតាន់ដឹងថាយើងត្រូវតែលះបង់អ្វីដែលល្អ ប្រសិនបើវាធ្វើឲ្យយើងចាកឆ្ងាយពី ផែនការរបស់ព្រះ ដែលមានសម្រាប់យើង ។ ■



*ហ្សូលតាន់ ស្ស៊ុលតាន់ពីក្រុងសេ្សច ប្រទេសហុងគ្រី បានលះបង់ចោលការអុំទូកខៃយ៉ាក ដើម្បីមាន ពេលកាន់តែច្រើនចំពោះដំណឹងល្អ។*

**កំណត់ចំណាំ**

1. សូមមើលអេលិនន័រ ណូល *ហារីជ ដបុលយូ ហ៊ីនឆើរ* (1994), ទំព័រ 81 ។

# « តើខ្ញុំត្រូវពន្យល់ដល់មិត្តភក្តិរបស់ខ្ញុំពីហេតុផលដែលថាការធ្វើខុសច្បាប់ព្រហ្មចារីភាពគឺជាគំនិតដ៏អាក្រក់មួយដោយរបៀបណា ? »

ព្រះវរបិតាសួគ៌ចង់ឲ្យយើងរីករាយ ហើយមានភាពសក្តិសម ទទួលព្រះវិញ្ញាណរបស់ទ្រង់ ដូច្នេះហើយទ្រង់បានផ្តល់ព្រះបញ្ញត្តិដល់យើង ដើម្បីនឹងជួយយើងឲ្យរក្សារគំនិតពាក្យសំដី និង សកម្មភាពនៅក្នុងកំរិតមួយដ៏សមរម្យ ។ ច្បាប់ព្រហ្មចារីយភាពជួយរក្សាអំណាចនៃការបង្កើតជីវិតនៅក្នុងរង្វង់នៃចំណងអាពាហ៍ពិពាហ៍។ មូលហេតុមួយដែលទ្រង់បញ្ជាថាអំណាចនៃការបង្កើតជីវិតត្រូវបានប្រើប្រាស់តែរវាងប្តី និង ប្រពន្ធគឺដោយ ព្រោះតែ « កូនៗមានឯកសិទ្ធិដើម្បីនឹងកើតមកនៅក្នុងរង្វង់នៃចំណងអាពាហ៍ពិពាហ៍។ »[1]

យើងអាចចែករំលែកសៀវភៅ*ដើម្បីកម្លាំងនៃយុវជន* មួយក្បាលជាមួយមិត្តរបស់អ្នក។ វាផ្តល់ជាមូលហេតុមួយចំនួន ថាហេតុអ្វីបានជាវាល្អ ដើម្បីរក្សារច្បាប់ព្រហ្មចារីយភាព ៖ « នៅពេលអ្នកមានបរិសុទ្ធភាពខាងផ្លូវភេទ អ្នករៀបចំខ្លួនអ្នកដើម្បីនឹងធ្វើហើយរក្សារសេចក្តីសញ្ញាពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ។ អ្នករៀបចំខ្លួនដើម្បីស្ថាបនាអាពាហ៍ពិពាហ៍ដែលរឹងមាំ ហើយនាំកូនចៅមកកាន់ពិភពលោកដែលជាផ្នែកមួយនៃគ្រួសារដ៏អស់កល្ប និង ជាទីស្រឡាញ់ ។ អ្នកការពារខ្លួនពីការខូចខាត ផ្នែកវិញ្ញាណ និង ផ្នែកសតិអារម្មណ៍ដែលកើតមកពីការមានទំនាក់ទំនងស្និទស្នាលខាងផ្លូវភេទ នៅក្រៅចំណងអាពាហ៍ពិពាហ៍ ។ អ្នកក៏ការពារខ្លួនពីជម្ងឺដ៏គ្រោះថ្នាក់ផងដែរ ។ ការរក្សាភាពបរិសុទ្ធខាងផ្លូវភេទជួយអ្នកឲ្យមានទំនុកចិត្ត និង ភាពរីករាយដ៏ពិត និង ពង្រីកសមត្ថភាពរបស់អ្នកដើម្បីធ្វើការសម្រេចចិត្តបានល្អនាពេលបច្ចុប្បន្ន និង ពេលអនាគត ។ »[2]

## ព្រះវិហារបរិសុទ្ធ



ព្រះវរបិតាសួគ៌មានគោលបំណងដ៏ទេវភាពសម្រាប់យើងទាំងអស់គ្នា ហើយគោលបំណងនោះគឺត្រូវអាច បំពេញបាននៅក្នុងព្រះវិហារបរិសុទ្ធ។ យើងត្រូវតែមានភាពសក្តិសមដើម្បីនឹងចូលក្នុងព្រះវិហារបរិសុទ្ធ ដើម្បីឲ្យគ្រួសាររបស់យើងត្រូវអាចផ្សារភ្ជាប់ជាមួយគ្នាជានិច្ច។ យើងនឹងរស់នៅជាមួយព្រះវរបិតាសួគ៌ម្តងទៀត ហើយដែលសំខាន់បំផុតនោះគឺថា យើងនឹងមាននូវសេចក្តីអំណរដែលគ្មានទីបំផុត ដែលជនមិនសក្តិសមមិនអាចទទួលបាន ។

*អាឡូហ្វា អិម. អាយុ 18 ឆ្នាំ កោះសាម៉ូ*

## អាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារ



យើងត្រូវបានលើកទឹកចិត្តដើម្បីរក្សាភាពបរិសុទ្ធខាងផ្លូវភេទ ដើម្បីឲ្យយើងអាចមានភាពសក្តិសមដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយរក្សាសេចក្តីសញ្ញាពិសិដ្ឋ។ ប្រសិនយើងធ្វើតាមច្បាប់ព្រហ្មចារីយភាព យើងអាចស្ថាបនាអាពាហ៍ពិពាហ៍ និង គ្រួសារដ៏រឹងមាំ នៅក្នុង អនាគត។ សាតាំងតែងតែល្បួងយើង តែតាមរយៈការអធិស្ឋាន ព្រះគម្ពីរ និង មិត្តភក្តិល្អៗ យើងអាចឈ្នះវាបាន។

*វេស្ទី អិម អាយុ 16 ឆ្នាំ ប្រទេសពីលីពីន*

## លទ្ធផលអវិជ្ជមានទាំងឡាយ

មានលទ្ធផលអវិជ្ជមានជាច្រើនចំពោះការបំពានលើច្បាប់ព្រហ្មចារីយភាព ប៉ុន្តែអ្នកពុំអាចរៀនអំពីលទ្ធផល ទាំងអស់នោះនៅក្នុងថ្នាក់ខាងផ្នែកសុខភាពឡើយ។ ការបំពានលើច្បាប់ព្រហ្មចារីភាពអាចបណ្តេញព្រះវិញ្ញាណចេញពីជីវិតរបស់អ្នក ហើយធ្វើឲ្យឈឺចាប់ ចំពោះអ្នកដែលជិតស្និទ្ធនឹងអ្នក ហើយធ្វើឲ្យអ្នកមានអារម្មណ៍មិនល្អអំពីខ្លួនរបស់អ្នក។ ខ្ញុំចង់ឲ្យអ្នកមើលវីឌីអូ Mormon Messages ដែលហៅថា « Chastity: What Are the Limits?» [នៅឯ youth.lds.org ក្នុងភាសាអង់គ្លេស ភាសា ព័រទុយហ្គាយនិង ភាសាអេស្ប៉ាញ]។

*ម៉ាថាយ ធី. អាយុ 17 ឆ្នាំ នៅរដ្ឋយូថាហ៍ ប្រទេសស.ហ.អ*

## បរិសុទ្ធភាព និង ការគោរព

ដោយការធ្វើតាមច្បាប់ព្រហ្មចារីយភាព យើងមានបរិសុទ្ធភាពនៅចំពោះព្រះនេត្ររបស់ព្រះ យើងគោរពខ្លួនយើង ហើយយើងជួយអ្នកដទៃឲ្យគោរពដល់យើងដែរ។ ប្រសិនបើយើងគោរពច្បាប់ព្រហ្មចារីយភាព យើងបង្ហាញថាយើងជាកូនរបស់ព្រះ ហើយថាយើងប្រកាន់ ភ្ជាប់តាមបទដ្ឋានខ្ពស់។ យើងនឹងជៀសផុតពីការស្តាយក្រោយ ។ នៅពេលយើងគោរពប្រតិបត្តិតាមព្រះវរបិតាសួគ៌របស់យើង

*ចម្លើយទាំងឡាយគឺមានបំណងទុកជាជំនួយ និង ជាទស្សនវិស័យមិនមែនជាការប្រកាស អំពី គោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

ជាពិសេសទាក់ទងនឹងច្បាប់នេះ នោះជីវិតរបស់យើងនឹងកាន់តែរីករាយនៅលើផែនដីនេះ ហើយនៅក្នុងពិភពលោកដែលនឹងមកដល់ដែរ។

*អាលីយ៉ាណា ដឹ. អាយុ 19 ឆ្នាំ មកពីប្រទេសពីលីពីន*

### អំណោយទានពិសិដ្ឋមួយ

ប្រសិនបើអំណោយទាននៃការបង្កើតជីវិតយកមកប្រើដោយខ្ជីខ្ជា នោះអំណោយទានដ៏មានតម្លៃ មកពីព្រះនេះ នឹងត្រូវបានប្រព្រឹត្តដូចជាអ្វីមួយដែលសមញ្ញ ។ ការផ្ដល់អំណោយមួយដល់នរណាម្នាក់ដែលពុំបានគិតថាវាពិសេសនោះទេ នោះយើងមានអារម្មណ៍ថាការឲ្យនោះពុំ មានប្រយោជន៍ទេ ។ យើងត្រូវតែប្រតិបត្តិ ចំពោះការបង្កើតជីវិតនោះឲ្យពិសិដ្ឋ ដ្បិតយើងរាល់គ្នាគឺជាព្រះវិហាររបស់ព្រះ ហើយគួរតែរក្សាឲ្យបានស្អាត និងបរិសុទ្ធដូចជាព្រះវិហារបរិសុទ្ធអញ្ចឹង ។

*យ៉ារុន ហ្វ៊ី អាយុ 15 ឆ្នាំ មកពីរដ្ឋអៃដាហូ ប្រទេសស.ហ.អ*

### ព្រះវិញ្ញាណគង់ជាមួយយើង



នៅពេលអ្នកស្អាតពីអំពើបាប អ្នកនឹងកាន់តែរីករាយ ហើយអ្នកនឹងបានពរទៀតផង។ របកាយរបស់យើងគឺដូចជាព្រះវិហារបរិសុទ្ធ ហើយព្រះវរបិតាសួគ៌ « មិនគង់ក្នុងព្រះវិហារមិនបរិសុទ្ធឡើយ » (អាលម៉ា 7:21)។ ដូច្នេះហើយ នៅពេលយើងស្អាតពីអំពើបាប ព្រះវិញ្ញាណអាចគង់ជាមួយយើង។

*ម៉ារីអាន ក៏ អាយុ 14 ឆ្នាំ មកពីរដ្ឋអាខាន់សាស ប្រទេសស.ហ.អ*

រាយ និង សុខសាន្ត ដោយគ្មានវិប្បដិសារីនៃការបំពានលើច្បាប់ដ៏ពិសិដ្ឋនេះ ។

*រ៉េបិន យេ អាយុ 13 ឆ្នាំ នៅរដ្ឋយូថា ប្រទេសស.ហ.អ*

### គុណធម៌ និង ព្រហ្មចារីយភាព



ព្រះអម្ចាស់សព្វព្រះហឫទ័យចំពោះគុណធម៌ និង ព្រហ្មចារីយភាព ហើយអ្វីៗទាំងអស់វានឹងកើតឡើងទៅតាមពេលវេលាដ៏ត្រឹមត្រូវរបស់វា។ ច្បាប់ព្រហ្មចារីយភាពគឺជាព្រះបញ្ញត្តិពីព្រះអម្ចាស់។ ការរួមគ្នាដ៏ឥតខ្ចោះនៃការអធិស្ឋាន និងភាពជាដៃគូនៃព្រះវិញ្ញាណ ធ្វើឲ្យដឹងថាការរស់នៅប្រកបដោយបរិសុទ្ធភាពគឺជាពរជ័យមួយ ។

*សាលីន អ័រ អាយុ 18 ឆ្នាំ ប្រទេសនីការ៉ាហ្គា*

### ស្ថិតក្នុងចំណងនៃអាពាហ៍ពិពាហ៍

ខ្ញុំនឹងពន្យល់ប្រាប់មិត្តភក្ដិរបស់ខ្ញុំថា ការបំពានលើច្បាប់ព្រហ្មចារីយភាព គឺជាទង្វើមិនល្អទេ ដោយសារអំណាចនៃការបង្កើតជីវិតគឺត្រូវបានផ្ដល់ឲ្យ សម្រាប់តែប្ដីប្រពន្ធដែលបានរៀបការស្របច្បាប់ប៉ុណ្ណោះ។ នៅពេលយើងបំពានលើច្បាប់ព្រហ្មចារីយភាព យើងបាត់បង់ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងជីវិតរបស់យើង។

*អហ្គូស្ទីណា អា អាយុ 15 ឆ្នាំ នៅប្រទេសហ្គាណា*

**កំណត់ចំណាំ**

1. « The Family៖ សេចក្ដីប្រកាសចំពោះពិភពលោក » *Liahona*, Nov. 2010, ទំព័រ 129 ។
2. *ដើម្បីកម្លាំងនៃយុវជន* ( កូនសៀវភៅ ឆ្នាំ 2011 ) 9 ។



### ការបំពានលើច្បាប់ព្រហ្មចារីភាពអាចធ្វើឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ

« ជាមួយនឹងការប្រកាន់ខ្ជាប់នូវសេចក្ដីសញ្ញាអាពាហ៍ពិពាហ៍ នោះព្រះអម្ចាស់បានអនុញ្ញាតឲ្យប្ដី និង ប្រពន្ធប្រើប្រាស់នូវ អំណាចនៃការបង្កើតជីវិតដ៏ពិសិដ្ឋនេះ នៅក្នុងសេចក្ដី ស្រឡាញ់ និង ភាពស្រស់ស្អាតរបស់គេ នៅក្នុងចំណងដែលទ្រង់បានតាំងឡើងប៉ុណ្ណោះ ។ . . .

« ទោះជាយ៉ាងនោះក្ដី ទង្វើដ៏ស្និទ្ធស្នាលទាំងនោះដែលនៅក្រៅចំណងអាពាហ៍ពិពាហ៍ដែលបានប្ដេជ្ញាចិត្តប្រកាន់ខ្ជាប់ ត្រូវបានហាមឃាត់ដោយព្រះអម្ចាស់ ដោយសារទង្វើទាំងនេះ បង្អាប់បង្អោនគោលបំណងរបស់ទ្រង់។ នៅក្នុងសេចក្ដីសញ្ញាពិសិដ្ឋនៃអាពាហ៍ពិពាហ៍ ទំនាក់ទំនងបែបនេះគឺសមស្របតាមផែនការរបស់ទ្រង់។ តែនៅពេលប្រព្រឹត្តិខុសពីនេះ ទង្វើទាំងនេះគឺប្រាសចាកនឹងឆន្ទៈរបស់ទ្រង់ហើយ។ ទង្វើទាំងនេះគឺជាភាពគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរខាងផ្លូវចិត្ត និងខាងផ្លូវវិញ្ញាណផងដែរ។ ទោះបីជា អ្នកដែលប្រព្រឹត្តិនោះ ដឹងថា វាពុំកើតឡើងនៅពេលនេះក៏ដោយ តែវានឹងកើតឡើងនៅពេលក្រោយ។ ភាពអសីលធម៌ខាងផ្លូវភេទបង្កើតជារនាំងបាំងអានុភាពនៃព្រះវិញ្ញាណបរិសុទ្ធ។ »

**អែលឌើរ រីឆាដ ជី ស្កតនៃកូរ៉ុមពួកសាវកដប់ពីរនាក់ « Making the Right Choices » *Ensign,* ខែវិច្ឆកា ឆ្នាំ 1994 ទំព័រ 38។**

### សំណួរដ៏សំខាន់នានា

ឆ្លើយនឹងសំណួររបស់មិត្តអ្នក ដោយសួរសំណួរខ្លះៗ ៖ « ចុះប្រសិនបើអនាគតប្ដី ឬ ប្រពន្ធ របស់អ្នកកំពុងសម្លឹងមើលអ្នកនៅពេលនេះវិញនោះ » ? មនុស្សគ្រប់រូបដែលខ្ញុំបានស្ដាប់ឮ អំពីអស់អ្នកដែលបានបំពានច្បាប់ព្រហ្មចារីយភាព បានមានចិត្តសោកសៅនឹងអំពើនោះ។ « ចុះប្រសិនបើកូនរបស់អ្នកនៅពេលអនាគតសួរសំណួរថា ប្រសិនបើប៉ា ឬម៉ាក់បាន បំពានលើច្បាប់ព្រហ្មចារីយភាពវិញដែរឬទេ » ? មិត្តភក្ដិរបស់អ្នកត្រូវការៀនអំពីសារៈសំខាន់នៃច្បាប់ព្រហ្មចារីយភាព ឥឡូវនេះមុនកូនៗ សួរនូវសំណួរបែបនេះ ។ អ្នកត្រូវតែរក្សាខ្លួនអ្នកឲ្យបានស្អាតស្អំ និង បរិសុទ្ធដើម្បីនឹងរស់នៅក្នុងជីវិតដ៏រីក

## សំណួរចេញលើកក្រោយ

« តើខ្ញុំត្រូវតែធ្វើដូចម្ដេចនៅពេលដែលមានប្រធានបទមួយត្រូវបានលើកយកមកពិភាក្សានៅឯសាលារៀនដែលជំទាស់នឹងការបង្រៀននៃដំណឹងល្អដូចជាការពន្លូតកូនជាដើម?

ផ្ញើចម្លើយរបស់អ្នកត្រឹម ថ្ងៃទី 15 ខែឧសភា liahona@ldschurch.org ឬផ្ញើជាសំបុត្រទៅកាន់ ៖

*Liahona*, Questions & Answers 5/13
50 E. North Temple St., Rm. 2420
Salt Lake City, UT 84150-0024, USA

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោមត្រូវតែបញ្ចូល នៅក្នុងអ៊ីម៉ែល ឬសំបុត្ររបស់អ្នក ៖ (1) ឈ្មោះពេញ, (2) ថ្ងៃ ខែ ឆ្នាំ កំណើត, (3) វួដ ឬ សាខា, (4) ស្តេក ឬ មណ្ឌល, (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក, ប្រសិនបើ អ្នកអាយុក្រោម 18 ឆ្នាំនោះ ត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយអ្នក ជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែលអាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។



ដោយ ប្រធាន ថូម៉ាស អេស ម៉នសុន

# របៀបដើម្បីបម្រើនៅក្នុងការហៅទាំងឡាយនៃបព្វជិតភាព

តើអ្នកធ្លាប់បានសញ្ជឹងគិតអំពីតម្លៃនៃព្រលឹងរបស់មនុស្សដែរឬទេ? តើអ្នកដែលសញ្ជឹងគិតអំពី**សក្ដានុពល**ដែលស្ថិតនៅក្នុងយើងម្នាក់ៗឬទេ ?

គ្រាមួយនោះ ខ្ញុំបានចូលរួមក្នុងសន្និសីទតេកមួយ ដែលអតីតប្រធានស្តេករបស់ខ្ញុំឈ្មោះប៉ុល ស៊ី ឆាលដ៍បានបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា កណ្ឌទី 18ហើយបានចាប់ផ្ដើមអានថា៖ « ចូរចាំចុះថា **តម្លៃនៃព្រលឹងទាំងឡាយ** គឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ » (ខទី10)។

បន្ទាប់មក ប្រធានឆាលដ៍ បានសួរថា « តើតម្លៃនៃព្រលឹងរបស់មនុស្សគឺជាអ្វី » ? គាត់មិនបាន ហៅឲ្យប៊ីស្សព ប្រធានស្តេក ឬ ទីប្រឹក្សាជាន់ខ្ពស់ឆ្លើយនូវសំណួរនោះទេ ។ ផ្ទុយទៅវិញ គាត់បានជ្រើសយកប្រធានកូរ៉ុមអែលឌើរវិញ។

បុរសនោះភ្ញាក់ផ្អើលដោយមិនបានឆ្លើយតបអ្វីសោះអស់រយៈពេលមួយសន្ទុះធំ ហើយបន្ទាប់មកបានប្រកាសថា « តម្លៃនៃព្រលឹងរបស់មនុស្សគឺជា**សមត្ថភាពរបស់ព្រលឹងនោះដើម្បីនឹងក្លាយទៅដូចជាព្រះ។**»

អស់អ្នកដែលមានវត្តមានបានសញ្ជឹងគិតនៅចម្លើយនោះ។ ប្រធានឆាលដ៍បានបន្តទៅទៀតជាមួយនឹងដំណើងរបស់គាត់ ប៉ុន្តែខ្ញុំបានបន្តសញ្ជឹងគិតអំពីចម្លើយដ៏បំផុសគំនិតនោះ។

**ដើម្បីឈោងទៅ ដើម្បីបង្រៀន ដើម្បីប៉ះដល់** ព្រលឹងដ៏មានតម្លៃ ដែលព្រះវរបិតាយើងបានរៀបចំសម្រាប់សារដំណឹងរបស់ទ្រង់ គឺជាភារកិច្ចដ៏ធំមហិមា។ ជ័យជំនះពិតជាពុំមែនងាយស្រួលឡើយ។ ជាទូទៅ ជ័យជំនះកើតចេញពី**ទឹកភ្នែកទុក្ខលំបាក ទំនុកចិត្ត ហើយនិងទីបន្ទាល់។**

អ្នកបម្រើរបស់ព្រះ ទទួលបាននូវការលួងលោមពីការអះអាងរបស់ព្រះអម្ចាស់ « ខ្ញុំនឹងនៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ » (ម៉ាថាយ 28:20)។ សេចក្ដីសន្យាដ៏មហិមានេះគាំទ្រអ្នករាល់គ្នា បងប្អូនប្រុសនៃបព្វជិតអើរ៉ុនទាំងឡាយ ដែលត្រូវបានហៅទៅក្នុងមុខតំណែងនៃថ្នាក់ដឹកនាំនៅក្នុងកូរ៉ុមឌីកុន គ្រូបង្រៀន និង សង្ឃអើយ។ ការសន្យានេះលើកស្ទួយអ្នកឡើង ក្នុងការរៀបចំដើម្បីនឹងបម្រើនៅក្នុងតំបន់បេសកកម្ម។ ការសន្យានេះលួងលោមអ្នក ក្នុងអំឡុងគ្រានៃការបាក់ទឹកចិត្តទាំងនោះ ដែលកើតមានដល់មនុស្សគ្រប់ៗរូប។

ព្រះអម្ចាស់មានបន្ទូលថា « ហេតុដូច្នេះហើយ**ចូរកុំណាយចិត្តនឹងធ្វើការល្អឡើយ ត្បិតអ្នករាល់គ្នាកំពុងតែដាក់គ្រឹះនៃកិច្ចដ៏ធំ** » ។ ហើយចេញពីការណ៍ដ៏តូចតាចនោះបណ្ដាលឲ្យមានការណ៍ដ៏ធំធេងឡើង។

មើលចុះ ព្រះអម្ចាស់ទ្រង់តម្រូវចិត្ត និង គំនិតដែលស្ម័គ្រតាម » ( គ. និង ស. 64:33–34) ។ **សេចក្ដីជំនឿបិតបេរ នឹងទំនុកចិត្តខ្ជាប់ខ្ជួន ហើយនិងសេចក្ដីប្រាថ្នាដ៏រឹងមាំ**តែងតែជាអត្តចរិកនៃអ្នកទាំងឡាយណា ដែលបម្រើព្រះអម្ចាស់យ៉ាងអស់ពីដួងចិត្តរបស់ពួកគេ។

ប្រសិនជាបងប្អូនប្រុសណាម្នាក់ដែលស្តាប់ឮ សំឡេងរបស់ខ្ញុំ មានអារម្មណ៍ថាមិនទាន់បានត្រៀមខ្លួននៅឡើយ សូម្បីតែមិនសមត្ថភាពក្នុងការឆ្លើយតបទៅនឹងការហៅឲ្យបម្រើ លះបង់ និងផ្ដល់ពរជ័យដល់ជីវិតរបស់អ្នកដទៃ ចូរចាំអំពីការពិតនេះថា ៖ « **នរណាដែលព្រះអម្ចាស់ទ្រង់ហៅ ព្រះអម្ចាស់នឹងធ្វើឲ្យគេមានសមត្ថភាព** » ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅ ខែ មេសា ឆ្នាំ 1987 ។*

## តើអ្នកនឹងអនុវត្តតាមគោលការណ៍ដោយរបៀបណា ?

« ការដឹងថាព្រះអម្ចាស់គឺស្ថិតនៅជាមួយខ្ញុំ ជួយខ្ញុំឲ្យចាំអំពីមូលហេតុដែលខ្ញុំទៅបម្រើបេសកកម្ម ៖ ដើម្បី បម្រើព្រះអម្ចាស់ និង នាំអ្នកដទៃមករកព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំដឹងថា ទ្រង់នឹងទុកឲ្យខ្ញុំឆ្លងកាត់អ្វីដែលខ្ញុំមិនអាចធ្វើបាន ខណៈដែលខ្ញុំកំពុងតែបម្រើបេសកកម្មរបស់ខ្ញុំនោះឡើយ។ »

**ឌីឡិន អិម. នៅរដ្ឋយូថាហ៍ ប្រទេសស.ហ.អ**



ថតរូបថតដោយ ក្រេ ឌីម៉ុល © IRI

រចនារូបភាព របស់ អាឡិច អូជីស្ស សេចក្តីលំអិតចេញពី *CHRIST AND THE RICH YOUNG RULER* ដោយ ហែនរីច ហូហ្វម៉ាន់ រចនារូបភាពរបស់ ក្រុមហ៊ុន C. HARRISON CONROY CO.; រចនារូបភាពដោយ ស្កត គ្រៀ

## ប្រឹក្សាជាមួយនឹងព្រះអម្ចាស់

នៅពេលខ្ញុំមានអាយុ 15 ឆ្នាំ ខ្ញុំបានចាប់ចិត្តនឹងយុវនារីម្នាក់នៅក្នុងថ្នាក់របស់ខ្ញុំនៅឯសាលារៀន ហើយចង់ទៅដើរលេងជាមួយនាង។ នាងមានរូបរាងស្រស់ស្អាត ប៉ុន្តែខ្ញុំគិតថា តើខ្ញុំគួរសុំនាងទៅដើរលេងជាមួយ មុននឹងខ្ញុំចូលដល់អាយុ 16ដែរឬទេ ។ ខ្ញុំបានចាំអំពីអាល់ម៉ា 37:37 ដែលនិយាយថា « ចូរប្រឹក្សាជាមួយនឹងព្រះអម្ចាស់នូវគ្រប់កិច្ចការរបស់កូន ហើយទ្រង់នឹងដឹកនាំកូនទៅរកការល្អ។ » ហើយនោះជាអ្វីដែលខ្ញុំបានធ្វើ ។ ខ្ញុំបានអធិស្ឋានហើយបានរង់ចាំពីរបីថ្ងៃសម្រាប់ ចម្លើយរបស់ព្រះអម្ចាស់មុននឹងធ្វើការសម្រេចចិត្ត។

ថ្ងៃមួយ នៅឯព្រះវិហារ ប៊ីស្សពរបស់ខ្ញុំបានហៅខ្ញុំចូលទៅក្នុងបន្ទប់ ហើយបានអញ្ជើញខ្ញុំឲ្យនិយាយ នៅថ្ងៃអាទិត្យបន្ទាប់។ ស្មានទៅមើលថាប្រធានបទនោះគឺជាអ្វីទេ? សូមកុំដើរលេងជាគូរហូតដល់អ្នកមានអាយុយ៉ាងហោចណាស់ 16 ឆ្នាំសិន ។ ខ្ញុំបានមានអារម្មណ៍ថានេះគឺជាចម្លើយរបស់ព្រះអម្ចាស់ចំពោះខ្ញុំ ហើយគឺជាចម្លើយថាមិនបានទេ ។ តើខ្ញុំអាចបង្រៀនអ្វីមួយ ដែលខ្ញុំមិនបានអនុវត្តដោយរបៀបណា ?

ពីព្រោះខ្ញុំបានប្រឹក្សានឹងព្រះអម្ចាស់ ខ្ញុំអាចរៀនអំពីឆន្ទៈរបស់ព្រះ សម្រាប់ជីវិតរបស់ខ្ញុំ ហើយក៏គេចវេសចេញពីសេចក្តីល្បួង។ ខ្ញុំដឹងថា ប្រសិនបើយើងប្រឹក្សាជាមួយនឹងព្រះអម្ចាស់ ទ្រង់នឹងប្រាប់យើងនូវឆន្ទៈរបស់ទ្រង់ ហើយថា យើងនឹងទទួលបាននូវពរជ័យដ៏មហិមា ។

អេឌូវដូ អូលីវេរ៉ា ក្រុងសេរ៉ា ប្រទេសប្រេស៊ីល



## ខគម្ពីរដែលជាទីពេញចិត្តរបស់ខ្ញុំ

### គោលលទ្ធិ និង សេចក្តីសញ្ញា 24:8

ខព្រះគម្ពីរនេះធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អ នៅពេលខ្ញុំកំពុងតែឆ្លងកាត់ទុក្ខលំបាកមួយ ព្រោះខនេះនិយាយថា « យើងនឹងនៅជាមួយនឹងអ្នក គឺដរាបដល់អស់មួយជីវិតរបស់អ្នក។ » ខនេះ មានន័យចំពោះខ្ញុំថា ប្រសិនបើខ្ញុំស្វែងរកទ្រង់ ព្រះវរបិតាសួគ៌នឹងតែងតែគង់នៅទីនោះ ជាមួយខ្ញុំ ដរាបដលអស់មួយជីវិតរបស់ខ្ញុំ។

អាឡិច អូជីស្ស នៅក្រុងនូវ៉ូ កាសាស គ្រែនដេស
ប្រទេសម៉ិកស៊ិក



## អំណាចនៃដង្វាយធួន

នៅពេលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំ នូវប្រធានបទដ៏សំខាន់នៃមេរៀនរបស់ពួកគេ គឺតែងតែអំពីព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់។ ពួកគេបានពន្យល់ថា ដង្វាយធួនគឺជាអំណោយទានមួយមកពីព្រះយេស៊ូវគ្រីស្ទសម្រាប់យើងម្នាក់ៗ ។ វាគឺជាអំណោយដែលយើងអាចប្រើប្រាស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង នៅពេលយើងត្រូវបាន ប្រឈមមុខនឹងទុក្ខលំបាក ឬនៅពេលយើងធ្វើបាប។ អំណាចនៃដង្វាយធួនលើកស្ទួយ ប្រោសឲ្យជា ហើយនិងជួយយើងឲ្យត្រឡប់ទៅតាមផ្លូវតូច និង ចង្អៀតវិញ ដែលនាំឆ្ពោះទៅជីវិតដ៏អស់កល្បជានិច្ច។



កាលដែលពួកអ្នកផ្សាយសាសនាបានចែកចាយប្រធានបទនេះ ខ្ញុំបានមានអារម្មណ៍ដ៏រំជើបរំជួលនៅក្នុងចិត្ត ដែលបានថ្លែងទីបន្ទាល់ដល់ខ្ញុំថា វាគឺជាការពិត ហើយខ្ញុំបានសម្រេចចិត្តចូលរួមក្នុងសាសនាចក្រ។

ក្រោយមក ខ្ញុំបានសម្រេចចិត្តបម្រើបេសកកម្ម ពីព្រោះខ្ញុំចង់ជួយអ្នកឯទៀតឲ្យដឹងអំពីអំណោយទានដ៏វិសេសនេះ។ ដោយការបង្រៀន និង ការចែករំលែកអំពីដង្វាយធួន ខ្ញុំបានឃើញអ្នកឯទៀតផ្លាស់ប្តូរទៅក្នុងផ្លូវថ្មីនៃជីវិត។ ការផ្លាស់ប្តូរទាំងស្រុងបានមក ការផ្លាស់ប្តូរនេះមិនមែនកើតឡើងដោយសារតែបានស្តាប់ពីដង្វាយធួនតែប៉ុណ្ណោះទេ គឺដោយការអនុវត្តន៍វានៅក្នុងជីវិតរបស់ខ្ញុំផងដែរ។

ខ្ញុំដឹងថាដង្វាយធួនគឺមានពិតមែន ។ នៅពេលយើងអនុញ្ញាតឲ្យអានុភាពនៃដង្វាយធួន ចូលមកក្នុងជីវិតរបស់យើងមិនថាកាលៈទេសៈបែបណាដែលយើងប្រឈមមុខនោះទេ អ្វីៗទាំងអស់ត្រូវបានដោះស្រាយ ហើយយើងនិងមានអារម្មណ៍នៃសេចក្តីអំណរ។

អែអូរីធី ថាប្អូរអៀ , គីរីបាទី




# មូលហេតុដែលយើងត្រូវការ ព្រះគម្ពីរមរមន

មនុស្សមួយចំនួនអាចសួរអ្នកថា តើហេតុអ្វីយើងត្រូវការព្រះគម្ពីរមរមន នៅពេលដែលយើងមានព្រះគម្ពីរបរិសុទ្ធហើយនោះ ។ តាមពិតទៅ ព្រះយេស៊ូវគ្រីស្ទបានធ្វើទីបន្ទាល់ថា ការណ៍នេះនឹងកើតឡើង ( សូមមើលនីហ្វៃទី 2 29:3 ) ។ មានហេតុផលជាច្រើន ដែលជាមូលហេតុធ្វើឲ្យព្រះគម្ពីរមរមនមានសារៈសំខាន់ក្នុងសម័យរបស់យើង ( សម្រាប់ឧទាហរណ៍ សូមមើលនីហ្វៃទី 2 29:7–11 ) ។ នេះគ្រាន់តែជាមូលហេតុខ្លះៗដែលបង្ហាញថា ព្រះគម្ពីរមរមនគឺមានសារៈសំខាន់ខ្លាំងណាស់ ។

## សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ

បទគម្ពីរទាំងឡាយបានបង្ហាញយើងនូវលំនាំនៃការប្រើប្រាស់សាក្សីចំរុះ ដើម្បីបង្កើតសេចក្ដីពិតនៅក្នុងសាសនាចក្ររបស់ព្រះគ្រីស្ទ ។ ព្រះគម្ពីរមរមនបញ្ចូលបន្ថែមជាសាក្សីទីពីរចំពោះព្រះគម្ពីរបរិសុទ្ធថា ជាសក្ខីបទមួយរបស់ព្រះគ្រីស្ទ ។ នៅគ្រាមួយនោះ អែលឌើរ



### សាក្សីពីរនាក់

« ព្រះគម្ពីរបរិសុទ្ធគឺជាសាក្សីមួយអំពីព្រះយេស៊ូវគ្រីស្ទ ហើយព្រះគម្ពីរមរមនគឺជាសាក្សីមួយទៀត ។ តើហេតុអ្វីសាក្សីទីពីរនេះមានសារៈសំខាន់អ្វីម្ល៉េះ ? គំនូសរចនាខាងក្រោមនេះអាចជួយបាន ៖ តើអ្នកអាចគូរបន្ទាត់ត្រង់បានប៉ុន្មាននៅតាមចំណុចតែមួយនៅលើក្រដាសមួយសន្លឹក ?ចម្លើយគឺមិនចេះចប់មិនចេះហើយ ។ សូមគិតមួយភ្លែតថា បន្ទាត់តែមួយនេះគឺតំណាងឲ្យព្រះគម្ពីរបរិសុទ្ធ ហើយថា មានបន្ទាត់ត្រង់រាប់រយទាំងនោះត្រូវបានគូសតាមចំណុចនេះ ដែលតំណាងឲ្យការបកស្រាយខុសៗគ្នានៃព្រះគម្ពីរបរិសុទ្ធ ហើយថា រាល់ការបកស្រាយនិមួយៗតំណាងឲ្យព្រះវិហារខុសៗគ្នា ។

« ប៉ុន្តែ តើមានអ្វីកើតឡើង ប្រសិនបើនៅលើក្រដាសមួយសន្លឹកនេះ មាននូវចំណុចទីពីរទៀតដែលតំណាងឲ្យព្រះគម្ពីរមរមន ? តើអ្នកអាចគូសបន្ទាត់ត្រង់បានប៉ុន្មាននៅចន្លោះចំណុចនៃសេចក្ដីយោងទាំងពីរនេះគឺ ៖ ព្រះគម្ពីរបរិសុទ្ធ និង ព្រះគម្ពីរមរមន ? គូរបានតែមួយ ។ មានតែការបកស្រាយនៃគោលលទ្ធិរបស់ព្រះគ្រីស្ទតែមួយប៉ុណ្ណោះ ដែលធ្វើឲ្យទីបន្ទាល់នៃសាក្សីទាំងពីរនេះនៅតែបន្តមាន ។

ព្រះគម្ពីរមរមនបានដើរតួនាទីម្ដងហើយម្ដងទៀតជាសាក្សីគាំទ្រ បញ្ជាក់ និង បង្រួបបង្រួមនៃគោលលទ្ធិទាំងឡាយដែលត្រូវបានបង្រៀននៅក្នុងព្រះគម្ពីរបរិសុទ្ធ »។

**អែលឌើរ ថាត អរ. ខាលីស្ទើរ នៃគណៈប្រធាននៃពួកចិតសិបនាក់ « The Book of Mormon—a Book from God »** ***លីអាហូណា*** **ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 75 ។**

រចនារូបភាពដោយ ប្រៃយ៉ាន ប៊ីច, រូបភាពនៃវីដេអូ© 2001 IRI

ម៉ាក អ៊ី. ភីធើរសិន ( ឆ្នាំ 1900 ទំព័–84 ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « មូលហេតុសំខាន់បំផុតដែលយើងមានព្រះគម្ពីរមរមនគឺថា គ្រប់ការណ៍ទាំងអស់នឹងត្រូវបានស្ថាបនាឡើងដោយនូវមាត់ពួកស្មរបន្ទាល់ពីរ ឬបីនាក់ ។ ( សូមមើលកូរិនថូសទី 2 13:1 ) ។ យើងមានព្រះគម្ពីរបរិសុទ្ធ ហើយយើងក៏មានព្រះគម្ពីរមរមនដែរ ។ ព្រះគម្ពីរទាំងពីរនេះបង្កើតឡើងនូវបញ្ជីពីរច្បាប់—ជាព្រះគម្ពីរពីរភាគ—បានមកពីមនុស្សបុរាណពីរក្រុមដែលនៅដាច់ឆ្ងាយពីគ្នា ពួកគេទាំងពីរក្រុមថ្លែងទីបន្ទាល់អំពីទេវភាពនៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ » ។[1] ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( ឆ្នាំ 1899–1994 ) បានមានប្រសាសន៍បន្ថែមទៀតថា « យើងមិនត្រូវភ្លេចថា ព្រះអម្ចាស់ទ្រង់ផ្ទាល់បានប្រទានព្រះគម្ពីរមរមន ជាសាក្សីសំខាន់បំផុតរបស់ទ្រង់ »។[2]

## ភាពពេញលេញនៃដំណឹងល្អ

យើងដឹងថា « សេចក្ដីដ៏ច្បាស់ និង ពិសេសៗ. . . ត្រូវបានដកយកពីព្រះគម្ពីរបរិសុទ្ធក្នុងអំឡុងពេញមួយសម័យកាល ( នីហ្វៃទី 1 13:40) ។ ព្រះគម្ពីរមរមនបង្ហាញយ៉ាងច្បាស់នូវគោលលទ្ធិនៃព្រះគ្រីស្ទ និង នាំមកនូវភាពពេញលេញនៃសេចក្ដីពិតមកកាន់ផែនដីម្ដងទៀត ( សូមមើល នីហ្វៃទី 1 13:38–41 ) ។ ជាឧទាហរណ៍ ព្រះគម្ពីរមរមនជួយយើងឲ្យដឹងថា ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើឡើងដោយការជ្រមុជទៅក្នុងទឹក ( សូមមើល នីហ្វៃទី 3 11:26 ) ហើយកូនក្មេងតូចៗមិនចាំបាច់ត្រូវទទួលបុណ្យជ្រមុជទឹកឡើយ ( សូមមើលម៉ូរ៉ូណៃ 8:4–26 ) ។

## ចំណុចកណ្ដាលនៃសាសនាចក្រដែលត្រូវបានស្ដារឡើងវិញ

យ៉ូសែប ស្ម៊ីធ បានធ្វើទីបន្ទាល់ថា ព្រះគម្ពីរមរមនគឺជា « មូលដ្ឋាននៃសាសនារបស់យើង » ។[3] ព្រោះតែយើងដឹងរឿងនេះ វាហាក់ដូចមិនមែនជារឿងចៃដន្យដែលថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានរៀបចំឡើងនៅថ្ងៃទី 06 ខែ មេសា ឆ្នាំ 1830 គឺគ្រាន់តែ 11 ថ្ងៃបន្ទាប់ពីព្រះគម្ពីរមរមនត្រូវបានដាក់លក់ជាសាធារណៈនៅថ្ងៃទី 26 ខែ មិនា ឆ្នាំ 1830 តែប៉ុណ្ណោះ ។ សាសនាចក្រមិនត្រូវបានរៀបចំឡើងលុះត្រាតែព្រះគម្ពីរគ្រឹះរបស់សានាចក្របានមានឡើងសម្រាប់សមាជិកក្នុងសាសនាចក្រ ។

## ពរជ័យមួយសម្រាប់ជីវិតរបស់យើង

ទាក់ទងទៅនឹងព្រះគម្ពីរមរមន យ៉ូសែប ស្ម៊ីធ បានមានបង្រៀនថា « បុគ្គលម្នាក់ៗអាចខិតទៅជិតព្រះបាន ដោយសារធ្វើតាមសិក្ខាបទទាំងឡាយនៃព្រះគម្ពីរនេះជាជាងព្រះគម្ពីរដទៃទៀត » ។[4] ព្រះគម្ពីរនេះមានឥទ្ធិពលដើម្បីផ្លាស់ប្ដូរជីវិតមនុស្សជាច្រើន រួមទាំងខ្លួនអ្នក និង អ្នកទាំងឡាយណាដែលអ្នកចែកចាយព្រះគម្ពីរមរមននេះជាមួយពួកគេ ។ប្រធាន ហិនរី ប៊ី. អាវរិង ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយបានថ្លែងទីបន្ទាល់ថា « អនុភាពនៃព្រះគម្ពីរមរមនដែលមានទៅលើចរិត អំណាច និង ភាពក្លាហានរបស់អ្នក ដើម្បីក្លាយជាសាក្សីម្នាក់សម្រាប់ព្រះ គឺពិតប្រាកដណាស់ ។ គោលលទ្ធិ និង គំរូដ៏ស្មោះត្រង់ទាំងឡាយនៅក្នុងព្រះគម្ពីរនោះនឹងលើកតម្កើង ដឹកនាំ និង ធ្វើឲ្យអ្នកក្លាហាន ។ . . . ការសិក្សានៅក្នុងព្រះគម្ពីរមរមនប្រកបដោយការអធិស្ឋាន នឹងស្ថាបនាសេចក្ដីជំនឿទៅលើព្រះជាព្រះវរបិតា ទៅលើព្រះរាជបុត្រាជាទីស្រលាញ់របស់ទ្រង់ និង ទៅលើដំណឹងល្អរបស់ទ្រង់ ។ ព្រះគម្ពីរមរមននឹងស្ថាបនាសេចក្ដីជំនឿរបស់អ្នកទៅលើព្យាការីរបស់ពទាំងពីបុរាណ និង សម័យទំនើប ។ . . . ព្រះគម្ពីរមរមនអាចនាំអ្នកខិតទៅជិតព្រះជាជាងគម្ពីរណាៗទាំងអស់ ។ ព្រះគម្ពីរមរមនអាចផ្លាស់ប្ដូរជីវិតឲ្យកាន់តែប្រសើរឡើង » ។[5] ■

**កំណត់ចំណាំ**

1. ម៉ាក អ៊ី. ភីធើរសិន « Evidence of Things Not Seen » *Ensign*ខែ ឧសភា ឆ្នាំ 1978 ទំព័រ 63 » ។
2. *The Teachings of Ezra Taft Benson* ( ឆ្នាំ 1988 ) ទំព័រ 204 ។
3. យ៉ូសែប ស្ម៊ីធ នៅក្នុងបុព្វកថានៃព្រះគម្ពីរមរមន ។
4. យ៉ូសែប ស្ម៊ីធ នៅក្នុងបុព្វកថានៃព្រះគម្ពីរមរមន ។
5. ហិនរី ប៊ី. អាវរិង « A Witness » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 69–70 ។

**មេរៀនទាំងឡាយនៅថ្ងៃអាទិត្យ**

*ប្រធានបទសម្រាប់ខែនេះគឺ ៖*

**ការក្បត់សាសនា និង ការស្ដារឡើងវិញ**

# ចូលរួមក្នុងការសន្ទនា



នៅអំឡុងខែ មេសា អ្នកនឹងសិក្សាអំពីការក្បត់សាសនា និង ការស្ដារឡើងវិញ នៅក្នុងថ្នាក់កូរ៉ុមបព្វជិតភាព និង ថ្នាក់យុវនារី និង ថ្នាក់សាលាថ្ងៃអាទិត្យ ( បើសិនវួដ ឬ សាខារបស់អ្នកមានមេរៀនថ្មីៗជាភាសារបស់អ្នក ) ។ ការលេចចេញមកនូវព្រះគម្ពីរមរមនគឺជាផ្នែកមួយដ៏សំខាន់នៃការស្ដារឡើងវិញ ។ បន្ទាប់ពីការអានអត្ថបទនេះ សូមគិតថា តើជីវិតរបស់អ្នកមានការផ្លាស់ប្ដូរយ៉ាងណាខ្លះ ដោយសារតែអ្នកមានព្រះគម្ពីរមរមននេះ ។ អ្នកអាចសរសេរអំពីអារម្មណ៍របស់អ្នកទុកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ហើយសូមស្វែងរកការចែកចាយអារម្មណ៍ទាំងអស់នេះជាមួយអ្នកដទៃ ដោយការថ្លែងទីបន្ទាល់នៅក្នុងគេហដ្ឋាន នៅព្រះវិហារ ឬ នៅតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ។



ការធំលូតលាស់ក្នុងដីមានជីវជាតិ ៖ យុវវ័យស្មោះត្រង់នៅ

# ប្រទេស យូហ្គាន់ដា

ដោយ សិនឌី ស្មីធ



*នៅពេលដែលពួកគេទទួលយក និង រស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នោះយុវវ័យនៅក្នុងប្រទេស យូហ្គែនដានេះកំពុងមើលឃើញសេចក្ដីជំនឿ និង សេចក្ដីសង្ឃឹមដែលរីកចម្រើនជុំវិញពួកគេ ។*

នៅចំកណ្ដាលទីតាំងនៃអាហ្វ្រិកខាងកើត ដែលជាប្រទេស យូហ្គែនដា ដ៏ស្រស់ស្អាតនេះមានសម្បូរ ទៅដោយជំរាលភ្នំតូចៗដែលមានទាំងដើមអំពៅ និង ដើមចេកជាច្រើន— ហើយមានមនុស្សវ័យជំទង់ជាច្រើនដែលត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលយក និង រស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

ស្ដេកដំបូងគេនៅប្រទេស យូហ្គែនដា ត្រូវបានបង្កើតឡើងនៅឆ្នាំ 2010 ។ សាសនាចក្រកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ដោយមានយុវជន និង យុវនារីជាច្រើននៅតាមបណ្ដារួដ និង សាខានិមួយៗ ។



ថតរូបដោយ ខិនឌី ស្មីត

**ការរៀបចំបទដ្ឋានមួយ ដែលក្លាយជាគំរូមួយ**

ពួកយុវនារីនៅក្នុងវួដមួយត្រូវបានបំផុសគំនិតមកពីការបង្រៀនអំពីគុណធម៌ ដោយសិស្ទើរ អេលែន អេស. ដាល់ថុន ជាប្រធានយុវនារីទូទៅដែលមានប្រសាសន៍ថា ៖ « ឥឡូវនេះគឺជាពេលសម្រាប់ពួកយើងម្នាក់ៗដើម្បីក្រោកឈរឡើង ហើយ លើកទង់មួយឡើងទៅកាន់ពិភពលោកនេះដោយអំពាវនាវឲ្យត្រឡប់ទៅរកគុណធម៌វិញ » ។[1] ពួកយុវនារីទាំងនេះបានឡើងទៅលើកំពូលភ្នំតូចមួយ ដើម្បីអាចមើលឃើញទីក្រុងរបស់ខ្លួន ហើយដើម្បីលើកបង្ហាញនូវទង់ពណ៌មាសទាំងឡាយ ដែលជានិមិត្តរូបនៃការសន្យារបស់ពួកគេដើម្បីធ្វើជាគំរូទាំងឡាយអំពីគុណធម៌ ។ ពួកគេបានច្រៀងរួមគ្នា « នៅលើកំពូលភ្នំខ្ពស់ » ( *ទំនុកតម្កើងទំព័រ* 30 )។

ពួកយុវនារីទាំងនេះបានលើកឡើងនូវបទដ្ឋាននៃសេចក្ដីសុចរិតផ្ទាល់ខ្លួនរបស់ពួកគេ ។ ការគោរពប្រតិបត្តិរបស់ពួកគេបានពង្រឹងទីបន្ទាល់របស់ពួកគេ ហើយបានជះឥទ្ធិពលដល់អ្នកដទៃទៀត ។ សិស្ទើរ ដាល់ថុន មានប្រសាសន៍ថា ៖ « មិនគួរបន្ទាបបន្ថោកអំណាចនៃឥទ្ធិពលសុចរិតរបស់អ្នកឡើយ » ។[2]ហើយគំរូនៃពួកនារីទាំងអស់នេះ គឺដូចជាទង់មួយដែលកំពុងតែលើកត្រដែរឲ្យពិភពលោកទាំងមូលឃើញ ។

ដូចជាពួកយុវនារីនៅក្នុងប្រទេស យូហ្គែនដា ដែរមាននារីម្នាក់ឈ្មោះ សាន់ដ្រា ដើរទៅកាន់ព្រះវិហារដែលមានចម្ងាយផ្លូវជាង 1500 ម៉ែត្រ ដើម្បីទៅជួយសំអាតសាលាប្រជុំនៅរាល់ថ្ងៃសុក្រ និង ចូលរៀនថ្នាក់សិក្ខាសាលានៅរាល់ថ្ងៃសៅរ៍ ។ អំឡុងពេលពេញមួយសប្ដាហ៍ នាងភ្ញាក់នៅមុនម៉ោង 5:00 ព្រឹក ដើម្បីអានសៀវភៅដែលរៀននៅសាលា ហើយបន្ទាប់មកនាងដើរទៅសាលា ហើយត្រឡប់មកផ្ទះវិញនៅក្រោយម៉ោង 6:00 ល្ងាច ។ នាងមិនបានទៅរៀនអស់រយៈពេលមួយឆ្នាំ ដោយសារវិបត្តិហិរញ្ញវត្ថុ ប៉ុន្តែប្រឈមមុខនឹងឧបសគ្គទាំងឡាយរបស់នាងជាមួយនឹងអាកប្បកិរិយាវិជ្ជមានថា ៖ « ដំណឹងល្អពិតជាបានជួយខ្ញុំឲ្យបន្តខ្ជាប់ខ្ជួន និង ឥតបែរចិត្ត » ។

នាងសាន់ដ្រាគឺជាសមាជិកសាសនាចក្រតែម្នាក់គត់នៅក្នុងផ្ទះរបស់នាង ប៉ុន្តែឪពុកម្ដាយរបស់នាងគាំទ្រនាងចំពោះការបម្រើក្នុងសាសនាចក្រ ដូចជាការជួយ





*សាន់ដ្រា*





នៅពេលរ្វដបានបោសសំអាតទីធ្លាមណ្ឌលកុមារកំព្រានៅតាមមូលដ្ឋាន ។ គ្រួសាររបស់នាងមើលឃើញរបៀបដែលដំណឹងល្អបានជួយនាងឲ្យរឹងមាំ សូម្បីតែនៅពេលដែលប្រឈមមុខនឹងបញ្ហាទាំងឡាយដែលមិនទាន់ដោះស្រាយ ។ សូមសញ្ជឹងគិតអំពីប្រភពនៃកំលាំងនោះ សាន់ដ្រានិយាយថា « នៅពេលខ្ញុំទៅព្រះវិហារ ខ្ញុំមានអារម្មណ៍ដូចជាកំពុងពាក់គ្រឿសឹករបស់ព្រះ » ( សូមមើល អេភេសូរ 6:11–17 )។

ស៊ូសាន ជាអ្នកប្រែចិត្តជឿថ្មីម្នាក់ទៀតដែលស្រលាញ់សាសនាចក្រ ។ មកពីប្រទេស ស៊ូដង់ភាគខាងត្បូង គ្រួសាររបស់នាងបានភៀសខ្លួនចេញពីសេចក្ដីវេទនា ហើយត្រូវបានប្រទានពរឲ្យជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនានៅក្នុងប្រទេស យូហ្គេនដា ។ នៅពេលដែលនាងនៅក្នុងជំរុំភៀសខ្លួនមួយ នាងបានរកឃើញសន្តិភាព និង ការការពារនៅក្នុងដំណឹងល្អ ។នៅរាល់ថ្ងៃអាទិត្យ នាងនឹងនាំប្អូនៗបង្កើតរបស់នាងទៅព្រះវិហារ ព្រមទាំងនាំក្មេងដប់នាក់ផ្សេងទៀតដែលមិនមែនជាសមាជិកទៅជាមួយដែរ ។បន្ទាប់ពីការស្លាប់ដោយយថាហេតុនៃសមាជិកគ្រួសារម្នាក់ នោះនាងបានត្រឡប់ទៅប្រទេស ស៊ូដង់ភាគខាងត្បូងវិញ ដែលជាកន្លែងដែលនាងរង់ចាំឲ្យគេបង្កើតសាសនាចក្រសាសនាចក្រមួយនៅក្នុងតំបន់របស់នាង ។ទាំងស៊ូសាន និង សាន់ដ្រា ប្រឈមមុខនឹងឧបសគ្គទាំងឡាយ ប៉ុន្តែពួកគេពឹងផ្អែកលើព្រះ និង អររីករាយនឹងផលផ្លែនៃការរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ( សូមមើល អាលម៉ា 32:6–8,43 ) ។

## ការលះបង់ដើម្បីបម្រើបេសកកម្ម

យុវជននៅក្នុងប្រទេស យូហ្គេនដា ចាប់ផ្ដើមលេងបាល់ទាត់តាំងពីពួកគេនៅក្មេងតូចៗមកម្ល៉េះ ដោយប្រើបាល់មួយដែលធ្វើអំពីមែកឈើដែលចាក់ស្រេះចូលគ្នាឲ្យក្លាយជាបាល់ ។ ចាប់តាំងពី ឌែននីសនៅក្មេង គាត់មានទេពកោសល្យខាងលេងកីឡា ហើយវិទ្យាល័យរបស់គាត់បានផ្ដល់ប្រាក់ឧបត្ថម្ភដល់គាត់ដើម្បីលេងកីឡានេះនៅក្នុងក្រុមរបស់ពួកគេ ។ បន្ទាប់ពីគាត់បានរៀន



*ខាងលើ ៖ យុវវ័យចូលរួមក្នុងការប្រជុំពិសេសរួមគ្នានៅក្នុងស្តេកមួយ ។*

*ខាងលើ ៖ ស៊ូសាន ( កណ្ដាល ) ជាជនភៀសខ្លួនម្នាក់នៅក្នុងប្រទេស យូហ្គេនដា បានរកឃើញសេចក្ដីសុខសាន្តនៅក្នុងដំណឹងល្អ ហើយនៅពេលនេះ កំពុងដឹកនាំបងប្អូនបង្កើតទាំងឡាយរបស់នាង និង កូនក្មេងដទៃទៀតទៅព្រះវិហារ ។*

*កណ្ដាល ៖ យុវនារីនៅក្នុងវួដនេះអររីករាយនឹងការប្រព្រឹត្តិតាមកម្មវិធីការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារី ។*

*ខាងស្ដាំ ៖ ឌែននីស បានបោះបង់ឱកាសក្លាយជាសមាជិកម្នាក់នៅក្នុងក្រុមបាល់ទាត់អាជីព ដើម្បីទៅផ្សព្វផ្សាយដំណឹងល្អ ។ គាត់ និង យុវជនដទៃទៀតនៅក្នុងក្លូរ៉ុមសង្ឃបានលះបង់ ហើយបានយកឈ្នះលើឧបសគ្គទាំងឡាយដើម្បីបម្រើបេសកកម្ម ។*

ចប់នៅវិទ្យាល័យ មានក្រុមកីឡាវិជ្ជាជីវៈមួយក្រុមបានឲ្យលុយ និង ផ្តល់ទីជំរកដល់គាត់ ។ ក្តីសុបិនរបស់គាត់បានក្លាយជាការពិត ប៉ុន្តែ ឌែននីស បានដឹងថា ការណ៍នេះទំនងជារាំងផែនការណ៍របស់គាត់ដើម្បីចេញបម្រើបេសកកម្មនៅក្នុងឆ្នាំខាងមុខនេះ ។

ឌែននីស មានបំណងប្រាថ្នាយ៉ាងខ្លាំង ដើម្បីធ្វើតាមអ្វីដែលព្រះវរបិតាមានព្រះទ័យចង់ឲ្យគាត់ធ្វើ ដែលធ្វើឲ្យគាត់ពុំមានបំណងត្រូវបានទាញល្បួង ដើម្បីបន្តនៅក្នុង



ក្រុមនេះនៅពេលដែលការបម្រើបេសកកម្មនឹងមកដល់សម្រាប់គាត់ ។ មានមនុស្សជាច្រើនបានឆ្ងល់នឹងជម្រើសរបស់គាត់ ប៉ុន្តែ ឌែននីស ដឹងយ៉ាងប្រាកដថា គាត់បានជ្រើសរើសត្រឹមត្រូវសម្រាប់ខ្លួនគាត់ និង អ្នកដទៃ ។ គាត់បាននិយាយថា « ប្អូនប្រុសពីរនាក់ និង ប្អូនសម្នាក់របស់ខ្ញុំទើបតែបានទទួលបុណ្យជ្រមុជទឹក » ។ « ខ្ញុំមិនដែលគិតថា ប្អូនស្រីរបស់ខ្ញុំនឹងស្តាប់តាមដំណឹងល្អនោះទេ ។ នៅពេលខ្ញុំមើលឃើញព្រះកំពុងបង្ហាញអព្ភូតហេតុនៅក្នុងគ្រួសាររបស់ខ្ញុំ នោះវាផ្តល់ក្តីសង្ឃឹមដ៏ភ្លឺចិញ្ចែងចិញ្ចចសម្រាប់អនាគតរបស់ខ្ញុំ » ។

នៅក្នុងសាខារបស់ ឌែននីស យុវជនទាំងឡាយសិក្សា*ប្រកាសដំណឹងល្អទ្រង់* នៅសប្តាហ៍នីមួយៗ ពួកគេបានក្លាយដូចជាក្រុមមួយ ដោយធ្វើការរួមគ្នាជាមួយពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង និង នាំមិត្តភក្តិទៅកាន់ការប្រជុំថ្ងៃអាទិត្យ និង សកម្មភាពផ្សេងៗទាំងឡាយព្រមទាំងលេងបាល់បោះ និង បាល់ទាត់នៅអំឡុងពេលថ្ងៃប្រចាំសប្តាហ៍ផងដែរ ។ ពួកសង្ឃបានធ្វើបុណ្យប្រមុជទឹកឲ្យមិត្តភក្តិ និង អ្នកដទៃទៀត ពួកគេបានជួយបង្រៀនជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។ អស់រយៈពេលពីរបីឆ្នាំក្រោយមក ក្រុមយុវជននេះបានពង្រឹងសាខាទាំងមូល ហើយពួកគេទាំងបួននាក់ ដោយមានរួមទាំង ឌែននីស ផង បានទទួលការហៅបម្រើបេសកកម្ម នៅក្នុងបេសកកម្មនៃប្រទេស កិនយ៉ា ណៃរ៉ូប៊ី ។

ពួកគេបានធ្វើតាមពាក្យទូន្មានរបស់អែលឌើរ ដេវីឌ អេ. បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដើម្បី « ក្លាយជាពួកអ្នកផ្សព្វផ្សាយសាសនាយ៉ាងយូរមុនអ្នកដាក់ទម្រង់បែបបទសុំបម្រើបេសកកម្មរបស់អ្នក » ។[3] ពួកគេបានធ្វើបែបនេះដោយការធ្វើការរួមគ្នាជាកូរ៉ុម ដែលជាក្រុមមួយដ៏ប្រសើរជាងក្រុមផ្សេងទៀត ។

ពួកអ្នកផ្សព្វផ្សាយសាសនាទាំងបួននាក់នេះបានឈ្នះលើឧបសគ្គទាំងឡាយដើម្បីបម្រើ ។ លោក វិល ប៊ីហ្វ៍ស៍បានពន្យល់ថា « ខ្ញុំស្ទើរតែអស់សង្ឃឹមក្នុងការចេញទៅបម្រើបេសកកម្ម [ដោយសារការចំណាយច្រើន] ប៉ុន្តែបន្ទាប់ពីខ្ញុំបានអានម៉ាថាយ 6:19–20 ៖ ‘ កុំឲ្យប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួនលើផែនដី . . . ប៉ុន្តែត្រូវប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួន នៅឯស្ថានសួគ៌វិញ ’ ។ ដូច្នេះដោយមានការឧស្សាហ៍ព្យាយាម និងការតាំងចិត្ត ខ្ញុំអាចសម្រេចបាននូវគោលដៅរបស់ខ្ញុំក្នុងការចេញបម្រើបេសកកម្មពេញម៉ោង ។ ខ្ញុំស្រឡាញ់ការបម្រើបេសកកម្ម ។ គ្មានអ្វីដែលប្រសើរជាងការស្វែងរកនគរស្ថានសួគ៌ជាមុននោះទេ » ។

## សេចក្តីសង្ឃឹមសម្រាប់ពេលអនាគត

យុវវ័យរបស់ប្រទេស យូហ្គែនដា កំពុងកសាងនគរនៃព្រះនៅទីនេះ ដោយមានសេចក្តីសង្ឃឹមសម្រាប់ពេលអនាគត ។ បើទោះជាមិនទាន់មានព្រះវិហារបរិសុទ្ធនៅក្នុងភូមិភាគអាហ្វ្រិកភាគខាងកើតក៏ដោយ ក៏យុវវ័យទាំងអស់នោះកំពុងរង់ចាំដោយរីករាយថា នឹងមានពេលណាមួយដែលពួកគេនឹងរៀបការនៅក្នុងព្រះវិហារបរិសុទ្ធដ៏ឆ្ងាយ ។ មានសកម្មភាពមួយនៅក្នុងស្តេកដែលបាននិយាយផ្តោតទៅលើការរៀបចំខ្លួនដើម្បីចូលព្រះវិហារបរិសុទ្ធ ហើយនៅចុងបញ្ចប់ សមាជិកម្នាក់នៃគណៈប្រធានស្តេកបានថ្លែងទីបន្ទាល់របស់គាត់ថា ៖ « ព្រះស្រលាញ់អ្នក ។ អ្នកគឺជាអនាគតនៃសាសនាចក្រនៅក្នុងប្រទេស យូហ្គែនដា នេះ » ។ យុវវ័យដែលសុចរិតទាំងនេះមានឥទ្ធិពលដ៏រឹងមាំរួចទៅហើយ ។

យុវជន និង យុវនារីរបស់ប្រទេស យូហ្គែនដា



កំពុងលះបង់រឿងខាងលោកកិយទាំងឡាយ ដើម្បីទទួលពរជ័យដែលនឹងនៅស្ថិតស្ថេរជាមួយពួកគេជារៀងរហូត ។ ពួកគេបានដាំគ្រាប់ពូជនៃសេចក្តីជំនឿ ហើយថែទាំវាដោយថ្នាក់ថ្នម ( សូមមើលអាលម៉ា 32:33–37 ) ។ ដូចជាដើមមួយដែលសម្បូរទៅដោយផ្លែជាច្រើន ( សូមមើល អាលម៉ា 32:42 ) យុវវ័យទាំងនេះចែករំលែកនូវសេចក្តីអំណរនៃដំណឹងល្អនៅលើដីដែលមានជីវជាតិនេះ ។ ■

*សិនឌី ស្មីធ បានរស់នៅក្នុងប្រទេស យូហ្គែនដា ខណៈដែលប្តីរបស់នាងបានធ្វើការនៅទីនោះ ហើយនៅពេលនេះ ពួកគេបានមករស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

1. អែលែន អេស. ដាល់ថុន « A Return to Virtue » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 80 ។
2. អែលែន អេស. ដាល់ថុន *លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 80 ។
3. ដេវីឌ អេ. បែដណា « ការក្លាយខ្លួនជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ »*លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ 2005 ទំព័រ 45 ។





# តើមិត្តពិតប្រាកដគឺជាអ្វី ?

ដោយ អេលលែន អេស. ដាល់ថុន
ប្រធានយុវនារីទូទៅ

អត្ថន័យអំពីមិត្តម្នាក់បានផ្លាស់ប្រែនៅក្នុងពិភពលោកមួយដោយការទំនាក់ទំនងគ្នាតាមរយៈបច្ចេកវិជ្ជានៅពេលបច្ចុប្បន្ននេះ ។ នៅពេលបច្ចុប្បន្ននេះ យើងអាចគិតថា យើងមាន« មិត្ត » ជាច្រើន ។ វាជាការពិត ៖ យើងពិតជារីករាយនឹងលទ្ធភាពដើម្បីទទួលពត៌មាន ហើយបន្តដឹងនូវអ្វីៗដែលកំពុងកើតឡើងចំពោះជីវិតរស់នៅរបស់អស់អ្នកដែលយើងស្គាល់ ព្រមទាំងមិត្តថ្មីៗ និង មិត្តពីអតីតផងដែរ បើទោះជាយើងមិនបានជួបពួកគេដោយផ្ទាល់ តែយើងនៅតែរាប់ថាពួកគេជាមិត្តរបស់យើង ។

នៅក្នុងបរិបទនៃប្រព័ន្ធផ្សព្វផ្សាយសង្គម ពាក្យថា « មិត្ត » ត្រូវបានប្រើប្រាស់ជាញឹកញាប់ដើម្បីពិពណ៌នាអំពី*មនុស្សដែលយើងអាចទាក់ទងជាជាងមនុស្សដែលយើងទំនាក់ទំនង* ។អ្នកមានសមត្ថភាពដើម្បីផ្ញើសារលិខិតទៅមិត្តទាំងឡាយរបស់អ្នក ប៉ុន្តែនេះមិនមែនដូចគ្នាទៅនឹង ការមានទំនាក់ទំនងជាមួយមនុស្សម្នាក់និងមនុស្សម្នាក់ទៀតនោះទេ ។

ពេលខ្លះកង្វល់របស់យើងគឺ*ការមាន*មិត្តភក្តិច្រើន ។ ប្រហែលជាយើងគួរតែផ្តោតលើ*ការធ្វើជា*មិត្តភក្តិម្នាក់ ។

ពាក្យថាមិត្តភក្តិគឺមានអត្ថន័យច្រើនយ៉ាង ។ ខ្ញុំនឹងមិនដែលបំភ្លេចការនិយាយរបស់អែលឌើររ៉ូបឺត ឌី. ហែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ អំពី អត្ថន័យដើម្បីធ្វើជាមិត្តភក្តិ និង ឥទ្ធិពលយ៉ាងខ្លាំងក្លារបស់មិត្តភក្តិដែលមានអំណាចទៅលើជីវិតរស់នៅរបស់យើង ។ ការពន្យល់របស់គាត់បានជះឥទ្ធិពលមកលើជីវិតរស់នៅរបស់ខ្ញុំជាយូរមកហើយ ។ គាត់បានមានប្រសាសន៍ថា « មិត្តភក្តិគឺជាមនុស្សទាំងឡាយណាដែលធ្វើឲ្យយើងកាន់តែងាយស្រួលដើម្បីរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » ។[1] នៅក្នុងន័យនេះ ការខ្វល់ខ្វាយចំពោះសុខមាលភាពរបស់មនុស្សណាម្នាក់គឺជាខ្លឹមសារនៃមិត្តភក្តិពិតប្រាកដ ។ វាគឺជការយកចិត្តទុកដាក់ចំពោះសុខមាលភាពរបស់មនុស្សណាម្នាក់មុននឹងខ្លួនយើង ។ វាប្រព្រឹត្តឡើងដោយភាពស្មោះត្រង់ ភក្តីភាព និង បរិសុទ្ធភាពយ៉ាងច្បាស់លាស់នូវរាល់ទង្វើទាំងអស់ ។ ប្រហែលវាគឺជាពាក្យថា*ការតាំងចិត្ត*ដែលជួយយើងឲ្យយល់នូវអត្ថន័យពិតនៃមិត្តភាព ។

នៅពេលដែលកូនស្រីរបស់ខ្ញុំឈ្មោះ អ៊ិមមី មានអាយុ 15 ឆ្នាំ នាងបានធ្វើការសម្រេចចិត្តពីមិត្តប្រភេទណាដែលនឹងសេពគប ។ នៅព្រឹកមួយ ខ្ញុំអង្កេតឃើញថា នាងបានអានព្រះគម្ពីរមរមននៅត្រង់ អាលម៉ា 48 ។នាងបានគូសចំណាំខគម្ពីរនោះដែលពិពណ៌នាអំពីមេទ័ពមរ៉ូណៃ ៖ « មរ៉ូណៃជាបុរសដ៏មានកម្លាំង ហើយ ខ្លាំងក្លា លោកជាមនុស្សម្នាក់ដែលប្រកបទៅដោយយោបល់ដ៏ឥតខ្ចោះ ។ . . . មែនហើយ ហើយលោកជាមនុស្សម្នាក់ដែលរឹងប៉ឹងនៅក្នុងសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ » ( ខគម្ពីរទី 11, 13 ) ។ នៅគែមព្រះគម្ពីរ នាងបានសរសេរថា « ខ្ញុំចង់មានការណាត់ដើរលេង និងរៀបការជាមួយបុរសម្នាក់ដូចជាមរ៉ូណៃ » ។ ខណៈដែលខ្ញុំបានឃ្លាំមើល អ៊ីមមី និង ប្រភេទបុរសទាំងឡាយដែលនាងបានទាក់ទងជាមួយ ហើយក្រោយមកបានណាត់ដើរលេងជាមួយ នៅពេលនាងបានឈានដល់អាយុ 16 ឆ្នាំ ខ្ញុំបានយល់ឃើញថា នាងកំពុងព្យាយាមមានគុណសម្បត្តិទាំងអស់នោះ ហើយកំពុងជួយអ្នកដទៃឲ្យបំពេញតាមតួនាទីរបស់





ពួកគេ ក្នុងនាមជាបុត្រាទាំងឡាយរបស់ព្រះ ជាអ្នកកាន់បព្វជិតភាព និង ជាឪពុក ហើយជាអ្នកដឹកនាំនាពេលអនាគត ។

មិត្តពិតប្រាកដមានឥទ្ធិពលលើអ្នកទាំងឡាយណាដែលពួកគេសេពគប់ជាមួយដើម្បី « លើកគ្នាឡើងទៅរកកម្រិតខ្ពស់បន្តិច [ ហើយ ] ប្រសើរឡើងបន្តិច » ។[2] អ្នកអាចជួយគ្នាទៅវិញទៅមក ជាពិសេស គឺជួយយុវជនដើម្បីរៀបចំខ្លួន ហើយបម្រើបេសកកម្មប្រកបដោយកិត្តិយស ។ អ្នកអាចជួយគ្នាទៅវិញទៅមកឲ្យបន្តមានភាពស្អាតស្អំខាងសីលធម៌ ។ ឥទ្ធិពលសុចរិត និងមិត្តភាពអាចមានអនុភាពដ៏អស់កល្បជានិច្ច មិនត្រឹមតែទៅលើជីវិតរស់នៅរបស់អ្នកទាំងឡាយណាដែលអ្នកសេពគប់នោះទេ ប៉ុន្តែក៏មានអនុភាពទៅលើជំនាន់ក្រោយៗទៀតដែរ ។

ព្រះអង្គសង្គ្រោះបានហៅសាវកទាំងឡាយរបស់ទ្រង់ថាជាមិត្តរបស់ទ្រង់ ។ ទ្រង់បានមានព្រះបន្ទូលថា ៖

នេះគឺជាសេចក្ដីបញ្ញត្តិរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រលាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ ។

« គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិត ជំនួសពួកសម្លាញ់របស់ខ្លួននោះទេ ។

« បើអ្នករាល់គ្នាធ្វើតាមសេចក្ដីដែលខ្ញុំបង្គាប់ នោះអ្នករាល់គ្នាជាសម្លាញ់ខ្ញុំហើយ ។

« ខ្ញុំមិនហៅជាអ្នកបម្រើទេ ពីព្រោះអ្នកបម្រើគេមិនដឹងថាចៅហ្វាយធ្វើអ្វីទេ គឺខ្ញុំហៅអ្នករាល់គ្នាថាជា*សម្លាញ់*ខ្ញុំ ៖ ពីព្រោះខ្ញុំបានឲ្យអ្នករាល់គ្នាដឹងគ្រប់ការទាំងអស់ ដែលខ្ញុំឮពីព្រះវរបិតាខ្ញុំមក » ( យ៉ូហាន 15:12–15 បញ្ជាក់បន្ថែម ) ។

នៅពេលអ្នករស់នៅតាម ហើយចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នោះអ្នកនឹងទាក់ទាញចិត្តពួកគេឲ្យមករកអ្នក ដែលនឹងចង់ចងមិត្តជាមួយអ្នក—មិនគ្រាន់តែជាអ្នកដែលអ្នកទាក់ទងតាមប្រព័ន្ធផ្សព្វផ្សាយសង្គមនោះទេ តែក៏ដូចជាសម្លាញ់ដែលព្រះអង្គសង្គ្រោះបានបង្ហាញជាគំរូ តាមរយៈព្រះបន្ទូល និង គំរូរបស់ទ្រង់ផងដែរ ។ នៅពេលអ្នកព្យាយាមចងមិត្តជាមួយអ្នកដ៏ទៃ ហើយបណ្ដោយឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺឡើង នោះឥទ្ធិពលរបស់អ្នករាល់គ្នានឹងផ្ដល់ជាពរដល់ជីវិតរស់នៅរបស់មនុស្សជាច្រើន ដែលអ្នកសេពគប់ជាមួយ ។ខ្ញុំដឹងថា នៅពេលអ្នកផ្ដោតលើការចងមិត្តជាមួយអ្នកដទៃដូចជាអ្វីដែលពួកព្យាការី និង គំរូទាំងឡាយនៅក្នុងបទគម្ពីរបានពន្យល់ប្រាប់អំពីមិត្ត នោះអ្នកនឹងសប្បាយរីករាយ ហើយអ្នកនឹងក្លាយជាឥទ្ធិពលមួយសម្រាប់សេចក្ដីល្អនៅក្នុងពិភពលោកនេះ ហើយថ្ងៃណាមួយអ្នកនឹងទទួលបានការសន្យាដ៏រុងរឿងមួយដែលពិពណ៌នានៅក្នុងព្រះគម្ពីរអំពីមិត្តភាពពិតប្រាកដថា ៖ « ហើយទំនាក់ទំនងដែលមានក្នុងចំណោមយើងនៅទីនេះយ៉ាងណា នោះក៏នឹងមានក្នុងចំណោមយើងនៅទីនោះយ៉ាងនោះដែរ គ្រាន់តែរួបរួមដោយសិរីល្អដ៏នៅអស់កល្បជានិច្ច » ( គ. និង ស.130:2 ) ។ ■

**កំណត់ចំណាំ**

1. រ៉ូបឺត ឌី. ហែល « This Is the Way; and There Is None Other Way » នៅក្នុង*Brigham Young University 1981–82 Speeches* ( ឆ្នាំ 1982 ) ទំព័រ 67 ។
2. ហ្គរដុន ប៊ី. ហ៊ិងគ្លី « The Quest for Excellence » *លីអាហូណា* ខែ កញ្ញា ឆ្នាំ 1999 ទំព័រ 8 ។

## អត្ថន័យគន្លឹះអំពីមិត្តភាព

« ចូរជ្រើសរើសមិត្តភក្ដិណាដែលឲ្យតម្លៃដល់អ្នកដើម្បីអ្នកអាចពង្រឹង និង លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងការរស់នៅតាមមាត្រដ្ឋានដ៏ខ្ពង់ខ្ពស់ ។

« ដើម្បីមានមិត្តភក្ដិល្អ ចូរធ្វើជាមិត្តល្អម្នាក់ ។ . . .

« នៅពេលដែលអ្នកព្យាយាមធ្វើមិត្តភក្ដិជាមួយនឹងអ្នកដទៃ ចូរកុំបន្ទាបបទដ្ឋានរបស់អ្នកឡើយ » ។

***ដើម្បីកម្លាំងនៃយុវជន*** **( កូនសៀវភៅ ឆ្នាំ 2011 ) ទំព័រ 9 ។**

រចនារូបភាពទាំងឡាយ © ISTOCKPHOTO.COM/FONIKUM និង ដោយ ឡេស និលសាន់



# ការអញ្ជើញរបស់ខ្ញុំទៅរកសេចក្ដីសង្គ្រោះ

ដោយ អិមមីសាន់ ហូសេ ដា ស៊ីលវ៉ា

កាលនៅក្មេង ខ្ញុំបានទៅចូលរួមព្រះវិហារជាច្រើន ហើយមានការយល់ច្រឡំច្រើន ពីព្រោះតែព្រះវិហារនីមួយៗបានបង្រៀនអំពីការបកស្រាយបទគម្ពីរខុសៗគ្នា ។ ខ្ញុំគ្មានអារម្មណ៍ល្អនោះទេ នៅពេលដែលខ្ញុំប្រទះឃើញពួកគេមួយចំនួនដែលគ្មានគារវភាព ដូច្នេះខ្ញុំបានបោះបង់ការព្យាយាមដើម្បីស្វែងរកព្រះវិហារណាមួយដែលខ្ញុំអាចចូលរួម ។

អស់រយៈពេលពីរបីឆ្នាំក្រោយមក មានមិត្តភក្តិខ្ញុំម្នាក់ឈ្មោះ ខ្លេតុន លីម៉ា បានទទួលពិធីបុណ្យជ្រមុជទឹកក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ គាត់មិនបានប្រាប់ខ្ញុំអំពីបុណ្យជ្រមុជទឹករបស់គាត់នេះទេ ថ្វីបើយើងគឺជាមិត្តល្អនឹងគ្នា ប៉ុន្តែនៅពេលដែលពេលវេលាចេះតែកន្លងផុតទៅ ខ្ញុំបានចាប់ផ្ដើមមើលឃើញការផ្លាស់ប្ដូរនៅក្នុងខ្លួនគាត់ ។ ជាធម្មតា រាល់ថ្ងៃអាទិត្យ ខ្ញុំបានទៅផ្ទះរបស់គាត់នៅពេលព្រឹក ដើម្បីយើងអាចលេងបាល់ទាត់ ប៉ុន្តែខ្ញុំអត់ឃើញគាត់នៅផ្ទះទេ ។ ខ្ញុំអត់ឃើញគាត់នៅផ្ទះ ពីរ ឬ បីអាទិត្យជាប់ៗគ្នាតែម្ដង ។ នៅទីបញ្ចប់ ខ្លីតុន បានប្រាប់ខ្ញុំ

ថា គាត់មិនអាចលេងបាល់ទាត់នៅថ្ងៃអាទិត្យបានតទៅទៀតទេ ដោយសារគាត់គោរពថ្ងៃរបស់ព្រះអម្ចាស់ ។ ខ្ញុំបានប្រាប់គាត់ថា « ព្រះវិហារនេះធ្វើឲ្យអ្នកជឿហួសហេតុពេកហើយ » ។

ក្រោយមក ខ្លីតុន បានអញ្ជើញខ្ញុំឲ្យទៅចូលរួមព្រះវិហារ ។ ខ្ញុំបានដោះសារជាមួយគាត់ថា ដោយសារខ្ញុំនៅតែមិនពេញចិត្តជាមួយនឹងសាសនា ។ អស់រយៈពេល 10 ខែមកហើយ ដែល ខ្លីតុន បាននាំពួកអ្នកផ្សព្វផ្សាយសាសនាឲ្យមកបង្រៀនខ្ញុំ ប៉ុន្តែខ្ញុំតែងតែនិយាយដោះសារ ឬ ប្រាប់ពួកគេថា ខ្ញុំរវល់ណាស់ ។ ប៉ុន្តែគាត់មិនដែលបោះបង់ការព្យាយាមនោះទេ ។

ថ្ងៃមួយនៅក្នុងខែ មិថុនា គាត់បានអញ្ជើញខ្ញុំឲ្យទៅចូលរួមការរាំកំសាន្តលេងនៅព្រះវិហារ ។ ខ្ញុំធ្វើជាសួរគាត់លេងៗថា « តើនឹងមានម្ហូបអាហារញុំា និង មានស្រីៗច្រើននៅទីនោះទេ ? » គាត់បានសើច ហើយនិយាយថា បាទ ! មាន

ខ្ញុំត្រូវតែសារភាពថា ខ្ញុំបានចុះចាញ់ ហើយសុខចិត្តទៅដោយសារតែការទាក់ទាញនឹងម្ហូបអាហារនោះ ។ខ្ញុំបានទៅលេងព្រះវិហារ ហើយបានស្រឡាញ់ព្រះវិហារនេះ ។ មនុស្សគ្រប់គ្នាបានស្វាគមន៍ខ្ញុំ ខ្ញុំបានបរិភោគច្រើន ហើយខ្ញុំបានចាប់ផ្ដើមចាប់អារម្មណ៍អំពីការចូលរួមនៅព្រះវិហារ ។ នៅពេលខ្ញុំបានទៅដល់ព្រះវិហារនៅថ្ងៃអាទិត្យ ខ្ញុំបានជួបមនុស្សជាច្រើន ហើយបានឮទីបន្ទាល់ជាច្រើនរបស់ពួកគេ ។ ខ្ញុំមិនស្គាល់ព្រះគម្ពីរមរមនទេ ប៉ុន្តែខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះអម្ចាស់ នៅពេលដែលសមាជិកនានាក្នុងសាសនាចក្រនេះបានធ្វើទីបន្ទាល់ថា « ខ្ញុំដឹងថា ព្រះគម្ពីរមរមនគឺជាព្រះគម្ពីរពិត ថា នេះគឺជាសាសនាចក្ររបស់ព្រះគ្រីស្ទ ហើយថា យ៉ូសែប ស៊្មីធ គឺជាព្យាការីម្នាក់ ដែលបានហៅដោយព្រះ » ។ ខ្ញុំពុំធ្លាប់មានអារម្មណ៍ល្អបែបនេះនោះទេ ។ ខ្ញុំនៅតែមិនចង់ជួបពួកអ្នកផ្សព្វផ្សាយសាសនា ប៉ុន្តែទីបន្ទាល់ក្នុងការប្រជុំនោះបានធ្វើឲ្យខ្ញុំរំជួលចិត្ត ។

នៅសប្ដាហ៍បន្ទាប់ ខ្លីតុន បានអញ្ជើញខ្ញុំឲ្យទៅព្រះវិហារម្ដងទៀត ។ ខ្ញុំមិនអាចទៅបានទេ ដោយសារខ្ញុំមានកិច្ចការមួយទៀតដែលត្រូវធ្វើ ។ នោះខ្ញុំអាចជ្រាបដឹងនូវភាពសោកសៅនៅលើផ្ទៃមុខរបស់គាត់ នៅពេលខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនដឹងថា តើខ្ញុំអាចទៅបានឬអត់នោះទេ ។

ទោះជាយ៉ាងណាក៏ដោយ នៅព្រឹកព្រលឹមថ្ងៃអាទិត្យខ្ញុំបានភ្ញាក់ពីដេកឡើងដោយមានបំណងប្រាថ្នាចង់ទៅព្រះវិហារ ។ វាជាការពិបាកសម្រាប់ខ្ញុំដោយភ្ញាក់ពីដេកនៅម៉ោង 6:30 ហើយខ្ញុំបានត្រៀមខ្លួនរួចជាស្រេចដើម្បីរង់ចាំ ខ្លីតុន មក ។ គាត់មានការភ្ញាក់ផ្អើលនៅពេលដែលគាត់បានឃើញខ្ញុំស្លៀកពាក់ជាស្រេចដើម្បីរង់ចាំគាត់ ។ នៅថ្ងៃអាទិត្យនោះ ប៊ីស្សពបានបង្រៀនអំពីបព្ជិតភាព ។ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណជាខ្លាំង ហើយមានអារម្មណ៍ថា ខ្ញុំគួរតែរៀនមេរៀនរបស់អ្នកផ្សព្វផ្សាយសាសនា ។ នៅចុងបញ្ចប់នៃការប្រជុំថ្នាក់យុវជនខ្ញុំបានដឹងថា ខ្ញុំនឹងទទួលពិធីបុណ្យជ្រមុជទឹក ។

នៅពេលការប្រជុំនៅព្រះវិហារចប់ ខ្ញុំបានប្រាប់ទៅខ្លីតុន ថា « ខ្ញុំចង់ទទួលពិធីបុណ្យជ្រមុជទឹក ! »

គាត់បានគិតថា ខ្ញុំនិយាយលេង ។ ប៉ុន្តែបន្ទាប់មកគាត់និយាយថា « បើខ្ញុំអញ្ជើញពួកអែលឌើរមក តើអ្នកនឹងជួបជាមួយពួកគេទេ ? » ខ្ញុំបានឆ្លើយតបថា បាទ ។

ពួកអែលឌើរដ៏ឆ្នើមបានបង្រៀនខ្ញុំ ។ នៅពេលខ្ញុំបានឮសារលិខិតនៃការស្ដារឡើងវិញ នោះខ្ញុំទទួលបានការបញ្ជាក់កាន់តែអស្ចារ្យថា ខ្ញុំគួរតែទទួលបុណ្យជ្រមុជទឹក ។ ប៉ុន្តែខ្ញុំចង់ដឹងសេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមនដោយខ្លួនខ្ញុំផ្ទាល់ ។ ពួកអែលឌើរបានគូសចំណាំនៅក្នុងម៉ូរ៉ូណៃ 10:3–5 នៅក្នុងព្រះគម្ពីរមរមនរបស់ខ្ញុំ ហើយអញ្ជើញខ្ញុំឲ្យអធិស្ឋាន និង ទូលសួរដល់ព្រះថាតើព្រះគម្ពីរមរមននេះពិតដែរទេ ។

នៅពេលល្ងាចបន្ទាប់ ខ្ញុំបាននឹកឃើញថា ខ្ញុំមិនទាន់បានអានព្រះគម្ពីរមរមននេះនៅឡើយទេ ។ នៅពេលខ្ញុំចាប់ផ្ដើមអាន ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណជាខ្លាំង ។ ខ្ញុំបានអធិស្ឋាន ហើយពីមុនខ្ញុំបញ្ចប់ការអធិស្ឋាន ខ្ញុំបានដឹងថា ព្រះគម្ពីរមរមនគឺជាព្រះគម្ពីរពិត ។ ខ្ញុំមានអំណរគុណចំពោះព្រះដែលបានឆ្លើយតបចំពោះការអធិស្ឋានរបស់ខ្ញុំ ។ ខ្ញុំបានទទួលបុណ្យជ្រមុជទឹកនៅខែ កក្កដា ឆ្នាំ 2006 ។

ក្រោយមក ខ្ញុំបានបម្រើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នៅក្នុងប្រទេសប្រេស៊ីល នៃបេសកកម្មគួយអាបា ហើយមិត្តរបស់ខ្ញុំ ខ្លីតុន បានបម្រើបេសកកម្មនៅក្នុងប្រទេសប្រេស៊ីល នៃតំបន់បេសកកម្ម សាន់តាម៉ារីយ៉ា ។ យើងបានធ្វើ អ្វីដែលខ្លីតុនបានធ្វើសម្រាប់ខ្ញុំគឺ ៖ អញ្ជើញមនុស្សដទៃឲ្យមកកាន់ព្រះគ្រីស្ទ ហើយជួយពួកគេឲ្យទទួលយកដំណឹងល្អដែលបានស្ដារឡើងវិញ តាមរយៈសេចក្ដីជំនឿនៅលើព្រះគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក និង ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ នេះពិតជារបៀបទៅរកសេចក្ដីសង្គ្រោះ ។

សូមយើងទាំងអស់គ្នាអញ្ជើញមិត្តភក្តិ និង សាច់ញាតិទាំងឡាយរបស់យើងឲ្យរៀនពីដំណឹងល្អនេះជានិច្ច ត្បិតព្រះអង្គសង្គ្រោះបានអញ្ជើញមនុស្សគ្រប់រូបនៅពេលទ្រង់មានព្រះបន្ទូលថា « ចូរមកឯខ្ញុំ » ( ម៉ាថាយ 11:28 ) ។ ខ្ញុំដឹងថា នេះគឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ហើយថា ឥឡូវនេះវាគឺជាពេលដែលត្រូវអញ្ជើញមនុស្សគ្រប់រូបឲ្យមករកព្រះគ្រីស្ទ ។ ■



រចនារូបភាពដោយ រ៉ូប៊ើរ ធុំគ្រូស



# របៀបដប់យ៉ាងដើម្បីដឹងថា អ្នកត្រូវបាន ផ្លាស់ប្រែចិត្តជឿ

ដោយ ថៃលី អរតុន

ខ្ញុំបានរៀននៅក្នុងការប្រជុំថ្នាក់បព្វជិតភាពថា មានគោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយនៃបព្វជិតភាពអើរ៉ុនគឺដើម្បីជួយយើង « ផ្លាស់ប្រែចិត្តទៅរកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និង រស់នៅតាមការបង្រៀនទាំងឡាយនៃដំណឹងល្អ » ។[1] ខ្ញុំមិនប្រាកដថា តើវាមានន័យយ៉ាងណានោះទេ ដើម្បី « ផ្លាស់ប្រែចិត្តទៅរកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ » ។ ខ្ញុំបានសួរឪពុកម្ដាយរបស់ខ្ញុំ និង ពួកបងៗបង្កើតរបស់ខ្ញុំថា តើពួកគេបានគិតថា វាមានអត្ថន័យបែបណា ហើយយើងបានពិភាក្សារួមគ្នាអំពីរបៀបមួយចំនួនដែលអ្នកអាចដឹងថា បើសិនអ្នកកំពុងផ្លាស់ប្រែចិត្តជឿ ។

ប្រហែលជាមានរបៀបផ្សេងទៀត ប៉ុន្តែនេះគឺជារបៀបទាំង 10 ដែលយើងបានគិតដល់ ។ ដោយសារការផ្លាស់ប្រែចិត្តជឿគឺជាដំណើរការណ៍ពេញមួយជីវិត នោះយើងមិនចាំបាច់មានលក្ខណៈឥតខ្ចោះតាមរបៀបទាំងអស់នេះនៅពេលឥឡូវនេះទេ ប៉ុន្តែរបៀបទាំងនេះអាចជួយយើងឲ្យដឹងថា បើសិនជាយើងកំពុងតែបោះជំហានទៅមុខ ។

**1.** នៅពេលអ្នកត្រូវបានផ្លាស់ប្រែចិត្តជឿ នោះអ្នកមិនត្រឹមតែ*ដឹង*នូវអ្វីៗដែលអ្នកគួរធ្វើនោះទេ អ្នកក៏ដឹងនូវ*បំណងប្រាថ្នាដើម្បីធ្វើអ្វីដែលត្រឹមត្រូវផងដែរ* ។ វាមិនគ្រប់គ្រាន់ទេដោយគ្រាន់តែជៀសវាងពីការធ្វើខុស ដោយព្រោះអ្នកខ្លាចគេចាប់កំហុសអ្នកបាន ឬធ្វើទោសនោះ ។ នៅពេលមានការផ្លាស់ប្រែចិត្តជឿដ៏ពិត នោះអ្នកពិតជាចង់ជ្រើសរើសដើម្បីធ្វើអ្វីដែលត្រឹមត្រូវ ។

**2.** សញ្ញាបង្ហាញមួយទៀតអំពីការផ្លាស់ប្រែចិត្តជឿគឺថា អ្នកគ្មានបំណងប្រាថ្នាដើម្បីធ្វើខុស ។ ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃគឺជាគំរូដ៏អស្ចារ្យអំពីរឿងនេះ ។ នៅពេលពួកគេត្រូវបានផ្លាស់ប្រែចិត្តជឿតាមដំណឹងល្អរបស់ព្រះគ្រីស្ទ « ពួកគេបានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងព្រះ ដើម្បីបម្រើទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ » ( ម៉ូសាយ 21:31 ) ។ ដូចជាពួកសាសន៍នីហ្វៃត្រូវបានបង្រៀនដោយ

ស្ដេចបេនយ៉ាមីនថា ពួកគេ « ពុំមានបំណងនឹងប្រព្រឹត្ត អំពើទុច្ចរិតទៀតឡើយ » ( ម៉ូសាយ 5:2 ) ។ ពួកគេ ពិតជាផ្លាស់ប្រែចិត្តជឿតាមដំណឹងល្អរបស់ព្រះគ្រីស្ទ ហើយការល្បួងទាំងឡាយរបស់សាតាំងនឹងគ្មានឥទ្ធិពល លើពួកគេនោះទេ ។

**3.** នៅពេលអ្នកត្រូវបានផ្លាស់ប្រែចិត្តជឿ នោះអ្នក កាន់តែខ្វល់ខ្វាយអំពីអ្វីដែលព្រះគិតជាជាងអ្វី ៗដែលអ្នកដទៃគិតអំពីអ្នក ។នៅសាលារៀនរបស់ខ្ញុំក្នុង ប្រទេស ឥណ្ឌូណេស៊ី សិស្សទាំងឡាយចូលចិត្តផឹក ស្រាច្រើន ។ ជួនកាលវាអាចនឹងល្បួងឲ្យចូលរួមក្នុងពិធី ជប់លៀងខាងក្រៅដែលមិនសមរម្យ នៅពេលដែលអ្នក ផ្សេងទៀតកំពុងទទួលរងការល្បួង ហើយសើចចំអក ដល់អ្នកដោយសារតែអ្នកមិនទៅជាមួយនឹងពួកគេ ។ បងប្រុសរបស់ខ្ញុំត្រូវបានគេបបួលឲ្យផឹកស្រា និង ចូលរួម ពិធីជប់លៀងជាច្រើនដង ប៉ុន្តែគាត់មិនដែលផឹកនោះទេ គាត់បានឈរយ៉ាងរឹងប៉ឹង និង រស់នៅតាមអ្វីដែលគាត់ បានជឿ ។ វាជាការលំបាក ហើយគាត់នៅផ្ទះតែម្នាក់ឯង ជាច្រើនយប់ ។ នៅពេលសិស្សទាំងឡាយបាននិយាយ លាគ្នានៅឯពិធីចែកសញ្ញាបត្រ នោះមានសិស្សមួយចំនួន បានភ្ញាក់ផ្អើលនឹងគាត់ ដោយសារគាត់អាចតស៊ូពីការរង សំពាធពីសម្លាញ់របស់គាត់ ហើយនៅស្មោះពិតនឹងបទ ដ្ឋានខាងសីលធម៌ ។ ពួកគេបានប្រាប់គាត់ថា ពួកគេសូម សរសើរជាខ្លាំងចំពោះគាត់ដោយសារតែរឿងនេះ ។ គាត់ បានបង្ហាញថា គាត់ត្រូវបានផ្លាស់ប្រែចិត្តជឿដោយការ តស៊ូពីការរងសំពាធពីសម្លាញ់របស់គាត់ ។

**4.** នៅពេលបានផ្លាស់ប្រែចិត្តជឿ នោះអ្នក ព្យាយាមអស់ពីសមត្ថភាពរបស់អ្នកដើម្បីរស់នៅ នោតាមដំណឹងល្អជានិច្ច— មិនមែនគ្រាន់តែនៅរាល់ អាទិត្យនោះទេ ឬ នៅពេលវាមានជីវិតងាយស្រួលនោះដែរ ប៉ុន្តែព្យាយាមអស់សមត្ថភាពគ្រប់ពេលវេលា ។ សកម្ម ភាពរបស់អ្នកមិនបានផ្លាស់ប្ដូរការប្រាស្រ័យទាក់ទងថា តើ អ្នកណាដែលអ្នកនៅជាមួយ ឬ ថាតើអ្នកណាអាចកំពុង ឃ្លាំមើលអ្នកនោះទេ ។ នៅពេលសម្លាញ់របស់អ្នកប្រាប់ នូវរឿងកំប្លែងអាសគ្រាម ឬ ចង់មើលរឿងអាសក្រាម នោះអ្នកមិនត្រូវចូលរួមជាមួយនឹងពួកគេ ដោយសារគ្មាន នណារមើលនោះទេ ផ្ទុយទៅវិញអ្នកត្រូវឈរយ៉ាងរឹងប៉ឹង ចំពោះអ្វីដែលអ្នកបានជឿ ។

**5.** នៅពេលអ្នកត្រូវបានផ្លាស់ប្រែចិត្តជឿ នោះអ្នក កាន់តែមានចិត្តសប្បុរស និង មេត្តាករុណាក្នុង ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ។ អ្នកមិនត្រូវ វិនិច្ឆ័យ ឬ រិះគន់ ឬ និយាយដើមគេនោះឡើយ ។ អ្នក កាន់តែយល់ពីអារម្មណ៍របស់អ្នកដទៃ ហើយវានឹងក្លាយ ទៅជាលក្ខណៈសម្បត្តិមួយដើម្បីស្វែងរករបៀបដើម្បី បម្រើ និង ជួយ ។ បើសិនអ្នកកំពុងដើរចេញពីសាលធំ ក្នុងសាលារៀនរបស់អ្នក ហើយមានអ្នកណាម្នាក់បាន



5.



6.



2.

ដើម្បីបង្ហាញថា ពួកគេនឹងស្មោះពិតចំពោះសេចក្ដី សញ្ញារបស់ពួកគេដើម្បីរស់នៅតាមដំណឹងល្អ នោះពួកសាសន៍លេមិនបានកប់គ្រឿងសស្ត្រាវុធ ពិជ័យសង្គ្រាមរបស់ពួកគេ ( សូមមើល អាលម៉ា 24 ) ។



## ផ្លូវដ៏ច្បាស់លាស់ទៅកាន់សុភមង្គល

« ព្រះអម្ចាស់ចង់ឲ្យសមាជិកទាំងឡាយ នៃសាសនាចក្រ ត្រូវបានប្រែចិត្តជឿ ទាំងស្រុងទៅលើដំណឹងល្អ ។ នេះគឺជា ផ្លូវច្បាស់លាស់តែមួយគត់ដើម្បីមានសុវត្ថិភាពខាងវិញ្ញាណ និង មានសុភមង្គលជារៀងរហូត » ។

**អែលឌើរ ដូណាល អិល. ហលស្ត្រម នៃគណៈប្រធាននៃពួកចិតសិបអ្នក « ប្រែចិត្តជឿតាមដំណឹងល្អរបស់ទ្រង់តាមរយៈសាសនាចក្ររបស់ទ្រង់ »*លីអាហូណា* ខែ ឧសភា ឆ្នាំ 2012 ទំព័រ 15 ។**

រចនារូបភាព © IRI ពួកសាសន៍អាន់ទី-នីហ្វៃ-លីហៃកប់អាវុធរបស់ពួកគេ ដោយ ដែល ផាសុន © IRI



7.



9.



10.

ជ្រុះ សៀវភៅរបស់គាត់ នោះអ្នកមិនត្រូវគិតអំពីអ្វីដែលត្រូវធ្វើនោះឡើយ ។អ្នកឈប់ជួយរើសសៀវភៅនោះដោយស្វ័យប្រវត្តិ ។

**6.** នៅពេលអ្នកត្រូវបានផ្លាស់ប្រែចិត្តជឿ នោះបំណងប្រាថ្នារបស់អ្នកដើម្បីអធិស្ឋាននឹងកើនឡើង ហើយអ្នកនឹងមានអារម្មណ៍ដូចជាអ្នកកំពុងទំនាក់ទំនងជាមួយព្រះនៅពេលអ្នកអធិស្ឋាន ។ អ្នកនឹងរៀបចំពេលដើម្បីអធិស្ឋានជានិច្ច មិនថាអ្នកទទួលអារម្មណ៍បែបណា ឬ អ្វីនឹងកើតឡើងនៅក្នុងជីវិតរបស់អ្នកនោះទេ ។ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( ឆ្នាំ 1899–1994 ) បានប្រាប់យើងថា « បើសិនយើងមិនមានអារម្មណ៍ថាចង់អធិស្ឋានទេ នោះយើងគួរតែអធិស្ឋានរហូតដល់យើងមានអារម្មណ៍ថាចង់អធិស្ឋាន » ។[2]

**7.** នៅពេលអ្នកផ្លាស់ប្រែចិត្តជឿ នោះអ្នកនឹងទន្ទឹងរង់ចាំថ្ងៃអាទិត្យមកដល់ដោយរីករាយ ដោយសារវាជាថ្ងៃបរិសុទ្ធ ។ នៅពេលថ្ងៃអាទិត្យមកដល់ ជាជាងការគិតថា « អូ ! អត់ទេ វាជាថ្ងៃដែលខ្ញុំមិនអាចដើរលេងខាងក្រៅជាមួយមិត្តភក្តិទាំងឡាយរបស់ខ្ញុំ ឬ ទៅមើលរឿងភាពយន្ត » បានឡើយ តែអ្នកគួរតែគិតបែបនេះវិញថា « ល្អណាស់! វាជាថ្ងៃដែលខ្ញុំអាចចូលរួមនៅព្រះវិហារ ហើយផ្ដោតលើរឿងទាំងឡាយខាងវិញ្ញាណ និងចំណាយពេលនៅជាមួយគ្រួសារខ្ញុំវិញ ! »

**8.** នៅពេលបានប្រែចិត្តជឿ នោះអ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយ ហើយអ្នកមិនព្យាយាមរកលេសដោះសារ បង្ហាញនូវអាកប្បកិរិយាខុសឆ្គង ឬ ព្យាយាមស្វែងរកហេតុផលដែលបំពានព្រះបញ្ញត្តិទាំងឡាយនោះទេ ។ អ្នកមិនត្រូវព្យាយាមបំពានលើបទដ្ឋានឡើយ អ្នកគ្រាន់តែកាន់តាមព្រះបញ្ញត្តិទាំងឡាយដោយសារអ្នកដឹងថា វាគឺជាវិធីដែលប្រសើរជាងវិធីផ្សេង ។

**9.** នៅពេលបានផ្លាស់ប្រែចិត្តជឿ អ្នកនឹងពេញចិត្តដើម្បីបង់ដង្វាយមួយភាគក្នុងដប់ ។ អ្នកយល់ឃើញថា ជាឯកសិទ្ធិមួយ ហើយទទួលអារម្មណ៍ថាចំនួន 10 ភាគរយ គឺមិនជាច្រើននោះទេ ជាពិសេសបើប្រៀបធៀបទៅនឹងពរជ័យ និង ការចាក់បំពេញមកវិញនូវអ្វីដែលអ្នកនឹងទទួល ។ ពរជ័យទាំងនេះគឺមានតម្លៃច្រើនជាងលុយដែលអ្នកបង់ទៅទៀត ។

**10.** នៅពេលអ្នកផ្លាស់ប្រែចិត្តជឿ នោះអ្នកមានបំណងប្រាថ្នាយ៉ាងខ្លាំងដើម្បីជួយអ្នកដទៃឲ្យស្គាល់សេចក្ដីពិត និង សុភមង្គលដែលអ្នកបានរកឃើញ ។ មានគំរូល្អមួយពីព្រះគម្ពីរគឺជាការសុបិនរបស់លីហៃ ដែលលោកបានមានបំណងប្រាថ្នាយ៉ាងខ្លាំងដើម្បីចែករំលែកនូវផ្លែដ៏ឆ្ងាញ់នៃដើមជីវិតនោះជាមួយគ្រួសាររបស់លោក ។ នៅពេលគាត់ទទួលទានផ្លែឈើនោះ នោះគំនិតដំបូងរបស់គាត់ គឺមិនត្រូវទទួលទានផ្លែឈើនោះតទៅទៀតទេ ប៉ុន្តែរកមើលគ្រួសាររបស់លោកដើម្បីឲ្យពួកគេអាចទទួលទានផ្លែឈើនោះដែរ ហើយមានសុភមង្គលដូចលោកដែរ ( សូមមើល នីហ្វៃទី 1 8:12 ) ។

និយាយឲ្យខ្លីទៅ អ្នកដឹងថា អ្នកកំពុងប្រែចិត្តជឿនៅពេលអ្នកចាប់ផ្ដើមរស់នៅតាមក្រឹត្យវិន័យខ្ពស់បំផុត គឺដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នករស់នៅតាមការគោរពប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែសម្រាប់មូលហេតុដ៏ត្រឹមត្រូវ ។ អ្នករស់នៅតាមដំណឹងល្អក្នុងទស្សនៈវិស័យទាំងអស់នៃជីវិតរបស់អ្នក ។ អ្នករស់នៅតាមដំណឹងល្អទាំងស្រុង មិនមែនដោយសារអ្នកត្រូវតែរស់នៅតាមនោះទេ តែដោយសារអ្នកចង់ធ្វើតាម ។ អ្នកគឺជាមនុស្សម្នាក់ដែលកាន់តែមានសុភមង្គល និងកាន់តែល្អប្រសើរ ហើយអ្នកចង់ក្លាយជាមនុស្សម្នាក់ដែលព្រះវរបិតាចង់ឲ្យអ្នកប្រែក្លាយ ។ អ្នកចង់ក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមគំរូរបស់ទ្រង់ ។ នៅពេលអ្នកក្លាយជាមនុស្សម្នាក់នោះ អ្នកពិតជាប្រែចិត្តជឿយ៉ាងពិតប្រាកដ ។ ■

*ថៃលី អរតុន រស់នៅក្នុងតំបន់ យ៉ាវ៉ា ប្រទេស ឥណ្ឌូណេស៊ី ។*

**កំណត់ចំណាំ**

1. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ 2010 ) ចំណុច 8.1.3 ។
2. អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន « Pray Always » *លីអាហូណា* ខែ មិថុនា ឆ្នាំ 1990 ទំព័រ 4 ។

ខាងលើ ៖ រូបថត © IRI; កាក់ទាំងឡាយ © ISSTOCKPHOTO.COM/THINKSTOCK; ទស្សនវិស័យរបស់លីហៃពីដើមឈើជីវិត ដោយ រ៉ូបឺរ ញូប © IRI




រចនារូបភាព ដោយ ប្រៀត និង ខាណេបាទរ; រូបភាពផ្ទៃខាងក្រោយ © THINKSTOCK

## អ្នកផ្សព្វផ្សាយសាសនា

# ក្មេងតូចម្នាក់របស់លោកយាយ ឌែនី



**ដោយ អ៊ីមមីលៀ ម៉ារៀ ហ្គាម៉ារាស់ ខូរៀ**

*« ត្បិតកាលណាមនុស្សណាមួយនិយាយ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនឹងនាំពាក្យទាំងនោះចូលទៅក្នុងចិត្តនៃកូនចៅមនុស្ស » ( នីហ្វៃទី 2 33:1 ) ។*

វិធី បានរស់នៅជាមួយម្ដាយ និង បងប្អូនស្រីរបស់គាត់នៅឯគេហដ្ឋានរបស់លោកយាយ ឌែនី ។ លោកយាយរបស់ វិធី បានធ្លាក់ខ្លួនឈឺ ហើយមិនអាចក្រោកពីគ្រែរបស់គាត់អស់រយៈពេលជាច្រើនសប្ដាហ៍ ។គាត់នៅក្នុងបន្ទប់តែម្នាក់ឯង ។

វិធី បានសម្រេចចិត្តថា គាត់អាចទៅលេងក្រុមហ៊ុនរបស់លោកយាយ ឌែនី បាន ។ ជារៀងរាល់ថ្ងៃ នៅពេលគាត់ចេញពីរៀន គាត់យកទស្សនាវដ្ដី *លីអាហូណា*មួយច្បាប់ចូលទៅក្នុងបន្ទប់របស់លោកយាយ ហើយអានរឿងផ្សេងៗពីក្នុងទំព័ររបស់កុមារ ។

ក្រោយពីគាត់អានទស្សនាវដ្ដី*លីអាហូណា*អស់ជាច្រើនច្បាប់ ដែលគ្រួសារគាត់មាន នោះគាត់បានចាប់ផ្ដើមអានព្រះគម្ពីរមរមន និង ព្រះគម្ពីរបរិសុទ្ធឲ្យលោកយាយ ឌែនី ស្ដាប់ ។ លោកយាយ ឌែនី មិនមែនជាសមាជិកនៃសាសនាចក្រ ប៉ុន្តែគាត់ចូលចិត្តឲ្យ វិធី អានឲ្យគាត់ស្ដាប់ ។ គាត់សប្បាយចិត្តដើម្បីរៀនដំណឹងល្អ ។

លោកយាយបានសួរសំណួរជាច្រើន ។ បើសិន វិធី មិនបានដឹងចម្លើយទេ នោះគាត់សួរគ្រូបង្រៀនក្នុងថ្នាក់បឋមសិក្សា ឬ រកមើលនៅក្នុងព្រះគម្ពីរ ។ លោកយាយបានហៅ វិធី ថាជាអ្នកផ្សព្វផ្សាយសាសនាក្មេងតូចម្នាក់របស់គាត់ ។

លោកយាយ ឌែនី បានប្រាប់ វិធី ថា គាត់បានរៀនច្រើនពី វិធី ។ គាត់បានសន្យាថា គាត់នឹងចូលរួមព្រះវិហារជាមួយ វិធី នៅពេលគាត់ជាសះស្បើយ ។ អ្វីដែលគាត់បានរៀន បានធ្វើឲ្យគាត់កាន់តែល្អប្រសើរឡើង ហើយសិក្សាដំណឹងល្អបន្ថែមទៀត ។

នៅពេលលោកយាយមានសុខភាពល្អ គាត់នឹងរក្សាការសន្យារបស់គាត់ ។ គាត់បានទៅព្រះវិហារជាមួយ វិធី ដើម្បីរៀនបន្ថែមទៀត នូវអ្វីដែលគាត់បានបង្រៀនដល់លោកយាយ ។ វាមិនជាយូរប៉ុន្មានទេ ពីមុនពេលដែលលោកយាយទទួលពិធីបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់ ។ វីធី បានជួយគាត់ឲ្យរៀនថា ដំណឹងល្អនេះគឺជាការពិត ។

នៅពេល វីធី បានធំឡើង នោះគាត់បានក្លាយជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងម្នាក់នៅក្នុងបេសកកម្ម បូស្តុន ម៉ាស្សាឈូសសិត។ ពីមុនពេលគាត់ចេញបេសកកម្ម គាត់បានទៅព្រះវិហារបរិសុទ្ធ—ជាមួយលោកយាយ ឌែនី ។ ■

ដោយ អ៊ីមមីលៀ ម៉ារៀ ហ្គាម៉ារាស់ ខូរៀ រស់នៅសង្កាត់ ហ្វីឌីរ៉ែល ប្រទេសប្រេស៊ីល ។



រូបភាពទាំងឡាយបានមកពី អ៊ីមមិលីយ៉ា ម៉ារីយ៉ា ហ្វីម៉ារាស់ ខូរៀ

សាក្សីពិសេស



# តើហេតុអ្វីបានជាសាសនាចក្រមានឈ្មោះវែងម្ល៉េះ ?

**ដោយ អែលឌើរ អិម. រ័សុល បាឡឺដ**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់
*សមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*

**ព្រះ**យេស៊ូវគ្រីស្ទផ្ទាល់បានឲ្យនាមដល់សាសនាចក្រ ( សូមមើលគោលលទ្ធិ និង សេចក្ដីសញ្ញា 115:4 ) ។

ពាក្យថា*សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ*ប្រកាសថា វាគឺជាសាសនាចក្ររបស់ទ្រង់ ។

*នៃថ្ងៃចុងក្រោយ*ពន្យល់ថា វាគឺជាសាសនាចក្រដូចគ្នានឹងសាសនាចក្រដែលព្រះយេស៊ូវគ្រីស្ទបានស្ថាបនានៅពេលទ្រង់បានរស់នៅលើផែនដីនេះ ប៉ុន្តែត្រូវបានស្ដារឡើងវិញនៅថ្ងៃចុងក្រោយនេះ ។

*ពួកបរិសុទ្ធ*មានន័យថា យើងធ្វើតាមទ្រង់ និងព្យាមយាមធ្វើតាមព្រះហឫទ័យទ្រង់ ។

ពួកសមាជិករបស់យើងត្រូវបានគេហៅថា*ពួកមរមន*ដោយសារយើងជឿលើព្រះគម្ពីរមរមន ប៉ុន្តែយើងគួរតែប្រើប្រាស់ឈ្មោះពេញរបស់សាសនាចក្រនៅពេលណាដែលអាចប្រើបាន ។ ■

*មកពី « សារៈសំខាន់នៃឈ្មោះ »* លីអាហូណា *ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 79–82 ។*



# ពិធីអបអរសាទរជាមួយនឹងព្រះវិហារបរិសុទ្ធ !

ដោយ ដាសុី ជេនសិន

នៅពេលព្រះវិហារបរិសុទ្ធ សលត៍ លេក ត្រូវបានសាងសង់ចប់ទាំងស្រុង នៅឆ្នាំ 1983 នោះពួកបរិសុទ្ធថ្ងៃចុងក្រោយបានអររីករាយជាខ្លាំង ។ ពួកគេបានចំណាយពេល 40 ឆ្នាំដើម្បីកសាងព្រះបរិសុទ្ធនេះ ។ ដោយសារកុមារទាំងឡាយបានបរិច្ចាគលុយដើម្បីជួយកសាងព្រះវិហារបរិសុទ្ធ នោះប្រធាន វិលហ្វូឌ វូឌរុព្វ បានសម្រេចចិត្តដើម្បីប្រារព្ធសម័យប្រជុំខួបឧទ្ទិសឆ្លងពិសេសចំនួនប្រាំដង សម្រាប់ឲ្យកុមារចូលរួម ។

មានព្រះវិហារបរិសុទ្ធជាច្រើននៅលើផែនដីនេះនៅពេលបច្ចុប្បន្ននេះ ហើយកុមារទាំងឡាយនៅតែជួយប្រារព្ធពិធីបញ្ចប់ព្រះវិហារបរិសុទ្ធទាំងឡាយ ។ សូមមើលរបៀបដែលកុមារទាំងឡាយបានចូលរួមនៅកាលពីអតីតកាល និង នៅពេលឥឡូវនេះ ។ ■

*ដាសុី ជិនសិន រស់នៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។*

*មានកុមារជាង12,000 នាក់ដែលបានមកកាន់ព្រះវិហារបរិសុទ្ធ សលត៍ លេកដើម្បីចូលរួមពិធីឧទ្ទិសឆ្លង ។ កុមារទាំងអស់នេះមកពីវួដ ស៊ូហ្គើ ហោស៍ ដែលបានធ្វើដំណើរតាមរទេះភ្លើង ។*




*សំបុត្រធ្វើដំណើរនេះបានអនុញ្ញាតឲ្យកុមារទាំងឡាយដែលមានអាយុរហូតដល់ 16 ឆ្នាំ ដើម្បីចូលរួមសម័យប្រជុំនៃពិធីឧទ្ទិសឆ្លងពិសេសសម្រាប់ព្រះវិហារបរិសុទ្ធ សលត៍ លេក នេះ ។ពួកសាវក និង សមាជិកទាំងឡាយនៃគណៈប្រធានទីមួយបាននិយាយទៅកាន់កុមារទាំងឡាយនៅក្នុងព្រះវិហារបរិសុទ្ធ ។*



*ជួនកាល ព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងឡើងវិញបន្ទាប់ពីមានការសាងសង់ឡើងវិញដែលមានទ្រង់ទ្រាយធំ ។ កុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សាបានច្រៀង និង នាំពន្លឺទាំងឡាយមកកាន់ការសម្ដែងដែលបានប្រារព្ធនូវពិធីឧទ្ទិសឆ្លងឡើងវិញនៃព្រះវិហារបរិសុទ្ធ អ៊ែងឃើរេ៉ច អាឡាស្កា ។*



*នៅអំឡុងពេលសប្ដាហ៍និមួយៗដែលព្រះវិហារបរិសុទ្ធ ហ្គិលប៊ឺត អារីស្សូណាកំពុងកសាង នោះកុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សាដែលមកពីស្តេក ហ្គិលប៊ឺត អារីស្សូណា ហាយឡែនដ៍ បានដាក់គោលដៅដើម្បីបម្រើអ្នកណាម្នាក់នៅក្នុងវួដទាំងឡាយរបស់ពួកគេ ។*

*នៅពេលដែលព្រះវិហារបរិសុទ្ធ សាន់ឌីអាហ្គូ កាលីហ្វូញ៉ាកំពុងសាងសង់ នោះកុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សាដែលមកពីប្រទេស ម៉ិកស៊ីកូ បានធ្វើកម្រាលព្រំដែលមានពណ៌ចំរុះស្អាតសម្រាប់ព្រះវិហារបរិសុទ្ធ ។ ពួកអ្នកមានសិទ្ធអំណាចទូទៅបានឈរនៅលើកម្រាលព្រំអំឡុង ពេលពិធីបឋមសិលានៅឯកន្លែងឧទ្ទិសឆ្លងនោះ ។*





កុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សានៅក្នុងតំបន់មែននីតូបា ប្រទេស កាណាដា បានជិះឡានអស់រយៈពេលបីម៉ោងទៅកាន់ព្រះវិហារបរិសុទ្ធរីហ្គិណា សាស្កាតឈូវែនដើម្បីពួកគេអាចទៅប៉ះជញ្ជាំង ហើយតាំងចិត្តថា នឹងចូលទៅខាងក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃណាមួយ ។

កុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សានៅឯព្រះវិហារបរិសុទ្ធ យីវ អ៊ុយក្រែន បានធ្វើពិធីបើកឲ្យចូលទស្សនាដំណាក់ថ្មី ដែលបានទទួលស្វាគមន៍ដល់អ្នកទស្សនាទាំងឡាយដោយការច្រៀង « *I Love to See the Temple* » ។





កុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សាដែលមានជាង 800 នាក់ដែលមកពីប្រទេស អាហ្វ្រិកភាគខាងលិច បានច្រៀងបទ « ខ្ញុំជាកូនរបស់ព្រះ » នៅក្នុងកម្មវិធីសិល្បៈពីមុនពេលដែលព្រះវិហារបរិសុទ្ធ អាកក្រាហ្គណាត្រូវបានឧទ្ទិសឆ្លង ។



កុមារទាំងឡាយក្នុងថ្នាក់បឋមសិក្សាបានច្រៀងចម្រៀងសម្រាប់ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី នៅពេលលោកមកដល់ដើម្បីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ អាបា នីហ្សេរីយ៉ា ។




ព្រះវិហារបរិសុទ្ធនិមួយៗមានបឋមសិលាមួយដែលបង្ហាញនូវឆ្នាំ ដែលព្រះវិហារបរិសុទ្ធនេះត្រូវបានឧទ្ទិសឆ្លង ។ នៅកន្លែងឧទ្ទិសឆ្លង ពួកអ្នកមានសិទ្ធិអំណាចទូទៅបិទភ្ជាប់ថ្មជ្រុងនេះជាមួយនឹងបាយអរ ។ អ៊ីសាក ប៊ី. អាយុ 9 ឆ្នាំ បានជួយដាក់បាយអរនេះនៅលើថ្មជ្រុងនៃព្រះវិហារបរិសុទ្ធខានសាស ស៊ីធី មិសសួរី ។

រូបភាព ( ពីខាងឆ្វេង ) ៖ ទទួលបានមកពីស្តេក ហ្គីប៊ឺត អារីសូណា ហាយឡែនដ៍, ទទួលបានមកពីបណ្ណាល័យសាសនាចក្រ, ទទួលបានមកពី រីឆាត អិន. ហូលស្វាពហ្វែល, ដោយ ឡឺនន៍ ហាវលិត, ដោយ ម៉ាបិល និង ឌែលប៊ឺត ផាលមើ, ទទួលបានមកពី រ័សុល ខេ. អានឌឺសាន់, ដោយ ដេវិត អែម. ដុបលយូ ភិកខាប់, ដោយ ឡូរី ហ្គារសៀ, ដោយ ហ្គ៏រី អាវ៉ែនត៍ និង ដោយ ជូលី ដក់ស្តាតឌី ហ៊ិបស៍, រចនារូបភាពដោយ ប្រ៊ែត ធៀ

# សំណួរ និង ចម្លើយ ទាំងឡាយអំពីព្រះវិហារបរិសុទ្ធ

**តើហេតុអ្វីយើងមានព្រះវិហារបរិសុទ្ធ ?**

ព្រះវិហារបរិសុទ្ធទាំងឡាយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាទីកន្លែងដ៏ពិសិដ្ឋដែលយើងរៀនអំពីសេចក្ដីពិតដ៏អស់កល្បជានិច្ច និង ចូលរួមក្នុងពិធីបរិសុទ្ធទាំងឡាយ ។

**តើនៅក្នុងព្រះវិហារបរិសុទ្ធមានសភាពបែបណាដែរ ?**

ព្រះវិហារបរិសុទ្ធគឺជាដំណាក់ដ៏សុខសាន្តប្រកបដោយគារវភាព និង ស្រស់ស្អាត ។ អ្វីៗទាំងអស់ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធគឺស្រស់ស្អាត និង មានរបៀបរៀបរយ ។ មនុស្សរាល់គ្នាស្លៀកសំលៀកបំពាក់ពណ៌ស ហើយនិយាយខ្សឹបតិចៗ ។

**តើគេធ្វើអ្វីខ្លះនៅក្នុងព្រះវិហារបរិសុទ្ធ ?**

ភរិយាអាចត្រូវបានផ្សារភ្ជាប់ជាមួយស្វាមីរបស់នាង ហើយកូនៗអាចត្រូវបានផ្សារភ្ជាប់ជាមួយនឹងឪពុកម្ដាយរបស់ពួកគេ ។ ពិធីផ្សារភ្ជាប់អាចធ្វើឲ្យក្រុមគ្រួសាររស់នៅជាមួយគ្នាដ៏អស់កល្បជានិច្ចបាន ។ នៅក្នុងព្រះវិហារបរិសុទ្ធ បុរស និង ស្ត្រីទាំងឡាយក៏ទទួលនូវអំណោយទាននៃពរជ័យខាងវិញ្ញាណដែលត្រូវបានហៅថា អំណោយទានពិសិដ្ឋផងដែរ ។ ពួកគេក៏អាចទទួលបាននូវអំណោយទានពិសិដ្ឋ ហើយត្រូវបានផ្សារភ្ជាប់ជំនួសអ្នកទាំងឡាយណាដែលដែលបានស្លាប់ទៅ ដោយមិនបានចុះសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ ។

**តើមានអ្វីទៀតដែលធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធ ?**

ក្រៅពីពិធីផ្សារភ្ជាប់ និង អំណោយទានពិសិដ្ឋក៏មានពិធីបរិសុទ្ធដ៏ទៃទៀតដែលត្រូវបានធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធផងដែរ ។ មនុស្សទាំងឡាយអាចត្រូវបានទទួលពិធីបុណ្យជ្រមុជទឹក និង ធ្វើពិធីបញ្ជាក់សម្រាប់អ្នកទាំងឡាយណាដែលមិនអាចចូលរួមក្នុងសាសនាចក្រខណៈដែលពួកគេនៅរស់ ។ នៅពេលអ្នកឈានដល់អាយុ 12 ឆ្នាំ ហើយមានភាពសក្ដិសមដើម្បីចូលព្រះវិហារបរិសុទ្ធ នោះអ្នកអាចមានឱកាសមួយដើម្បីធ្វើពិធីបុណ្យជ្រមុជទឹក និង ទទួលពិធីបញ្ជាក់សម្រាប់អ្នកទាំងឡាយណាដែលបានស្លាប់ទៅដោយគ្មានដំណឹងល្អ ។

**តើមានអ្វីកើតឡើងបើគ្រួសាររបស់ខ្ញុំមិនបានទៅព្រះវិហារបរិសុទ្ធនោះ ?**

ព្រះវរបិតាសួគ៌ទ្រង់ជ្រាបដឹង និង ស្រលាញ់អ្នក និង គ្រួសាររបស់អ្នក ។ ទ្រង់ចង់ឲ្យអ្នករាល់គ្នាទទួលបានពរជ័យនៃពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធ ។ សូមរស់នៅឲ្យសក្ដិសមដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។ចូរដាក់គោលដៅនៅពេលឥឡូវនេះដែលអ្នកនឹងទទួលបាននូវអំណោយទានពិសិដ្ឋ ហើយរៀបការនៅក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃណាមួយ ។ ព្រះវរបិតាសួគ៌របស់អ្នកនឹងប្រទានពរអ្នក និង គ្រួសាររបស់អ្នក ។ ■



« ពួកយុវមិត្តរបស់ខ្ញុំអើយ . . . សូមផ្ដោតចិត្តរបស់អ្នកទៅលើព្រះវិហារបរិសុទ្ធជានិច្ច ។ សូមកុំធ្វើអ្វីដែលបង្ខាំងអ្នកពីការចូលទៅតាមទ្វារនៃព្រះវិហារបរិសុទ្ធ ហើយទទួលនូវពរជ័យដ៏ពិសិដ្ឋ និង អស់កល្បជានិច្ចនៅទីនោះឡើយ » ។

**ប្រធាន ថូម៉ាស អេស. ម៉នសុន « The Holy Temple—a Beacon to the World » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 93 ។**



គំនូរព្រាងដោយ ប្រ៊ែត ហ្វៀ

# ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍

(សាមពា)

និពន្ធទំនុកច្រៀង ដោយ រ៉ូស មា ហ្គាតទី
និពន្ធបទភ្លេង ដោយ វេញ៉ា វ៉ាយ វត់យិន




ទំនុកច្រៀង និង បទភ្លេង © 1980 ការរៀបចំ © 2012 រក្សាសិទ្ធិគ្រប់យ៉ាង
បទចម្រៀងនេះ អាចថតចម្លងសម្រាប់ការប្រើប្រាស់ធ្វើជាឯកសារជំនួយ ហើយគ្មានលក្ខ ណៈជាការប្រើប្រាស់បែបអាជីវកម្មនៅក្នុងសាសនាចក្រ ឬនៅក្នុងផ្ទះទេ

ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន

# ព្រះយេស៊ូវគ្រីស្ទបានស្ដារសាសនាចក្ររបស់ទ្រង់ឡើងវិញនៅក្នុងថ្ងៃចុងក្រោយ



អ្នកអាចប្រើមេរៀន និងសកម្មភាពនេះ ដើម្បីរៀនសូត្របន្ថែមទៀតពីបាវចនាថ្នាក់កុមារសម្រាប់ខែនេះ ។

ស្រមស្រមៃគិតថា កំពុងទៅស្វែងរករតនសម្បត្តិ ។ តើអ្នកនឹងរករតនសម្បត្តិនេះនៅកន្លែងណា ? តើអ្នកនឹងស្វែងរករតនសម្បត្តិនេះដោយរបៀបណា ? តើនឹងមានប្រអប់រតនសម្បត្តិឬទេ ? តើមានអ្វីនៅក្នុងប្រអប់នេះ ?

ប្រអប់រតនសម្បត្តិ មួយចំនួនមាននូវគ្រឿងអលង្ការដ៏ស្រស់ស្អាត និង កាក់ដ៏មានតម្លៃ ។ ប៉ុន្តែក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងមាននូវរតនសម្បត្តិ ដែលមានតម្លៃច្រើនជាងនេះគឺ ៖ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

មានមនុស្សជាច្រើនមិនដឹងអំពីរតនសម្បត្តិនេះទេ ដូច្នេះក្នុងចំណោមកាតព្វកិច្ចមួយរបស់យើងគឺត្រូវចែករំលែករតនសម្បត្តិនេះទៅកាន់មនុស្សឲ្យកាន់តែច្រើនតាមដែលយើងអាចធ្វើទៅបាន ។

បន្ទាប់ពីព្រះយេស៊ូវ និង ពួកសាវករបស់ទ្រង់បានទទួលមរណភាពទៅ នោះការបង្រៀន និង ពិធីបរិសុទ្ធសំខាន់ៗមួយចំនួននៃដំណឹងល្អត្រូវបានបាត់បង់ ឬត្រូវបានកែប្រែ ដោយមានរួមទាំងពិធីបុណ្យជ្រមុជទឹក, សិទ្ធអំណាចបព្វជិតភាព, ព្រះវិហារបរិសុទ្ធ, ពួកព្យាការីដែលរស់នៅ, និង ពិធីសាក្រាម៉ង់ ។

រាល់រតនសម្បត្តិនៃដំណឹងល្អទាំងអស់ត្រូវបានស្ដារឡើងវិញតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ បានលេចមកជួបយ៉ូសែប ស្ម៊ីធ នៅព្រៃពិសិដ្ឋមួយនៅពេលដែលលោកអធិស្ឋានដើម្បីដឹងសេចក្ដីពិត ។

ក្រោយមក យ៉ូសែប បានទទួលផ្ទាំងមាសទាំងឡាយ ហើយបានបកប្រែផ្ទាំងមាសទាំងនេះទៅជាព្រះគម្ពីរមរមន ។ ព្រះគម្ពីរមរមនមាននូវការបង្រៀនទាំងឡាយដែលយើងឲ្យតម្លៃខ្ពស់ ដោយសារព្រះគម្ពីរមរមននេះពន្យល់នូវសេចក្ដីពិតទាំងឡាយដែលត្រូវបានបាត់បង់នៅគ្រាមួយនោះ ។ យើងទទួលបានពរជ័យជាច្រើនដោយសារតែយើងមានសេចក្ដីពិតនៃដំណឹងល្អទាំងនេះ ។

ទាំងនេះគឺជារតនសម្បត្តិដ៏មានតម្លៃ ! ■

## ព្រះគម្ពីរ និង បទចម្រៀង

- គោលលទ្ធិ និង សេចក្ដីសញ្ញា 35:17
- « The Sacred Grove » *Children's Songbook* ទំព័រ 87 ( បទចម្រៀងមួយផ្សេងទៀតអំពីការស្ដារឡើងវិញនៃដំណឹងល្អ )

## សូមយើងពិភាក្សាគ្នា

សូមចែកចាយនូវរបៀបដែលរតនសម្បត្តិទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទប្រទានពរដល់គ្រួសាររបស់អ្នក ។

## សូមធ្វើប្រអប់រតនសម្បត្តិនៃដំណឹងល្អមួយ

សូមបត់ប្រអប់រតនសម្បត្តិនៃដំណឹងល្អនេះដូចជាគំនូសព្រួញនៅបាតរបស់វា ។ សូមកាត់ក្រដាសជារាងកាក់មូលៗ ដោយសរសេរឈ្មោះរតនសម្បត្តិ មួយចំនួនដែលដំណឹងល្អបានប្រទានពរដល់អ្នក ហើយដាក់ក្រដាសកាក់ទាំងអស់នេះនៅក្នុងប្រអប់នេះ ។ សូមរកមើលរតនសម្បត្តិទាំងឡាយនៅក្នុងប្រអប់នេះជាញឹកញាប់ដើម្បីជួយរំឭកអ្នកអំពីពរជ័យទាំងឡាយនៃដំណឹងល្អ ។









# កន្លែងដែលសាសនាចក្រត្រូវបាន រៀបចំឡើង




**ដោយ ជេន ភិនប្ល៉ូហ្វ**
ទស្សនាវដ្ដីសាសនាចក្រ

*ចូរមកតាមយើងដើម្បីស្វែងរកទីតាំងសំខាន់មួយ នៅក្នុងប្រវត្តិសាស្ត្ររបស់សាសនាចក្រ !*

បើសិន ម៉ែគគី និង លីលី អ៊ី. ចង់ឃើញកន្លែងដែលសាសនាចក្រត្រូវបានរៀបចំឡើងលើកដំបូង នោះពួកគេមិនត្រូវទៅរកឯណានោះទេ ។ វានៅខាងស្ដាំដៃក្បែរទៅនឹងសាលាប្រជុំនៅក្នុងតំបន់ ហ្វាយិត រដ្ឋ នូវយ៉ក ជាកន្លែងដែលពួកគេទៅព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ !

សាសនាចក្រមិនត្រូវបានរៀបចំឡើងនៅក្នុងអគារព្រះវិហារនេះទេ ប៉ុន្តែនៅក្នុងផ្ទះឈើហ៊ុបមួយ ។



ព្យាការី យ៉ូសែប ស្ម៊ីធ បានមកស្នាក់នៅទីនោះជាមួយគ្រួសារ វិតម័រ នៅក្នុងឆ្នាំ 1829 ។ ផ្ទះពីដើមគឺលែងមានតទៅទៀតហើយ ប៉ុន្តែខ្ទមឈើហ៊ុបនេះគឺដាក់តាំងនៅកន្លែងដដែល ។

អគាររបស់សាសនាចក្រដែល ម៉ែគគី និង លីលី ទៅចូលរួមព្រះវិហារនោះ មានមជ្ឈមណ្ឌលរបស់ពួកអ្នកទស្សនាដែលដាក់តាំងមានរួមទាំងផ្ទះរបស់ វិតម័រ និង រឿងពិសេសទាំងឡាយដែលបានកើតមាននៅទីនោះ ។ ■

*1. យ៉ូសែប ស្ម៊ីធ បានបញ្ចប់ការបកប្រែព្រះគម្ពីរមរមននៅទីនេះ ។*



រូបភាពទាំងឡាយដោយ ប្រិន វែលតុន, រចនារូបភាពនានាដោយ រ៉ូប៊ឺត ធី. បារិត © IRI, *ការរៀបចំនៃសាសនាចក្រ*ដោយ រ៉ូប៊ឺត ធី. បារិត, ហាមថតចម្លង



*2. នៅខាងក្រៅមិនឆ្ងាយពីផ្ទះរបស់គាត់ នោះមានបុរសបីនាក់បានឃើញទេវតា មរ៉ូណៃ និង ផ្ទាំងមាស ។ ពួកគេត្រូវបានហៅថា ជាពួកសាក្សីបីនាក់ដោយសារពួកគេបានធ្វើទីបន្ទាល់ ឬ បានឃើញផ្ទាំងទាំងនោះ ។ អ្នកអាចស្វែងរកទីបន្ទាល់របស់ពួកគេនៅផ្នែកខាងមុខនៃព្រះគម្ពីរមរមន ។*



*3. នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 1830 មានមនុស្សប្រហែលជា 60 នាក់បានមកចូលរួមការប្រជុំពិសេសមួយ ។ យ៉ូសែប ស្ម៊ីធ បានរៀបចំសាសនាចក្រជាផ្លូវការណ៍ ហើយពិធីសាក្រាម៉ង់ត្រូវបានប្រសិទ្ធិពរ និង បានចែកដល់ពួកគេ ។ នេះគឺជាការប្រជុំពិធីសាក្រាម៉ង់ជាលើកដំបូង !*

## ពិធីបុណ្យជ្រមុជទឹកនៅពេលនោះ និង នៅពេលនេះ

មែគគី អាយុ 11 ឆ្នាំ និង លីលី អាយុ 9 ឆ្នាំ បានទទួលបុណ្យជ្រមុជទឹក នៅខាងមុខក្បែរទៅនឹងកន្លែងមួយដែលពួកសមាជិកក្នុងសាសនាចក្រដំបូងគេបានទទួលបុណ្យជ្រមុជទឹក ។

ក្មេងស្រីទាំងពីរនាក់នេះមានមានចិត្តរំភើបជាខ្លាំងនៅពេលទទួលបុណ្យជ្រមុជទឹក ។ នៅពេលដែលដល់វេនរបស់ លីលី ដើម្បីទទួលបុណ្យជ្រមុជទឹក នោះនាងបានមានការសម្ភាសន៍ជាមួយនឹងប៊ីស្សពរបស់នាង ។ លីលី បាននិយាយថា « ប៊ីស្សពបានសួរខ្ញុំថា តើខ្ញុំមានទីបន្ទាល់អំពីព្យាការី ហើយថា តើខ្ញុំបានបង់ដង្វាយមួយភាគក្នុងដប់ដែរឬទេ » ។

ក្មេងស្រីទាំងពីរនាក់នេះមានការចងចាំដ៏ល្អអំពីថ្ងៃបុណ្យជ្រមុជទឹករបស់ពួកគេ ។ មែគគី បាននិយាយថា « នៅពេលខ្ញុំងើបចេញពីទឹក ខ្ញុំបានមានអារម្មណ៍ថា ខ្ញុំអាចធ្វើអ្វីៗក៏បានដែរ » ។

ក្មេងស្រីទាំងពីរនាក់បានទិញសៀវភៅកំណត់ហេតុ ដើម្បីពួកគេអាចកត់ត្រានូវអារម្មណ៍របស់ពួកគេ អំពីថ្ងៃដ៏ពិសេសរបស់ពួកគេ ។



*បន្ទាប់ពីការប្រជុំភ្លាម នោះឪពុកម្ដាយរបស់ យ៉ូសែប ស្ម៊ីធ និង មនុស្សមួយចំនួនផ្សេងទៀតត្រូវបានទទួលបុណ្យជ្រមុជទឹកនៅទីឆ្ងាខាងក្រៅ ។*

សម្រាប់កុមារតូចៗ

# ម៉ែខស៍ និង មៀអា ព្យាយាមធ្វើឲ្យបានសម្រេច

**ដោយ គ្រីស ឌៀរី** រដ្ឋ តិចសាស ស.រ.អា.

មែខស៍ បានត្រៀមខ្លួនរួចរាល់ដើម្បីដើរតួជាមហាវីរបុរស ។ គាត់បានពាក់អាវយឺតពណ៌ក្រហម ។ គាត់បានពាក់អាវដណ្ដប់នៃមហាវីរបុរសរបស់គាត់ ។ បន្ទាប់មក គាត់បានទៅបន្ទប់ប្អូនស្រីរបស់គាត់ ។



មែខស៍ បាននិយាយថា « មកនេះ មៀអា » ។ « តោះយើងធ្វើឲ្យសម្រេច ! »

រូបភាពគំនូរ ដោយ អេលីស ប្លាក



មែខស៍ និង មៀអា បានចូលក្នុងបន្ទប់ទទួលភ្ញៀវ ។ ពួកគេបានឃើញកញ្ច្រែងមួយដែលមានសំលៀកបំពាក់ពេញ ។

« តើកូនយល់ព្រមជួយម៉ាក់ទេ ? » ម៉ាក់បានសួរ ។

មែខស៍ បានឆ្លើយថា « យល់ព្រម » ។ « បន្ទាប់មកយើងអាចព្យាយាមធ្វើឲ្យបានសម្រេច » ។





មែខស៍ និង មៀអា បានជួយម៉ាក់បត់សំលៀកបំពាក់ទាំងអស់ ហើយដាក់សំលៀកបំពាក់នោះតាមលំដាប់ ។

បន្ទាប់មក មែខស៍ បានឃើញសំរាមនៅលើកម្រាលឥដ្ឋ ។ មែខស៍ បាននិយាយថា « តោះយើងរើសសំរាមទាំងអស់នោះ » ។ « បន្ទាប់មក យើងអាចព្យាយាមធ្វើឲ្យបានសម្រេច » ។

ម៉ែខស៍ និង មៀអា បានរត់ជុំវិញផ្ទះដើម្បីរកមើលសំរាម ។ ពួកគេបានបោះចោលសំរាមទាំងអស់ដែលពួកគេរកឃើញក្នុងធុងសំរាម ។

ពួកគេបានឃើញម៉ាក់កំពុងបោសសំអាតផ្ទះបាយ ។ ម៉ែខស៍ បាននិយាយថា « ពួកកូនអាចជួយសំអាតម៉ាក់បាន » ។

មៀអា កាន់ប្រដាប់ចូកសំរាមខណៈដែល ម៉ែខស៍ បោសសំអាតនៅលើកម្រាលឥដ្ឋ ។





ម៉ែខស៍ បាននិយាយថា « ឥឡូវនេះចូរយើងព្យាយាមធ្វើឲ្យបានសម្រេច » ។

ម៉ាក់បានសម្លឹងមើលជុំវិញផ្ទះដ៏ស្អាត ។ បន្ទាប់មក ម៉ាក់បានឱប ម៉ែខស៍ និង មៀអា ។ « ម៉ាក់គិតថា កូនៗបានធ្វើរួចរាល់ហើយ ! » ■



# ព្រះយេស៊ូវដើរនៅលើទឹក

« កាលពួកសិស្សឃើញទ្រង់យាងលើទឹកដូច្នេះ នោះក៏ភ័យរស់ ហើយនិយាយថា ខ្មោចលងហើយ រួចពួកគេស្រែកឡើងដោយសេចក្ដីតក់ស្លុត ។

« តែព្រះយេស៊ូវទ្រង់មានបន្ទូលដល់គេភ្លាមថា ចូរសង្ឃឹមឡើង គឺខ្ញុំទេតើ កុំឲ្យភ័យឡើយ »( ម៉ាថាយ 14:26–27 ) ។

រចនារូបភាពដោយ យ៉ារ៉េត បើក ស្រ្តែន

10684_258_Gen News Apr 2/26/13 12:31 PM Page 74

# ព័ត៌មានអំពីសាសនាចក្រ

*សូមមើលគេហទំព័រ news.lds.org សម្រាប់ព័ត៌មាន និង ព្រឹត្តិការណ៍បន្ថែមទៀតរបស់សាសនាចក្រ ។*

## ការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោក—វិធីសាស្ត្រថ្មី



***អែលឌើរ អិល. ថម ភែរី, អែលឌើរ ដូណាល អិល. ហលស្ត្រម និង ប៊ីស្សព ដេន អិម. ដេវីស ដឹកនាំវគ្គនៃការពិភាក្សាស្ដីអំពីសារៈសំខាន់នៃការប្រើប្រាស់កូនសោទាំងឡាយនៃបព្វជិតភាព ។***

ទៅប៉ុន្មានខែខាងមុខនេះ សមាជិកសាសនាចក្រទាំងឡាយជុំវិញពិភពលោក នឹងចូលរួមក្នុងវិធីសាស្ត្រថ្មីមួយដ៏បំផុសគំនិតពីការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោក ។

មិនដូចជាការប្រជុំបំពាក់បំប៉នមុនៗឡើយ ការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោកឆ្នាំនេះ នឹងមិនត្រូវបានចាក់ផ្សាយជាព្រឹត្តិការណ៍តែឯកឯងសម្រាប់អ្នកដឹកនាំវួដ និង ស្តេកទេ ។ ផ្ទុយទៅវិញ ការប្រជុំបំពាក់បំប៉ននេះត្រូវបានបំបែកជាប្រាំបួនវគ្គខ្លីៗ—ដែលមានជា ឌី.វី.ឌី. និង មាននៅលើគេហទំព័រ LDS.org—ដែលលើកទឹកចិត្តឱ្យធ្វើការពិភាក្សាដោយអ្នកដឹកនាំ, សមាជិក និង ក្រុមគ្រួសារទាំងអស់ សម្រាប់ឆ្នាំថ្មីនេះ និង ឆ្នាំបន្ទាប់ៗទៀត ។

ការផ្តោតយ៉ាងជាក់ច្បាស់នៃការប្រជុំបំពាក់បំប៉ននេះគឺ « ការពង្រឹងក្រុមគ្រួសារ និង សាសនាចក្រតាមរយៈបព្វជិតភាព » ។ នៅក្នុងការប្រជុំបំពាក់បំប៉ននេះ សមាជិកនៃគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ រួមជាមួយ និង ពួកអ្នកមានសិទ្ធិអំណាចទូទៅ និង អ្នកមានតំណែងទូទៅទាំងឡាយ ផ្តល់នូវការណែនាំដ៏បំផុសគំនិតស្តីអំពី ៖

- របៀបដែលក្រុមគ្រួសារអាចស្វែងរកភាពរឹងមាំ និង សន្តិភាពតាមរយៈអំណាចបព្វជិតភាព ។
- របៀបដើម្បីជួយគ្រួសារនីមួយៗ ឱ្យពិសោធន៍ពរជ័យទាំងឡាយនៃបព្វជិតភាព ។
- របៀបដែលអស់អ្នកដែលកាន់កូនសោបព្វជិតភាព ពង្រឹងគេហដ្ឋាន និង ក្រុមគ្រួសារ ។
- របៀបដើម្បីបម្រើតាមគំរូទាំងឡាយនៃព្រះគ្រីស្ទ ។
- របៀបដើម្បីចិញ្ចឹមកូនចៅនៅក្នុងពន្លឺ និង សេចក្តីពិត ។

គ្រប់អង្គភាពនៃសាសនាចក្រទាំងអស់នឹងទទួលបាន ឌី.វី.ឌី. ទាំងនោះ ហើយក្រុមប្រឹក្សាវួដ និង ស្តេក ត្រូវបានស្នើសុំដើម្បីមើលឌី.វី.ឌី.នេះ ដែលមានការប្រជុំបំពាក់បំប៉នទាំងអស់នៅក្នុងនោះ ។ បន្ទាប់មកពួកគេគួរតែប្រឹក្សាជាមួយគ្នា អំពីរបៀបដែលពួកគេអាចជួយសមាជិកទាំងឡាយនៃវួដ និង ស្តេកឱ្យទទួលបានប្រយោជន៍ពីការណែនាំនេះ ។

នៅក្នុងការប្រជុំ និង ថ្នាក់រៀនផ្សេងៗទៀត សមាជិកទាំងឡាយអាចមើល និង ពិភាក្សាវគ្គនីមួយៗនៃឌី.វី.ឌី.នេះបាន ។ ក្រុមគ្រួសារ និង បុគ្គលទាំងឡាយអាចមើលវគ្គនៃការប្រជុំបំពាក់បំប៉ននេះ រួមទាំងធនធានបន្ថែមផ្សេងទៀត ដើម្បីស្វែងយល់ការសិក្សារបស់ពួកគេនៅគេហទំព័រ wwlt.lds.org ។

គ្រប់ការប្រជុំនីមួយៗ ផ្នែកដែលមានឥទ្ធិពលខ្លាំងបំផុតនៃការប្រជុំបំពាក់បំប៉ននេះ នឹងកើតមានឡើងបន្ទាប់ពីមើលវគ្គមួយចប់ ហើយក៏ចាប់ផ្តើមការពិភាក្សាគ្នាតែម្តង ។ នៅពេលពួកអ្នកដឹកនាំ, សមាជិក និង ក្រុមគ្រួសារទាំងឡាយគិតពិចារណា ចែកចាយ និង ថ្លែងទីបន្ទាល់អំពីអ្វីដែលពួកគេបានឮ និង ទទួលអារម្មណ៍ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិត និង បង្រៀនពួកគេ ពីរបៀបដើម្បីអនុវត្តការណែនាំនេះនៅក្នុងកាលៈទេសៈផ្ទាល់ខ្លួនទាំងឡាយរបស់ពួកគេ ។ តាមរយៈបទពិសោធន៍ទាំងនេះ នោះការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោក នឹងជួយពង្រឹងក្រុមគ្រួសារ និង សាសនាចក្រនៅទូទាំងពិភពលោក ។ ■

***ឈរនៅខាងក្រៅផ្ទះ ម៉ារី ហ្វៀលឌីង ស្មីធ នៅក្នុង This Is the Place Heritage Park, អែលឌើរ អិម. រ័សុល បាឡឺដ, លីនដា ខេ. ប៊ើតន់, អែលឌើរ រ៉ាណុល អេ. រ៉ាសបាន, អេលែន អេស. ដាល់ថុន, រ៉ូស ម៉ារី អិម. វីស្ស្រម និង ប៊ីស្សព ហ្គារី អ៊ី. ស្ទីវិនសុន ពិភាក្សាគ្នាអំពីពរជ័យទាំងឡាយនៃការមានអ្នកកាន់បព្វជិតភាពនៅក្នុងផ្ទះនីមួយៗ ។***



10684_258_Gen News Apr 2/26/13 12:31 PM Page 75

**ការឆ្លើយតបចំពោះការហៅ ដើម្បីឱ្យមានអ្នកផ្សព្វផ្សាយសាសនាបន្ថែមទៀត ៖**

# ការបណ្ដុះគំនិតនៃការធ្វើជាអ្នកផ្សព្វផ្សាយសាសនានៅឯគេហដ្ឋាន និង នៅក្នុងសាសនាចក្រ ។

**ដោយ ហ៊ីតធើរ វិតថល ហ្វ្រីចលី**
ព័ត៌មាន និង ព្រឹត្តិការណ៍នានាអំពីសាសនាចក្រ

ប៊ីស្សព វ៉ិចទ័រ ណូហ្គេលស៍ នៃ វួដ ផាក ឆាកាប៊ូកូ នៃស្តេក ប៊ុយណូ អ៊ែរេស អាហ្សង់ទីន កុងហ្គេសូ អង្គុយនៅពីមុខ ក្ដារខៀនបិទប្រកាស ដែលមានពេញដោយរូបថតរបស់យុវជន និង យុវនារីចំនួន 37 នាក់នៅក្នុងវួដរបស់គាត់ ។ នៅពេលមាននរណាម្នាក់ចេញបម្រើបេសកកម្ម នោះគាត់សរសេរកំណត់សម្គាល់នៅក្បែររូបថតនោះ ។

គាត់បាននិយាយថា « យុវវ័យរបស់ខ្ញុំ មានអារម្មណ៍រីករាយក្រៃលែង នៅពេលពួកគេបានមកការិយាល័យរបស់ខ្ញុំ ហើយមើលរូបថត និង កំណត់សម្គាល់ទាំងនោះ ។ រូបថត និង កំណត់សម្គាល់ទាំងនោះជម្រុញឱ្យពួកគេរៀបចំខ្លួនសម្រាប់បេសកកម្មផ្ទាល់របស់ពួកគេ » ។

វួដនេះនៅក្នុងទីក្រុង ប៊ុយណូ អ៊ែរេស បង្ហាញពីវិញ្ញាណនៃកិច្ចការអ្នកផ្សព្វផ្សាយសាសនា ។ នៅក្នុងប្រាំមួយខែដំបូងក្នុងឆ្នាំ 2012 មានយុវវ័យ 19 នាក់—ក្នុងនោះមាន 14 នាក់ជាអ្នកប្រែចិត្តជឿ—បានចាកចេញពីផ្ទះរបស់ពួកគេ ទៅបម្រើបេសកកម្មពេញម៉ោងនៅក្នុងប្រទេសចំនួនប្រាំបី ។ មានយុវវ័យដែលមានសមត្ថភាពច្រើនជាង 80 ភាគរយ បានប្ដេជ្ញាចិត្តដើម្បីបម្រើបេសកកម្ម ។

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អ្នកដឹកនាំសាសនាចក្របានស្នើសុំបីបួនដងថា សុំឱ្យយុវវ័យបន្ថែមទៀតបម្រើបេសកកម្ម ។

អំឡុងសន្និសីទទូទៅខែ មេសា ឆ្នាំ 2005 បន្ទាប់ពីសាសនាចក្របានបោះពុម្ពចេញសៀវភៅ *ប្រកាសដំណឹងល្អរបស់យើងភ្លាមៗ ៖ សេចក្ដីណែនាំចំពោះការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា* អែលឌើរ អិម. រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានទូន្មានក្រុមគ្រួសារ និង អ្នកដឹកនាំទាំងឡាយ ឱ្យបណ្ដុះគំនិត នៃការផ្សព្វផ្សាយសាសនា និង រៀបចំយុវជន និង យុវនារីបន្ថែមទៀត ដើម្បីបម្រើដោយកិត្តិយស ក្នុងជួយពួកគេឱ្យយល់ថាតើពួកគេគឺជានរណា ហើយដោយបង្រៀនគោលលទ្ធិដល់ពួកគេ (សូមមើល « បន្ថែមទៀត » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2005 ទំព័រ 69) ។

ការប្រកាសរបស់ប្រធាន ថូម៉ាស អេស. ម៉នសុន អំឡុងសន្និសីទទូទៅខែ តុលា ឆ្នាំ 2012 បាននិយាយថា ការកំណត់អាយុអ្នកផ្សព្វផ្សាយសាសនាឱ្យតិចជាងមុននោះ គឺជាការរំឭកមួយទៀតថា ព្រះអម្ចាស់កំពុងបង្ហើយកិច្ចការរបស់ទ្រង់ ។

សព្វថ្ងៃនេះ មានក្រុមគ្រួសារ និង អ្នកដឹកនាំសាសនាចក្រ ជាច្រើន កំពុងពាំនាំសារលិខិតទាំងនេះទៅកាន់ដួងចិត្ត និង បង្កើតប្រពៃណីដ៏រុងរឿងមួយនៃកិច្ចការផ្សព្វផ្សាយសាសនា នៅក្នុងតំបន់របស់ពួកគេ ។

## ការជួយឱ្យយុវវ័យយល់ថា តើពួកគេគឺជានរណា

ចម្លើយចំពោះសំណួរនេះ « តើអ្នកអាចរៀបចំយុវវ័យជាច្រើនរបស់អ្នក ឱ្យមានបំណងបម្រើដោយរបៀបណា ? » ប៊ីស្សព ណូហ្គេលស៍ បានឆ្លើយថា « នៅពេលខ្ញុំត្រូវបានហៅធ្វើជា ប៊ីស្សព កង្វល់ទីមួយរបស់ខ្ញុំនោះគឺ យុវវ័យនៅក្នុងវួដរបស់ខ្ញុំ ហើយខ្ញុំបានធ្វើឱ្យអ្នកដឹកនាំវួដដទៃផ្សេងទៀតដឹងច្បាស់ថា យើងចាំបាច់ត្រូវតែធ្វើជាចំណែកមួយនៃជីវិតរបស់ពួកគេ » ។

ឧទាហរណ៍ គ្រប់អ្នកផ្សព្វផ្សាយសាសនាទាំងអស់នៃវួដ ឆាកាប៊ូកូ មានការហៅបម្រើនៅក្នុងវួដមុនពេលការចេញបម្រើរបស់ពួកគេ ។ ជាញឹកញាប់ សមាជិកប្រែចិត្តជឿថ្មីៗ និង សមាជិកមិនសូវសកម្ម ត្រូវបានអញ្ជើញដើម្បីបម្រើជា គ្រូបង្រៀន ដែលជួយពួកគេឱ្យរៀបចំខ្លួន ដើម្បីបង្រៀនដំណឹងល្អ ។

ប៊ីស្សព ណូហ្គេលស៍ ក៏បានរៀបចំសម្រាប់យុវវ័យ ឱ្យរៀបចំខាងវិញ្ញាណ សម្រាប់បេសកកម្ម ដោយធ្វើការជាមួយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក្នុងមូលដ្ឋាន ។

នៅពេលអ្នកដឹកនាំ និង សមាជិកសាសនាចក្រទាំងឡាយបានប្ដេជ្ញាចិត្តរបស់ពួកគេ ចំពោះយុវវ័យក្នុងវួដនោះពួកគេបានរីករាយ ដោយឃើញវិញ្ញាណនៃការផ្សព្វផ្សាយសាសនាបានរីកដុះដាលឡើង ។

## គ្រួសារផ្ដោតចិត្តលើកិច្ចការផ្សព្វផ្សាយសាសនា

ហ្គាថ និង អេឡូអ៊ីស អែនដ្រ័ស មកពី ទីក្រុង ត្រាបភើរ រដ្ឋ យូថាហ៍ ស.រ.អា. ដឹងពីអត្ថន័យនៃឃ្លាថា គ្រួសារផ្ដោតចិត្តលើកិច្ចការផ្សព្វផ្សាយសាសនា ។ ពួកគាត់មានចៅ 17 នាក់ដែលបានបម្រើបេសកកម្ម ហើយពួកគាត់បានបម្រើបេសកកម្មរបស់គាត់ប្រាំមួយដងហើយ ។

បងប្រុស អែនដ្រ័ស បាននិយាយថា ការ បង្កើតវិញ្ញាណនៃកិច្ចការផ្សព្វផ្សាយសាសនា នៅក្នុងគ្រួសាររបស់អ្នក គឺជាអ្វីមួយដែលចាប់ផ្ដើមតាំងពីកូនៗនៅតូច ។

បងស្រី អែនដ្រ័ស បានយល់ស្រប ។ គាត់បាននិយាយថា « អ្នកមិនមែនទៅបម្រើបេសកកម្ម ដោយមិនបាននិយាយពីបេសកកម្មនោះទេ ប៉ុន្តែអ្នកនិយាយប្រាប់កូន និង ចៅៗរបស់អ្នកអំពីបេសកកម្ម ដោយរំពឹងថាពួកគេនឹងបម្រើបេសកកម្ម ដោយមិនចាំបាច់សួរថាតើ—នៅពេលណា កូនៗទៅបម្រើបេសកកម្ម ហើយក៏មិនសួរថាបើសិនជា ពួកគេចង់ទៅបម្រើបេសកកម្ម ឬអត់នោះទេ » ។

ការបង្រៀនយុវវ័យ ឱ្យដឹងថាពួកគេជានរណា ដោយការធ្វើជាគំរូនៃកិច្ចការផ្សព្វផ្សាយសាសនា គឺជាចំណុចមួយសំខាន់ផងដែរ ។ បងប្រុស និង បងស្រី អែនដ្រ័ស បានទទួលការហៅដំបូងរបស់ពួកគេនៅក្នុងឆ្នាំ 1980 គឺនៅចំពេលដែលកូនប្រុសពៅរបស់ពួកគេចេញបម្រើបេសកកម្មរបស់គាត់ ។

ចៅប្រុសម្នាក់បានសរសេរទៅពួកគេ បន្ទាប់ពីបាន

10684_258_Gen News Apr 2/26/13 12:32 PM Page 76

រូបថតដោយ ជល អិល. ក្លាំង



*ប៊ីស្សព វ៉ិចទ័រ ណូហ្គេលស៍ ឈរនៅក្ដារខៀនបិទប្រកាស ដែលបង្ហាញពីយុវវ័យទាំងអស់នៅក្នុងវួដរបស់គាត់ រួមទាំងអ្នក ដែលកំពុងបម្រើបេសកកម្មនាពេលបច្ចុប្បន្ននេះ ។*

ទទួលអំណោយមួយ ដែលពួកគេបានផ្ញើ ដើម្បីជួយគាត់ឱ្យ រៀបចំសម្រាប់បេសកកម្មរបស់គាត់ ។ បងស្រី អែនដ្រ័ស បាននិយាយថា « គាត់បានអរគុណយើង [សម្រាប់ អំណោយនោះ] ប៉ុន្តែ គាត់បាននិយាយថា ‘ អ្វីដែល សំខាន់ជាងនោះគឺ ចៅសូមអរគុណចំពោះគំរូល្អដែលយាយ តាបានផ្ដល់ឱ្យចៅ ’» ។

## ការបង្រៀនគោលលទ្ធិ

អែលឌើរ បាឡឺដ បានមានប្រសាសន៍ថា « យុវវ័យរបស់យើងមានសិទ្ធិដើម្បីសង្ឃឹមថា ឪពុកម្ដាយ និង អ្នកដឹកនាំសាសនាចក្រ និង គ្រូបង្រៀនរបស់ពួកគេ នឹងឃើញថា ពួកគេដឹង និង យល់ពីដំណឹងល្អរបស់ ព្រះយេស៊ូវគ្រីស្ទ ។ ព្រះវិញ្ញាណបរិសុទ្ធ នឹងបញ្ជាក់សេចក្ដីពិត ដល់ដួងចិត្តរបស់ពួកគេ ហើយនឹងបញ្ឆេះពន្លឺនៃព្រះគ្រីស្ទ នៅក្នុងព្រលឹងទាំងឡាយរបស់ពួកគេ ។ ហើយបន្ទាប់ មកអ្នកនឹងមានអ្នកត្រៀមផ្សព្វផ្សាយសាសនាយ៉ាង ពេញលេញម្នាក់ទៀត » (អិម. រ័សុល បាឡឺដ « បន្ថែមទៀត » ទំព័រ 71) ។

នៅចម្ងាយប្រមាណជា 6000 ម៉ាយ (9600 គីឡូម៉ែត្រ) ពី ប៊ូណូស អ៊ែរេស ជាតំបន់ ជនបទនៃសាខា ហស៍ស៊ូ បែន នៅក្បែរ ប៊ិយស៊ី រដ្ឋ អៃដាហូ ស.រ.អា. ក៏បានឃើញមានការកើន ឡើងក្នុងកិច្ចការផ្សព្វផ្សាយសាសនាយ៉ាងខ្លាំង នៅពេលដែលក្រុមគ្រួសារ និង អ្នកដឹកនាំបានពង្រឹង កិច្ចខិតខំដើម្បីបង្រៀន ដំណឹងល្អដល់យុវវ័យ របស់ពួកគេ ។

ចេញមកពីសាខាដ៏តូចមួយដែលមាន សមាជិក 75 នាក់ នោះមានយុវវ័យប្រាំបួននាក់ កំពុងបម្រើបេសកកម្ម ។

អែលឌើរ រ័សុល អិម. ណិលសុន នៃកូរ៉ុមនៃពួក សាវកដប់ពីរនាក់ បានគូសបញ្ជាក់ពីហេតុផល និង សារៈប្រយោជន៍នៃការបម្រើ ។ លោកមាន ប្រសាសន៍ថា « អ្នកផ្សព្វផ្សាយសាសនាទាំងអស់ . . . បម្រើដោយក្ដីសង្ឃឹមថា នឹងជួយឱ្យមនុស្សដទៃ ទទួលបានជីវិតប្រសើរឡើង ។ ការសម្រេចចិត្តដើម្បី បម្រើបេសកកម្ម នឹងមានឥទ្ធិពលលើជោគវាសនា ខាងវិញ្ញាណ របស់អ្នកផ្សព្វផ្សាយ ហើយ នឹងញាតិ សន្តានខ្លួន សម្រាប់ជំនាន់ខាងមុខ ។ ឆន្ទៈដើម្បីបម្រើ គឺជាភស្តុតាងធម្មតាមួយរបស់អ្នកប្រែចិត្តជឿ សក្តិសម និង រៀបចំ » (« *សូមសួរអ្នកផ្សព្វផ្សាយទៅ ! ពួកគេ អាចជួយអ្នកបាន !* » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 17) ។

ម៉ាទីន វ៉ែកឃើរ ប្រធានស្តេក អ៊ីមមែត អៃដាហូ បានយល់ស្រប ។ គាត់បាននិយាយថា « ការបម្រើ បេសកកម្ម គឺដាក់យុវវ័យម្នាក់ឱ្យនៅលើផ្លូវមួយ ដែល នឹងជះឥទ្ធិពលលើជំនាន់ជាច្រើនទៀត ។ ក្នុងនាម យើងជាសមាជិកស្តេក យើងធ្វើអ្វីៗគ្រប់យ៉ាង ដែលយើង អាចធ្វើបាន ដើម្បីរៀបចំយុវវ័យសម្រាប់កិច្ចការផ្សព្វផ្សាយ សាសនា » ។

ផ្នែកមួយនៃការរៀបចំនោះ រួមមានក ការបង្រៀន យុវវ័យពីគោលលទ្ធិនេះ ។ យុវវ័យនៅក្នុងសាខា ហស៍ស៊ូ បែន បានចូលរួមថ្នាក់រៀបចំអ្នកផ្សព្វផ្សាយ សាសនាប្រចាំសប្ដាហ៍ ដែលបង្រៀនដោយអតីតប្រធាន បេសកកម្មម្នាក់—គឺជាការប្រជុំបំពាក់បំប៉នដែល បន្ថែមលើការប្រជុំបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ដែល ធ្វើឡើងដោយការប្រជុំរៀបចំអ្នកផ្សព្វផ្សាយ សាសនាយុវវ័យរបស់ស្តេករៀងរាល់ខែ និង ការបោះជំរុំ ប្រចាំឆ្នាំរបស់បព្វជិតភាពអើរ៉ុន ។

ឡារ៉ែន អ័ដាម—ដែលកូនម្នាក់ក្នុងចំណោម កូនប្រាំមួយនាក់របស់បងប្រុស និង បងស្រី អែនដ្រ័ស —បានបម្រើជាមួយស្វាមីរបស់គាត់ គឺ ជីម នៅក្នុង បេសកកម្ម ខូភិនហេហ្គិន ដាណាម៉ាក ចាប់ពីឆ្នាំ 2007 ដល់ 2009 ។ គាត់បានថ្លែងទីបន្ទាល់ពី សារសំខាន់ នៃការបង្រៀនដំណឹងល្អដល់កូនៗនៅ ក្នុងផ្ទះ ។

គាត់និយាយថា « អ្វីមួយដែលអស្ចារ្យបំផុត ដែលអ្នកអាចធ្វើបាន ដើម្បីជួយកូនៗរបស់អ្នក សាង ទីបន្ទាល់នៃកិច្ចការផ្សព្វផ្សាយសាសនា គឺធ្វើរាត្រីជួបជុំ ក្រុមគ្រួសារ និង សិក្សាព្រះគម្ពីរជាគ្រួសាររបស់អ្នក ។ បើសិនអ្នកបានផ្ដល់នូវគ្រឹះដ៏រឹងមាំនៃការសិក្សា ដំណឹងល្អ និង ចំណេះដឹងនៃដំណឹងល្អនេះហើយ នោះពួកគេនឹងរៀបចំខ្លួន និង ដឹងបានកាន់តែជ្រៅជ្រះ អំពីដំណឹងល្អ » ។ ■

10684_258_Gen News Apr 2/26/13 12:32 PM Page 77

# អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងផ្នែកសេវាកម្មសាសនាចក្ររកឃើញសេចក្ដីអំណរក្នុងការបម្រើ

**ដោយ ខារ៉ូលីន ខាធើរ**
ព័ត៌មាន និង ព្រឹត្តិការណ៍ទាទាំងពីសាសនាចក្រ

អែលឌើរ អ៊ីណែស្ត សារ៉ាបៀ ស្ពាយកាបូបអ្នកផ្សព្វផ្សាយពណ៌ខ្មៅរាល់ថ្ងៃក្នុងបេសកកម្មរបស់គាត់ ។ ប៉ុន្តែការចាត់តាំងបេសកកម្មរបស់គាត់ គឺប្លែកពីការចាត់តាំងបេសកកម្មផ្សេងៗ—អែលឌើរ សារ៉ាបៀ បានបម្រើជាអ្នកផ្សព្វផ្សាយសាសនាផ្នែកសេវាកម្មសាសនាចក្រ (YCSM) នៅក្នុងការិយាល័យបេសកកម្ម ហ៊ើរម៉ូស៊ីឡូ ម៉ិកស៊ិកូ ។

អែលឌើរ អិម. រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « យើងទទួលស្គាល់ថា វាប្រហែលជាគ្មានភាពវៃឆ្លាតសម្រាប់យុវជន និង យុវនារីមួយចំនួនរបស់យើង ដើម្បីជួបប្រទះនឹងការគាប់សង្កត់ និង ឧបគ្គសទាំងឡាយនៃបេសសកម្មពេញម៉ោងនោះទេ » ។ ប៉ុន្តែអ្វីដែលលោកបានមានប្រសាសន៍មិនមែនមានន័យថា ពួកគេមិនអាចចូលរួមនៅក្នុងពរជ័យនៃកិច្ចការផ្សព្វផ្សាយសាសនាឡើយ (« បន្ថែមទៀត » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2005 ទំព័រ 69) ។



អែលឌើរ រ័សុល អិម. ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « បេសកកម្មគឺជាទង្វើស្ម័គ្រចិត្តដើម្បីបម្រើដល់ព្រះ និង មនុស្សជាតិ » (សូមសួរអ្នកផ្សព្វផ្សាយទៅ ! ពួកគេអាចជួយអ្នកបាន ! » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 18) ហើយមានរបៀបជាច្រើននៃការផ្ដល់ការបម្រើនោះ ។

សម្រាប់អស់អ្នកដែលត្រូវបានដោះលែងដោយកិត្តិយសពីការបម្រើបេសកកម្មផ្សព្វផ្សាយពេញម៉ោង ឬសម្រាប់អស់អ្នកដែលត្រូវតែត្រឡប់មកផ្ទះវិញមុនកាលកំណត់ នោះកម្មវិធី YCSM អាចផ្ដល់បទពិសោធន៍បេសកកម្មយ៉ាងមានអត្ថន័យ ។

## គុណសម្បត្តិទាំងឡាយដើម្បីបម្រើ

អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងផ្នែកសេវាកម្មសាសនាចក្រ ត្រូវតែអាចបំពេញកាតព្វកិច្ចនៃការហៅបម្រើរបស់ពួកគេដោយមានសុខភាពល្អ, សតិស្មារតីនឹងធឹង, វិញ្ញាណរឹងមាំ និង មានអារម្មណ៍រំភើប ដែលពួកគេត្រូវបានផ្ដុកផ្ដាក់យ៉ាងយកចិត្តទុកដាក់ ។

អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងផ្នែកសេវាកម្មសាសនាចក្រ បម្រើចន្លោះពេលចាប់ពី 6 ទៅ 24 ខែ ហើយអាចបម្រើចាប់ពីពីរថ្ងៃក្នុងមួយសប្ដាហ៍ទៅ បម្រើពេញម៉ោង ។ មានឱកាសជាច្រើនដើម្បីបម្រើនៅក្នុងសហគមន៍ ព្រមទាំងការបម្រើមកពីផ្ទះ ។ ការចាត់តាំងដ៏មានសក្ដានុពលរបស់អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងផ្នែកសេវាកម្មសាសនាច្រក រួមមាន ការស្រាវជ្រាវកិច្ចការពង្សប្រវត្តិ, ព័ត៌មានបច្ចេកទេសវិទ្យា, ជំនួយការការិយាល័យបេសកកម្ម, ឃ្លាំងរបស់ប៊ីស្សព ហើយនឹងមានច្រើនថែមទៀត ។

## ការគាំទ្រគ្រួសារ និង បព្វជិតភាព

ឪពុកម្ដាយ, ពួកអ្នកដឹកនាំបព្វជិតភាព និង សមាជិកសាសនាចក្រទាំងឡាយ អាចជួយអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងផ្នែកសេវាកម្មសាសនាច្រកដែលមានសក្ដានុពលឱ្យរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ។

គ្រួសាររបស់ ស៊ីស្ទើរ អ៊ីលីស្សា ជយ យ៉ាំង បានធ្វើការគាំទ្រយ៉ាងខ្លាំងដល់គាត់ ដោយជូនដំណើរគាត់ទាំងទៅទាំងមក ទៅកាន់ការិយាល័យសាសនាចក្រនៅក្នុងទីក្រុងស៊ីដនី ប្រទេស អូស្ត្រាលី ។

អែលឌើរ ម៉ៃឃើល ហីលឡាម ដែលធ្វើការនៅក្នុងមជ្ឈមណ្ឌលចែកចាយនៃទីក្រុង ហុងកុង បាននិយាយថា « គ្រូបង្រៀនថ្នាក់សិក្ខាសាលាពេលព្រឹកព្រលឹមរបស់ខ្ញុំ និង អ្នកដឹកនាំថ្នាក់យុវជនបានជួយរៀបចំខ្ញុំឱ្យត្រៀមខ្លួន » ។

## ការលះបង់នាំមកនូវពរជ័យ

ស៊ីស្ទើរ យ៉ាំង បានលះបង់ថ្ងៃឈប់សម្រាកពីការងារក្រៅម៉ោងរបស់គាត់ ដើម្បីបម្រើបេសកកម្មផ្នែកសេវាកម្មសាសនាចក្រ ។ គាត់និយាយថា « ខ្ញុំមានអារម្មណ៍កាន់តែខិតជិតព្រះវរបិតាសួគ៌របស់ខ្ញុំ ដោយដឹងថាខ្ញុំកំពុងជួយទ្រង់ » ។

លើសពីពរជ័យខាងវិញ្ញាណ ការបម្រើបេសកកម្មផ្នែកសេវាកម្មសាសនាចក្រ ផ្ដល់ឱកាសខាងសង្គម និង វិជ្ជាជីវៈដ៏មានតម្លៃជាច្រើនដល់អ្នកផ្សព្វផ្សាយសាសនាវ័យក្មេង ។ ស៊ីស្ទើរ យ៉ាំង បាននិយាយថា « បេសកកម្មរបស់ខ្ញុំបានបង្ហាញខ្ញុំថា ខ្ញុំអាចធ្វើការដោយឯករាជ្យ » ។ (កាលពីមុនគាត់ធ្លាប់ធ្វើការដោយសារតែមានជំនួយ) ។

បើទោះបីជាមជ្ឈិមវ័យវ័យក្មេងទាំងអស់ដែលអាចបម្រើហើយមិនចង់បម្រើ ធ្វើការខិតខំដ៏អស្ចារ្យដើម្បីសម្រុះសម្រួលមជ្ឈិមវ័យវ័យក្មេងគ្រប់រូប ។ យុវជន និង យុវនារីទាំងឡាយដែលចង់បម្រើតាមរបៀបនេះ អាចនិយាយជាមួយប៊ីស្សព ឬប្រធានសាខារបស់ពួកគេ ដែលអាចរកឱកាសសមរម្យជាច្រើនសម្រាប់ពួកគេ ។

សូមអានបន្ថែមទៀតនៅគេហទំព័រ news.lds.org ដោយស្វែងរក « young church-service missionaries » ។ ■

10684_258_Gen News Apr 2/26/13 12:32 PM Page 78

# អ្នកដឹកនាំយុវនារី និង សមាគមសង្គ្រោះទូទៅធ្វើទស្សនកិច្ចទៅតំបន់អាស៊ី

**ដោយ ប្រែនដា ហ្វ្រែនសិន អ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយតំបន់អាស៊ី**

ដោយមានជំនួយមកពី ដេវីឌ អ្វ. ហ៊ីព, ផល ស្ទីវីន និង លីនដា វ៉េ ផន ស្មីធ

អស់រយៈប្រាំបួនថ្ងៃក្នុងខែ វិច្ឆិកា ឆ្នាំ 2012 ម៉ារី អិន. យុក ទីប្រឹក្សាទីមួយក្នុងគណៈប្រធានយុវនារីទូទៅ និង លីនដា អេស. រីវស៍ទីប្រឹក្សាទីពីរក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ បានណែនាំ និង បំផុសបងប្អូនស្រីទាំងក្មេងទាំងចាស់នៅទូទាំងតំបន់អាស៊ីទាំងមូល ។

ដំណើរការនេះ ជួនពេលនឹងការប្រកាសនៃកម្មវិធីយុវជនកែប្រែថ្មី *Come, Follow Me* ដែលយុវជន យុវនារី និង ថ្នាក់សាលាថ្នាក់សាលាថ្ងៃអាទិត្យរបស់យុវជន នឹងចាប់ផ្ដើមប្រើនៅក្នុងខែ មករា ឆ្នាំ 2013 ។ កម្មវិធីសិក្សាថ្មីនេះ ត្រូវបានរៀបចំឡើង ដើម្បីជួយគ្រូបង្រៀនឱ្យបង្រៀនកាន់តែដូចជាព្រះគ្រីស្ទបានបង្រៀន ហើយអភិវឌ្ឍទំនាក់ទំនងកាន់តែរឹងមាំជាមួយសមាជិកទាំងឡាយក្នុងថ្នាក់រៀន ។

បន្ទាប់ពីទស្សនកិច្ចរបស់ស៊ីស្ទើរ យុក និង ស៊ីស្ទើរ រីវស៍ទៅកាន់តំបន់អាស៊ី នោះមានយុវវ័យអាស៊ីជាច្រើន និង ឪពុកម្ដាយរបស់ពួកគេបានគិតថា ឥឡូវនេះពួកគាត់កាន់តែជម្រុញចិត្ត ឱ្យមានភាពបរិសុទ្ធ និង ផ្ដោតចិត្តទុកដាក់ឡើងវិញលើជីវិតរបស់ពួកគេ ហើយក្លាយជាគំរូដល់អ្នកនៅក្នុងសហគមន៍ក្នុងមូលដ្ឋានរបស់ពួកគេ ។

ស៊ីស្ទើរ រីវស៍បានសន្ទនាជាមួយយុវវ័យ នៅក្នុងទីក្រុង ហុងកុង ថា « បើសិនអ្នកនៅតែរក្សាជីវិតរបស់អ្នកឱ្យបានស្អាតស្អំ នោះអ្នកអាចឈរដោយមានទំនុកចិត្តនៅមុខមនុស្សគ្រប់គ្នា ! »

***នៅក្នុងប្រទេស តៃវ៉ាន់ ម៉ារី អែន. យុក និង លីនដា អេស. រីវស៍ បានជួបជាមួយពួកអ្នកមានសិទ្ធិអំណាចក្នុងតំបន់ និង អ្នកដឹកនាំបព្វជិតភាព និង សមាជិកជនជាតិតៃវ៉ាន់ ។***



ថតរូបដោយ វែង ឈី វិន

ដោយបានទទួលការបំផុសគំនិតដោយពាក្យសម្ដីរបស់គាត់នោះ តាង កាក ខិ អាយុ 12 ឆ្នាំ បាននិយាយបន្ទាប់ពីការប្រជុំនោះថា « ខ្ញុំដឹងថា ខ្ញុំត្រូវតែព្រះគម្ពីរមរមនរាល់ថ្ងៃ ។ រៀនដើម្បីប្រែចិត្ត និង រស់នៅដោយសុចរិតគឺជាអ្វីដែលស្បៀវភៅដើម្បីកម្លាំងនៃយុវជន បានបង្រៀន ការធ្វើដូច្នោះ ពន្លឺនៃព្រះគ្រីស្ទ និង សុភមង្គលពិតអាចជ្រួតជ្រាបពេញដួងចិត្តខ្ញុំ » ។

នៅក្នុងប្រទេស ឥណ្ឌា ស៊ីស្ទើរ យុក បានជួបជាមួយសមាជិកជាច្រើននៅក្នុងសាលាប្រជុំនៅក្នុង មណ្ឌល ជិនទា ឥណ្ឌា និង សមាជិកជាច្រើនមកពីស្ដេក ហៃដ្រាបាដ ឥណ្ឌា និង បានដាស់តឿនមជ្ឈិមវ័យវ័យក្មេង ឱ្យត្រៀមខ្លួនសម្រាប់ពេលអនាគត ។ គាត់បានជម្រុញដោយទទូចថា « សូមផ្ដល់គុណសម្បត្តិគ្រប់គ្រាន់សម្រាប់ខ្លួនឯង ដោយការអប់រំ ជាមួយនឹងជំនាញទាំងឡាយ ដើម្បីជួយអ្នកក្នុងការស្ថាបនានគរ ។ សូមផ្ដោតចិត្តលើគ្រួសាររបស់អ្នក និង អ្វីដែលអ្នកអាចធ្វើដើម្បីប្រទានពរដល់សមាជិកគ្រួសាររបស់អ្នក ហើយដោយសារការរៀបចំខាងវិញ្ញាណរបស់អ្នក ដូច្នេះអ្នកនឹងសក្តិសមចំពោះការបំផុសខាងវិញ្ញាណទាំងនោះ ហើយអ្នកនឹងដឹងកន្លែងដែលត្រូវទៅ និង អ្វីដែលត្រូវធ្វើ » ។

នៅក្នុងប្រទេស ឥណ្ឌូនេស៊ី ស៊ីស្ទើរ រីវស៍បានចូលរួមសន្និសីទស្ដេកដំបូងគេ នៃស្ដេកថ្មីឈ្មោះ ស៊ូរ៉ាកាតា ឥណ្ឌូនេស៊ី ។ « យើងមានអារម្មណ៍នៃវិញ្ញាណដ៏រាបទាប និង ជាទីស្រឡាញ់របស់ពួកគេ ។ ឱសមាជិកដ៏ស្មោះត្រង់ទាំងឡាយអើយ ! » គាត់បានមានប្រសាសន៍ថាដូច្នេះ ។

បន្ទាប់មកទៀត ស៊ីស្ទើរ រីវស៍បានទៅធ្វើទស្សនកិច្ចនៅប្រទេស ម៉ាឡេស៊ី ជាកន្លែងដែលគាត់បានពិភាក្សាជាមួយបងប្អូនស្រីសមាគមសង្គ្រោះមួយក្រុម អំពីបញ្ហាសំខាន់បំផុត សម្រាប់សមាគមសង្គ្រោះក្នុងនាមជាអង្គការមួយក្នុងប្រទេស ម៉ាឡេស៊ី និង របៀបដែលសាសនាចក្រអាចផ្ដល់ការណែនាំ និង ការបំផុសគំនិត ។

នៅក្នុងប្រទេស តៃវ៉ាន់ ស៊ីស្ទើរ រីវស៍បានមានប្រសាសន៍ស្ដីអំពីកម្លាំង និង ការលះបង់របស់សមាជិកទាំងឡាយក្នុងមូលដ្ឋាននោះ ។ គាត់បានមានប្រសាសន៍ថា « យើងមានភាពរីករាយ ដើម្បីដឹងពីការរស់នៅដ៏ស្មោះត្រង់របស់ពួកគេ និង ការបន្តចូលរួមព្រះវិហារបរិសុទ្ធ ។ . . . សមាជិកទាំងឡាយគឺជាគំរូដ៏គួរឱ្យស្រឡាញ់ចំពោះមិត្តភក្ដិ និង អ្នកជិតខាងរបស់ពួកគេ » ។ ■

10684_258_Gen News Apr 2/26/13 12:32 PM Page 79

## នៅជុំវិញសាសនាចក្រ



*យុវវ័យនៅជុំវិញ ពិភពលោកបង្ហាញ ពីរបៀបដែល ពួកគេកំពុងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ។*

### ការអំពាវនាវរកថតរូបទាំងឡាយរបស់យុវវ័យ

បាវចនាម្ភ៉ូតឆលឆ្នាំនេះគឺ « ចូរអ្នករាល់គ្នាឈរក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ » (គ. និង ស. 87:8) ។ យុវជន និង យុវនារីទាំងឡាយអើយ ! ទស្សនាវដ្ដី លីអាហូណា កំពុងតែស្វែងរករូបថតទាំងឡាយរបស់អ្នក ដែលឈរនៅលើទីបរិសុទ្ធទាំងឡាយ ។ រូបថតទាំងនោះ អាចជារូបថតដែលបង្ហាញថាអ្នកចំណាយពេលជាមួយគ្រួសារ, ការបម្រើ, ធ្វើកិច្ចការផ្សព្វផ្សាយសាសនា, គូរគំនូរ, ការសិក្សាដំណឹងល្អ, ការធ្វើដំណើររុករកក្នុងធម្មជាតិ និង អ្វីៗជាច្រើនទៀត ! នេះជារបៀបដើម្បីបញ្ជូនរូបថតរបស់អ្នក ៖

- សុំឱ្យនរណាម្នាក់ថតរូបរបស់អ្នក ដែលឈរនៅក្នុងទីបរិសុទ្ធមួយ ។
- សូមផ្ញើរអ៊ីម៉ែលរូបថតដ៏ច្បាស់ល្អរបស់អ្នកទៅកាន់ liahona@ldschurch.org ។
- សូមបន្ថែមសារលិខិតមួយអំពីមូលហេតុ ដែលកន្លែងនោះជាទីបរិសុទ្ធសម្រាប់អ្នក ។
- នៅក្នុងអ៊ីម៉ែលរបស់អ្នក សុំសរសេរឈ្មោះពេញរបស់អ្នក, ថ្ងៃខែឆ្នាំកំណើត, ឈ្មោះវួដ និង ស្ដេក (ឬ សាខា និង មណ្ឌល) និង អាសយដ្ឋានអ៊ីម៉ែលរបស់ឪពុកម្ដាយរបស់អ្នក ។

រូបថតរបស់យុវវ័យមកពីជុំវិញពិភពលោក នឹងត្រូវបានដាក់បង្ហាញនៅក្នុងទស្សនាវដ្ដីច្បាប់បន្ទាប់ ។

### សាវកធ្វើទស្សនកិច្ចទៅប្រទេស ម៉ារ៉ុក

កាលពីខែ ធ្នូ ឆ្នាំ 2012 បន្ទាប់ពីបានបង្កើតស្ដេកទី 3000 របស់សាសនាចក្រនៅក្នុងប្រទេស ស៊ីអេរ៉ា លីអូន នៅក្នុងទ្វីបអាហ្វ្រិក បែកខាងលិច អែលឌើរ ជែហ្វ្រី អ័រ. ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានធ្វើទស្សនកិច្ចពិសេសមួយទៅកាន់សាខាដ៏តូច ហើយឆ្ងាយដាច់ស្រយាលមួយរបស់សាសនាចក្រនៅក្នុងទីក្រុង រ៉ាបាត់ ប្រទេស ម៉ារ៉ុក ។

នៅក្នុងការប្រជុំធម្មនិដ្ឋានពិសេសនាល្ងាចថ្ងៃអាទិត្យមួយ អែលឌើរ ហូឡិន បានចែកចាយសេចក្ដីស្រឡាញ់ដែលពួកអ្នកដឹកនាំសាសនាចក្រមាន សម្រាប់សមាជិកគ្រប់រូបនៃសាសនាចក្រទូទាំងពិភពលោក ទោះបីជាមានសមាជិកតិច ឬ ស្ថិតនៅទីតាំងឆ្ងាយដាច់ស្រយាលក៏ដោយ ។

លោកមានប្រសាសន៍ថា « អ្នកទាំងអស់គ្នាមិនត្រូវបានបំភ្លេចចោលឡើយ ហើយអ្នកទាំងអស់គ្នាគឺជាផ្នែកមួយនៃកិច្ចការដ៏អស្ចារ្យមួយនេះ នៅពេលដែលព្រះអម្ចាស់កំណត់អត្តសញ្ញាណ និង បង្ហើយការប្រមូលផ្ដុំនៃវង្សអ៊ីស្រាអែលនៅក្នុងសម័យកាន់កាប់ត្រួតត្រាដ៏ធំចុងក្រោយនេះ » ។

### ព្រះវិហារបរិសុទ្ធ តេហ្គូឈីហ្គាលប៉ា ហុនឌូរ៉ាស បានឧទ្ទិសឆ្លង

កាលពីថ្ងៃ អាទិត្យ ទី 17 ខែ មិនា ឆ្នាំ 2013 បន្ទាប់ពីការប្រារព្ធពិធីវប្បធម៌ និង ការបើកសម្ពោធរយៈពេលបីសប្ដាហ៍ នោះព្រះវិហារបរិសុទ្ធ តេហ្គូឈីហ្គាលប៉ា ហុនឌូរ៉ាស ត្រូវបានឧទ្ទិសឆ្លងជាបីវគ្គ ដែលត្រូវបានចាក់ផ្សាយទៅកាន់អង្គភាពសាសនាចក្រទាំងអស់នៅក្នុង ប្រទេស ហុងឌូរ៉ាស និង ប្រទេស នីការ៉ាហ្គា ។

សមាជិកហុនឌូរ៉ាសទាំងឡាយ ដែលមានទម្លាប់ធ្វើដំណើរបីបួនម៉ោងទៅកាន់ព្រះវិហារបរិសុទ្ធ ហ្គូតេម៉ាឡា ស៊ុ.ធិ. ហ្គូតេម៉ាឡា បានរីករាយដើម្បីឃើញព្រះវិហារបរិសុទ្ធដំបូងគេនៅក្នុងប្រទេសត្រូវបានឧទ្ទិសឆ្លង ។ ព្រះវិហារបរិសុទ្ធនេះត្រូវបានប្រកាសដំបូងក្នុងសារលិខិតដោយ គណៈប្រធានទីមួយនៅថ្ងៃទី 9 ខែ មិថុនា ឆ្នាំ 2006 ហើយត្រូវបានបើកសម្ពោធសាងសង់នៅទីតាំងបច្ចុប្បន្ននេះនៅថ្ងៃទី 12 ខែ កញ្ញា ឆ្នាំ 2009 ។

### ប្រធាន ម៉នសុន ធ្វើទស្សនកិច្ចទៅប្រទេស អាល្លឺម៉ង់

នៅក្នុងចុងឆ្នាំ 2012នេះ ប្រធាន ថូម៉ាស អេស. ម៉នសុន បានធ្វើដំណើរទៅកាន់ប្រទេសអាល្លឺម៉ង់ ដើម្បីជួបជាមួយនឹងសមាជិកទាំងឡាយនៃសាសនាចក្រនៅក្នុងទីក្រុង ហាមប៊ើរ, ប៊ើឡាំង, ម៉ូនីច និង ទីក្រុង ហ្វ្រែងហ្វើត ប្រទេស អាល្លឺម៉ង់ ហើយដើម្បីទូន្មានពួកគេឱ្យធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។

លោកបានប្រាប់សមាជិកទាំងឡាយនៅក្នុងទីក្រុង ហ្វ្រែងហ្វើត ថា « ទ្រង់បានបង្រៀនអំពីការអភ័យទោស ដោយអភ័យទោស ។ ទ្រង់បានបង្រៀនសេចក្ដីមេត្តាករុណា ដោយមានសេចក្ដីមេត្តាករុណា ។ ទ្រង់បានបង្រៀនការលះបង់ ដោយលះបង់រូបអង្គទ្រង់ផ្ទាល់ » ។

## សេចក្ដីអធិប្បាយ

### ព្រះវិញ្ញាណបរិសុទ្ធបង្រៀនខ្ញុំ

ចាប់តាំងពីគ្រួសាររបស់ខ្ញុំចូលរួមក្នុងសាសនាចក្រ ខ្ញុំបានឃើញពីឥទ្ធិពលដែលបានមកពីការអាន *លីអាហូណា* ។ តាមរយៈពាក្យសម្ដីដ៏បំផុសគំនិតទាំងនេះហើយ ដែលខ្ញុំត្រូវបានបំផុសដើម្បីបម្រើបេសកកម្ម ។ មានប្រធានបទជាច្រើនត្រូវបានពិភាក្សានៅក្នុងទស្សនាវដ្ដី ប៉ុន្ដែបញ្ហាចំពោះខ្ញុំ នោះគឺជាអ្វីដែលព្រះវិញ្ញាណបរិសុទ្ធបង្រៀនខ្ញុំគ្រប់ពេលដែលខ្ញុំអាន ។ ជាការពិតណាស់ យើងនឹងត្រូវបានរំដោះឱ្យរួច—ទោះបីនៅក្នុង « ដែនដីរបស់សត្រូវ » ក៏ដោយ (សូមមើល ប៊យដ៏ យេ. ផាកកឺ « របៀបដើម្បីរស់រានក្នុងដែនដីរបស់សត្រូវ » *លីអាហូណា* ខែ តុលា ឆ្នាំ 2012 ទំព័រ 34)—នៅពេលដែលយើងសិក្សា អាន និង អនុវត្តគោលការណ៍ដែលបានបង្រៀនទាំងនោះ ។ ព្រះអង្គសង្គ្រោះមានព្រះជន្មរស់នៅបព្វជិតភាពមាននៅលើផែនដីនេះ ហើយព្រះគង់នៅឋានសួគ៌ ។

**ញូតុន ធី. សេនយាំង ប្រទេស អ៊ូហ្គង់ដា**

### ការកែតម្រូវ

ទស្សនាវដ្ដី *លីអាហូណា* ខែ តុលា ឆ្នាំ 2012 មានការសន្មត់ខុសលើរូបថតមួយចំនួននៅក្នុងអត្ថបទ « ស្ដេកទីមួយដែលបានបង្កើតឡើងនៅក្នុងប្រទេសឥណ្ឌា » ទំព័រ 76–77 ។ រូបថតទាំងនេះគឺថតដោយបងស្រី ហ្គាឌីវីហ្គ ។ យើងសុំអភ័យទោសចំពោះកំហុសឆ្គងនេះ ។

នៅក្នុងទស្សនាវដ្ដី *លីអាហូណា* ខែ ធ្នូ ឆ្នាំ 2012 គ្រួសារ វិជិល ដែលបានពិភាក្សានៅក្នុងអត្ថបទ « ការផ្លាស់ប្ដូរដ៏ពិសិដ្ឋ » នៅទំព័រ 26 បានជ្រមុជទឹកនៅខែ កក្កដា 2010 មិនមែនខែ មិថុនា ឆ្នាំ 2011 ទេ ។ ហើយ អែនឌ្រា វិជិល កើតនៅខែ កក្កដា ឆ្នាំ 2011 មិនមែនខែ សីហា ឆ្នាំ 2012 ទេ ។

*នៅក្នុងការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរែនសូ ស្នូ*, រូបភាពនៅទំព័រ 2 ដែលមិនបានដាក់ឈ្មោះ ។ តាមពិតវាគឺជារូបភាពមួយនៃកូនប្រុសច្បងរបស់ប្រធាន ឡូរែនសូ ស្នូ គឺ អូលីវើរ ហ្គូដជាត ស្នូ ។ ផងដែរ នៅក្នុងចំណងជើង នៅលើទំព័រ 28 មានឈ្មោះ ព្រិកហាំ យ៉ង់ ជុញ្ញ័រ និង ហ្វ្រាំងស៊ីស អេម. លីមេន ត្រូវប្ដូរគ្នា ។

# ផឹកទឹកពីម៉ាស៊ីនទឹក

**ដោយ អើរ៉ុន អិល. វើស**
អ្នកបោះពុម្ពផ្សាយ សេវាកម្មបោះពុម្ពរបស់សាសនាចក្រ

**នៅ**ពេលយើងនិយាយអំពីសោភ័ណភាពនៃព្រះវិហាបរិសុទ្ធទាំងទ្បាយ យើងរៀបរាប់ជាតួយ៉ាងដូចជា កំពូលស្រួចៗបង្អួចនិមួយៗ និង ផ្ទាំងគំនូរធំៗជាច្រើន ។ យើងនិយាយប្រកដដោយគារវភាពអំពីអាងជ្រមុជទឹក បន្ទប់អំណោយទានពិសិដ្ឋ បន្ទប់ផ្សារភ្ជាប់ និង បន្ទប់សេទ្បេស្ថាលនីមួយៗ ។

ប៉ុន្តែនៅពេលដែលព្យាការីម្នាក់ឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធថ្វាយព្រះអម្ចាស់ នោះលោកឧទ្ទិសឆ្លងអគារទាំងមូល មិនមែនគ្រាន់តែផ្នែកដ៏ស្រស់ស្អាតនានាដែលមនុស្សរាល់គ្នាមើលឃើញនោះទេ ។ នៅក្នុងពាក្យអធិស្ឋាននៃការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ខាន់សាសស៊ីធី មិសសួរី នោះ ប្រធាន ថូម៉ាស អេស. ម៉នសុន បានមានប្រសាសន៍ថា ៖ « យើងឧទ្ទិសឆ្លងបរិវេណដែលព្រះវិហារបរិសុទ្ធនេះតាំងនៅ ។ យើងឧទ្ទិសឆ្លងនូវរាល់ផ្នែករចនាសម្ព័ន្ធដ៏ស្រស់ស្អាតនេះចាប់ពីគ្រឹះនៃអគារទៅដល់រូបសំណាកដ៏ខ្ពស់នៃទេវតា មរ៉ូណៃ ដែលដាក់ចំពីលើកំពូលឮដ៏ខ្ពស់បំផុតរបស់អគារនេះ » ។[1] នៅពេលប្រធានយ៉ូសែប ហ្វីលឌីង ស្ម៊ីធសូត្រការអធិស្ឋាននៃការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ អូហ្គឌិន យូថាហ៍ លោកបានឧទ្ទិសឆ្លង « គ្រឹះទាំងទ្បាយជញ្ជាំងទាំងទ្បាយ កម្រាលឥតទាំងទ្បាយ ពិដានទាំងទ្បាយ កំពូលទាំងទ្បាយ ហើយនិង ផ្នែកនៃអាគារទាំងអស់ » ហើយលោកបានអធិស្ឋានសុំការការពារនៃ « ផ្នែកម៉ាស៊ីនទាំងអស់ ប្រព័ន្ធបញ្ជានិងភ្ជាប់ភ្លើងទាំងអស់ ប្រព័ន្ធខ្យល់ចេញចូល និង ជណ្ដើរយន្តទាំងទ្បាយ និងរបស់របរទាំងអស់ដែលមាននៅក្នុងអាគារនេះ » ។[2]

ខ្ញុំមានអំណរគុណដែលព្រះអម្ចាស់បំផុសគំនិតពួកព្យាការីនៅពេលឧទ្ទិសឆ្លងរាល់ផ្នែកនានានៃព្រះវិហារបរិសុទ្ធទាំងអស់ ។ បើទោះជាត្រចៀកទ្វា ឬ ប្រព័ន្ធចង្កៀងភ្លើងពិតជាមានគោលបំណងសំខាន់តិចតួចជាងអាសនានៅក្នុងបន្ទប់ផ្សារភ្ជាប់ក៏ដោយ ក៏របស់របរមិនសូវសំខាន់ទាំងអស់នេះបានជួយបំពេញគោលបំណងលើកតម្កើងដ៏ខ្ពស់បំផុតរបស់ព្រះវិហារបរិសុទ្ធដែរ ។



*ព្រះយេស៊ូវគ្រីស្ទគឺជាប្រភពទឹករស់ ។*

រូបភាព© iSTOCKPHOTO.COM/AMPHOTORA

របស់មួយក្នុងចំណោមរបស់របរមិនសូវសំខាន់ទាំងអស់នេះបានជួយខ្ញុំឲ្យរៀនអំពីមេរៀនដ៏បិតថេរមួយ ។មានថ្ងៃមួយ ខ្ញុំបាននៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក នៅពេលរៀបចំខ្លួនដើម្បីចាកចេញពីបន្ទប់ផ្លាស់សំលៀកបំពាក់បន្ទាប់ពីការចូលរួមនៅក្នុងពិធីបរិសុទ្ធសម្រាប់មនុស្សស្លាប់ ។ ដោយឃើញម៉ាស៊ីនទឹកផឹកមួយ ខ្ញុំក៏មានអារម្មណ៍ថា ស្រេកទឹក ដូច្នេះខ្ញុំបានបន្ទន់ខ្លួនដើម្បីផឹកទឹកមួយភ្លែត ។ ស្រាប់តែមានសារមួយបានចូលមកក្នុងគំនិតខ្ញុំថា ៖

*អ្នកផឹកទឹកនេះនៅក្នុងព្រះវិហារបរិសុទ្ធ ប៉ុន្តែតើអ្នកពិតជាផឹកទឹករស់ដែលមាននៅទីនេះឬ ?*

វាមិនមែនជាការថ្កោលទោសដ៏ធ្ងន់ធ្ងរនោះទេ គឺគ្រាន់ជាការស្តីបន្ទោសស្រាលៗ និង ជាសំណួរដែលជ្រាបចូលក្នុងសតិអារម្មណ៍ខ្ញុំប៉ុណ្ណោះ ។

ចម្លើយរបស់ខ្ញុំចំពោះសំណួរនោះគឺថា ទេ ។ ខ្ញុំមិនកំពុងផឹកទឹករស់នៃព្រះវិហារបរិសុទ្ធនេះទាំងស្រុងនោះទេ ។ ខ្ញុំត្រូវតែសារភាពថាចិត្តរបស់ខ្ញុំកំពុងគិតរឿងផ្សេង ខណៈដែលខ្ញុំបានទទួលពិធីបរិសុទ្ធទាំងទ្បាយសម្រាប់អ្នកស្លាប់នោះ ។ ថ្វីបើខ្ញុំបានធ្វើការងារល្អសម្រាប់មនុស្សដែលត្រូវការជំនួយរបស់ខ្ញុំក៏ដោយ ក៏ខ្ញុំមិនបានអនុញ្ញាតឲ្យខ្លួនខ្ញុំទទួលបាននូវជំនួយទាំងអស់ដែលខ្ញុំត្រូវការនោះដែរ ។

ឥឡូវនេះ រៀងរាល់ពេលដែលខ្ញុំទៅព្រះវិហារបរិសុទ្ធ ខ្ញុំតែងតែរកមើលម៉ាស៊ីនទឹកផឹក ហើយឈប់មួយភ្លែតដើម្បីផឹកទឹកនោះ ។ ខ្ញុំបានសួរខ្លួនឯងថា តើខ្ញុំកំពុងផឹកទឹកពីក្បាលទឹករស់នេះបានជ្រាលជ្រៅប៉ុណ្ណា ។ ចម្លើយរបស់ខ្ញុំ ៖ នៅតែមិនទាន់បានជ្រាលជ្រៅគ្រប់គ្រាន់នៅឡើយទេ ។ ប៉ុន្តែការស្រេករបស់ខ្ញុំនៅតែកើនឡើង ។ ■

**កំណត់ចំណាំ**

1. ថូម៉ាស អេស. ម៉នសុន នៅក្នុង « Kansas City Missouri Temple: 'Beacon of Divine Light'—an Offering of Hands and Hearts » *Church News* ថ្ងៃទី 12 ខែ ឧសភា ឆ្នាំ 2012 ldschurchnews.com ។
2. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ នៅក្នុង « *Ogden Temple Dedicatory Prayer* » *Ensign* ខែ មិនា ឆ្នាំ 1972 ទំព័រ 12 ។




រចនារូបភាពដោយ រ៉ូប៊ឺត ធី. បារ៉េត

# វិលហ្វូឌ វូឌរ្រុព្វ

**វិលហ្វូឌ វូឌរ្រុព្វ** បានបម្រើបេសកកម្មមួយនៅក្នុងចក្រភពអង់គ្លេស នៅអំឡុងទសវត្សរ៍ឆ្នាំ 1840 ។ ដោយសារតែការបម្រើរបស់គាត់ ទើបមានមនុស្សជាង 1000 នាក់បាន**ទទួលបុណ្យជ្រមុជទឹក ។** ក្រោយមក វិលហ្វូឌ វូឌរ្រុព្វ បានបម្រើជាប្រធាននៃព្រះវិហារបរិសុទ្ធ**សេន ចច យូថាហ៍ ។** ក្នុងនាមជាប្រធាននៃសាសនាចក្រ លោកបានជម្រុញឲ្យ**យូថាហ៍**ក្លាយជារដ្ឋផ្លូវការណ៍មួយ ។ គាត់ក៏បានទទួលបានវិវរណៈ ហើយបានប្រកាសនូវ**សេចក្ដីប្រកាសជាផ្លូវការ** 1 ណែនាំឲ្យពួកបរិសុទ្ធឈប់អនុវត្តការរៀបអាពាហ៍ពិពាហ៍ដែលមានភរិយាច្រើន ។



សម្ដែងបង្ហាញពីឈុតឆាកដែលចេញមកពីជីវិតនៃព្រះយេស៊ូវគ្រីស្ទ សម្រាប់វីដេអូដាក់នៅលើអ៊ិនធើរណេត មាននៅលើគេហទំព័រ *biblevideos.lds.org* ឈុតឆាកមួយចំនួនពីជីវិតរបស់ព្រះអង្គសង្គ្រោះកាលពីសប្ដាហ៍មុននេះ មានបង្ហាញក្នុងអត្ថបទនៅទំព័រ 26 ។ នៅក្នុង « បេសកកម្ម និង ការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ » ( ទំព័រ 18 ) អែលឌើរ រ័សុល អិម ណិលសុន បង្រៀនពីចំណុចប្រាំយ៉ាងនៃការបម្រើរបស់ព្រះអង្គសង្គ្រោះ ដែលយើងអាចយកគំរូតាម នៅក្នុងជីវិតយើងផ្ទាល់ ។

4 02107 84258 1
CAMBODIAN